# រឿង

# តន្ត្រីបេះដូង

និពន្ធ គូររូប និង រចនាក្រប ដោយ

**អ្នកស្រី កែវ ចន្ទបូរណ៍**

រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

P.O.Box 600279
Saint Paul, MN 55119
USA
chanbokeo@yahoo.com
www.angkorwat.com

សូមទាក់ទង
016-318-023
012-774-751

ខែធ្នូ ២០០៦

រក្សាសិទ្ធិគ្រប់យ៉ាង

CHANBOKEO.COM

## ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៌


| | |
|---|---|
| ១- រឿង សំនៀងស្នេហ៍កវី | ២- រឿង និស្ស័យស្នេហ៍ |
| ៣- រឿង ផ្កាយវង្វេងមេឃ | ៤- រឿង ស្នាមញញឹម |
| ៥- រឿង កុលាបស្មឹងខៀវ | ៦- រឿង ក្លិនផ្កាមាលតី |
| ៧- រឿង លិខិតមរតកសម្ងាត់ | ៨- រឿង បំណុលជីវិត |
| ៩- រឿង ចរណៃដួងទ័យា | ១០- រឿង អំបែងអណ្ដែត |
| ១១- រឿង ស្នេកចាកផុតទៅ | ១២- រឿង តន្ត្រីបេះដូង |
| ១៣- រឿង សារាណីយមាតា | ១៤- រឿង ទារុណដួងចិត្ត |
| ១៥- រឿង បើសិននៅមានថ្ងៃស្នេក | ១៦- រឿង លំអងផ្កាស្នេហ៍ |
| ១៧- រឿង ត្រៃមិត្ររតននារី | ១៨- រឿង ខ្មែយវាសនា |
| ១៩- រឿង បើសិនអាចបង្វិលផែនដី | ២០- រឿង លីវបុរេកាល |
| ២១- រឿង មេឃដ៏សក្តិសិទ្ធិ | ២២- រឿង មួយពាន់ទំព័រ |
| ២៣- រឿង អាមេរិកដែនដីមាស | ២៤- រឿង អាធ្រាតថ្ងៃរះ |
| ២៥- រឿង បក្សីសួនសុបិន | ២៦- រឿង ម្លប់អសោក |
| ២៧- រឿង ពិជេន្ទភានុមា | ២៨- រឿង ផ្ការីកក្រៅសួន |
| ២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ | ៣០- រឿង អនង្គលាភា |
| ៣១- រឿង ពណ្ណរាយពេជ្រ | ៣២- រឿង សារិកា |
| ៣៣- រឿង ផ្ការាជបឹងរាំង | ៣៤- រឿង នភាមណី |
| ៣៥- រឿង ស្រីនាថភ្នួងមាលា | ៣៦- រឿង វាយោដួងចិត្ត |


ISBN: 99950-79-07-0

9 789995 079079

CHANBOKEO.COM

# សូមឧទ្ទិសស្នាដៃនេះប្រគេននិងជូនចំពោះ

- ព្រះគ្រូ សេងប៊ុនសង ព្រះគ្រូចៅអធិការ ម៉ឹងសាង ភិក្ខុ វុមភិរម្យ ភិក្ខុ គិមសុវត្ថិ ភិក្ខុ ជុំ វិចិត្រ ភិក្ខុ គង់សុជា
- លោក មេងសួងសុវណ្ណធី ជាស្វាមី និង កុមារី សុវណ្ណធីធម្មិកាបារមីបុណ្យជាបុត្រី
- លោកឪពុក ប៊ុនថង អ្នកម្តាយ កែវយឿង និងប្អូនទាំងបួនព្រមទាំងក្រុមគ្រួសារ
- លោកឪពុកក្មេក មេងសួង និងអ្នកម្តាយក្មេក កូវសារ៉ាន់ ព្រមទាំងកូនចៅ
- បណ្ឌិតឃួគិមទូយ
- អ្នកស្រីនៅសារិម វិទ្យុសម្លេងសហរដ្ឋអាមេរិក VOA
- លោក លីតាយហុង អ្នកគ្រូ ទូចសារៀង អ្នកគ្រូ កែវសុផុន លោករីនរស់ អ្នកស្រីមាងបេងយង់ អ្នកស្រីប៉ក់ដារិនី លោកលេកស៊ីវហុង និង អ្នកស្រីអ៊ាបគិមណាង និងអ្នកគ្រូមៀចសុខារី ។
- អ្នកស្រី ប៊ិចសង្វាវ៉ាន វិទ្យុបារាំងអន្តរជាតិ RFI
- លោកអ៊ុមសុនាថ លោកជិនសៅរិន លោកជាសយនា សារពត៌មានកោះសន្តិភាព
- លោកខូតារាប្ញទ្ធិ នាយកកម្មវិធីសម្ទូហកម្មទូហាច ភ្នំពេញ
- សាស្ត្រាចារ្យ យូសុភា មជ្ឈមណ្ឌលគរុកោសល្យតំបន់កំពង់ចាម ។

CHANBOKEO.COM



អ្នកស្រី កែវ ចន្ទ័បូរណ៏

# វាចាអ្នកនិពន្ធ

តន្ត្រីបេះដូង លាតត្រដាងនូវចំណងគ្រួសារ និងការបែកបាក់ គ្នាដោយការខ្វះភាពកក់ក្ដៅ មិនស្គាល់ទុក្ខធុរៈគ្រួសារ និង ការ ខុសប្លែកទម្លាប់រស់នៅ ។ នេះជាចំណងសំណេរដ៏ប្លែកដែលឆ្លុះបញ្ចាំងនូវជីវភាពពិតរបស់ក្រុមគ្រួសារខ្មែរខ្លះៗ ដែលទទួលភាពរការរកូសដោយសារតែភាពខុសគ្នារវាងប្ដីនិងប្រពន្ធ និងភាពខុសគ្នានៃទំនៀមទម្លាប់របស់សង្គមពីរ គឺអាមេរិកនិងខ្មែរ ។

អ្នកនិពន្ធខ្ញុំសូមទទួលនូវមតិយោបល់អំពីប្រិយមិត្តអ្នកអានទាំងឡាយតាមរយៈអាសយដ្ឋានដូចខាងក្រោមនេះ ៖

Pannalai KhmerVissal
P.O.Box 600279
Saint Paul, MN 55119
USA
chanbokeo@yahoo.com

www.angkorwat.com

សូមប្រិយមិត្តបានប្រកបតែវឌ្ឍនសុខនិងសុវត្ថិភាព រៀងរាល់ ទិវារាត្រី ។

អ្នកស្រី កែវ ចន្ទ័បូរណ៍
រដ្ឋមិនីសូតា សហរដ្ឋអាមេរិក
ខែឆ្នាំ២០០៦

CHANBOKEO.COM

# កំណាព្យ

================================================================

# ច្បាប់កូនខ្មែរ

នេះគឺច្បាប់ថ្មី សីលធម៌វិន័យ ទូន្មាននរជន
សណ្តាប់ធ្នាប់មាន រក្សាជាធន ច្បាប់ក្លាយជាបុណ្យ
មង្គលចេរកាល ។

ច្បាប់ចែងវិន័យ ទំលាប់ជាថ្មី វិសេសវិសាល
គួរចងចាំទុក ប្រព្រឹត្តតាមកាល វិន័យបណ្តុល
ឱ្យចាកវិបរិត ។

នៅជាកុមារ ចូលខ្លួនសិក្សា សាលាឆ្ងាយជិត
ជួបក្មេងដទៃ សាងគ្នាជាមិត្ត សភាពជិតស្និទ្ធ
នាំខ្លួនសប្បាយ ។

ទោះខ្លួនជាស្រី ក៏ត្រូវឃ្នាតខ្មី សាងចិត្តសាងកាយ
ចូលរៀនដូចគ្នា កុំបីជិនណាយ តម្លៃនោមឆាយ
ពឹងលើ វិជ្ជា ។

ពេលកូននៅផ្ទះ ចូរប្រណិបតន៍ គោរពវន្ទា
ឪពុកម្តាយខ្លួន ហាក់បីទេវា ផលក្រោយគ្រប់គ្រា
ផលលោកស្រលាញ់ ។

មានប្អូនមានបង តូចធំសព្វហោង កុំបីកំណាញ់
ត្រូវចែករំលែក កុំមានចិត្តខ្ចាញ់ ត្រូវចេះស្រលាញ់
ស្ងួនហើយអាណិត ។

កុំបីមុខមួរ កុំឡើយទ្រើស្ទូរ នឹងញាតិឆ្ងាយជិត
ចចារពិរោះ ស្មោះពីដួងចិត្ត ញាតិភូមិផងពិត
រាប់អានកន្លង ។

កិច្ចការក្នុងផ្ទះ ជួយបោសជួយច្រាស ទោះប្អូនឬបង
សំអាតចានក្បាន រៀបគ្រែភួយផង ការតូចធំហោង

CHANBOKEO.COM

ធ្វើតាមខ្លួនចេះ ។

តូចធ្វើតាមតូច ធំកុំប្រដូច ឱ្យតូចកើតធ្វេស
កើតការច្រណែន ជជែកចចេស ត្បិតបងប្រហែស
ភ្លេចគិតមុខងារ ។

ឃើញអ្វីជ្រុះធ្លាក់ រើសស្រវាដាក់ ផុតពីដួលផ្ការ
ឃើញអ្វីមិនស្អាត លាតដៃស្រវា សំអាតអស់ការ
ទុកដាក់ល្អហោង ។

ឃើញប្អូនប្រលាក់ ងូតទឹកឱ្យជាក់ ផ្លាស់ខោអាវផង
នរណាគេងជ្រុល ប្អូនដាស់បង១ បងដាស់ប្អូនផង
ជួយរំលឹកគ្នា ។

ឃើញប្អូនដួលយំ បង១រត់ជុំ លួងបាត់ឈឺផ្សា
ពេលបងរវល់ ប្អូនជួយកិច្ចការ កុំខ្ជិលសោតណា
ខ្ជិលមិនចំរើន ។

ពេលម្តាយមិននៅ ប្អូនតូចប្អូនពៅ ហៅបងក្រវើន
កុំទាញរំពាត់ វ៉ាត់ទាំងព្រហើន កុំមានចិត្តផ្តើន
ត្បិតយើងជាបង ។

ព្រឹកក្រោកលប់មុខ ដុសធ្មេញសព្វគ្រប់ ជំរះកាយផង
ស្លៀកពាក់ខោអាវ នាំប្អូននាំបង ចូលសាលាហោង
ដុសខាត់វិជ្ជា ។

លុះវិលដល់ផ្ទះ ងូតទឹកជំរះ បរិភោគអាហារ
ឆ្អែតហើយសំរាក រួចចាប់កិច្ចការ លំហាត់សាលា
ធ្វើឱ្យសព្វគ្រប់ ។

ទៅណាមកណា សុំច្បាប់មេបា កាយាគោរព
រៀនអនុញ្ញាត្តសុំ សមជាទំលាប់ កុំដើរគេចបាត់
ម៉ែពុកមិនដឹង ។

លោកពិតបារម្ភ ខ្លាចកូនគ្រោះធំ ច្បាស់ភ័យសញ្ជឹង
ឆ្លេឆ្លាកើតកល បណ្តាលឱ្យខឹង លុះអ្នកវិលវឹង
លោកកើតមួម៉ៅ ។

បើអ្នកមានមិត្ត ទោះឆ្ងាយឬជិត ទៅរកមកហៅ
នាំជួបអ្នកម្តាយ ឪពុកអ្នកទៅ កុំបីគិតខ្លៅ
ចៀសវាងរូបលោក ។

CHANBOKEO.COM

ជួបមនុស្សចំលែក ភូមិក្រុងគ្រប់ប៉ែក ចៀសចេញកុំសោក
កុំទុកចិត្តគេ ល្អឬស្មោកគ្រោក ខ្លួនតូចទាបជោគ
គេបំពានបាន ។

កុំបីទទួល ពិបាកឬស្រួល រង្វាន់កល្យាណ
ពីមនុស្សចំលែក នៅក្រៅភូមិឋាន ច្បាប់មានលំអាន
រក្សាក្តីសុខ ។

ជួបលោកចាស់ទុំ លំទោនប្រណម្យ សូមលោកផុតទុក្ខ
ជួបជនជរា កុំមួរគេចមុខ ពរលោកនាំសុខ
មង្គលទាំងឡាយ ។

ឃើញអ្នកពិការ ត្រូវមានមេត្តា កុំពើលែបខាយ
កុំស្តោះទឹកមាត់ កុំគេចប្រាសឆ្ងាយ អស់បុត្រឆោមឆាយ
ជួយស្រាយធុរៈ ។

ឃើញពិការមិត្ត ពិការគំនិត ពិការកាយជាក់
កុំដើរកន្លង ពើមិនទុកដាក់ កុំពើជាខ្វាក់
មិនឃើញវេទនា ។

ឃើញស្រីមានគភ៌ គប្បីចិត្តធម៌ គោរពគ្រប់គ្នា
ប្រៀបនឹងម្តាយខ្លួន ពកាយពំងា ពិបាកអង្គា
ប្រាំបួនខែពេញ ។

ពេលអ្នកជួបគ្រោះ បន់គុណទឹកដោះ ឱ្យរួចទោម្នេញ
ម៉ែឃ្លាតឆ្ងាយទៅ កូនហៅវិលវិញ នោះយ៉ាងណាមិញ
កុំភ្លេចគុណម៉ែ ។

ម៉ែថៃរក្សា ចិញ្ចឹមបុត្រា បុត្រីហូរហែ
កុំភ្លេចរូបលោក កុំផ្តើនចិត្តម៉ែ កុំរត់គេចកែ
មិនជួយការម្តាយ ។

ម៉ែប្តូរការពារ ថែទាំពំងា គេចគ្រោះអន្តរាយ
ម្តាយស៊ូស្លាប់ពិត ត្បិតបុត្រចរណៃ ច្នេះសូមបុត្រថ្លៃ
នឹកដល់ម៉ែផង ។

គ្រាបានសប្បាយ គ្រាទុក្ខខ្វល់ខ្វាយ វិលរកម្តាយហោង
កុំជឿពាក្យគេ ញុះញង់ឱ្យឆ្គង កូកហៅប្អូនបង
រក្សារូបម៉ែ ។

ពេលឃើញលោកឈឺ មិនស្រាន្តជំងឺ កង្វល់ឥតល្ហែ

CHANBOKEO.COM

គប្បីខិតខំ ប្រៀនខ្លួនអ្នកទ្វេ បំរើឥតគ្នេរ
លោកអ្នកមានគុណ ។

ឯពុកខំប្រឹង ចិត្តកាយកំលាំង ស្វែងរកទ្រព្យធន
រក្សាកូនចៅ ផុតក្តៅជាគ្រុន ផុតអត្តខាត់ធ្ងន់
កូនអើយចាំចង ។

រីលោកឪពុក លំបាកសព្វមុខ រក្សាគ្រប់គ្រង
កូនពុកតូចធំ រស់ឥតសៅហ្មង ពឹងផ្អែករបង
ពុកស្រាស់ការពារ ។

ចង់ចេញទៅក្រៅ វរមិត្រពាលពៅ សុំច្បាប់ពុកណា៎!
លោកច្បាស់ជាជូន លូនតាមកាប់ឆ្ការ រំលើងបន្លា
ឧបសគ្គជាទុក្ខ ។

កូនចាកពីភ័យ ចាកគ្រោះចង្រៃ ផុតអបាយមុខ
ត្បិតអីត្រង់ត្រាប់ ស្តាប់ពាក្យឪពុក ថ្ងៃនេះថ្ងៃមុខ
ស្តាប់លោកទូន្មាន ។

នៅក្នុងសាលា ខិតខំសិក្សា ស្តាប់គ្រូបង្រៀន
កុំរំខានមិត្ត កុំគិតខ្មាស់អៀន តាំងចិត្តក្លាហាន
សាកសួរគ្រប់ជ្រោយ ។

សួរឱ្យអស់ឆ្ងល់ សាស្ត្រាកុំសល់ កុំឡើយបណ្តោយ
កុំលេងឡេះឡោះ កុំគេចគោះតើយ គ្រូអ្នកហ្នឹងហើយ
ជួយអ្នកឱ្យភ្លឺ ។

សូមគោរពលោក ដើម្បីជ័យជោគ ចៀសផុតជំងឺ
ឈឺអវិជ្ជា ពុំមានពន្លឺ វិធីរន្ធឺ
ពឹងគ្រូបាធ្យាយ ។

លោកនាំយើងឆ្លាត ឧស្សាហ៍សង្វាត រៀនសូត្រធ្លុះធ្លាយ
ផុតអវិជ្ជា ផុតភាពរាយមាយ ផុតពុនសំពាយ
ទុរគតក្រក្រី ។

ប្រទះព្រះសង្ឃ វិន្ទាកាយអង្គ ពរសង្ឃនាំជ័យ
ជួបលោកអាចារ្យ សាសនាណាក្តី អស់បុត្រគប្បី
ស្តែងក្តីគោរព ។

កុំឡើយនិន្ទា មាក់ងាយសាសនា ថាមួយឧបទ្រព
មួយនោះចង្រៃ មួយទៀតនាំភ័ព្វ ដៀលនាំគេស្អប់

CHANBOKEO.COM

អស់ជោគសេរី ។

កុំហារដៀលហោង អ្នកដទៃផង មនុស្សគ្រប់វ័យ

រៀនគោរពគ្នា ទើបសុខសិរី ប្រមាថនាំក្តី

គំនុំទៅមក ។

ប្រទះអ្នកក្រ ខ្សត់បាយបបរ ខ្សត់ឥតជំរក

ត្រូវមានអាសូរ ជួយថែរជួយចូក ហុចបាយហុចស្លក

តាមដែលធ្វើបាន ។

ឃើញអ្នកល្ងង់ខ្លៅ រស់នៅសោកសៅ ចូរនាំឱ្យរៀន

ចូលក្នុងសាលា អាចារ្យបង្រៀន តិចតួចនាំមាន

តម្រេះចាកល្ងង់ ។

ឃើញគេកំព្រា កុំហារដៀលគ្នា ពាក្យអាពាក្យមឹង

ពាក្យដៀលនាំស្អប់ ប្រមាថនាំខឹង ច្នេះកូនត្រូវប្រឹង

ចៀសវាងដៀលត្មះ ។

រៀនមានអាសូរ ចេះជួយគិតគូរ បំពេញកង្វះ

ឃើញគ្នាកំសត់ ព្រាត់គ្មានមែឪឡាស់ ឈឺចាប់ផ្សាណាស់

ពិតឥតប្រមាណ ។

បើគ្មានទ្រព្យចែក បែងត្រឹមបំណែក ចិត្តធមិកល្យាណ

ឱ្យត្រឹមអាសូរ ក៏ជួយឱ្យស្រាន្ត ទៅមករាប់អាន

ហៅគ្នាជាញាតិ ។

ឃើញគេក្មេងជាង ជួយមើលកុំល្បែង កុំបីរវាត

កុំរំលោភសិទ្ធិ កុំចិត្តចង្អៀត កុំបែរមានស្មៀត

ធ្វើបាបក្មេងៗ ។

ជួបអ្នកទន់ខ្សោយ កុំបែរតោះតើយ កុំឡើយលលេង

គ្នាតូចអភព្វ័ កុំនាំវង្វេង ឱ្យឃ្លាតបែរឆ្វេង

ចាកឆ្ងាយគុណធមិ ។

កុំប្រទុស្តរាយ ជួបមិត្តទាំងឡាយ ត្រូវចេះហៅរក៏

កុំគិតច្រណែន ចិត្តខ្មៅកករ ប្រទុស្តនាំមក៏

នូវចិត្តអន្ធពាល ។

ការឃាឃីមិត្ត នាំញាតិឆ្ងាយជិត ចិត្តក្តៅរោលរាល

ដាក់បណ្តាសា វាចាតិះដៀល មិនខុសសត្វគ្រៀល

ដៀលគ្រួចប្រទុស្ត ។

CHANBOKEO.COM

កុំឡើយអាស្មិ មានះអារិ ឱ្យខ្លួនគិតខុស
ចាកឆ្ងាយគុណធម៌ យល់តែទុក្ខទោស ច្នេះបុត្រស្រីប្រុស
រក្សាសីលធម៌ ។

ជួបគេអ្នកខ្ពស់ មានទ្រព្យសក្តិយស សម្បូរស្សបវរ
កុំឡើយតូចចិត្ត ថាខ្លួនមិនល្អ វ៉ាសនាកករ
ឱ្យខ្លួនអាប់ឱន ។

តំលៃរូបអ្នក ខ្ពង់ខ្ពស់ប្រត្យក្ស ឥតឡើយស្រពោន
ត្បិតព្រោះចិត្តធម៌ កិរិយាលំទោន ពិតមែនកាយឱន
យសអ្នកត្រដែត ។

ខ្ពស់ព្រោះវិជ្ជា ព្រោះចេះវន្ទា គ្មានចិត្តជាប្រេត
មានតែសីលធម៌ ចិត្តល្អជាហេតុ នាំយសអណ្តែត
ត្រសែតយ៉ាងឆ្ងាយ ។

កុំមានចិត្តលោភ លោភនាំស្មោកគ្រោក នាំទុក្ខដាក់កាយ
លោភនាំជំលោះ នាំកលឧបាយ នាំក្តីអន្តរាយ
ក្សាន្តក្លាយជាទុក្ខ ។

ចចើងចង់លាភ ឃ្លាតចាករបៀប នឹងបំផ្លាញសុខ
លោភហួសប្រមាណ នាំកង្វល់ទុក្ខ ទាំងម្តាយឪពុក
សោយទុក្ខជួសអ្នក ។

កុំលួចទ្រព្យគេ ទោះជាទ្រព្យម៉ែ ទ្រព្យឪពុកអ្នក
លួចនាំទំលាប់ អាក្រក់មុខយក្ស ម្ចាស់ទាន់ចាប់ធាក់
អ្នកផងសើចយំ ។

កុំរៀនបញ្ចោរ ពាក្យជេរមោហោ ឃ្លាតចាកភិរម្យ
ពាក្យជេរនាំឈ្លោះ នាំស្អប់ជិតជុំ ច្នេះពាក្យមិនសម
កុំពោលហារស្តី ។

កុំរៀនភរភូត ភរមុខស្រងូត ភរសើចប្រិមប្រិយ
ភរភូតកុហក សព្វគ្រប់សំដី នាំញាតិគ្រប់វ័យ
លែងជឿទុកចិត្ត ។

សំដែងចិត្តត្រង់ ទោះជាឆោតល្ងង់ ញាតិចោមជុំជិត
រាប់អានទៅមក ហៅគ្នាជាមិត្រ ស្និទ្ធស្នាលព្រោះត្បិត
ចិត្តត្រង់ស្មោះស ។

កុំខ្ជិលស្រពន់ កុំពើទំរន់ ដៃជើងនៅល្អ

CHANBOKEO.COM

ក្រេវីនឧស្សាហ៏ កាយាចេញចរ បំពេញរបរ
នាទីឆោមឆ្លៅ ។
កុំលេងវាយតប់ កុំគ្រវែងគប់ ភ្លេចពាក្យប្រដៅ
កុំអាងសាច់ដុំ កុំវាយតបឪ កុំជៀលម៉ែខ្លៅ
ដៅពូជអំបូរ ។
ត្រូវរៀនសុភាព លំទោនដរាប កុំឡើយមុខខ្វូរ
ស្រដីរួសរាយ សមរម្យថ្លៃថ្នូរ កុំពើជាជោរ
អួតអាងឱ្យឆ្គង ។
កុំលេងបង្ហិន ខ្លួនតូចមិនប៊ិន រកមិនបានសង
កុំឡើយបំផ្លាញ វត្ថុសព្វហោង ជួយរក្សាហោង
ឱ្យគង់វង្សនៅ ។
កុំលេងដុតភ្លើង ដុតឱសចំបើង ឆេះរាលលំនៅ
បំផ្លាញសព្វកើ្ត ស្នាដៃម៉ែឪ លុះឆេះអស់ទៅ
ខ្លួនជ្រកឯណា?
កុំលេងកាំបិត មិនប្រសព្វចិត នាំមុតអាត្មា
កុំលេងព្រនង់ ទាត់ធាក់ឡូឡា កុំចិត្តយក្សា
ចាស់ៗគាត់ហាម ។
កុំលេងលោតទឹក ទោះល្ងាចឬព្រឹក ស្តាប់ពាក្យបណ្តាំ
បើចង់រៀនហែល ត្រូវមានអ្នកឃ្លាំ ពេលមានបំណាំ
គេសង្គ្រោះបាន ។
ពេលដើរឆ្លងថ្នល់ រវ៉ែកកាយកល សំលឹងជ្រោយឋាន
កុំឆ្លងកាត់មុខ កង់ម៉ូតូឡាន អស់សព្វយន្តយាន
ក្រែងមានគ្រោះថ្នាក់ ។
ដំណើរទៅមក៏ ភ្លើងចរាចរ ពុំមានបណ្តាក់
គោរពភ្លើងខៀវ ក្រហមច្បាស់ជាក់ នោះរួចគ្រោះថ្នាក់
គ្រោះភ័យឈឺខ្លួន ។
ទៅណាមកណា ស្លៀកតាមមាត្រា ចរិយាសមសួន
គោរពវិន័យ ឈរដើរដេកពួន រហ័សរហួន
សមសួនគ្រប់ពេល ។
ចូលក្នុងទីវត្ត វន្ទាប្រណិបតន៏ ពុទ្ធកេ្តីដំណែល
ចូលក្នុងសាលា រៀនឱ្យក្រាស់ក្រែល ចុះស្ទឹងរៀនហែល

CHANBOKEO .COM

កុំឱ្យលង់ទឹក ។

ចូលផ្ទះគោរព ពុកម៉ែសំណព្វ ម្លប់ដូចពោធិព្រឹក្ស
ចូលពេទ្យនឹកគុណ គ្រូពេទ្យសន្ធឹក ជំងឺវិវរឹក
លោកព្យបាលសព្វ ។

ឈានដល់ទីណា រៀនរៀបកាយា មានសណ្ដាប់ធ្នាប់
គោរពញាតិផង នាំល្អទំលាប់ ញាតិផៅហៅរាប់
គាប់ជាសង្គម ។

កុំអួតក្អេងក្អាង កុំពឹងសំណាង កុំពើសើចយំ
វាសនាបានខ្ពស់ ព្រោះត្បិតយើងខំ បើដេកសំងំ
សំណាងរត់ចោល ។

កុំប្រមាថគេ នាំគេជៀលម៉ែ មានកូនក្រៅក្រោល
ភ្លេចមិនប្រដៅ ទើបកូនកំរោល ប្រវាយផាយបោល
ធ្លាក់អវិចីសុង ។

កុំជោរយសឪ ជោរទ្រព្យម៉ែនៅ ទំនុកបំរុង
សម្បត្តិអនត្តា កង់ត្រាចកង់ធ្នង់ ច្នេះគួរឆោមយង់
ស្វែងទ្រព្យចើរ្ដីកាល ។

ទ្រព្យដ៏វិសេស វិជ្ជាតិរិះ បណ្ដុះជាថ្នាល
ស្ថិតស្ថេរចើរ្ដីលង់ ប្រើបានគ្រប់កាល កោសល្យវិសាល
នាំអ្នករុងរឿង ។

*សរសេរនៅខែមេសា ១៩៨៦*
*អ្នកស្រីកែវចន្ទ័បូរណ៍*

CHANBOKEO.COM

# ឫស្សីសាយគុម្ព

ឫស្សីមួយមែកដាំសាយគុម្ព ព្រោះទំពាំងធំលូតលាស់មក់
ភ្លោះកូនថ្មីៗមិនឈប់ឈរ ជាឫស្សីល្អខ្ពស់លើសមុន ។
បើឫស្សីក្រោយក្លាយតូចស្ដួច គុម្ពច្បាស់ជាហោចប្រែស៊ិយស៊ុន
ស្រកម្ដងបន្តិចតូចជាងមុន គុម្ពទ្រោមតគ្រុនលែងឲ្យផល ។
ដូចប្រទេសជាតិក្លាយខ្សោយទន់ បើបច្ឆាជនយន់កាយកល
ទំពាំងក្រោយទ្រោមស្រុតគុម្ពគល់ ជាតិច្បាស់ជាយល់ហាយនៈ ។
ឫស្សីសាយគុម្ពពឹងទំពាំង ជាន់ក្រោយធំខាំងខ្ពស់ប្រត្យក្ស
លើសឫស្សីមុនយ៉ាងអនគ្ឃ សាយគុម្ពឥតអាក់ស្ដុកស្ដម្ភក្រៃ ។
មិនខុសប្រទេសដែលជឿនលឿន ពលរដ្ឋជំរឿនសព្វវិស័យ
ក្មេងមានវិជ្ជាខ្ពស់លលៃ លើសចាស់សម័យពីបុរាណ ។
ច្នេះយើងចាស់ៗគួរបណ្ដុះ ឲ្យក្មេងលូតលាស់ខ្ពស់ថ្កើងថ្កាន
គំនិតប្រាជ្ញវិជ្ជាបាន ចំណេះសំខាន់ជួយជាតិយើង ។
ហើយទទួលផងថាយើងចាញ់ ក្មេងក្រោយត្របាញ់ខ្ពស់ថ្កុំថ្កើង
កាន់តែលាស់ទៅលើសរូបយើង សាយគុម្ពរីកឡើងយ៉ាងវិសាល ។

អ្នកស្រីកែវចន្ទ័បូរណ៍

CHANBOKEO.COM

# វគ្គទីមួយ
# មិត្តភាពថ្មី

ក្រុងភ្នំពេញ...

នៅមុខមហាវិទ្យាល័យភូមិន្ទ...

យុវជនម្នាក់អង្គុយលើម៉ូតូ ដែលចតស្ងៀមក្រោមម្លប់ឈើតូច មួយ ។ យូរៗម្តងគេលើកដៃមើលនាឡិកា... ទំនងដូចជាកំពុងរង់ ចាំនរណាម្នាក់ ។

- បងសិលា!

ឮស្នូរសម្លេងនារីម្នាក់ហៅឈ្មោះ នរៈបែររកមើលម្ចាស់សម្លេង ភ្លាម ស្រាប់តែញញឹមឡើង ៖

- ធីតា ?

នារីម្នាក់ក្នុងសម្លៀកសិស្សសាលាដើរមកដល់យ៉ាងរហ័ស ៖

- បងចាំខ្ញុំយូរហើយមែនទេ ?
- ប្រហែល១០នាទីហើយទេដឹង! រួចអូនដាឃ្លានបាយឬនៅ ?
- ចាស នៅទេ! បងមានការទៅណាហ្នុស ?
- គឺបងចង់ចូលហាងសេវាឥន្ទ្រីណែត ឆែកអ៊ីមែលបន្តិច!
- យី! ឥឡូវនេះ បងខ្ញុំឆែកអ៊ីមែលញឹកញាប់ណាស់! មាននរណា សំខាន់ពីបរទេសសរសេរមកហ្នុស ?
- មិត្តរួមគេហទំព័រមាននាមប៉ាកកាថា ស្រស់ឆោម ។ គេប្រាប់បង ថា គេត្រូវមកដល់ភ្នំពេញអាទិត្យនេះ ហើយចង់ណាត់ជួបបង រាប់អានដើម្បីគ្នាជាមិត្ត!

CHANBOKEO.COM

- អីយ៉ា! ជាស្រីផង ? សង្ស័យតែគេចាប់ចិត្តលើបងហើយ!
- តែផ្ដាស! យើងមិនដែលស្គាល់មុខគ្នាផង ធ្វើម៉េចហ្នឹងចាប់ចិត្ត គ្នាកើត ?
ការពិតយើងជួបគ្នាតែនៅក្នុងបន្ទប់សំណេះសំណាលនៅ លើ គេហទំព័រឥន្ទ្រីណិតខ្មែរប៉ុណ្ណោះ ។
- ហើយមានដែលប្ដូររូបថតគ្នាមើលតាមខ្សែអ៊ីមែលទេ ?
- មានម្ដងដែរ...
- អញ្ចឹងហ្នឹងណា៎... បានខ្ញុំថា... ប្រហែលជាមិត្តរបស់បងឈ្មោះ ស្រស់នោមនោះ
គេពេញចិត្តនឹងរូបសង្ហារបស់បងប្រុសហើយទើប គេសុំដាក់ការណាត់ជួបជាមិត្ត...
- ចេះតែនិយាយអត់បានការហើយ អូនដានេះ!
យុវជនយើងក៏ធាក់បញ្ឆេះម៉ូតូ ឌុបប្អូនចេញទៅយ៉ាងលឿន
ទំនងអៀននឹងការចំអន់របស់ប្អូនស្រី ។
- បងសិលា! កុំបរលឿនពេកមើល៍! តិចធ្លាក់ប្អូនដែលនៅជិះពី ក្រោយបងនេះបាត់ទៅណា៎!
ធីតាលេងបងប្រុសសើចកក្អឹកតាមផ្លូវ ។ ឆ្នាំនេះ នាងមាន វ័យ២២ឆ្នាំហើយ
ហើយក៏កំពុងបញ្ចប់ឆ្នាំទីបួននៅមហាវិទ្យាល័យ ដែរ ។ សិលាជាបងប្រុសអាយុ២៦ឆ្នាំ
ធ្វើការជាអ្នកភ្លេងប្រចាំក្រុម តន្ត្រីនៅភោជនីយដ្ឋានទំនើបមួយ ។ ឪពុកសិលាមានគ្រោះថ្នាក់ក្នុង
ការងារ បណ្ដាលអោយពិការជើងម្ខាង ធ្វើការមិនកើត ក៏សំរាកនៅ ផ្ទះ ។ ចំណែកម្ដាយវិញ
ជាអ្នករកស៊ីជួញដូរលក់ខោអាវនៅផ្សារ អូឡាំពិក ។
សិលានិងធីតាមានប្អូនប្រុសពៅម្នាក់ទៀតឈ្មោះសុធន
អាយុទើបតែ១៧ឆ្នាំ ត្រូវប្រលងបញ្ចប់មធ្យមសិក្សាឆ្នាំនេះ ។

នៅមុខហាងសេវាទូរសព្ទ័និងឥន្ទ្រីណិត...
ធីតាឈរយាមម៉ូតូធ្វើត្រិះត្រុះៗ ចាំសិលាឆែកអ៊ីមែលពីមិត្តនារី ម្នាក់មកពីអាមេរិក ។
- យូរម្ល៉េះលោកអើយ! សង្ស័យតែអាល័យអានសំបុត្រសង្សារ ភ្លេចប្អូនស្រីហើយមើលទៅ!
កំពុងតែគិតភ្លឹកៗ ស្រាប់តែមានក្មេងតូចម្នាក់រត់តាមចិញ្ចើមថ្នល់ ទៅបុកបុរសម្នាក់
ដែលកំពុងដើរចេញពីហាងសេវាឥន្ទ្រីណិតនោះ បណ្ដាលឲ្យបុរសផ្ងាកក្រោយ ។
គេក៏ស្រវាទប់ខ្លួននឹងដៃម៉ូតូរបស់ នារី ធ្វើឲ្យនាងភ្ញាក់ព្រើត ផ្ងាកក្រោយរិះដួលធ្លាក់ ។
ឃើញដូច្នោះ បុរសនោះក៏លូកដៃយ៉ាងលឿនទៅជួយទប់ខ្នងនារី មិនអោយនាង ផ្ងាកដួលធ្លាក់ដី ។

CHANBOKEO.COM

ធីតាស្ទុះងើបបានដំហរវិញហើយ ក៏បែរក្រោយ មើល
ស្រាប់តែប្រទះនឹងបុរសសង្ហាមួយរូបមុខមាត់ស្លូតបូតស្អាត បាត កំពុងញញឹមដាក់នាង ៖
- សូមទោសបាទ ដែលធ្វើអោយអ្នកនាងភិតភ័យ!
- ចាស... មិនអីទេ...! អរគុណដែលជួយទប់មិនអោយដួល!
បុរសនោះងក់ក្បាល ហើយក៏ដើរត្រឡប់ទៅឡើងរថយន្តមួយ
ដែលមានមិត្តចតចាំនៅមិនឆ្ងាយពីនោះប៉ុន្មាន ។ ភ្លាមនោះ នរៈក៏ បែរមកញញឹមដាក់ធីតាបន្តិច
ទើបឡើងរថយន្តចេញទៅ ។
- នែ! មើលនរណាគេហ្នឹងអូនដា បានជាភ្លឹកចំហាមាត់ដូច្នេះ ?
ធីតាភ្ញាក់ព្រើត បែរក្រោយឃើញបងប្រុសឈរកាន់ដៃម៉ូតូ ។
នាងក៏និយាយបន្លប់ថា ៖
- គឺ... ដាកំពុងភ្លឹកនឹកគិតទៅដល់សោភ័ណនារីឈ្មោះស្រស់ឆោម
ដលបំរុងមកជួបបងនោះអី ។
- អញ្ចឹង ? បងថាដូចជាមិនមែនទេ! បងគិតថា ដាកំពុងភ្លឹកនឹក
ស្រមៃយដល់ភាពសង្ហារបស់បុរសណាម្នាក់ទេដឹង ?
- ចេះតែថាហើយ បងឯងនេះ! តោះទៅផ្ទះ!
អៀនពេក ធិតាក៏បែរមុខចេញមិនអោយបងប្រុសឃើញ ខ្លាច នាយចំអន់ថែមទៀត ។
សិលាក៏ឌុបប្អូនចេញទៅ ។

មកដល់ផ្ទះវិញ...
- អាឡូ! កូនដា!
- ចាស! ម៉ាក់!
- ថ្ងៃនេះ មិនបាច់ដាក់បាយស្រាក់ផ្ញើម៉ាក់នៅឯផ្សារទេ ព្រោះអ្នក
លក់ជិតខាងនេះគេហៅអោយបរិភោគជាមួយគេម៉ាពេល ។
- ចាស!
- ហើយជួយមើលប៉ាកូនផងណា៎!
- ចាស! ម៉ាក់!

CHANBOKEO.COM

បុរសចំណាស់ម្នាក់វ័យប្រមាណ៥០ឆ្នាំដើរទប់ឈើច្រត់ចេញមក ដល់ ៖
- ប៉ាដាំបាយឆ្អិនហើយកូន! ឆាប់ទៅរៀបចាសញ៉ាំទៅ!
- ចា៎ស!
នោះគឺអ៊ំសាឡាង ឪពុករបស់សិលា ។ ដោយសារអ៊ំមានតែ ជើងម្ខាង ទើបមិនអាចធ្វើអ្វីបានក្រៅពីកិច្ចការផ្ទះបន្តិចបន្តួច ប្តូរគ្នា អោយអ៊ំសារីចេញរកស៊ីចិញ្ចឹមគ្រួសារវិញ រួមផ្សំនឹងប្រាក់ខែដែល សិលារកបានខ្លះផង ដើម្បីជួយទំនុកបំរុងអោយធីតានិងសុធនរៀន សូត្រ ។ សិលាមិនបានរៀនដល់មហាវិទ្យាល័យទេ ព្រោះគេត្រូវធ្វើ ការជួយគ្រួសារ តាំងពីឪពុកមានគ្រោះថ្នាក់ពិការជើងនោះមក ។ រីឯធីតាដែលរៀនពូកែឆ្លៀវឆ្លាតបានត្រូវឪពុកម្តាយរបស់នាងឧបត្ថម្ភ អោយរៀនយ៉ាងខ្ពស់បំផុតដែលក្រុមគ្រួសារអាចធ្វើទៅបាន រហូត ដល់សុធនលួចតូចចិត្តថា ឪពុកម្តាយស្រឡាញ់កូនស្រីជាងគេ ក្នុង ចំណោមកូនទាំងបីនាក់ ។
- ប៉ាអញ្ជើញពិសារបាយ! (សិលាហៅឪពុក)
- អឺ! ញ៉ាំមុនទៅកូន! ប៉ាចាំនៅបរិភោគក្រោយជាមួយសុធនចុះ
- ចាំសុធន នោះមិនដឹងម៉ោងប៉ុន្មានទើបមកទេ ប៉ា ព្រោះសុធន ចេញចូលផ្ទះមិនទៀងទាត់ តិចលោប៉ាមិនស្រួលខ្លួនទៅ ។
- ប៉ាមិនអីទេកូន! ញ៉ាំមុនចុះ ។
សិលានិងធីតាសម្លឹងមុខគ្នា ។ មែនហើយ! ថ្មីៗ ប៉ុន្មានខែនេះ សុធនដូរចរិតប្លែកណាស់ ។ គេចេញទៅរៀនរាល់ថ្ងៃមិនសូវឃើញ ត្រឡប់មកបរិភោគអាហារថ្ងៃត្រង់ជាមួយគ្រួសារទេ ។ ជួនកាលគេ រំលងបាយល្ងាច ហើយមកដល់ផ្ទះយប់ជ្រៅ ។ លុះដល់ឪពុកម្តាយ សួរនាំ គេក៏ខឹងភ្លាម រួចគំហកតបវិញថា គេរវល់យជាប់រៀនដើម្បី ប្រឡងបាក់ឌុប ។ បើដដឹកសួរច្រើន គេក៏ឆក់កាតាបរៀនហក់ឡើង កង់ចេញទៅបាត់ មិនដឹងទៅណាទេបាត់ពេញមួយយប់ទៅ ។
ក្រុមគ្រួសារអ៊ំសាឡាង ក៏មិនជាធូរធារប៉ុន្មានដែរ ។ គាត់រស់ នៅក្នុងផ្ទះចាស់មួយតូច តាំងពីឆ្នាំ១៩៨០មក នៅពីក្រោយខ្នងគេ ចូលតាមច្រកចង្អៀត តូចមួយម្តុំផ្សារសន្ធរម៉ុក ។ សព្វថ្ងៃ គ្រប់គ្នា រំពឹងលើធីតានិងសុធន ថានឹងបានរៀនសូត្រខ្ពង់ខ្ពស់ មានការងារ ល្អ នឹងអាចបានជួយយិតយោងគ្រួសារ កុំអោយដុនដាបពេក ។ រីឯការងារជាអ្នកតូរ្យតន្ត្រីរបស់សិលាយើងវិញ ក៏មិនជាលូតលាស់ ប៉ុន្មានដែរ ។ សព្វថ្ងៃ សិលាបានទទួលប្រាក់ខែ៩០ដុល្លារមួយខែ ផ្សំនឹងប្រាក់ដែលអ៊ំសារីរកស៊ីខ្លះៗ

CHANBOKEO.COM

ទើបអាចទប់ទល់ការចំណាយ រាល់ថ្ងៃបាន ។ នេះបើកុំតែធីតាបានទទួលអាហារូបករណ៍សិក្សាពី
សាលា កុំអីមិនដឹងជាយ៉ាប់យ៉ាងណាទេ ព្រោះគ្រួសារនេះ មិនមាន
អ្វីជាទុននឹងជួយកូនចៅអោយរៀនឡើយ ក្រៅពីការងារធ្វើការ ដោយកម្លាំង ។

ព្រលប់ថ្ងៃនដែល...
- បងសិលា! បានអ៊ីមែលជួបគ្នាជាមួយមិត្តរបស់បងពីអាមេរិក ឈ្មោះឆោមស្រស់ហើយមែនទេ
បានជាថ្ងៃនេះ ស្លៀកពាក់ដូចជា សង្ហាខុសធម្មតា ។
សិលាញញឹម ហើយស្រដីថា ៖
- មែនហើយ! គេអ៊ីមែលប្រាប់បងថា គេនឹងទៅមើលបងលេង
ហ្គីតានៅហាងភោជនីយដ្ឋានជំនោរផៃ ល្ងាចនេះតែម្តង ។ ប្អូនដា ចង់ទៅលេងទេ
ដើម្បីអោយបានជួបនឹងនាងផង ?
ធីតាគ្រវីក្បាល ៖
- អត់ទេ! ដើរលេងយប់ មិនល្អទេបង!
- ចុះអូនដាមានទៅដើរម្នាក់ឯងឯណា ? អូនទៅជាមួយបងទេតើ!
ហើយយប់នេះជាយប់ថ្ងៃសៅរ៍ ថ្ងៃស្អែក ប្អូនអត់មានថ្នាក់រៀនទេ!
ទៅដើរលេងជាមួយបងម្តងទៅ ណា៎!
- អីយ៉ា! បងសិលា! សង្ស័យតែបងអៀនមិនហ៊ានជួបគេហើយ បានជាយកប្អូនដើរតាម
អោយកក់ក្តៅ ។
ធីតាសើចកខឹក លលេងបងប្រុស ។
- បើដឹងហើយ កុំជាន់កែង ប្រយត្ន័ដល់វេនប្អូនវិញ តិច... លោ អៀនជាងបងទៅទៀត...
- ដាមិនដែលគិតចង់មានសង្សារជាអ្នកអាមេរិកទេ បងអើយ...
- ថាមិនត្រូវទេ... នរណាទៅមើលអនាគតឃើញ ?
- ហើយចុះមានកម្លោះអាមេរិកភ្នែកខ្វាក់ឯណា មកមើលឃើញ អូនដាដ៏គ្រីគ្រ រូបក៏មិនល្អ
ហើយរៀនក៏មិនទាន់ចប់យ៉ាងនេះ ?
- នរណាទៅដឹង ? ស្រាប់តែដើរជំពប់ជើងម្តង ភ្ជាប់និស្ស័យមួយ ជីវិតក៏មិនដឹង!!
ធីតាភ្ញាក់ព្រើត ៖
- បងសិលា! ចង់ចាក់ផាអូនដារឿងបុរសព្រឹកមិញនោះមែនទេ ?

CHANBOKEO.COM

- បើមិនហ្នឹង... ស្អី ?
- បងសិលានិយាយផ្ដាស ! ដាយប់និយាយជាមួយបងហើយ !

ធីតាស្ទុះដើបចេញទៅ ប៉ុន្តែ សិលាចាប់ដៃឃាត់ ៖

- នែ៎ ! កុំទៅណា៎ ! ស្លៀកពាក់មក៎ ! ទៅជាមួយបង !
- អោយងាទៅយ៉ាងណា បើមិនបានសុំច្បាប់ម៉ាក់ប៉ាផង ?
- បងសុំគាត់រួចអំបាញ់មិញរួចហើយ ។
- អូហ៎ ! បងប្រាប់គាត់ថាម៉េច បានជាអោយទៅស្រួលម្ល៉េះ ?
- ប្រាប់ថា មានភ្ញៀវអាមេរិកមកសុំណាត់ស្ដាប់ស្នាដៃបងលេងភ្លេង ទើបបងសុំអោយអូនឯងទៅជួយទះដៃអបអរ ។
- ហើយបងមានប្រាប់គាត់ទេ ថាគេជាភ្ញៀវនារីសំខាន់ ?

សិលានឹកខ្នាស់ចំពោះប្អូនស្រីដៃលចំអន់ពេក ក៏យកដៃទៅច្បាមក្បាលនាងលេងបន្តើរៗ ធ្វើអោយធីតារសើបសើចកក្អឹកឡើង តែម្ដង ។ បន្តិចមក គេក៏នាំប្អូនស្រីឡើងជិះម៉ូតូចេញទៅ ស្រាប់តែ អ៊ំសាវីសួរថា ៖

- ចុះសុធនវិញ គេទៅមើលកូនសម្ដែងលើឆាកយប់នេះដែរទេ សិលា ?
- បាទ ! អត់ទេ ម៉ាក់ !
- អញ្ចឹងហ៎ុស ? ហើយចុះតើគេដើរទៅណា ទើបថ្មើរនេះមិនទាន់ ឃើញមកផ្ទះ ?
- ប្រហែលជានៅផ្ទះពួកម៉ាកជិតៗនេះ ធ្វើកិច្ចការត្រៀមប្រឡងទេ ដឹង បាទ ?
- អឺ... បើឯងឃើញប្អូន ជួយរំលឹកអោយវាមកផ្ទះផង ប្រាប់ថា ម៉ាក់ប៉ាបារម្ភ ។
- បាទ ម៉ាក់ !

នៅភោជនីយដ្ឋានជំនោរផៃ ដ៏សែនស្អាតទំនើបវិចិត្របំផុត...

សិលាលើកហ្គីតាឡើងប្រដេញសូរយ៉ាងពិរោះខ្ទ័រខ្ទារ អមដោយសំនៀងសព្ទនៃគ្រឿងតន្ត្រីជាច្រើនផ្នែកទៀត ផ្សំនឹងសម្លេងដ៏មាន ទឹកដមនៃអ្នកចម្រៀង បានរណ្ដំខាបអារម្មណ៍ទស្សនិកជនគ្រប់ៗគ្នា អោយសោមនស្សរីករាយក្រៃលែង ។ បន្តិចមក បទភ្លេងក៏បណ្ដើរ មកដល់ចម្រៀងថ្មីជាចង្វាក់មនោសញ្ចេតនាយ៉ាងស្រទន់មួយ ។

ធីតាអង្គុយស្ងៀមនៅក្បែរឆាក លួចគយគន់មើលទៅនារីទាំង ឡាយនៅទីនោះ ក្រែងមាននរណាលួចបោះក្រសែភ្នែកចម្លែកទៅ លើបងប្រុសរបស់នាង ។ ប៉ុន្តែ

CHANBOKEO.COM

ច្រើនបទកន្លងទៅហើយ ធីតា សង្កេតឃើញថា ភ្ញៀវនារីទាំងនោះសម្តែងកិរិយារីករាយសប្បាយ ធម្មតាៗ មិនមាននរណាម្នាក់លួចចាប់អារម្មណលើសិលាជាពិសេស សោះ ។ រំពេចនោះ សំនៀងចម្រៀងដ៏ស្រទន់មួយបានរណ្តំឡើង យ៉ាងមនោរម្យ បបោសអង្អែលទងបេះដូងនារីយើងអោយរំភើប ប្លែក ក្នុងចិត្តតែម្តង ។ ធីតាភ្ញាក់ព្រើត លាន់មាត់ខ្សិបៗថា ៖

- យី! បទនេះពីរោះណាស់តើហ៍!

ធិតាក៏ចោលភ្នែកទៅរកអ្នកច្រៀង ស្រាប់តែប្រទះនឹងបុរស សង្ហាម្នាក់ដែលដើរជល់ម៉ូតូរបស់សិលាថ្ងៃត្រង់ នៅមុខហាងសេវា ឥន្ទ្រីណិត ។ ភ្លាមនោះ គេដាក់ភ្នែកមកចំនារីយើង ហើយក៏ញញឹម យ៉ាងស្រស់ដាក់នាង ធ្វើអោយស្រស់ស្រីភ្ញាក់ក្រញាងបើកភ្នែកធំៗ នឹកងឿងឆ្ងល់ក្នុងចិត្តតែម្នាក់ឯងថា ៖

- ការពិត! បុរសម្នាក់នេះ ជាអ្នកចម្រៀងទេហ្ន៎ស ? ខ្ញុំគិតស្មាន ថាគេជាជនបរទេសហើយតើហ៍ ព្រោះឫកពាមិនសមជាអ្នកនៅក្នុង ស្រុកខ្មែរអ្វីបន្តិចសោះ ។

ឯសំនៀងដ៏ពិរោះនៃបទចម្រៀងរបស់បុរសសង្ហាយើងវិញ ក៏ បានធ្វើឲ្យធីតាលួចរំជួលចិត្តម្តងជាពីរដងទ្វេឡើងរកថាមិនត្រូវ...

CHANBOKEO.COM

## ជួបភក្ត្រ័ជំពាក់ចិត្ត

ពេលបានជួបភក្ត្រ័ជំពាក់ចិត្តស្នេហ៍ ពៅល្អដូចខែពេញវង់សោភា
បេះដូងបងឆ្លាក់រូបស្រស់ពាំងា ក្នុងដួងទ័យាជាគូនៃបនិត្យ ។
មិនទាន់យល់ប្រាណបានត្រឹមស្រមោល ឱរាតែលតោលនឹកកែវវរមិត្រ
បងសូមស្រែកច្រៀងផ្ញើសៀងដួងចិត្ត សារភាពការពិតឲ្យស្រីបានដឹង ។
ស្រស់អើយអើយស្រស់មាសម៉ុំធិតា ទទួលផងណាបេះដូងបងហ្នឹង
កាត់ផ្ញើជូនអូន ឱ! កែវព្រលឹង រៀមសូមដណ្តឹងអូនហ្នឹងជាគូ ។
ឆ្លើយចាំសណាំអូនកុំអោយបងខក ផ្សងថៃត្របកផ្កាស្រស់ផង់ផ្ទូរ
ឧបសគ្គយ៉ាងណាបងស្មគ្រ័ផ្តាច់ប្តូរ យកអូនជាគូរួមជីវិតរៀងអើយ ។

ភ្ញៀវទាំងឡាយក៏ទះដៃគគ្រឹកគគ្រេងខ្ទ័រផ្ទៃហាងភោជនីយដ្ឋាន ទាំងមូល ។ នៅចំហៀងឆាក ធីតាអង្គុយស្តាប់ចម្រៀងដ៏ពិរោះនោះ ផង លួចគយគន់ភាពសង្ហារបស់បុរសនោះផង ។

មិនដឹងជាហេតុ អ្វីទេហ្ន៎ បានជានាងចាប់អារម្មណ៍លើបុរសនោះម្ល៉េះ ? ភ្លាមនោះ មាណវីងាកទៅរកបងប្រុសរបស់នាង ឃើញនាយញញឹមមករក រកនាងវិញយ៉ាងរីករាយ ។

ពេលសម្រាកក៏បានមកដល់...

សិលាចុះពីលើឆាកសំដៅប្អូនស្រី ៖

- ម៉េចទៅ ការសម្តែងរបស់បងយប់នេះ ពិរោះទេអូនដា ?
- ឡូយអស្ចារ្យហើយបងសិលា!

សិលាញញឹមដាក់ប្អូន ស្រាប់តែមានស្ត្រីម្នាក់ ស្លៀកពាក់ទំនង ប្លែកជាងអ្នកភ្នំពេញបន្តិច បានដើរមកដល់ ស្រដីហៅថា ៖

- សិលា មែនទេ ?

សិលាភ្ញាក់ព្រើត បែរមើលវិញ ហើយសួរត្រឡប់ទៅវិញថា ៖

- ស្រស់ឆោម ?
- ចា៎ស! មែនហើយ!
- ជំរាបសួស្តីអ្នកនាង!

សិលាពោលទាំងញញឹម ព្រមទាំងលួចគន់លក្ខណៈសម្បត្តិរបស់ នាងភ្លៀកៗផង ។

- សួស្តី! ថ្ងៃនេះ ខ្ញុំសប្បាយចិត្តព្រោះយើងជួបមុខគ្នា ។
- ខ្ញុំក៏សប្បាយចិត្តដែរ ។

សិលានិយាយផង លូកដៃផង បំរុងចាប់ដៃនារីស្វាគមន៍របៀប បស្ចឹមប្រទេស ស្រាប់តែនាងបែរជាលើកដៃជំរាបសួរត្រឡប់វិញ ធ្វើអោយសិលាខកដៃរលីង ហើយនឹកខ្មាស់ចំពោះកិរិយារបស់ខ្លួន រហូតឈរអេះអុញបន្តិច ទើបលើកដៃសំពះទទួលវិញ ។

- សូមទោស អ្នកនាង! អំបាញមិញ ខ្ញុំបំរុងចាប់ដៃព្រោះនឹកថា ចង់ស្វាគមន៍អ្នកនាងរបៀបអាមេរិក!
- ចា៎ស! មិនអីទេ! ការពិតទៅ យើងជាខ្មែរនៅលើដីខ្មែរ គួរតែ ស្វាគមន៍គ្នាជារបៀបខ្មែរទើបសម ។

សិលាភ្ញាក់ព្រើត នឹកខ្មាសក្នុងចិត្តរិតតែខ្លាំងថែមទៀត រហូត ដល់ក្រហមត្រចៀកងាំង ៖

- ពិតជាប្រពៃណាស់អ្នកនាង! កិរិយានឹងគំនិតរបស់អ្នកនាងធ្វើ អោយខ្ញុំមានមោទនភាពចំពោះអ្នកនាងក្រៃលែងតែម្តង ។

CHANBOKEO.COM

- អរគុណសិលា!

បន្តិចមក សិលានឹកពិភាល់ក្នុងចិត្តក៏សួរថា ៖

- អ្នកនាងស្រស់នោម! តើខ្មែរយើងនៅអាមេរិក ពេលគេជួបគ្នា គេចាប់ដៃ ឬក៏គេសំពះសួរ ពេលគេជួបគ្នា ?

ស្រស់នោមសើចញញឹមឡើង ៖

- គឺគេសំពះសួរគ្នាដូចតែយើងនៅស្រុកខ្មែរអញ្ចឹង ។ ខ្មែរចាប់ដៃ ជនជាតិអាមេរិកតែនៅក្នុងពេលសម្ភាសន៍រកការធ្វើ ឬពេលមាន ជំនុំក្រសួងជាមួយពួកអាមេរិកាំងប៉ុណ្ណោះ ។ ចំពោះខ្មែរគ្នាឯង យើងនៅតែរក្សាទំនៀមទម្លាប់សំពះសួរ ដូចស្រុកខ្មែរដដែលទេ ។
- ប៉ុន្តែ ចុះហេតុដូចម្តេច បានជាកូនខ្មែរអាមេរិកខ្លះ មិនចេះ សំពះជំរាបសួរ ពេលគេមកលេងស្រុកខ្មែរ ?
- គឺមកពីក្មេងទាំងនោះមិនបានទទួលការអប់រំពីឪពុកម្តាយអោយ ដិតដល់ ហើយជួនកាលឪពុកម្តាយរបស់ក្មេងទាំងនោះ មិនសូវចាប់ អារម្មណ៍ពីការការអប់រំកូនចៅ មិនសូវចង់រក្សាភាពថ្លៃថ្នូររបស់ខ្មែរ ព្រោះគាត់ខ្លួនឯងមិនស្គាល់ផង តើថាភាពថ្លៃថ្នូររបស់ខ្មែរជាអ្វី ។ ចំណែកទម្លាប់ធម្មតារបស់អាមេរិកចំពោះមនុស្សស្គាល់គ្នា គេច្រើន ញញឹមដាក់គ្នាហើយនិយាយថា «សួស្តី» ។ គេមិនសូវចាប់ដៃទេ វៀរលែងតែពួកគេទើបតែស្គាល់ជួបគ្នាដំបូង ។ ប៉ុន្តែ បើសិនពពួក អាមេរិកាំងចូលចំណោមខ្មែរ គឺគេទម្លាប់សំពះគោរពគ្នាតាមរបៀប ខ្មែរយើងជានិច្ច ។
- អូហ៎ អញ្ចឹង! ខ្ញុំស្មានថា ខ្មែរនៅអាមេរិកគេលែងសំពះគ្នាទៀត ហើយ ។
- នរណាថា ? ខ្មែរនៅអាមេរិកនៅរក្សាទម្លាប់ល្អរបស់ខ្មែរច្រើន ណាស់ ដែលខ្មែរយើងនៅភ្នំពេញនេះគួរតែដឹង ។ ការពិត ខ្មែរនៅ អាមេរិក នៅស្តាប់ចំរៀងខ្មែរ នៅស្លៀកពាក់ខ្មែរពេលធ្វើបុណ្យ នៅនិយាយខ្មែរពេលជួបគ្នា នៅអានកាសែតខ្មែរ នៅមានផ្សារលក់ ឥវ៉ាន់និយាយខ្មែរ នៅរក្សាពិធីមង្គលការជាខ្មែរ ច្រើនណាស់!
- ចំណែក អ្នកនាងក៏និយាយខ្មែរច្បាស់ណាស់ទៀតផង ។
- មែនហើយ ព្រោះឪពុកម្តាយខ្ញុំតែងតែប្រដៅថា កាលបើយើង ជាខ្មែរ យើងត្រូវរក្សាអត្តសញ្ញាណជាខ្មែរ ចេះនិយាយខ្មែរ ចេះ សំពះគោរពញាតិ ចេះញ៉ាំប្រហុក ហើយចេះវន្ទាព្រះសង្ឃ ។

CHANBOKEO.COM

- ស្លាប់ហើយ អ្នកនាងចេះសព្វយ៉ាងតែម្តង! ហើយចុះអ្នកនាង ចេះអក្សរខ្មែរទេ?
- ចេះតិចៗ! ជួនកាលរៀនអានតាមថាសកាវ៉ាអូខេ ប៉ុន្តែ ប៉ាម៉ាក់ ខ្ញុំមានប្រសាសន៍ថា
ពាក្យខ្មែរនៅក្នុងកាវ៉ាអូខេនោះមានខុសច្រើន ណាស់ ។ ដោយសារខ្ញុំគ្មានសៀវភៅរៀន
ម្ល៉ោះហើយក៏រៀនអាន តាមកាវ៉ាអូខេទៅ អាចចេះច្រៀងចម្រៀងផង ចេះអក្សរខ្មែរផង ។
- អញ្ចឹង ប្រហែលជាអ្នកនាងចេះច្រៀង ល្មមអាចដាក់ម៉ាបទពីរ នៅលើឆាកបានទេ?
សិលានឹងលេងហ្គីតាអោយអ្នកនាងច្រៀង ។
- កុំអី! ខ្លាចរំខានភ្ញៀវ! ប៉ុន្តែបើនៅផ្ទះវិញ ស្រស់ឆោមនឹង
ច្រៀងអោយស្តាប់មិនខាន ។

សិលាសង្កេតឃើញថាស្រស់ឆោមរួសរាយណាស់ ក៏សួរថា ៖
- ស្រស់ឆោម! អ្នកអាមេរិកគេរួសរាយដាក់គ្នាណាស់ មែនទេ?
- មែនហើយ! ពួកអាមេរិករួសរាយហើយច្រើនមានសន្តានចិត្ត ចំពោះគ្នា
ថ្វីបើមានបុគ្គលខ្លះនៅប្រកាន់ខ្លួន ជាពិសេសរវាងពពួក ស្បែកសនិងស្បែកខ្មៅ ។ ជាទូទៅ
ពួកអាមេរិកចូលចិត្តញញឹម ដាក់គ្នាពេលប្រទះឃើញគ្នាហើយនិយាយថា «សួស្តី» ទោះបីជា
មិនស្គាល់គ្នាក៏ដោយ ។
- អញ្ចឹងតើហ៎ បានជាអ្នកនាងរួសរាយដាក់ខ្ញុំយ៉ាងហ្នឹង ។

ស្រស់ឆោមញញឹម ។ លុះបែរឃើញធិតាភ្លាម នាងក៏សួរថា ៖
- ហើយចុះនារីរូបស្អាតម្នាក់នេះជានរណាដែរ?
- ជាប្អូនស្រីរបស់ខ្ញុំ ឈ្មោះធីតា ។
- អូហ៎ ជំរាបសួរធិតា! ស្រស់ស្អាតណាស់!
- ជំរាបសួរបងស្រី! មិនដឹងជាសរសើរខ្ញុំអីទេ ខ្ញុំធម្មតាៗតើហ៎!

ស្រស់ឆោមញញឹមក្របួចមាត់ហើយនៅស្ងៀមទំនងប្លែកចិត្ត ។
ឃើញដូច្នោះធីតាក៏សួរថា ៖
- បងស្រីមានការអ្វីទើសទាល់ក្នុងចិត្តមែនទេ?
- គឺ ភ្ញាក់ផ្អើលនឹងទំនៀមទម្លាប់រវាងខ្មែរដែលខុសពីអាមេរិក ។
- ខុសគ្នាអ្វីទៅ បងស្រី?
- គឺខ្ញុំចង់ប្រាប់ធិតាថា បើនៅអាមេរិកវិញ ពេលណាគេសរសើរ រឿងអ្វីមួយ យើងត្រូវឆ្លើយថា
អរគុណ ។ ពាក្យនេះមិនមែនបាន ន័យថា យើងស៊ីជោរនិងពាក្យដែលគេសរសើរទេ ប៉ុន្តែជាការ

CHANBOKEO.COM

សម្តែងមោទនភាពរបស់យើង ចំពោះសំដីនិងការគិតសុទន្ធិរបស់ ញាតិ
ដែលសំគាល់ឃើញនូវបុគ្គលិកលក្ខណៈវិជ្ជមានរបស់យើង ។

ធីតាញញឹម ព្រោះថ្ងៃនេះ នាងបានស្តាប់នឹងពត៌មានច្រើនពី
នារីដែលមានឈ្មោះស្រស់ឆោម ។ កាន់តែស្តាប់ នាងកាន់តែចូល ចិត្ត ។ មើលទៅនារីនោះ
គេមានវ័យស្រករៗនឹងបងប្រុសរបស់ នាង ប៉ុន្តែ មានកិរិយានិងការស្លៀកពាក់សាមញ្ញ
មិនឡូយឆាយអ្វី ឡើយ ។ បែរទៅសិលានិងស្រស់ឆោមវិញ ហាក់ដូចស៊ីឆ្នូងមួយ ។
គេនិយាយឆ្លើយឆ្លងគ្នាសើចអោយរអឹក ។ បន្តិចមក ស្រស់ឆោមក៏
អូសដៃអ្នកទាំងពីរទៅរកតុរបស់នាង ហើយណែនាំមនុស្សពីរនាក់ ទៀត ប្រុសម្នាក់ស្រីម្នាក់
អោយស្គាល់គ្នា ៖

- សិលា! ធីតា! នេះ ដារិន និង ដារី ជាមិត្តរបស់ខ្ញុំ ។ គេ ទាំងពីរជាបងប្អូនបង្កើតនឹងគ្នា ។
ដារិនជាបង ហើយដារីជាប្អូន ។
- ជំរាបសួរ ។

ទាំងបួននាក់សំពះសួរគ្នាទៅវិញទៅមក ។ ក្នុងចំណោមនោះ
ធិតាមានការភ្ញាក់ផ្អើលក្នុងចិត្តច្រើនជាងគេ ត្បិតដារិននោះមិនមែន
នរណាក្រៅពីបុរសសង្ហាដែលឡើងច្រៀងលើវេទិកាអំបាញ់មិញមុន នេះនោះឡើយ ។
ធិតាគិតក្នុងចិត្ត ៖
- ពុទ្ធោ! គេនេះជាអនិកជនមកពីអាមេរិកមែនតើហ៏!

ភ្លាមនោះ ធីតាក៏ចាប់ភ្លឹកដៃរថា បុរសសង្ហានោះលួចញញឹម ដាក់នាងដែរ ជាសញ្ញាថា
គេនៅចាំនាងបាន ។ ធីតានឹកខ្មាសក្នុង ចិត្ត ក៏លួចបែរខ្លួនឈរអែបបាំងខ្លួនពីក្រោយបងប្រុស
ព្រោះនរៈ ចេះតែសម្លឹងនាងមិនដាក់ភ្នែកសោះ ។ ទាំងអស់គ្នាអង្គុយសំណេះ
សំណាលយ៉ាងសប្បាយ ។ ដារីបានស្រដីទៅសិលាថា ៖
- សិលាលេងហ្គីតាបានពិរោះដល់ហើយ! លេងភ្លេងយូរហើយ មែនទេ ទើបថ្នឹកដៃដល់ម្លឹង ?
- បាទ គឺប្រហែល៧ឆ្នាំហើយ តាំងពីរៀនចប់មធ្យមសិក្សាមក ។
- អូហ៏! ហើយចុះអាល័យតែមកលេងហ្គីតា បានពេលឯណាទៅ រៀនបន្ត ? (ស្រស់ឆោមសួរ)
- គឺ ខ្ញុំមិនបានរៀនទេ ព្រោះអាល័យជួយគ្រួសារ និងជួយប្អូនឲ្យ រៀន (សិលានិយាយផង
ងាកមុខដាក់ធីតាផង)

CHANBOKEO.COM

- គួរអោយស្តាយណាស់ណ៎ា កាលបើយើងនៅក្មេង មិនបានរៀន បន្តអោយខ្ពង់ខ្ពស់ (ដាវីនិយាយ)

- មែនហើយបាទ (សិលាតប) បើសិនជាជីវភាពក្រុមគ្រួសារមិន អត្តខាត់ពេកទេ ខ្ញុំប្រហែលជាមិនបោះបង់សាលាទេ ។

- បើសិនជានៅអាមេរិកវិញ សិលានឹងបានចូលរៀនមិនខានព្រោះ រដ្ឋគេទំនុកបំរុងអាហារូបករណ៍ដល់សិស្សក្រីក្រ ហើយក្រុមគ្រួសារ ដែលខ្វះខាតក៏ទទួលការទំនុកបំរុងពីរដ្ឋដូចគ្នា ដូចជាលុយកាក់និង ផ្ទះសំបែងជាដើម ជាពិសេសបើសិនមេគ្រួសារមានជំងឺឬពិការ ។

សិលាឈ្ងោកមុខនៅស្ងៀម ទំនងនឹកស្តាយដែលខ្លួនមិនបាន ទៅរៀនខ្ពង់ខ្ពស់ ។ រំពេចនោះ មានគេមកហៅសិលាឲ្យត្រឡប់ទៅ សម្តែងតន្ត្រីកំដរភ្ញៀវបន្តទៀត ។

- សូមទោស ខ្ញុំទៅធ្វើការបន្តវេនបន្តិចសិន ។

ថាហើយគេក៏ទាញដៃប្អូនស្រីត្រឡប់ទៅវិញ ស្រាប់តែស្រស់ ឆោមយាត់ ៖

- គឺ..ទុកធីតាអោយនៅអង្គុយលេងជាមួយយើងទីនេះសិនហើយ ។ សិលាទៅធ្វើការសិនចុះ ។

ឮដូច្នោះ សិលាក៏ញញឹមឡើង ហើយព្រលែងដៃប្អូនឲ្យអង្គុយ ចុះវិញ ទើបដើរបោះពួយឡើងទៅលើឆាក ។

នៅជុំវិញតុ ទាំងបួននាក់មិនបានចាប់អារម្មណ៍អំពីបរិយាកាស ខាងក្នុងភោជនីយដ្ឋានទេ ព្រោះពេលនេះ ម្នាក់ៗអាល័យតែចង់សួរ ពត៌មានពីធីតា អំពីជីវិតរបស់ពលរដ្ឋនៅស្រុកខ្មែរ ។

- នេះ បងប្រុសបងស្រីមិនដែលមកលេងស្រុកខ្មែរម្តងណាទេ ?

ធីតាសួរ ។

- អត់ទេ! (ដាវីឆ្លើយ) បងកើតនៅជំរុំទល់ដែន ទៅនៅអាមេរិក តាំងពីតូច ចេះខ្មែរតិចៗ រៀនអក្សរខ្មែរនៅជំរុំបានខ្លះ ប៉ុន្តែ បង ត្រឡប់មកស្រុកខ្មែរពេលនេះ ព្រោះចង់ដឹងអំពីឫសគល់របស់ខ្លួន ឯងនិងក្រុមគ្រួសារ ។ ចំណែកបងដាវីឌកើតនៅស្រុកខ្មែរសម័យ ខ្មែរក្រហម រួចបានមកអាមេរិកឆ្នាំ១៩៨៦ ម្ល៉ោះហើយគាត់ចងចាំ ស្រុកខ្មែរតិចតួចណាស់ ។ ចំណែកស្រស់ឆោមវិញ គេមានសំណាង ជាងគេព្រោះមានឪពុកម្តាយគេជាគ្រូបង្រៀន ។ គេចេះភាសាខ្មែរ ច្រើនជាងបង

CHANBOKEO.COM

ប៉ុន្តែក៏នៅឆៅច្រើនយ៉ាងណាស់ ស្គាល់ពាក្យខ្មែរមិន គ្រប់គ្រាន់ទេ ។ ហើយចុះធិតាវិញ ធ្លាប់មានពួកម៉ាកមិត្តភក្តិជា អនិកជនទេ ?

ធីតាគ្រវីក្បាល ៖

- ចាស! មិនដែលទេ! គឺបងទាំងបីជាអនិកជនដំបូងហើយដែល ខ្ញុំជួប ។
- អញ្ចឹង យើងសុំគ្នាជាមិត្តណា! (ដារីនិយាយ) ធិតាបង្រៀនបង អំពីអ្វីៗនៅស្រុកខ្មែរ ហើយបងវិញនិងបង្រៀនប្អូនពីអ្វីៗនៅស្រុក អាមេរិក ក្រែងថ្ងៃណាមួយមានសំណាង បានទៅរស់នៅទីនោះនឹង

គេ ។

ធីតាញញឹមមិនហ៊ានឆ្លើយទេ ព្រោះកំពុងបែកញើសខ្លួង នឹក ខ្មាសក្រសែភ្នែករបស់ដារិង ដែលសម្លឹងមាឈរទីមិនព្រមដាក់ភ្នែក ម្តងណាឡើយ ។ មួយស្របក់ក្រោយមក ស្រស់ឆោមនិងដារីបាន ទទួលទូរស័ព្ទមួយពីមិត្តភក្តិនៅអាមេរិក ក៏បបួលគ្នាចេញទៅខាង ក្រៅ ព្រោះសម្លេងត្សូតន្ត្រីលាន់ទ្រហឹង នៅក្នុងភោជនីយដ្ឋានខ្លាំង ពេក មិនអនុញ្ញាត្តិអោយគេនិយាយឆ្លើយឆ្លងទូរសព្ទ័បានស្រួល ។ ម្ល៉ោះហើយ ធិតាក៏ត្រូវនៅអង្គុយទោលតែឯងជាមួយដារិង ។

ដើម្បីបន្លប់សេចក្តីអៀនខ្មាស់ដែលនាងត្រូវមកអង្គុយតុជាមួយ បុរសតែពីរនាក់ ធិតាក៏បំបែរកៅអី បែរមុខទៅរកឆាកសម្លឹងបង ប្រុសដែលកំពុងទាត់ប្រដេញបទភ្លេងយ៉ាងរន្ទើន ។

ភ្លាមនោះ ដារិងឌូរកៅអីមកអង្គុយជិតធីតា ហើយស្រដីថា ៖

- មិនចូលចិត្តខ្ញុំរឿងអ្វីធីតា បានជាគេចមុខមិនហ៊ាននិយាយរកខ្ញុំ សោះអញ្ចឹង ?

នារីយើងភ្ញាក់ព្រើត បែររកដារិង ហើយបែរទៅវិញ ៖

- គឺខ្ញុំមិនទម្លាប់អង្គុយក្បែរបុរស... ត្បិតមិនសមភ្នែកអ្នកផង ។
- អូហ៍ ស្រុកខ្មែរគេប្រកាន់មិនអោយបុរសនារីអង្គុយក្បែរគ្នាទេ ?

ធីតាឈ្ងោកមុខបន្តិច ទើបងើបឡើងវិញហើយឆ្លើយថា ៖

- គឺ... ភាគច្រើន ពេលគេឃើញឌូច្នោះ គេនឹងគិតថា យើងទាំង ពីរមានចំណងអ្វីសម្ងាត់នឹងគ្នា...
- ចំណងអ្វីទៅដែលសម្ងាត់នោះ ? មានន័យថា សង្សារមែនទេ ?
- បើត្រឹមជាសង្សារនោះ មិនសូវអីទេ...!
- អូហ៍.. ? អញ្ចឹងលើសពីហ្នឹងទៅទៀត ?

CHANBOKEO.COM

- ចាស...! គឺ... ហួសខាងផ្លូវមិនល្អ....
- មានន័យថាម៉េចហ្នឹង ?
- ខ្ញុំ... មិនហ៊ានពន្យល់ទេ... ចាំសួរបងប្រុសខ្ញុំទៅ!
- ម៉េចចាំសួរបងប្រុសផង ? ធិតាធំពេញវ័យហើយ ហេតុម្ដេចក៏ ពុំមានភាពរឹងប៉ឹង ល្មមគ្រាន់នឹងឆ្លើយត្រឹមសំនួរប៉ុនហ្នឹងបានទេ ?

ចាក់ចំចំណុចខ្សោយ ធីតាងើបមុខឡើង ឆ្លើយថា ៖
- មិនមែនធីតាមិនរឹងប៉ឹងទេ... ប៉ុន្តែស្រីៗស្រុកខ្មែរមិនចូលចិត្ត និយាយរឿងមិនសមរម្យ ។
- រឿងអ្វីទៅមិនសមរម្យ ? បើធិតាមិនប្រាប់ខ្ញុំ នោះខ្ញុំធ្វើម៉េច នឹងដឹងថា សមរម្យឬមិនសម ?
- ណ្ហើយ! ខ្ញុំជំរាបលោកចុះ ថាបើសិនគេឃើញនារីអង្គុយតុតែពីរ នាក់ជាមួយបុរស ហើយសម្ដែងកិរិយាស្និទ្ធស្នាលនឹងគ្នាទៀតនោះ គេនឹងគិតថា ខ្ញុំនេះជានារីរកស៊ីពេលយប់ណា៎ ដឹងទេ ?

ដាវីដភ្ញាក់ព្រើត បើកភ្នែកធំៗ ងើបងួរកៅអីរឹង ៖
- អូហ៍អញ្ចឹង ? បើដូច្នេះ យើងមិនបាច់ស្និទ្ធស្នាលក៏បានដែរ ។ ខ្ញុំ ក៏មិនហ៊ានឲ្យជាប់ឈ្មោះអញ្ចឹងដូចគ្នាដែរ ក្រែងទៅដល់អាមេរិក វិញ ឮឈ្មោះសុសសាយមិនល្អស្ដាប់ ។

គេក៏ស្ទុះងើបទៅអង្គុយនៅឯជាយតុម្ខាង ឆ្ងាយពីធីតាយ៉ាង រហ័ស ធ្វើឲ្យនារីយើងភ្ញាក់ផ្អើលសាថ្មី នឹកក្នុងចិត្តថា ៖
- ហេតុអ្វីក៏ចាំបាច់ភ្ញាក់ផ្អើលដល់ម្លឹង ? គិតទៅអ្នកអាមេរិក ចង់ ចូលជិត ជិតហួស ដល់ដកឆ្ងាយ ឆ្ងាយហួសតែម្ដង ។

បន្តិចមក តន្ត្រីក៏បញ្ចប់កម្មវិធី ។ សិលាក៏ដើរចុះមក ចំពេល ជាមួយនឹងនារីពីរនាក់ទៀតដើរត្រឡប់មកតុវិញ ព្រមគ្នា ។
- អេហ៍ អ្នកទាំងពីរមិននិយាយអ្វីនឹងគ្នាទេ ហ្អែស បានជាអង្គុយ ម្នាក់ម៉ាទិសយ៉ាងនេះ ? (ស្រស់ឆោមសួរ)

ដាវីដមិនឆ្លើយទេ គ្រាន់តែចោលកន្ទុយភ្នែកដាក់ធីតា ហើយ ក៏ញញឹមធ្វើមិនដឹង ។ បន្ទាប់ពីសំណេះសំណាលបានមួយស្របក់ ទាំងអស់គ្នា ក៏សុំបំបែកផ្លូវ ។

CHANBOKEO.COM

- ថ្ងៃក្រោយជួបគ្នាទៀត ស្រស់ឆោម ដារី បងដារិន ។ បើទំនេរ
កុំភ្លេចមកស្តាប់ភ្លេងរបស់ពួកខ្ញុំផង ។ ថ្ងៃនេះ បានដារិនឡើង ច្រៀងពីរបទជាមួយភ្លេងយើង
ពិតជាអនុស្សាវរីយ៍ដ៏មានតម្លៃមិន អាចបំភ្លេចបានឡើយ (សិលានិយាយ)
- មែនហើយ! តើថ្ងៃណាពួកយើងអាចទៅលេងផ្ទះសិលាបាន ?
យើងចង់ស្គាល់ស្ថានភាពគ្រួសារខ្មែរនៅស្រុកខ្មែរណាស់ (ស្រស់
ឆោមសួរសិលា)
- គឺ... គ្រួសារខ្ញុំក្រីក្រ ផ្ទះតូចចង្អៀត មិនដឹងថា សមរម្យអាច ទទួលអ្នកទាំងបីឬយ៉ាងណាទេ
(សិលាតប)
- កុំទៅភ័យអីសិលា! ពួកយើងទាំងពីរនាក់ជានិស្សិត សុទ្ធតែមាន បំណងស្រដៀងៗគ្នា
ចង់ធ្វើការស្រាវជ្រាវឬសគល់កំណើតរបស់ ខ្លួនផង
ចង់សរសេរអត្ថបទសំរាប់ការសិក្សារបស់យើងផង ។ បើ
បានស្គាល់គ្នាតាមលក្ខណៈសាមញ្ញនោះរិតតែប្រសើរ ។ យើងមិន ចង់ស្គាល់អ្នកវណ្ណៈខ្ពស់
ឬអ្នកមានទ្រព្យទេ ព្រោះភាពថ្កុំថ្កើងរបស់ គេ អាចបាំងភ្នែកយើង មិនឲ្យឃើញស្ថានភាព
ជីវភាពពិតប្រាកដ របស់សង្គមខ្មែរ ។
- បើអ្នកទាំងបីពិតជាមិនប្រកាន់មែន ចាំខ្ញុំជូនលេខទូរសព្ទ័និង អាសយដ្ឋានរបស់ខ្ញុំចុះ ។
សិលាក៏ស្រវាប៉ាកកានិងក្រដាសចារយ៉ាងរហ័សហុចទៅអោយ ស្រស់ឆោម ។
- អរគុណ ។ អញ្ចឹង! បើទំនេរ ពួកយើងនឹងទៅលេងស្អែក
យ៉ាងម៉េចដែរ សិលា ? (ស្រស់ឆោមសួរ)
- ស្អែកក៏បាន! ចាំខ្ញុំជំរាបប៉ាម៉ាក់ខ្ញុំ ។
បន្ទាប់មក គេក៏បំបែកផ្លូវគ្នា ។ មុននឹងឡើងរថយន្តចេញទៅ ដារិនលួចចោលភ្នែកសម្លឹងនីតា
បញ្ជូនស្នាមញញឹមតូចមួយនៅលើ ផ្ទៃមុខមករកនារី
ធ្វើអោយមាណវីយើងក្តៅមុខភាយៗតែម្តង ។
ភ្លាមនោះ សិលាលាន់មាត់ឡើងថា ៖
- បងគិតថា បងដារិនកំពុងតែចាប់អារម្មណ៍ចំពោះប្អូនស្រីរបស់ បងហើយ ។
- ចេះតែថាហើយ បងសិលា! ដារិនគេជាមនុស្សចំណូលថ្មីនៅ ភ្នំពេញនេះ ។
នរណាក៏គេចាប់អារម្មណ៍ចង់ស្គាល់ទាំងអស់ហ្នឹង!
- ថាមិនត្រូវទេ ចាំតែមើលទៅ ។

CHANBOKEO.COM

ធីតានឹកអៀននឹងសំដីបងប្រុសណាស់ តែមិនហ៊ានមាត់តទៅ ទៀតទេ ខ្លាចបងប្រុសចាប់ចំណុចខ្សោយបាន ក៏នៅស្ងៀម ឡើងជិះម៉ូតូពីក្រោយបងប្រុសចេញទៅ ។

*ooooooooooooooooo*

*oooooo*

*o*

CHANBOKEO . COM

# វគ្គទី២
# ភ្លើងស្ទាវ

តាមផ្លូវ...

សិលាឌុបប្អូនស្រីបណ្តើរ ជជែកគ្នាបណ្តើរ ស្រាប់តែ...

ផាំង! ប្រាវ!

សិលាឃើញក្មេងស្ទាវមួយហ្វូងធំបរម៉ូតូដេញគ្នាបុកដួលគ្រេងៗ តាមដងផ្លូវនៅខាងមុខឯណោះ ហើយគេឃើញពួកគេចុះវាយ គ្នាផង ។ សិលាលើកដៃមើលនាឡិកា...

- នេះ ម៉ោងជាង១២អាធ្រាតហើយ ក្មេងអស់នេះមិនទាន់ចូលផ្ទះ ទៀត ?

សិលាបង្អង់ម៉ូតូ ស្រាប់តែប្រទះឃើញក្មេងជំទង់ម្នាក់លាបសក់ ហាយឡៃកំពុងប្រឡូកប្រវាយប្រតប់ជាមួយនឹងគេដែរ ។ សិលាក៏ ឧទានឡើងថា ៖

- សុធន ?

គេក៏ឈប់ម៉ូតូ ៖

- អូនដាមើលម៉ូតូ! បងទៅចាប់សុធនសិន ។
- បងសិលា កុំទៅអី ក្រែងក្មេងវាជ្រុលដៃជើងលើបងណា!

ធិតាស្រែកឃាត់ ប៉ុន្តែហួសពេលទៅហើយ ។ សិលាបានទៅ ដល់កណ្តាលហ្វូងស្រវាអូសដៃសុធនចេញមក ក៏ត្រូវក្មេងៗវាយ ពីរបីព្រនង់ពីក្រោយដួលប្រូសទៅដីតែម្តង ។

- បងសិលា!

CHANBOKEO.COM

ធីតាស្រែកភ្លាត់សម្លេង ។ ភ្លាមនោះ រថយន្តឡិចសិសមួយបាន បញ្ចាំងភ្លើងឆ្វាចយ៉ាងភ្លឺរន្ទាលទៅលើហ្វូងក្មេង ព្រមទាំងស៊ីផ្លេយ៉ាង រន្ថើនផង ។ ខ្លាចគេចំណាំមុខបាន ក្មេងៗក៏បែកហ្វូងរត់អស់រលីង នៅសល់តែសិលាដែលដួលផ្កាប់មុខនៅលើដី និងសុធនដែលឈរ ក្បែរនោះ មាត់មុខមាត់ប្រឡាក់សុទ្ធតែឈាម ។

ធិតាព្រលែងម៉ូតូចោល ហើយស្ទុះទៅលើកបងប្រុសឡើង ទាំង ក្តីភិតភ័យតក្កមា ៖

- បងសិលា! បងសិលា!

ប៉ុន្តែសិលាសន្លប់បាត់មាត់ទៅហើយ ។ ធីតាភ័យពេកក៏គំហក អោយសុធនថា ៖

- សុធន! ឃើញអំពើរបស់ប្អូនហើយនៅ ? ឯងកំពុងនាំទុក្ខដល់ គ្រួសារយើងហើយ ។

សុធនមិនឆ្លើយទេ ឃើញតែឈរយកដៃជូតឈាមចេញពីមុខ តែប៉ុណ្ណោះ ។ មើលទៅប្រហែលជាគេភិតភ័យខ្លាំងរហូតដល់គិតអ្វី លែងចេញក៏មិនដឹង ទើបមិនឃើញនិយាយអ្វីតបមកធីតាយើងវិញ ទេ ។ នារីក៏ស្ទុះគ្រាហ៍បងប្រុសអោយងើបឡើង ប៉ុន្តែលើក មិនរួចសោះ ព្រោះគេមានមាឌធំដំបងពេក ។

រំពេចនោះ មនុស្សដែលនៅលើរថយន្តក៏នាំគ្នាចុះព្រួមក ៖

- ធីតា ? សិលា ?

ឮសម្លេងគេហៅឈ្មោះ ធីតាក៏ងើបមុខឡើង ប្រទះឃើញដារី ដារិន និងស្រស់ឆោមដើរមកដល់ ។ នាងក៏ស្រែកឡើង ៖

- បង! បង! ជួយបងប្រុសខ្ញុំផង!

ដារិនក៏លីសិលាដាក់ទៅលើពូកឡានខាងក្រោយ ។ រីឯស្រស់ ឆោមក៏សួរនារីយើងថា ៖

- តើធីតាចង់អោយយើងជួយដឹកបងប្រុសរបស់នាងទៅខាងណា ដែរ ?

- ចាស! ទៅផ្ទះរបស់ខ្ញុំ!

- អឺអញ្ចឹង! ធិតាបរម៉ូតូនាំមុខពួកយើងទៅ ។

ធិតាក៏ឡើងបញ្ឆេះម៉ូតូ ស្រាប់តែនឹកដល់ប្អូន ៖

- ធន! ឯណាកង់ ?

- គឺ... គឺ... កង់បាត់...តាំងពីម្សិល... (សុធនឆ្លើយរតាក់រតុប)

- ហេតុអ្វីបានបាត់ ?....

សុធនមិនឆ្លើយទេបែរជាឈ្ងោកមុខនៅស្ងៀម ។ ឯធីតាក៏គ្មាន វេលាសំរាប់គិតច្រើនដែរ ។ នាងក៏សង្ឃើញអោយសុធនឡើងជិះ ម៉ូតូពីក្រោយនាង ដើម្បីនាំមុខរថយន្តនាំសិលាទៅផ្ទះ ។

CHANBOKEO.COM

នៅលើគ្រែ...

សិលាប្រែខ្លួនឡើង បើកភ្នែកព្រឹមៗ ស្រដីខ្សាវៗថា ៖

- ធន!... ធន! ប្អូនយ៉ាងណាទៅហើយ... ?
- សុធនមិនអីទេកូន!
- ប៉ា ?
- អឺ! ប្អូនទាំងពីរបានមកដល់ផ្ទះហើយ មិនអីទេកូន!

សិលាបែរភ្នែកមើលជុំវិញខ្លួន ឃើញម្តាយឪពុកនៅអង្គុយអម សងខាងព្រមទាំងធិតានៅអង្គុយចុងជើង ព្រមទាំងមិត្តភក្តិបីនាក់ ដែលគេទើបតែជួបនៅភោជនីយដ្ឋានកាលពីព្រលប់ ។

- សិលា ? យ៉ាងម៉េចទៅហើយ ? (ដារិនសួរ)
- ខ្ញុំមិនអីទេ គ្រាន់តែចុកខ្នង ហើយវិលមុខ ។ អ្នកទាំងបីជាអ្នក សង្គ្រោះខ្ញុំមកមែនទេ ?
- គឺគ្រាន់តែជួយដឹកមកប៉ុណ្ណោះ ប៉ុន្តែ បានលោកគ្រូពេទ្យនៅជិត ខាងនេះ គាត់មកជួយមើលអំបាញ់មិញ ។
- គឺលោកពូពេទ្យនៅជាប់ផ្ទះយើងនេះណា៎កូន! ប៉ាទៅដាស់គេឲ្យ មកជួយពិនិត្យកូននោះអី (អ៊ំសាឡាដពោលបន្ថែម)

ឃើញកូនដឹងខ្លួនមកវិញ អ៊ំសាឡាដនិងអ៊ំសារីក៏ដកដង្ហើមបន្ធូរ ទ្រូងទាំងពីរនាក់ ។ ភ្លាមនោះ អ៊ំសាឡាដក៏សួរទៅអ្នកទាំងបីថា ៖

- ហើយចុះក្មួយមកពីខាងណាដែរ ? អ្នកភ្នំពេញនេះដែរទេ ?
- បាទ! គឺខ្ញុំមកពីអាមេរិកទេ លោកអ៊ំ!
- អូហ៍ ជាអនិកជនទេហ៍ ? ជាមិត្តដែលថា ជួបស្គាល់គ្នាជាមួយ សិលាតាមប្រពន្ធ័ឥន្ត្លឺណិតខ្មែរនោះ មែនទេ ?
- បាទ! មែនហើយ! ការពិត ស្រស់ឆោមរស់នៅរដ្ឋកាលីហ្វ័រញ៉ា ចំណែកខ្ញុំនឹងប្អូនស្រីមកពីរដ្ឋមិនីសូតា ។
- អូហ៍! អ៊ំឮតែកូនវានិយាយ ប៉ុន្តែអ៊ំមិនស្គាល់អាឥន្ត្លឺណិតជាស្អី ឡើយ ។ គិតៗទៅ គួរអោយអស្ចារ្យណាស់ហ្ន៎! ម្នាក់នៅអាមេរិក ម្នាក់នៅស្រុកខ្មែរ មិនដែលស្គាល់គ្នាសោះ ស្រាប់តែឥន្ត្លឺណិតនាំឲ្យ ស្គាល់គ្នាបាន ។ វិទ្យាសាស្ត្រពិតជាជឿនលឿនមែន ធ្វើអោយអ៊ំ

CHANBOKEO.COM

នេះក៏ចង់រៀនប្រើដែរ ក្រែងលោះអាចរកឃើញក្រុមគ្រួសារដែល
បែកព្រាត់គ្នាកាលពីសម័យខ្មែរក្រហម ៧៥-៧៨ ចង់ដឹងថាគេនៅ មាននៅជីវិត
រស់នៅជ្រកកោនស្រុកគេត្រង់ណាមួយឬយ៉ាងណា ។

អ៊ំសាឡាដនិងអ៊ំសារីហៅអោយអ្នកទាំងបីនៅស្នាក់លេង ប៉ុន្តែ ដោយយប់អាធ្រាតពេក
គេក៏នាំគ្នាលាត្រឡប់ទៅវិញ ។

- អឺ! បើទំនេរ ស្អែកមកលេងផ្ទះអ៊ំណា៎ ចាំយើងដណ្តាំអាហារខ្មែរ ទទួលអោយឆ្ងាញ់មាត់ម្តង
(អ៊ំសារីផ្តាំ)

អ្នកទាំងបីក៏លាចេញទៅវិញ ។ នារីពីរនាក់ហក់ឡើងឡានទៅ ហើយ
នៅតែដាវិដដែលនៅឈរវេរាៗ បែរក្រោយលួចមើលទៅ ក្នុងផ្ទះ ។
បន្តិចមកទើបគេហក់ឡើងរថយន្តតាមក្រោយ ។ ឃើញ ដូច្នេះ ស្រស់ឆោមក៏យកដៃកេះដាវិដ ៖

- នៅបែរក្រោយធ្វើវេរាៗ ចាំនរណាគេមកជូនដំណើរមែនទេ ?
- អត់ទេ! (ដាវិដឆ្លើយ) ខ្ញុំគ្រាន់តែចង់ដឹងថា តើសិលាគេស្រួល បួលហើយឬនៅ
ទាន់យើងនៅទំនេរអាចជួយដឹកទៅពេទ្យ បើសិន គេមិនស្រួលខ្លាំង ។

ស្រាប់តែដារីសើចខឹកៗ ៖

- ខ្ញុំថា បងដាវិដកំពុងលួចមើលអ្នកផ្សេងទៀត!
- មែនហ្នឹង (ស្រស់ឆោមបន្ទរ) ខ្ញុំឃើញបងដាវិដលួចចោលភ្នែក
ដាក់គេឡើងជិតស្រឡេវទៅហើយ... សង្ស័យតែលួចចាប់អារម្មណ៍
លើក្រមុំភ្នំពេញដ៏ស្រស់ស្អាតនោះហើយ ។
- យី! ឃើញគេស្រស់ស្អាតអញ្ចឹង បងសម្លឹងលេងផងមិនបាន ទេឬ ស្រស់ឆោម ?
(ដាវិដស្រដីត្រង់ៗ)
- សម្លឹងចេះតែបានហើយ តែប្រយ័ត្នសម្លឹងប៉ះក្មេងមិនទាន់ពេញ
វ័យទៅ (ឆោមស្រស់ចំអន់)
- ម៉េចថាមិនទាន់ពេញវ័យកើត ? ឆោមមានឮសិលាគេនិយាយទេ
ថាប្អូនរបស់គេរៀននៅមហាវិទ្យាល័យ ? បើដូច្នេះមែនគឺមានន័យ
ថា នាងពេញវ័យហើយណា៎!

CHANBOKEO.COM

- មែន! តែគេជាកូនក្មេងសំរាប់បង! មើលទៅ អាយុដូចជាខុស គ្នាច្រើនយ៉ាងនេះ និយាយគ្នាមិនស៊ីខ្សែទេ ។

- បងទើបតែអាយុ៣០តើហ៎ បងប្អូនគ្នាប្អូនដប់ឆ្នាំមានទាស់ថី ? ពួកអាមេរិកគេមិនប្រកាន់អាយុទេ!

- តែក្មេងគេគិតផ្សេងពីចាស់យើងគិតណា៎! តិចលោតាមគេមិន ទាន់ទៅ បងដារិនអើយ (ដារីបន្ថែម)

ដារិនសើចខឹកៗ កាលបើត្រូវនារីទាំងពីរលលេងចំអន់ ។ ភ្លាម នោះ គេដាក់ភ្នែកទៅក្នុងផ្ទះរបស់សិលាម្តងទៀត ស្រាប់តែឃើញ ធីតាចេញមកបិទទ្វារផ្ទះ ។ គេក៏លើកដៃបក់បោយ លាមាណារី ។ ធីតាឃើញហើយក៏ញញឹមតបវិញបន្តិច រួចហើយក៏បិទទ្វារទៅ ។

CHANBOKEO.COM

តាមផ្លូវ...

- ឃើញទេបងដារិន! នាងមិនព្រមលើកដៃបក់បោយតបបងវិញ ផង មានន័យថា នាងមិនចាប់អារម្មណ៍ពីបងឡើយ ។

ស្រស់ឆោមមិនអស់ចិត្ត នៅទទូចលលេងនឹងដារិន ។

- នរណាថា ? ខ្ញុំធ្លាប់ឮចាស់ៗថា ក្រមុំស្រុកខ្មែរប៉ិនលាក់អារម្មណ៍ ណាស់ មិនងាយបញ្ចេញអោយបុរសដឹងទេ ។ ជួនកាល នាងចាប់ អារម្មណ៍ពីខ្ញុំដែរ តែមិនមាត់អោយគេដឹង ក៏មិនដឹង ។

- អញ្ចឹង យើងភ្នាល់គ្នាទេ បងដារិន ?

- ភ្នាល់! បើធីតាមិនចាប់អារម្មណ៍ពីបង បងសុខចិត្តប៉ាវសំបុត្រ យន្តហោះឆ្នាំក្រោយអោយអ្នកទាំងពីរមកលេងស្រុកខ្មែរទៀត ។

- ជយោ! (ស្រស់ឆោម និងដារីទះដៃហ៊ោរឡើង)

- ប៉ុន្តែ បើធីតាគេចាប់អារម្មណ៍ពីខ្ញុំដែរ តើអ្នកទាំងពីរគិតយ៉ាង ម៉េចវិញ ?

- មានគិតយ៉ាងម៉េច ? គឺទិញសំបុត្រយន្តហោះអោយពួកយើងមក ស៊ីការបងដារិនឆ្នាំក្រោយនោះអី!

- ពុទ្ធោ! អីក៏ចេះម្លេះ ? ទិសណាក៏ដារីនិងឆោមឈ្នះបងរហូត!

- អញ្ចឹងហើយ ! ស្រីៗគេមានគ្នាពីរនាក់ ត្រូវតែឈ្នះសម្លេងឆ្នោត លើបងម្នាក់ឯងជានិច្ចអញ្ចឹងឯង ។

អ្នកទាំងបីក៏នាំគ្នាសើចកក្អឹកឡើង...

ព្រហាមថ្ងៃបន្ទាប់...

អ៊ំសាវីដើរទៅជិតកូនប្រុសពៅដែលកំពុងស្លៀកពាក់ ហើយ សួរថា ៖

- ឯងស្លៀកពាក់ទៅណាទៀតហើយ សុធន ?
- គឺទៅក្រៅម៉ាក់ភ្លេត !
- ក្បាលបែកមិនទាន់ស្ងួតឈាមផង ទៅទៀតហើយហ្ន៎សកូន ?
- ចុះកូនសម្លាញ់របស់ម៉ាក់នៅផ្ទះហើយតើ ចាំបាច់រវល់ពីខ្ញុំធ្វើអី ?
- ម៉េចបាននិយាយផ្ដេសផ្ដាសអញ្ចឹងសុធន ? ម៉ាក់ស្រឡាញ់ហើយ បារម្ភពីកូនគ្រប់គ្នា ដឹងទេ ?
- បើបារម្ភពីកូនមែន ហេតុអ្វីទៅសំកុកនៅតែផ្សាររាល់ថ្ងៃ ?
- គឺម៉ាក់ទៅលក់ឥវ៉ាន់ណាកូន មិនមែនទៅដើរលេងទេ ។
- ប៉ុន្តែម៉ាក់មិននៅផ្ទះដដែល តើអោយកូននៅផ្ទះម្នាក់ឯងកណ្ដោច កណ្ដែងម៉េចកើត ?
- ចុះប៉ាឯងនោះ ? ប៉ានៅផ្ទះជាមួយកូនហើយតើហ៎ !
- តែប៉ាធ្វើអ្វីផ្គាប់ចិត្តបងៗ មិនដែលឃើញអ្វីដែលខ្ញុំត្រូវការទេ
- កូននិយាយខុសហើយសុធន ។ ប៉ាតាមមើលបងស្រីឯងព្រោះគេ ជាស្រី ហើយគេកំពុងរៀនមហាវិទ្យាល័យ ។ ប៉ាមិនចង់អោយបង ឯងបែកអារម្មណ៍រៀនមិនចប់ បានជាគាត់ផ្ដល់ចំណាប់អារម្មណ៍ទៅ លើនាងច្រើន ។
- ឆ្នាំនេះ ខ្ញុំក៏ត្រូវប្រលងបញ្ចប់សាលាដូចគ្នា តែប៉ាមិនដែលរវី រវល់នឹងខ្ញុំអ្វីបន្តិចសោះ ។
- នរណាថា ? ប៉ាបារម្ភពីកូនឯងណាស់ ប៉ុន្តែកូនទេតើដែលចេះតែ គិតមិនល្អពីប៉ា ហើយដើរគេច មិនអោយប៉ាមានឱកាសបាននិយាយ អ្វីជាមួយកូនទេ ។

សុធនឈ្ងោកមុខនៅស្ងៀម ។ អ៊ំសាវីសួរបន្តទៀត ៖

- កូនដាបានប្រាប់ម៉ាក់ថា ឯងបាត់កង់ ។ តើមែនទេ ?
- គឺ... គឺ..

សុធនឆ្លើយតតាក់តតុប ។

CHANBOKEO.COM

- ព្រោះតែហេតុហ្នឹងឬ បានជាកូនមិនចូលផ្ទះ ? (អ៊ំសារីសួរ)

សុធននៅស្ងៀមដដែល ។

- ថ្ងៃនេះ ម៉ាក់មិនអោយកូនទៅណាទេ លុះត្រាតែយើងនិយាយគ្នា ដឹងរឿងសិន ណា៎សុធន ។

សុធនចងចិញ្ចើមធ្វើមុខក្រញូវ ។ រំពេចនោះ ស្រាប់តែមាន យុវជនពីរនាក់ជិះម៉ូតូមកឈប់នៅមុខផ្ទះ ចំនងមកទទួលសុធន ។ យុវជនក្រឡេកមកម្តាយ រួចហើយក៏ដើរចេញទៅយ៉ាងលឿន ។

- សុធនមកវិញ! ម៉ាក់មិនអោយទៅទេ ។

តែសុធនមិនស្តាប់ទេ ចេះតែដើរទៅមុខទៀត ស្រាប់តែមាន រថយន្តមួយថ្មីស្រឡាងមកឈប់ពីមុខម៉ូតូពីរនាក់នោះ ។ ភ្លាមនោះ បុរសង្ហាដារិនចុះពីរថយន្តមក ដោយកាន់ផ្លែឈើមួយស្បោងផង ប៉ុន្តែមិនឃើញស្រមោលនារីពីរនាក់នោះមកជាមួយទេ ។

- សួស្តី ប្អូនប្រុស! ស្អាមរបួសយប់មិញមិនធ្ងន់ធ្ងរទេហ្ស៎ បាន ជាថ្ងៃនេះ ចេញទៅក្រៅទៀតហើយ ? (ដារិនសួរសុធន)

តែសុធនដើរធ្វើពើជាមិនឮ ដើរហួសទៅឡើងម៉ូតូរបស់មិត្ត ស្រាប់តែធីតារត់មកដល់ យកបំពង់ឫស្សីមួយរុកទទឹងកាំម៉ូតូ ៖

- ឆាប់ចុះភ្លាម សុធន! នេះប្អូនមិនឮសំដីម៉ាក់យាត់ឯងទេហ៎ ?

ស្រាប់តែ សុធនស្ទុះទាញបំពង់ឫស្សីដែលធីតារុកទទឹងកាំម៉ូតូ នោះចេញហើយរុញធីតាថយក្រោយយ៉ាងខ្លាំង ធ្វើអោយនាងដួល ព្រូសទៅដីគ្រាំង ។ បន្ទាប់មកសុធនប្រាប់ពួកម៉ាកអោយបត់ម៉ូតូ ថយក្រោយ គេចរកច្រកចេញ ។ ដារិនឃើញដូច្នោះ ក៏ទម្លាក់ ស្បោងផ្លែឈើចោល ហើយស្ទុះទៅទាញម៉ូតូទប់មិនអោយទៅមុខ រួចយកដៃម្ខាងស្រវាអោបចង្កេះសុធនទម្លាក់ពីម៉ូតូរឹង ។ ដោយ សារមិនបានប្រុងប្រៀប សុធនក៏ធ្លាក់ពីលើម៉ូតូមែន ។ ឯពីរនាក់ ទៀត ឃ្លោងលំនឹង ក៏ដួលគ្រាំងទាំងពីរនាក់ ច្រងាប់ច្រងិល ។

សុធនដើបឡើង ស្រែកគំហកអោយដារិនថា ៖

- ឯងជានរណា ហ៊ានមកប្រកាសភាពជាសត្រូវនឹងយើង ?

ដារិនសើច ហើយឆ្លើយថា ៖

- ហើយចុះប្អូនប្រុសជានរណាដែរ ដែលហ៊ានយារដៃធ្វើបាបនារី ភេទដោយឥតអៀនខ្មាស់ ?

សុធនបើកភ្នែកមូលខ្លំ ៖

CHANBOKEO.COM

- គេជាបងស្រីយើង កុំមកចេះហៃហៃ!
- អូហ៍ ហើយចុះបងស្រីមានរឿងអ្វី បានជាប្អូនឯងប្រកាសភាព
ជាសត្រូវជាមួយបងស្រីរបស់ខ្លួនឯងដូច្នេះ ?
ភ្លាមនោះ ឪពុកម្តាយរបស់សុធនបានមកដល់ទាំងពីរនាក់ ។
- សុធន! ចូលផ្ទះវិញកូន!
សុធន បែរក្រោយឃើញពីរនាក់នោះប្រវេប្រវាទាញម៉ូតូរត់ គេចចេញទៅ ។
ទាល់ច្រកទៅណាមិនរួច សុធនក៏បែរដើរចូលផ្ទះ វិញ ។
រីឯធីតាបានលួចដើបឈរបបោសដីចេញពីកែងដៃដែលដួល រលាត់អំបាញមិញ ។
- មិនអីទេឬធីតា ?
ដារិទស្ទួរពេលឃើញនាងឈរបែរខ្នងបបោសដីពីដៃជើង ។
- ចា៎ស មិនអីទេ!
ធិតាឆ្លើយ រួចឈ្ងោកមុខដើរគេចចូលទៅក្នុងផ្ទះបាត់ ព្រោះ នឹកខ្មាស
ដែលនាងបានដួលរលាត់កែងដៃ នៅចំពោះភ្នែកបុរស ។ ដារិទ លួចមើលតាមនាងបន្តិច
ទើបងាកមកជំរាបសួរម្ចាស់ផ្ទះ ។ ព្រឹកនោះ គេនៅលេងសំណេះសំណាលជាមួយសិលា
ប៉ុន្តែមិនសូវ ហ៊ានរាក់ទាក់អ្វីនឹងអ៊ំសាឡាងនិងអ៊ំសារី ព្រោះឃើញគាត់ខ្វល់ខ្វាយ នឹងសុធនពេក ។
ដារិទកំពុងតែនិយាយគ្នាជាមួយសិលា ស្រាប់តែ
គេឮសម្លេងសុធនប្រកែកតមាត់ខ្លាំងៗជាមួយឪពុកម្តាយ ។
- ប៉ាកុំចេះតែបង្កាច់ខ្ញុំរបៀបនេះ!
- មិនបង្កាច់ទេ គឺអ្នកជិតខាងនេះ គេឃើញឯងយកកង់ទៅបញ្ចាំ
ហើយយកលុយចូលហាងហ្គេមក្បែរសាលា ដើរលេងជាមួយមិត្ត គេចរេះថ្នាក់រៀន
ព្រមទាំងលួចដក់អំហ្វីតាមីនហេរ៉ូអ៊ីនទៀតផង ។
- ប៉ាជឿតែអ្នកដទៃ មិនព្រមជឿកូនខ្លួនឯងម្តងណាសោះ!
- ហើយកូនមានប្រព្រឹត្តកិរិយាសមរម្យ ល្មមអោយប៉ាជឿកូនពេល
ណាម្តងដែរទេ កូន ?
- ខ្ញុំជំរាបប៉ាហើយតើហ៍ ថាកង់ខ្ញុំត្រូវចោរលួច ប្រហែលជាចោរ
ហ្នឹងវាលួចហើយយកទៅបញ្ចាំទេដឹង ?
- ឯងកុំភូតប៉ាអី! កូនប្រុសត្រូវហ៊ានស៊ីហ៊ានសង មិនមែនមុខ

CHANBOKEO.COM

ក្រាស់ហ៊ានស៊ីមិនសងនោះទេ ។ ពេលនេះ តើឯងក្លាហានស្មគ្រ័ទៅ ពេទ្យដោះឈាមជាមួយប៉ាទេ ?

- ទៅដោះធ្វើអ្វី ?

- ដោះដើម្បីអោយដឹងថា នៅក្នុងឈាមឯងវាមានជាតិថ្នាំញៀនឬ អត់ ? បើមានជាតិថ្នាំញៀន ប៉ានឹងសួរកូនថា កូនបានប្រាក់ពីណា ទិញវា ? ហើយបើរកចម្លើយល្អមកប្រាប់ប៉ាមិនបានទេ ប៉ានឹង សន្និដ្ឋានថា កូនយកកង់ទៅបញ្ចាំយកលុយទៅទិញថ្នាំញៀន ។

- ម៉េចក៏ប៉ាជ្រាបកើតថា ខ្ញុំប្រើថ្នាំញៀន ? (សុធនសួរ)

អ៊ំសាឡាងក៏មានប្រសាសន៍តបថា ៖

- គឺយប់មិញ ឯងមានរបួសឈាមហូរស្រោចខ្លួន តែមិនឃើញកូន ថ្ងូរថាឈឺមួយម៉ាត់សោះ សូម្បីតែពេលពេទ្យមកដេរថ្ពេរអោយពេញ ក្បាលហើយ កូននៅតែស្ពឹកមិនមានអារម្មណ៍ឈឺចាប់ ទើបប៉ានឹងថា ពេលនោះ ជាតិញៀនបានចូលក្នុងឈាមរបស់កូនជោគជាំទៅ ហើយ ទើបបានជាឯងស្ពឹកអារម្មណ៍យ៉ាងហ្នឹង ។

សុធនខាំធ្មេញក្រឹតៗ ក្តាប់ដៃ ទំនងហាក់ខឹងក្រៃលែងដែល ត្រូវឪពុកដេញទាន់ជាន់កែង ។ គេក៏ដាក់ភ្នែកទៅម្ខាងឃើញដារិង សម្លឹងមករកខ្លួន ក៏គំហកថា ៖

- នែ៎មើលអី ?

ដារិងអត់មិនបាន ក៏ឆ្លើយថា ៖

- ព្រោះបងចម្លែកចិត្ត នឹកឆ្ងល់នោះអី !

- ឆ្ងល់ស្អីដែរ ?

- ឆ្ងល់នឹងក្មេងស្រុកខ្មែរដែលបងប្រទះពេលនេះ ព្រោះអីកាលបង នៅអាមេរិក បងធ្លប់ឮឪពុកម្តាយបងមានប្រសាសន៍ថា ក្មេងស្រុក ខ្មែរស្តាប់បង្គាប់ឪពុកម្តាយហើយមានសណ្តាប់ធ្នាប់ណាស់ ។ ភាគ ច្រើន កូនខ្មែរក្លាហានចេះជួយការពារបងប្អូន ការពារក្រុមគ្រួសារ ណាស់ មិនសូវពិបាកប្រដៅដូចក្មេងស្រុកអាគាំងទេ ព្រោះក្មេងៗ ស្រុកអាគាំងវាពុលសេរីភាពខ្លាំងពេក ។ ចៃដន្យ ពេលបងប្រទះ ក្មេងនៅស្រុកខ្មែរនេះ បែរជាឃើញគេយ៉ាប់ជាងក្មេងអាមេរិកឆ្ងាយ ហៅមិនឮ ព្រោះគេហ៊ានគំហកអោយម្តាយឪពុក ដោយឥតក្រែង រអែងចិត្ត ហ៊ានតដៃបងស្រីអោយរបួស ហ៊ានលួចរបស់ទ្រព្យឪពុក

CHANBOKEO.COM

ម្តាយយកទៅបញ្ចាំ ដើម្បីទិញថ្នាំញៀន ហ៊ានអោយពួកម៉ាកវាយបងប្រុសឡើងមានរបួសទ្រោមខ្លួន ឯខ្លួនឯងឈរមើល មិនហ៊ាន ចូលទៅជួយ...

ដាវិឌនិយាយត្រង់ៗ តាមរបៀបអ្នកអាមេរិក ជាពិសេសដើម្បីឆ្លើយនឹងសំនួរដ៏គ្រោតគ្រាតរបស់សុធន ។ ពេលនោះយុវជនយើង ក៏ស្ងាត់មាត់ឈឹងនិយាយមិនរួច ។ បន្តិចមកដាវិឌក៏វាចាបន្តថា ៖

- ប្អូនចង់ដឹងទេ ថានៅអាមេរិក គេដាក់ទោសក្មេងដែលប្រព្រឹត្ត ឧក្រិដ្ឋយ៉ាងម៉េចខ្លះ ? ហើយហេតុអ្វីបានជារដ្ឋាភិបាលអាមេរិកនិរទេសក្មេងៗជាច្រើនអោយមកស្រុកខ្មែរវិញជាអចិន្ត្រៃយ៍ ?

សុធនបើកភ្នែកមូលក្លំទំនងចង់ដឹង ។ ព្រមជាមួយគ្នានោះដែរឪពុកម្តាយរបស់សុធនក៏បញ្ចេញកិរិយាចង់ដឹងដូចគ្នា ។ ដាវិឌក៏ ពន្យល់ថា ៖

- ចំពោះក្មេងក្រោម១៨ឆ្នាំ បើសិនគេគេចសាលា អវត្តមានបីថ្ងៃ ឡើងទៅអ្នកធ្វើការនៅសាលានឹងតាមរកឪពុកម្តាយ ដើម្បីរលឹក អោយនាំកូនទៅរៀនវិញ ។ បើបាត់លើសពីមួយអាទិត្យ គេបញ្ជូន សំណុំរឿងទៅតុលាការកាត់ទោសសិស្សដែលមិនចូលសាលា និង កាត់ទោសមាតាបិតាដែលខ្ជីខ្ជាមិនអោយកូនមករៀនទៀងទាត់ ។ ក្នុងករណីខ្លះ រដ្ឋដកកូនចេញពីផ្ទះយកទៅចិញ្ចឹមរួចពិន័យទោស ឪពុកម្តាយថែមទាំងបញ្ជាឲ្យបង់ពន្ធចិញ្ចឹមកូន នៅពេលកូនត្រូវរដ្ឋដកយកទៅចិញ្ចឹមអោយរៀនសូត្រ ។ បើក្មេងប្រព្រិត្តស្រា ញៀន អាភៀន ប្រព្រឹត្តបទឧក្រិដ្ឋឬអំពើហឹង្សាលើរូបកាយអ្នកដទៃ បង្ក ស្នាមរបួសឬក៏ឃាដកម្មវិញ គេនឹងកាត់ទោសក្មេងនោះតាមកំរិត ច្បាប់ធរមានតាមរដ្ឋនិមួយៗ រួចហើយគេយកទៅអប់រំផ្តាច់គ្រឿង ញៀនផ្តាច់ចរិតហឹង្សាព្រហើនកោងកាច នៅមន្ទីរដែលដាច់ឆ្ងាយពីសង្គមគ្រួសារនិងសហគមន៍ដែលខ្លួនធ្លាប់រស់នៅ ។ រដ្ឋតែងតែ ផ្តល់ឱកាស ម្តងជាពីរដងដើម្បីអោយក្មេងកែខ្លួន ប៉ុន្តែ បើកែមិនឡើងទេនោះទើបគេចាប់បញ្ជូនអោយមកនៅស្រុកខ្មែរវិញ ។

- ប៉ុន្តែ... ខ្ញុំមិនមែនក្មេងស្រុកអាមេរិកអស់នោះឯណា ? ចាំបាច់ ទៅភ័យអ្វីនឹងច្បាប់អស់នោះ ?

ដាវិឌញញឹមហើយបែរទៅអ៊ំសាឡាដនិងអ៊ំសារី សួរថា ៖

- អោយខ្ញុំសុំអនុញ្ញាតឆ្លើយបានទេ លោកអ៊ំ ?

CHANBOKEO.COM

ដោយចង់ដឹងពីបែបបទស្រុកគេផង អ៊ីសាឡាដក៏ឆ្លើយភ្លាម ៖

- អឺ! និយាយទៅ ក្មួយ!

ដាវិដក៏ពោលបន្តថា ៖

- មែនហើយ! ប្អូនមិនមែនក្មេងក្បាលខូចដែលគេបញ្ជូនមកពី អាមេរិកនោះទេ ប៉ុន្តែ ប្អូនកំពុងចម្លងចរិតពាលដាក់ខ្លួនហើយ ។

- ខ្ញុំមិនដែលចម្លងចរិតពាលទេ កុំមកបង្កាច់ខ្ញុំ!

- ចុះអំពើហឹង្សាវាយតប់បាញ់គ្នាតាមផ្លូវនោះ ហៅស្អីទៅវិញ? ចុះការដើរលេងយប់អាធ្រាត ញុំស្រា ជក់ថ្នាំញៀន លេងហ្គេម គេចសាលា បញ្ចេញភាពព្រហើនកោងកាចដាក់ឪពុកម្តាយនិងបង ប្អូននោះ មិនហៅថាអំពើពាលទេហ្ន៎ស?

- ក្មេងសម័យឥឡូវ នរណាៗក៏គេធ្វើបែបនេះដែរ មិនមែនតែខ្ញុំ ម្នាក់ទេ ។ បើបងចង់ប្រដៅ ទៅប្រដៅម៉ាប្រទេសទៅ!

- អូហ៍ ក្មេងខ្មែរម៉ាប្រទេស ធ្វើដូចប្អូនឥឡូវនេះអញ្ចឹងមែនទេ? ពុទ្ធោ! ក្មេងស្រុកយើងយ៉ាប់ដល់ម្លឹងផងហ្ន៎ស?

- នរណាថាយ៉ាប់? (សុធនគំហក) គឺពួកយើងកំពុងដើរទាន់ សម័យជឿនលឿន?

- ម៉េចក៏ថាជឿនលឿនទៅកើត ការពិត គឺប្អូនកំពុងនាំគ្នាដើរថយ ក្រោយទេ ។

- ម៉េចក៏ថាថយក្រោយទៅវិញ?

- ព្រោះអីប្អូនកំពុងបបួលគ្នាល្ងង់ជាងមុន!

- ម៉េចក៏ថាល្ងង់កើត? ក្មេងសព្វថ្ងៃឆ្លាតចេះប្រើទូរសព្ទ័ ចេះប្រើ ឥន្ទ្រីណិត ចេះលេងកុំព្យូទ័រហ្គេម មិនដូចចាស់បុរាណទេ ដែលល្ងង់ ទៅណាមិនរួច ធ្វើអីមិនចេញ ។

រំពេចនោះ ដាវិដសើចខឹកៗ ធ្វើអោយសុធនភ្ញាក់ព្រើត លាន់ មាត់ថា ៖

- សើចអីហ្នឹង?

- គឺសើចនឹងភាពល្ងង់ខ្លៅរបស់ប្អូនណ៎! បើប្អូនគេចសាលាមិន ចូលរៀនផង តើប្អូនឆ្លាតចេះនឹងត្រង់ណា? បើគេចផ្ទះ ដើរលេង កណ្តាលអាធ្រាត ផឹកស្រាជក់ម៉ា ស្រវឹងវង្វេងសតិ វាយគ្នាបែក ក្បាលហូរឈាម តើប្អូនឆ្លាតត្រង់ណា? បើមិនចេះស្គាល់ផង ថា ការគោរពឪពុកម្តាយនោះ គេត្រូវធ្វើយ៉ាងម៉េច តើអោយគេហៅ ប្អូនថាឆ្លាតត្រង់ណាកើត? បើឆ្លាតពិតមែន ត្រូវមានសតិប្រាជ្ញ ។ បើគ្មានសតិប្រាជ្ញទេ យើងនឹងក្លាយជាស្វាហើយ ហើយបើយើង ក្លាយជាស្វាមែន តើអោយគេហៅថាជឿនលឿនទាន់សម័យម្តេច នឹងកើត?

CHANBOKEO.COM

មនុស្សជឿនលឿន គឺគេមានសតិប្រាជ្ញានិងការចេះដឹង មិនពាលដូចសត្វ ។ គេដឹងខុសដឹងត្រូវ មិនមែនប្រជែងយកឈ្នះ ទាំងងងឹតងងល់ ទាំងកម្រោលនោះទេ ។ ការប្រើកម្លាំងពាល កម្រោល សម្តែងអោយឃើញថា យើងនៅខ្វះសតិប្រាជ្ញស្វែងរក មធ្យោបាយដោះស្រាយបញ្ហា ដោយមិនបាច់ប្រើកម្លាំងបាយមិន បាន ។ នោះមានន័យថា យើងមិនទាន់មានការចេះដឹងឆ្លៀវឆ្លាត មានការវិវត្តន៍ជឿនលឿនទាន់សម័យនៅឡើយទេ ។ សម័យជឿន លឿន គេប្រើប្រាជ្ញដោះស្រាយ មិនមែនកម្លាំងបាយទេ ណាំប្អូន!

សុធនបាត់មាត់ឈឹង មួយស្របក់ក៏ស្រដីថា ៖

- បងមិនមែនជាម៉ែឪខ្ញុំទេ កុំមកធ្វើឫកចង់ប្រដៅខ្ញុំធ្វើអី ?
- នរណាថាបងប្រដៅ ? ការពិត បងកំពុងអណោចអធម្មក្នុងចិត្ត ទៅវិញទេតើហ៍ ដែលបងមកពីអាមេរិក ចូលប្រទេសខ្មែរខ្លួនឯង ប្រទះឃើញក្មេងស្រុកយើង គេកំពុងចម្លងវប្បធម៌សីលធម៌ទាបៗ ដាក់ខ្លួន ហើយគិតច្រឡំថា ខ្លួនឯងជាអ្នកស៊ីវីល័យទាន់សម័យ ។ គិតៗទៅ បងហាក់ដូចជាអាណិតពួកគេដល់ហើយ ។
- សីលធម៌អ្វីខ្លះទៅដែលថាទាបៗនោះ ?
- គឺចរិតក្មេងក្មាង ឥតវិន័យ តួយ៉ាងដូចប្អូនកំពុងសម្តែងចំពោះ ឪពុកម្តាយ និងចំពោះខ្ញុំនៅពេលនេះនោះអី !
- វាជាសិទ្ធិរបស់ខ្ញុំ! កុំមកចេះ !
- ប្អូនច្រឡំហើយ ! ប្អូនមានសិទ្ធិពិតមែនណាំ! ប៉ុន្តែសិទ្ធិនិមួយៗ ត្រូវដណ្តប់ដោយវិន័យ ។
- មានន័យថាយ៉ាងម៉េច ?
- មានន័យថា ប្អូនមានសិទ្ធិរស់នៅក្នុងគ្រួសារ តែត្រូវគោរពវិន័យ ក្នុងផ្ទះដែលមានចាស់ទុំគ្រប់គ្រង ។ ប្អូនមានសិទ្ធិបើកបរម៉ូតូលើ ផ្លូវថ្នល់ តែត្រូវគោរពវិន័យចរាចរ ។ ប្អូនមានសិទ្ធិទទួលការសិក្សា តែគោរពវិន័យសាលា ។ ប្អូនមានសិទ្ធិនិយាយស្តី តែគ្មានសិទ្ធិជេរ ម្តាយគេ ឬគម្រាមសម្លាប់គេ គឺត្រូវរក្សាព្រំដែនវិន័យមិនរំលងទៅ ប្រមាថគម្រាមអ្នកដទៃ ។ ប្អូនមានសិទ្ធិប្រើដៃជើងរបស់ខ្លួនអោយ ក្លាយជាប្រយោជន៍ តែគ្មានសិទ្ធិវាយធ្វើបាបអ្នកដទៃ ។ល ។

និយាយទៅនិយាយមក សុធនក៏បាត់មាត់ឈឹង លែងស្តីតប ទៅដាវិងលែងរួច ក៏ដើរប្រុយចូលទៅក្នុងផ្ទះ លាក់ខ្លួនបាត់ទៅ ។ អ៊ំសាលាងយកដៃទះស្មានរះបន្តើរៗ ៖

CHIANBOKEO.COM

- អរគុណណាស់អ្នកកម្លោះ ដែលបានមកជួយបំភ្លឺភ្នែកកូនប្រុស របស់ខ្ញុំថ្ងៃនេះ ។
សង្ឃឹមថាគេនឹងយកពាក្យរបស់ក្មួយទៅគិត ខ្លះៗ !
សំណាងហើយដែលសិលាវាស្គាល់សុំក្មួយជាមិត្ត កុំអីពេល នេះ
អ៊ំមិនដឹងជារកក្បួនអ្វីមកនិយាយប្រដៅកូនទេ ។

ដាវិដញញឹម ហើយឆ្លើយថា ៖

- សូមទោស លោកអ៊ំ បើខ្ញុំមាននិយាយស្តីលើសខ្វះ សូមមេត្តា អភ័យទោសផង
ព្រោះខ្ញុំមិនចង់អោយប្អូនមានការយល់ច្រឡំថា ផ្លូវដែលគេកំពុងដើរ
ជាផ្លូវជឿនលឿនទាន់សម័យនោះទេ ។

ភ្លាមនោះ អ៊ំសារីក៏ស៊ីញ៉ូកេះអោយធីតាលើកផ្លែឈើមកទទួល ភ្ញៀវ ។
ដាវិដលួចសម្លឹងនារីភ្លៀកៗ ។ ការពិត ផ្ទះរបស់អ៊ំសារី តូចណាស់ ។ នរណាៗក្នុងផ្ទះ
ក៏បានឮការសន្ទនារវាងសុធននិង ដាវិដទាំងអស់ហ្នឹង ។
សិលានិងធីតានៅស្ងៀមសម្ងំស្តាប់ការឆ្លើយ ឆ្លងរបស់អ្នកទាំងពីរទាល់តែចប់
សឹងតែមិនហ៊ានដកដង្ហើមអោយ
ឮឡើយ ។

CHANBOKEO.COM

ថ្ងៃនោះ ដាវិដនៅអង្គុយលេងជាមួយក្រុមគ្រួសារអ៊ំសាឡាង មួយព្រឹក
ហើយសុធនក៏បាត់មុខទៅ ពេញមួយព្រឹកដែរ ប្រហែល ជាគេខ្មាសសំដីដាវិដក៏មិនដឹង ។

- ដាវិដ! ឯណាមិនឃើញស្រស់ឆោមនិងដាវីអញ្ជើងថ្ងៃនេះ ?

សិលាសួរ ។

- គេអាល័យដើរផ្សារទិញរបស់ស្រីៗ ទើបដេញអោយខ្ញុំមកទីនេះ
សួរសុខទុក្ខសិលាជំនួសពួកគេ ។

សិលាក្រោកអង្គុយបានហើយ ប៉ុន្តែក្បាលនិងខ្នងនៅពកហើម ខៀវនៅឡើយ ។ ភ្លាមនោះ
ដាវិដសួរថា ៖

- លោកអ៊ំ! បើខ្ញុំសុំធីតាទៅដើរលេងជាមួយពួកយើង តើលោកអ៊ំ អនុញ្ញាត្តទេ ?

អ៊ំសាឡាងនិងប្រពន្ធភ្ញាក់ព្រើតដែលមានប្រុសកម្លោះមកសុំកូន
ស្រីរបស់គាត់ដើរលេងត្រង់ៗ ។ គាត់ទាំងពីរមិនទុកចិត្តទេ ព្រោះ ដាវិដជាមនុស្សចម្លែក
ទើបតែស្គាល់គ្នាដំបូង ។ ទាំងពីរនាក់មើល មុខគ្នាធ្វើអេះអុញ ស្រាប់តែដាវិដនិយាយបន្តថា ៖

- បើមិនអនុញ្ញាត្ត ក៏មិនអីដែរលោកអ៊ំ ព្រោះខ្ញុំដឹងថា ប្រពៃណី ខ្មែរគេប្រកាន់មិនអោយកូនស្រីដើរលេងក្រៅផ្ទះជាមួយបុរសរហេត រហូតទេ ។ អញ្ចឹង ខ្ញុំគ្រាន់តែសុំធ្វើជាមិត្តរាប់អានគ្នាជាមួយកូន ប្រុសកូនស្រី លោកអ៊ំទៅចុះ ប៉ាទ!

  អ៊ំទាំងពីរមើលមុខគ្នាសាជាថ្មី ព្រោះឃើញដាវិដនិយាយអ្វី ត្រង់ៗ ឥតលាក់លៀម ។ ទ្រាំមិនបាន អ៊ំសាឡាងសួរថា ៖

- អ្នកស្រុកអាមេរិកគេនិយាយត្រង់ៗអញ្ចឹងហ្ស៊ែស ?

- បាទ! (ដាវិដឆ្លើយ) ការនិយាយត្រង់ចំពោះមុខ បញ្ជាក់នូវការ ស្មោះត្រង់នឹងគ្នា ។

  អ៊ំសាឡាងក៏លួចគយគន់សង្កេតឥរិយាបថរបស់ដាវិដរិតតែខ្លាំង កាលបើដឹងថា ដាវិដលួចចាប់អារម្មណ៍មកលើកូនស្រីរបស់គាត់ ។ ប៉ុន្តែ ដាវិដធ្វើកិរិយាហាក់ដូចធម្មតាៗ មិនមានអ្វីគួរអោយសង្ស័យ ថានាយមានគំនិតទុច្ចរិតទេ ។ ទីបំផុត អ៊ំសាឡាងក៏មានប្រសាសន៍ ទៅដាវិដថា ៖

- បើដាវិដត្រូវការភ្នែកច្រមុះជួយបង្ហាញផ្លូវក្រុងភ្នំពេញកុំអោយ វង្វេងនោះ អ៊ំអនុញ្ញាត្តអោយធីតាគេនាំផ្លូវក្មួយចុះ!

  ឮដូច្នោះ ដាវិដញញឹមពព្រាយតែម្តង ។ ភ្លាមនោះ អ៊ំសារីលួច កេះប្តី ព្រោះគាត់មានការភ្ញាក់ផ្អើលដែលអ៊ំសាឡាងបណ្តោយកូនជា លើកដំបូង តែអ៊ំបែរជាញញឹមហើយធ្វើមិនដឹង ។ រីឯធីតាយើងវិញ កាលបើឮឪពុកនាងថា អោយនាងទៅជាមួយដាវិដ ស្រាប់តែភ័យ បែកញើសជោគខ្លួនតែម្តង ។ ការពិត គេជាមនុស្សស្អាតបាតម្នាក់ ជាជនបរទេសម្នាក់ មានសំដីសំដៅឫកពាសមរម្យ ។ ថៃដន្យ នាង មិនដែលស្គាល់គេសោះ តើនឹងអោយដើរជាមួយគ្នា និយាយគ្នា យ៉ាងណា ? ឯសិលាវិញ ក៏លួចសម្លឹងមុខប្អូនស្រីមិនឈប់ តែក៏ មិនមាត់កអ្វីដែរ ទំនងចង់អោយប្អូនរៀនសំរេចចិត្តដោយខ្លួន ឯងហើយ ។

  បន្តិចមក ដាវិដក៏នាំធិតាចេញទៅ ។ អ៊ំសារីកេះអ៊ំសាឡាងសួរ ទៅគាត់ថា ៖

- បងទុកចិត្តបុរសនេះដែរ ?

  គាត់ងក់ក្បាល ឆ្លើយថា ៖

CHANBOKEO.COM

- បើតាមសំដីរបស់គេ ឃើញថា គេជាមនុស្សស្គាល់សីលធម៌ខ្ពស់ មានការចេះដឹងគួរសម ប្រហែលជាមិនអីទេដឹង ?

អ៊ំសាវីជ្រួញចិញ្ចើម ។ ឃើញដូច្នោះ អ៊ំសាឡាងស្រដីថា ៖

- កូនស្រីរបស់យើងជាក្មេងឆ្លាតម្នាក់ ។ បងថាគេពិតជាមិនធ្វើឲ្យគ្រួសាររបស់យើងបាក់មុខទេ ។

- យ៉ាងណាក៏កូនយើងជាស្រី បើបណ្តោយពេកក៏មិនកើតដែរណា៎ បង! ប្រយត្ន័ខ្លះក៏គង់គ្រាន់បើជាថ្លោះធ្លោយដែរ ។

អ៊ំសាឡាងគ្រវីក្បាល ៖

- មិនថ្លោះធ្លោយទេ! ជឿភ្នែករបស់ឪពុកគេចុះ!

oooooooooooooooo

ooooo

o

CHANBOKEO.COM

# វគ្គទី៣
# ចំណងចិត្ត

នៅក្នុងរថយន្ត...
- យើងទៅលេងខាងណាសប្បាយ ធីតា ?
- ខ្ញុំមិនដឹងទេ ព្រោះមិនសូវបានទៅដើរលេងឯណាផង ។
- ចុះដែលឮគេនិយាយទេ ថាពេលអ្នកភ្នំពេញគេចង់ដើរលេង តើគេទៅលេងនៅឯណាដែរទៅ ?
- ទៅព្រែកលាប ទៅកៀនស្វាយ ទៅទន្លេបាទី ទៅឧត្តុង្គ...
- ហើយធីតាស្គាល់ផ្លូវទៅទេ ?
- ចា៎ស! អត់ស្គាល់ទេ ។ ស្គាល់តែជិតៗនេះឯង ។
- ហ្អ៊ុក! បើអញ្ចឹង ធ្វើជាអ្នកជូនផ្លូវបងដើរលេងម្ដេចនឹងកើត ?
- គឺមកពីបងប្រុសមិនសួរខ្ញុំមុននោះអី ?

ដារិងសើចខឹកៗឡើង ។
- យើងមិនស្គាល់ផ្លូវដូចគ្នា ។ អញ្ចឹងយើងទៅជិតៗនេះទៅចុះ!
- ទៅណា៎ ចា៎ស ?
- ទៅណាហ្ន៎ បើបងមិនសូវស្គាល់ភ្នំពេញផង ?
- បើមិនស្គាល់ទេ ហេតុអ្វីក៏ហ៊ានបើករថយន្តខ្លួនឯង ? មើលចុះ... រថយន្តក៏ថ្មីស្រឡាងទៀត...គួរអោយសង្ស័យដល់ហើយ...!
- សង្ស័យរឿងអី ?

CHANBOKEO.COM

- គឺសង្ស័យថា បើទើបនឹងមកស្រុកខ្មែរជើងដំបូង ហេតុអ្វីក៏ហ៊ាន
បើករថយន្តនៅលើថ្នល់ភ្នំពេញដូចជាថ្មឹកយ៉ាងនេះ ?
- នរណាថា បងមកទីនេះជើងដំបូង ?
- អូហ៍ ? បងប្រុសមិនមែនមកទីនេះដំបូងទេហ៍ ?
- អត់ទេ! អ្នកដែលមកជើងដំបូង គឺស្រស់ឆោមនិងដារី ចំណែក បងវិញ
មកលេងពីរបីដងហើយ ។
- អញ្ចឹងដូចជាសមខ្លះ!... អូហ៍ បើមកច្រើនដងហើយ ម្តេចក៏សុំ ប៉ាម៉ាក់ខ្ញុំ
អោយខ្ញុំមកជូនផ្លូវបងប្រុសធ្វើអ្វី ?
- នរណាថា បងសុំធីតាអោយមកជូនផ្លូវ ? ធីតាមិនឮទេ ? បងសុំ
អនុញ្ញាតពីគាត់នាំធីតាដើរលេងទេតើហ៍!

ធីតាឮដូច្នោះនៅស្ងៀម នឹកអៀនបុរសតិចៗក្នុងចិត្ត ។ ប៉ុន្តែ
ភាពរួសរាយនិងភាពសាមញ្ញរបស់គេ បានធ្វើអោយនាងហាក់ដូច ធូរទ្រូង
ជាមិនសូវខ្លាចចិត្តបុរសយើងទេ ។

មួយសន្ទុះធំក្រោយមក គេក៏បានមកដល់ប្រាសាទភិមានសួគ៌ដ៏ សែនស្រស់ស្អាត ។ នៅទីនោះ
មានហ្វូងមនុស្សជាច្រើន ស្លៀក ពាក់ប្លែកៗ ។ ដារិនដនាំធិតាចុះពីរថយន្ត
ដើរតម្រង់ទៅហ្វូងមនុស្ស ទាំងនោះសួរថា ៖
- តើគេធ្វើបុណ្យអ្វី ឬមានពិធីសម្តែងអ្វីមែនទេ ទើបមានការតុប តែងឆាក មានកាម៉ារ៉ា
និងការស្លៀកពាក់ប្លែកៗដូច្នោះ ?

បុរសម្នាក់ឆ្លើយថា ៖
- គឺគេកំពុងថតខ្សែភាពយន្តការ៉ាអូខេ ។
- អូហ៍អញ្ចឹង ? ថតរឿងបុរាណមែនទេ ?
- មែនហើយ! គឺរឿងព្រះសុធននាងកែវមនោរាហ៍ ។

ឮដូច្នោះ ដារិនដក៏សម្លឹងទៅហ្វូងនារីដ៏ស្រស់ស្អាត រួចហើយ លួចញញឹម
ហើយក៏កេះធិតាដើរចេញមក ។ ដោយពិភាល់ក្នុងចិត្ត
ព្រោះឃើញដារិនដលួចញញឹមតែម្នាក់ឯង ធីតាក៏សួរថា ៖
- លួចពេញចិត្តនឹងសម្ផស្សនារីសម្តែងទាំងនោះមែនទេ បានជា
បងប្រុសលួចញញឹមតែម្នាក់ឯងអញ្ចឹង ?

CHANBOKEO.COM

- អត់ទេ... តែបងចម្លែកភ្នែកទេតើហ៍!
- ចម្លែកភ្នែករឿងអី ? មិនដែលឃើញនារីៗគេស្លៀកសម្លៀកខ្មែរ បុរាណទេ មែនទេ ?
- ធ្លាប់ឃើញ ប៉ុន្តែពេលនេះប្លែកខុសសព្វដង!
- ប្លែក ? ប្លែកត្រង់ណា ?
- គឺប្លែកភ្នែកត្រង់តួនាងកែវមនោរាហ៍និងនាងកិន្នរី ចុះមកពីស្ថាន ស្ទឹគទាំងនោះ សុទ្ធតែមានលាបសក់ហាយឡៃ ពណ៌ប្លែកៗ ។

ឮប្រយោគនេះភ្លាម ធីតាបែរក្រោយលួចមើលទៅហ្វូងនារីទាំង នោះ ឃើញដូចដារិនថាមែន ។ នាងក៏សើចខឹកៗតាមនរៈ ។ ដារិនក៏ខទានទាំងសើចកខឹកថែមទៀត ថា ៖

- សម័យសតវត្សទី២១ ខ្មែរយើងជឿនលឿនអញ្ចឹងឯងណា៎ សូម្បី តែទេពធិតាចុះពីស្ថានសួគ៌ចតកុនការាអូខេក៏មានសក់ហាយឡៃដែរ ហ៉ៃសៗ ។

ឃើញដារិនអស់សំណើចខ្លាំងពេក ធីតាអត់មិនបានក៏លាន់មាត់ ឡើងថា ៖

- អីក៏ប៉ិនឃើញគេម្ល៉េះ បងប្រុស ?
- ចុះមើវាប្លែកភ្នែកពេកនោះអី ?

ភ្លាមនោះ គេក៏ដាក់ភ្នែកក្រឡេកមកមើលធីតាហើយក៏ឈប់ សើចភ្លាម រួចសួរថា ៖

- សូម្បីតែសុធនប្អូនរបស់ធីតាក៏មានសក់ហាយឡៃដែរ ចុះធិតានិង សិលា ហេតុអ្វីមិនមានហាយឡៃសក់អោយប្លែកៗដូចក្មេងខ្លះទៀត នៅភ្នំពេញនេះ ?

ធិតាញាក់មុខ សួរបញ្ច្រាសទៅវិញ ៖

- ហើយចុះបងប្រុសអ្នកអាមេរិកនឹងគេដែរ ហេតុម្តេចក៏មិនមាន សក់ហាយឡៃដូច្នេះ ?

ដារិនយកដៃអង្អែលសក់ក្បាល ៖

- មិនមែនអោយតែពួកមកពីអាមេរិក សុទ្ធតែលាបសក់ហាយឡៃ ទាំងអស់នោះទេ ។ ភាគច្រើនអ្នកដែលមានសក់ហាយឡៃ ច្រើន ជាក្មេងៗហើយជាអ្នកដែលទាមទារចំណាប់អារម្មណ៍ពីគេឯង ព្រោះ គេខ្វះសេចក្តីកក់ក្តៅក្នុងជីវិត ។
- ខ្ញុំក៏ដូចគ្នាដែរ មិនមែនអោយតែក្មេងស្រុកខ្មែរ សុទ្ធតែព្រើល តាមគ្នានោះដែរ ។ ជីវភាពគ្រួសាររបស់ខ្ញុំតឹងតែងណាស់ រកលុយ រៀនមិនបានផង តើអោយមានលុយឯណាចូលហាងសំអាងខ្លួន អោយហ៊ឺហានោះ ?

CHANBOKEO.COM

ដាវិដឮហើយសម្លឹងមុខធីតា មួយស្របក់ទើបស្រដីថា ៖
- នោះជាការជ្រើសរើសដ៏ល្អប្រសើរបំផុតណា់ធិតា ដែលសន្សំលុយ សំរាប់ការសិក្សា ហើយមិនយកទៅចាយលាបសក់ ធ្វើក្រចក តែងខ្លួនតែងប្រាណហ៊ឺហា តាមយុវជនយុវតីឈាមរាវខ្លះៗទៀត ។
ធិតាញញឹមហើយស្រដីបន្តថា ៖
- ជួនកាលគេធ្វើ ព្រោះគេចម្លងតាមគ្នា គឺធ្វើដោយគេមិនពិចារណា ថាតើគេធ្វើហ្នឹងសមនឹងរូបដែរឬអត់ ? ខ្មែរស្បែកខ្មៅសក់ទង់ដែង ឃើញហើយគួរអោយអាណិតម្ចាស់សោភ័ណណាស់ ! !
- ហេតុអ្វីធីតាមិនស្រឡាញ់សក់ហាយឡៃ អញ្ចឹង ?
- ព្រោះខ្ញុំគិតថា អ្នកដែលប្រឹងស្វែងរករូបសោភណ៍ក្រៅខ្លួនអោយ គេចាប់អារម្មណ៍ សុទ្ធតែជាមនុស្សដែលខ្វះជំនឿលើខ្លួនឯង ថាខ្លួន ល្អស្អាតមិនគ្រប់គ្រាន់ ទើបចង់ធ្វើនេះកែនោះ អោយស្អាតអោយល្អ ជាងមុន ដើម្បីអោយអ្នកដទៃចាប់អារម្មណ៍ហើយសរសើរ ។
- មានន័យថា ធីតាមានជំនឿលើខ្លួនឯងណាស់មែនទេ ?
- ចា៎ស ! ខ្ញុំថា ខ្ញុំចូលចិត្តអោយគេឃើញសោភណ៍ធម្មជាតិរបស់ខ្ញុំ វិញ ទាំងរូបសម្បត្តិ វិជ្ជាសម្បត្តិ និងចរិយាសម្បត្តិ ដោយមិនបាច់ យកអ្វីមកលាបពីក្រៅបំបិទចំណុចខ្សោយរបស់ខ្លួនទេ ។
ដាវិដឮដូច្នេះក៏ញញឹមពព្រាយដាក់នាងភ្លាម ។
- បងប្រុសញញឹមស្អីហ្នឹង ?
- គឺ... ញញឹមព្រោះមានមោទនភាពចំពោះនារីឆ្លៀវឆ្លាតម្នាក់ ។
- នរណាគេទៅ ?
- គឺ... នរណាហ្នឹ ដែលមានចិត្តរឹងប៉ឹង មិនបណ្តោយអោយឥទ្ធិពល សង្គមឈាមរាវ ទាញខ្លួនអោយវង្វេងភ្លើតភ្លើនបាននោះអី !
ថាហើយ ដាវិដដៀងភ្នែកអោយធីតា ។ មាណវីយើងយល់ ភ្លាម សើចកខឹកឡើង ៖
- មិនទាន់ឆ្លាតគ្រប់គ្រាន់ទេ នៅកំពុងរៀនតទៅទៀត ។ បន្តិច ទៀតនឹងឆ្លាតដូចបងៗមិនខានឡើយ ។
អ្នកទាំងពីរក៏ញញឹមដាក់គ្នាឡើងយ៉ាងបំព្រង ។ ពេលនោះធីតា មានអារម្មណ៍ថា ដាវិដជាមនុស្សដែលងាយចុះសម្រុងជាមួយណាស់

CHANBOKEO.COM

ថ្វីបើគេចូលចិត្តនិយាយអ្វីត្រង់ៗដោយមិនខ្លាចចិត្តក៏ដោយ ។ នោះ
ប្រហែលជាទម្លាប់របស់អ្នកស្រុកអាមេរិកក៏មិនដឹង ។ ចំណែកដាវិឌ
ក៏ចូលចិត្តសួរនារីមិនព្រមឈប់ដែរ មិនថាជាអ្វីទេ ។ គេជាមនុស្ស មានសំដីរួសរាយ
មិនចាញ់គ្នានឹងធិតាទេ ។ ម្ល៉ោះហើយ ពេញមួយ ថ្ងៃនោះ
គេមានរឿងសើចរអឹកនឹងនារីយើងជានិច្ច ។

អ្នកទាំងពីរបានចូលអង្គុយលេង បរិភោគបាយថ្ងៃត្រង់នៅក្នុង
ពោងស្បូវយ៉ាងត្រជាក់រហើយមួយ មិនឆ្ងាយប៉ុន្មានពីម៉ូតអ្នកស្រុកថត កុនកាវ៉ាអូខេនោះទេ ។
បន្ទាប់ពីបរិភោគរួចហើយ ដាវិឌនិងធីតា នាំគ្នាអង្គុយយោលអង្រឹងម្នាក់មួយជជែកគ្នា ។

- ធិតារៀនដល់ណាហើយ សព្វថ្ងៃ ?
- កំពុងប្រឡង បញ្ចប់ឆ្នាំទីបួនហើយ ។
- អូហ៍ រៀនលឿនណាស់តើហ៍! ហើយចុះមានបំណងទៅរៀន ឯណាទៀតទេហ៍ ?
- ចាស អត់ទេហ៍! គ្រួសាររបស់ខ្ញុំក្រីក្រណាស់ មិនអាចមាន
សមត្ថភាពបញ្ជូនកូនអោយទៅរៀនហួសនេះទៀតទេ ព្រោះឆ្នាំ ក្រោយនេះ
សុធនត្រូវចូលមហាវិទ្យាល័យដែរហើយ ។ ដូច្នេះ ខ្ញុំ ត្រូវតែចេញធ្វើការហើយ ។
- គួរអោយស្តាយណាស់ហ្ន៎! ខ្ញុំថា បើសិនធីតាបានរៀនខ្ពស់ជាង នេះ
ឬក៏អាចមានលទ្ធភាពចេញទៅរៀននៅបរទេសយកតម្រេះ បន្ថែម ប្រហែលជាប្រសើរណាស់
ព្រោះធីតាមានសម្បទាល្អ!
- បើស្តាយ បងប្រុសជួយរកមធ្យោបាយឲ្យខ្ញុំសុំទុនអាហារូបករណ៍ ទៅរៀននៅប្រទេសបងទៅ...
ខ្ញុំសន្យាថានឹងរៀនមិនអោយខក ចិត្តក្រសួងដែលផ្តល់ទុនជំនួយនោះឡើយ ។

ដាវិឌសម្លឹងមុខនារី ដែលសម្តែងការម៉ឺងម៉ាត់ចំពោះការសិក្សា និងការឈោងចាប់តម្រេះវិជ្ជា
៖

- ចាំខ្ញុំសាកសួរគេឯងសិន ថាតើមានមធ្យោបាយណាទេ ដែល
អាចជួយធីតាបាន ។
- អរគុណបងប្រុសណាស់ បើសិនជាអាចជួយខ្ញុំបានពិតមែន!

ធិតាញញឹមដាក់ដាវិឌយ៉ាងស្រស់ កាលបើឮនរៈនិយាយថា នឹង
ជួយរកមធ្យោបាយអោយនាងបានរៀនបន្ត ។ កាលបើបានឃើញ ស្នាមញញឹមលើផ្ទៃមុខរបស់នារី
ដាវិឌលួចគយគន់មើលយ៉ាងភ្លន់ ភ្លឹកអារម្មណ៍ ធ្វើអោយធីតានឹករអៀសខ្លួនបែរមុខចេញភ្លាម ។

CHANBOKEO.COM

- ចង់ស្តាប់ចំរៀងមួយទេ ធិតា ?

- ចា៎ស ! សុំបទមនោសញ្ចេតនាបានទេ ?

- បាទ ! ដោយក្តីសោមនស្សជានិច្ច ។

និតាយោលទោងយឺតៗបណ្តើរ ស្តាប់សំនៀងក្រអួនរបស់នរៈ បណ្តើរដោយក្តីរំភើបក្នុងដួងចិត្ត ។ គេលួចចោលកន្ទុយភ្នែកមើល គ្នាទៅវិញទៅមកម្តងម្កាល ។ លុះប្រទាក់ក្រសែភ្នែកគ្នា គេក៏នាំគ្នា គេចលួចញញឹមតែរៀងខ្លួន ។

រំពេចនោះស្រាប់តែ ៖

- ពូៗ ! ពូជាម្ចាស់ឡានមួយនោះមែនទេ ?

ក្មេងតូចៗពីរនាក់អាយុប្រហែល៧-៨ឆ្នាំ រត់មកសួរដាវិដ ។

- មែនហើយ ! មានការអ្វីដែរអូនតូច ?

- គឺខ្ញុំនិងប្អូនសូមទោសបាទ ដែលនាំគ្នាលេងបាល់ រួចហើយធ្លាក់ បាល់ចំឡានរបស់ពូ ប្រឡាក់ស្នាមខាងនុះ៎ !

ដាវិដក្រឡេកទៅឃើញស្នាមធូលីដីជាប់ឡាន ក៏ឆ្លើយថា ៖

- អឺ មិនអីទេ ! មិនមានខូចខាតឯណា ! ក្មួយទៅវិញចុះ !

- បាទ !

ក្មេងៗនោះរត់ត្រឡប់ទៅវិញ ស្រាប់តែដាវិដនិងធីតាឮម្តាយ របស់ក្មេងស្រែកកោកៗ ជេរក្មេងទាំងពីរនោះថា ៖

- យី ! អាភ្លើនេះ ! ម្ចាស់គេមិនទាំងដឹងផង ថាបាល់ឯងប៉ះឡាន គេប្រឡាក់ ហើយឯងភ្លើទៅហ្មែស ដែលសុខៗដើរតត្រុកទៅប្រាប់ អោយគេដឹង ? ចំមែនអាភ្លើ !

ធិតានិងដាវិដសម្លឹងមុខគ្នានឹកចម្លែកចិត្ត ។ ភ្លាមនោះដាវិដ លាន់មាត់និយាយខ្សិបៗជាមួយធិតា ថា ៖

- ហេតុអ្វីក៏ម្តាយមួយរូបនោះ ខ្វះសតិមនសិការដល់ម្លឹង ? ហេតុអ្វី បែរជាជេរកូនវិញ កាលបើកូនសម្តែងនូវការស្មោះត្រង់រៀនទទួល ខុសត្រូវចំពោះការប្រព្រឹត្តរបស់គេ ? នេះ ខ្ញុំមានទៅយកទោស ពៅក្មេងនោះឯណា ? ម្តាយនោះគួរណាស់តែឈប់ជេរបញ្ចោះកូន ពីរនាក់នោះហើយលើកដៃសំពះសុំរៀនពីកូនវិញទើបសម ដែល កូនទាំងពីរមានសតិមនសិការខ្ពស់ជាងគាត់ ព្រោះគេចេះទទួល ខុសត្រូវចំពោះអំពើរបស់គេ ។ តើស្រុកខ្មែរមានមនុស្សដែលមាន សតិមនសិការដូចក្មេងតូចៗពីរនាក់នោះដែរឬទេហ្ន៎ ?

CHANBOKEO.COM

និតាក៏ស្រដីថា ៖

- ខ្ញុំថា ប្រហែលជាមិនអត់ទេ...
- បើដូច្នោះមែន ប្រទេសខ្មែរនឹងចំរុងចំរើនមិនខានដែលពលរដ្ឋជំនាន់ក្រោយចេះទទួលខុសត្រូវតាំងពីតូចៗទៅ ។ ចំពោះចាស់ៗដែលមានទង្វីបាក់ផ្នត់របៀបកម្លៅ តួយ៉ាងដូចជាម្តាយរបស់ក្មេង ទាំងពីរនាក់នោះ ប្រហែលជាលំបាកកែទង្វីបន្តិចហើយ ។
- ខ្ញុំគិតថា ប្រហែលជាគាត់ខ្លាចក្មេងត្រូវទទួលទោសទេដឹង បាន ជាបង្រៀនអោយកូនព្រងើយធ្វើពើមិនទទួលស្គាល់ទោសកំហុស របស់ខ្លួន ។
- ខ្លាចទទួលទោសអ្វីទៅ ម៉ាគ្រាន់តែប្រឡាក់ឡានបន្តិចហ្នឹង ? ខ្ញុំ មិនទាំងស្តីអោយម៉ាម៉ាត់ផង ។
- ចុះបើបងប្រុសស្តីអោយវិញនោះ មិនបាក់មុខទៅហើយទេហ៍ ?
- បាក់ម្តេចកើត ? បើប្រឡាក់ដី យកទឹកលាងទៅជ្រះបាត់រួចគ្នា ។
- ប៉ុន្តែអ្នកមានខ្លះៗវាយឫកឆ្មើងកន្ទ្រើងណាស់ ជួនកាលគេមិនធ្វើ ដូចបងប្រុសទេ បែរជាជេរប្រទេចក្មេង មានកាលដល់ចាប់ទះក្មេង ទៀតផងក៏មានដែរ ដែលក្មេងធ្វើប្រឡាក់ឡានថ្មីរបស់គេ ។
- ដូច្នោះ មានន័យថា គេនោះគ្មានសីលធម៌និងការអប់រំក្នុងខ្លួនទេ ព្រោះគេយកកម្លាំងបាយអំណាច និងពាក្យប្រមាថជាធំ ។ ការពិត បើគេធ្វើដូច្នោះមែនគឺគេកំពុងសម្តែងនូវការខ្វះខាតខាងសតិប្រាជ្ញ ហើយព្រោះគេមិនចេះដោះស្រាយអ្វីៗដោយសន្តិវិធី ដើម្បីរក្សា មនុស្សជាញាតិមិត្តនឹងគ្នាតទៅទៀត ។ ឯការប្រព្រឹត្តដោយហឹង្សា ដូច្នោះ នឹងបង្កអោយមានភាពស្អប់ខ្ពើមនិងគំនុំគុំគួនក្នុងចិត្តមនុស្ស រួចហើយក៏កើតការសងសឹកគ្នាពុំចេះចប់ពុំចេះហើយ ។ ហឹង្សា និងការវាយឫកឆ្មើងចំពានមិនមែនជាសញ្ញានៃភាពថ្លៃថ្នូរនិងការ ចេះដឹងទេ តែជាសញ្ញានៃភាពកម្លៅខ្វះសតិប្រាជ្ញទៅវិញទេតើ ។ តួយ៉ាងដូចជាម្តាយរបស់ក្មេងទាំងពីរនោះ ដែលខំវាយឫកឆ្មើងមិន អោយកូនទទួលកំហុស មិនអោយកូនទៅសុំទោសគេ ហើយថែមទាំងប្រើហឹង្សាសម្លុតដណ្តប់ស្មារតីកូន នោះគឺជាភាពកម្លៅមួយ ដែលនាំជីវិតធ្លាក់ក្នុងភាពល្ងិតល្ងង់កាន់តែខ្លាំងឡើង ។ ចំណែកបង វិញ បើទៅជេរវាយក្មេងដោយសារគេធ្វើប្រឡាក់ឡាននោះ បង

CHANBOKEO.COM

នឹងក្លាយជាសត្វស្វាមួយរូបដែលស្គាល់តែឡាន មិនស្គាល់មនុស្សធម៌ មិនស្គាល់ភាពជាញាតិ មិនស្គាល់ថាសីលធម៌ហើយ...!

រំពេចនោះ ធីតាសើចកខឹកឡើង...

- យ៉ាងណា ក៏ខ្ញុំមិនចង់ឃើញបងប្រុសក្លាយជាសត្វស្វាដែរ!

- ហេតុអ្វីទៅ ?

- ព្រោះបើក្លាយជាស្វាទៅ បាននរណាច្រៀងអោយខ្ញុំស្តាប់ទៀត ?

អ្នកទាំងពីរក៏សើចកខឹកឡើង ។

តាមផ្លូវត្រឡប់មកផ្ទះវិញ...

ដាវិឌក្រឡេកឃើញអ្នកស្រុកអុំទូកកាច់ផ្កាឈូកនៅក្នុងបឹងតាម ដងផ្លូវ ។ គេឈប់រថយន្ត ហើយចុះសួរថា ៖

- មីងកាច់ផ្កាឈូកយកទៅណាដែរ បាទ ?

- គឺ យកទៅលក់នៅផ្សារ ។

- ចុះបើខ្ញុំសុំជួលទូក ចុះកាច់ផ្កាឈូកខ្លួនឯងយកថ្លៃប៉ុន្មានដែរ ?

ស្ត្រីនោះបែរមើលធីតានិងដាវិឌ ឃើញគេជាគូស្រករដ៏ស្រស់ ស្អាត ទំនងទើបនឹងរៀបការហើយ ក៏ញញឹមហើយស្រដីថា ៖

- ខ្ញុំជូនទូកអោយអុំលេងសប្បាយចុះ មិនគិតលុយទេ ប៉ុន្តែ សុំគិតតម្លៃផ្កាឈូកអោយដូចតម្លៃលក់នៅផ្សារ សុខចិត្តទេ ?

ដាវិឌញញឹម ៖

- បាទ យល់ព្រម! អរគុណណាស់មីង!

មាណពយើងក៏នាំធីតា ដើរចុះទៅលើស្ពានសំដៅទូកភ្លាម ។ ថ្ងៃនោះ ធីតាមានអារម្មណ៍ប្លែកណាស់ ព្រោះនាងមិនដែលដើរលេង ជាមួយមិត្តប្រុសទេ ថ្វីបើនាងមានស្គាល់មិត្តភក្តិប្រុសនៅសាលា ជាច្រើនក៏ដោយ ។ នៅលើទូក ដាវិឌអុំមួយៗ ភ្នែកសម្លឹងធីតា មិនព្រិច... ធ្វើអោយនារីនឹកព្រឺព្រួចក្នុងចិត្តយ៉ាងណាមិនដឹង ម្ល៉ោះ ហើយ នារីយើងចេះតែបែរមុខងាកគេចចេញពីក្រសែភ្នែកដ៏ភ្លឺថ្លា ពណ្ណរាយរបស់បុរសយើង ។

មកដល់កណ្តាលផ្ទៃបឹងដ៏ទូលាយ មានសុទ្ធតែផ្កាឈូករហង់រីក រោយពាសផ្ទៃបឹង ដាវិឌកាច់ផ្កាមួយទងហុចអោយនារី ៖

- សូមជូនផ្កាមួយទងនេះជូននារីសោភា!

CHANBOKEO.COM

ធីតាគ្រវីក្បាល ៖

- មិនយកទេ!
- ម៉េចអញ្ចឹង ?
- ព្រោះធីតាមិនមែននារីសោភានោះអី!

ដារិនសើចខឹកៗ ស្រដីម្ដងទៀត

- អញ្ចឹង! សូមជូនផ្កានេះចំពោះធីតាដែលខំជូនដារិនដើរលេង ។

ទងផ្កាចំណារស្នេហ៍

ផ្កាឈូកមួយទងជូនចរណៃ សំណព្វហឫទ័យស្រស់ស្នេហា
ទទួលយកផងណា៎ជីវ៉ា ក្រពុំឈូកផ្កាចំណារចិត្ត ។
ឈូកផ្កាបរិសុទ្ធដុះបឹងព្រៃ គន្ធានិស្ស័យគួរនៃបនិត្យ
យល់សោភណ៍ផ្កាឱភាពិត រសាយវិបរិតពីទ័យា ។
បេះដូងបងមួយផ្ញើទងផ្កា សូមថៃផងណា៎ស្រស់ពាំងា
ស្រឡាញ់ភក្ដីឈូកសោភា ផ្សងសុំជួបគ្នាជាគូគ្រង ។
ឱ! ទឹកបឹងអើយជួយប្រស់ព្រំ ស្នាមស្នេហ៍ឧត្ដមអូននិងបង
ជាតិនេះជាតិណាសច្ចាផ្សង ជួបជាគូគ្រងកុំបីឃ្លាត ។

ធីតាញញឹមឡើង លូកដៃទទួល ។ គ្រាន់តែដៃទាំងពីរប៉ះគ្នា ភ្លាម ធីតារិតតែមានអារម្មណ៍ចម្លែកឡើង ក៏ឆក់ផ្កាឈូកយ៉ាងរហ័ស ពីដៃដារិន ហើយគេចមុខមិនហ៊ានមើលក្រសៃភ្នែកគេវិញទេ ។ ដារិនឃើញកិរិយាអឹមអៀនរបស់នារី គេក៏លួចញញឹមតែម្នាក់ឯង...

- ធីតា! ថ្ងៃក្រោយអាចចេញដើរលេងនៅក្រៅជាមួយខ្ញុំទៀតទេ ?
- គឺសម្រេចលើប៉ាម៉ាក់ទេ ។ បងប្រុសទៅសុំអនុញ្ញាតគាត់សិនទៅ ម្យ៉ាងទៀត ខ្ញុំជាប់រៀនផង ប្រហែលជាមិនមានពេលនឹងដើរលេង
ប៉ុន្មានទេ ។
- បើអញ្ចឹងបងសុំពេលមួយថ្ងៃមួយម៉ោងបានទេ ដើម្បីជួបនិយាយ លេងជាមួយគ្នា ព្រោះបងមានពេលតែបីអាទិត្យទេ ត្រូវត្រឡប់ទៅ អាមេរិកវិញហើយ ។

CHANBOKEO.COM

- អូហ៍ ហេតុអ្វីក៏ប្រញាប់ម្លេះ ?
- ព្រោះបងត្រូវត្រឡប់ទៅធ្វើការវិញផង ត្រូវធ្វើកិច្ចការបង្កើយ សំរាប់បញ្ចប់ការសិក្សាផង ។
- បងប្រុសបញ្ចប់ការសិក្សាខាងមុខវិជ្ជាអ្វីដែរ ?
- គឺ ខាងចិត្តវិទ្យាអប់រំយុវជន ។
- អូហ៍ អញ្ចឹងតើហ៍ បានជាសម្បូណ៌ទ្រឹស្តីប្រដៅសុធនអោយហូរ ដូចទឹក កាលពីព្រឹកមិញនេះ ។
- ចេះតែរបៀបអប់រំបែបអាមេរិកទេ ពេលនេះបងកំពុងតែមក
រៀនរបៀបអប់រំពីចាស់ៗស្រុកខ្មែរម្តង ថាតើមានការអប់រំបែបណា ដែលមានប្រសិទ្ធភាព
នឹងអាលឲ្យបងយកមកសរសេរសៀវភៅ ចងក្រងចែកចាយ
អោយក្រុមគ្រួសារខ្មែរអានហើយទទួលការចេះ ដឹងប្លែកៗ សមស្របនឹងសម័យសង្គមអភិវឌ្ឍន៍
មិនអោយសង្គម សីលធម៌នៅនឹងមួយកន្លែងឬធ្លាក់ទាបជាងមុនទេ ។ គឺធ្វើយ៉ាងណា ជួយជំរុញ
អោយសង្គមយើងវិវត្តន៍ទាន់ការជឿនលឿនផ្នែកដទៃ ទៀត កុំអោយចាញ់ល្បឿនគ្នា ។
- គិតវែងឆ្ងាយមែនហ្ន៎ អ្នកប្រាជ្ញអាមេរិក!
- ចេះតែគិតលេងៗទៅណា៎ ក្រែងលោមានប្រសិទ្ធភាពពិតមែន!

ធិតាញញឹមលើកទឹកចិត្តបុរសយើងភ្លាម...

oooooooooooooooooooo

CHANBOKEO . COM

# វគ្គទី៨
# ជញ្ជាំងវណ្ណៈ

តាមផ្លូវមកផ្ទះវិញ...

មកដល់ម្តុំវាលវង់ចុងស្ពានជ្រោយចង្វារ ស្រាប់តែមានរថយន្ត សង្ហាមួយបើកប្រឆាបនឹងរថយន្តរបស់ដារិនហួសទៅ ។ ភ្លាមនោះ ដារិនធ្វើមុខចម្លែក រួចបន្ថែមសន្ទុះល្បឿនតាមរថយន្តនោះភ្លាម ។ លុះទៅដល់ក្បែរ ធីតាបានឃើញនារីរូបស្អាតម្នាក់កំពុងបើកបរគេច ពីដារិនយ៉ាងលឿនថែមទាំងសម្លេងទឹកមុខយ៉ាងចម្លែកក្រៃលែង ។ រីឯដារិនក៏ដូច្នោះដែរ ។ ភាពញញឹមរីករាយនៅលើផ្ទៃមុខរបស់គេ បានបាត់រូបភ្លាម នៅសល់តែចិញ្ចើមទាំងគូកំពុងចងគ្នួចមិនព្រម ស្រាយ ។ ពេលនោះ គេហាក់ដូចជាភ្លេចបាត់ទៅហើយថា មាន មនុស្សម្នាក់ជិះក្នុងរថយន្តជាមួយគេ ។ ចំណែកធីតាវិញក៏បែរមុខ ចេញនៅស្ងៀម ត្បិតមិនហ៊ានខានចិត្តដារិន ប៉ុន្តែក្នុងចិត្តនៅគិត សង្ស័យមិនអស់មិនហើយទាល់តែសោះ ។

នៅព្រលប់ថ្ងៃដដែល...

នៅក្នុងផ្ទះអ៊ំសាឡាង...

- យ៉ាងម៉េចដែរ អូនដាដើរលេងជាមួយដារិនសប្បាយទេ ?

សិលាសួរ ។ ធិតាញញឹមហើយឆ្លើយថា ៖

- សប្បាយ ព្រោះខ្ញុំចាប់គំនិតល្អៗពីបងដារិនប្លែកៗច្រើនណាស់ ។

CHANBOKEO .COM

- គំនិតពីអ្វីទៅ ?
- ពីសង្គមធម៌និងសីលធម៌ណា៎! បើសិនសុធនបានស្គាល់គាត់ច្រើន ប្រហែលជាគេអាចដូចចរិតល្អមកវិញមិនខាន ។
- បងក៏យល់ថាអញ្ចឹងដែរ! ឃើញគេនិយាយជាមួយសុធនកាលពីព្រឹកមិញពេញចិត្តបងណាស់ ។ ម្យ៉ាងទៀត តាំងពីដាវិននិយាយ ប៉ុន្មានឃ្លានោះមក សុធនពួនក្នុងបន្ទប់មិនឃើញចេញមកទេ ពេញ មួយថ្ងៃហើយ ។
- សាធុ! សូមអោយគេប្តូរចរិតអោយបានឆាប់ៗផង ។

សិលាសម្លឹងមុខប្អូនស្រីរួចញញឹម ហើយលួចខ្សិបសួរថា ៖
- ហើយដាវិនមានលួចខ្សិបសុំស្នេហាពីប្អូនស្រីរបស់បងទេ ?

ធីតាភ្ញាក់ព្រើត យកដៃក្តិចកំភួនដៃបងប្រុស ៖
- តែផ្តាសហើយបងឯងនេះ! នរណាគេមកសម្លឹងមនុស្សរូបមិន ស្អាតដូចខ្ញុំនោះ ?
- ចំណង់ចិត្តមិនអាស្រ័យនៅលើរូបប៉ុន្មានទេ សំខាន់នៅលើចិត្ត និងចំណងនិស្ស័យរបស់អ្នកទាំងពីរទេតើ!
- ទើបតែស្គាល់គ្នាម៉ាដើ មានចំណងនិស្ស័យអ្វីកើតទៅបង ?
- ដឹងអីថា ជួនកាលអនុស្សាវរីយ៍ម៉ាថ្ងៃ មានន័យម៉ាជាតិផងក៏មិន ដឹង ណា៎អូន!
- ចេះតែថាហើយ បងឯងនេះ!

ធីតាអៀននឹងបងប្រុសពេកក៏រត់គេចចេញទៅ ទុកអោយសិលា នៅឈរសើចញឹមៗតែម្នាក់ឯង ។

ពីរម៉ោងក្រោយមក...

រថយន្តមួយបានបរមកដល់មុខផ្ទះអ៊ំសាឡាង ។ គ្រាន់តែគាត់ ក្រឡេកឃើញភ្លាម អ៊ំក៏ស្ទុះទៅទទួល ។ ដាវិន ដាវី ស្រស់ឆោមក៏ នាំគ្នាចុះពីរថយន្តទាំងទឹកមុខពព្រាយ ។
- ជំរាបសួរលោកអ៊ំ!
- បាទ! អញ្ជើញចូលក្នុយ!

តាមពិត អ្នកទាំងបីបានទទួលការអញ្ជើញពីចាស់ៗអោយមក បរិភោគបាយជុំគ្នា ។ ទាំងអស់គ្នាបានទទួលការទទួលរាក់ទាក់យ៉ាង កក់ក្តៅពីអ៊ំសាឡាងនិងអ៊ំសារី ព្រមទាំងសិលានិងធីតាផង បាត់តែ សុធនមិនឃើញចេញមុខមក ។

CHANBOKEO.COM

- ឯណាកូនពៅលោកអ៊ំ ? (ស្រស់ឆោមសួររក)

អ៊ំសាឡាងកេះសិលាអោយទៅហៅសុធនមក ។ បន្តិចក្រោយ មកសុធនក៏បង្ហាញខ្លួន ស្រាប់តែទាំងអស់គ្នា ភ្ញាក់ក្រញាង ។

អ៊ំសារីលាន់មាត់មុនគេ ៖

- ពុទ្ធោ សុធនកូន! ហេតុអ្វីកោរសក់អស់រលីងអញ្ចឹង ?

សុធនយកដៃអង្អែលក្បាលដែលទើបកោរហើយ ស្រដីថា ៖

- មើលាបសក់ហាយឡៃ គេថាជាម៉ូដក្មេងខ្វះសតិប្រាជ្ញ ដូច្នេះកោរ វិញទៅ ក្រែងលោសតិប្រាជ្ញវាវិលមកវិញ ។

ដារិនភ្ញាក់ព្រើតដោយដឹងថា សុធនកំពុងតែបញ្ឆោះបញ្ឆៀក ចំពោះជីវិតរបស់សុធនផ្ទាល់ ។ គេមិនហ៊ានមាត់កអ្វីទេ ព្រោះពេល នោះជាពេលបរិភោគ ។ ដារិនប្រែជានិយាយថា ៖

- យី! ដល់កោរសក់រួចទៅ ដូចជាសង្ហាម្យ៉ាងដែរតើហ៍ សុធន! ម៉ោះ ញុំាបាយជាមួយបង! រួចចាំបងនិងសិលាលេងភ្លេងអោយ ប្អូនស្តាប់ ជាការលើកទឹកចិត្តចំពោះការផ្លាស់ប្តូររបស់ប្អូន ។

ទាំងអស់គ្នាក៏នាំគ្នាទទួលទានអាហារផង ជជែកពីនេះពីនោះ ផង ប៉ុន្តែ គ្មាននរណាហ៊ាននិយាយអ្វីអោយប៉ះអារម្មណ៍សុធនទេ ព្រោះគេកំពុងតែមានសតិពុះកញ្ជ្រោលដោយភ្លើងឈាមរាវ ។

ក្រោយពីបរិភោគបាយហើយ សិលាចាប់ហ្គីតាហុចទៅអោយ ដារិន ៖

- ថ្ងៃនេះ ខ្ញុំនៅឈឺស្មា ឈឺឆ្អឹងខ្នងនៅឡើយ ដេញហ្គីតាមិនកើត ទេ ។ សូមដារិនទទួលជំនួសខ្ញុំផង!

ដារិនញញឹមហើយស្រវាហ្គីតាពីដៃសិលាយកមកក្ដាម ដោយ ឥតមានប្រកែកទេ ហើយគេក៏ចាប់ដេញជាបទចំរៀងដោយមានដារី ស្រស់ឆោម និងក្រុមគ្រួសាររបស់អ៊ំសាឡាងអង្គុយដំកង់ទះដៃអប អរផង ។ ម្រាមដៃដារិនរត់រវើកលើខ្សែហ្គីតា អមជាមួយសំនៀង ក្រអួនរបស់នរៈ ធ្វើឲ្យបទចម្រៀងរណ្ដំពិរោះឡើងប្រឡៃងប្រលោម មនោសញ្ចេតនាគ្រប់ៗគ្នានៅទីនោះ ជាពិសេស ធីតារបស់យើង តែម្តង ។ នាងនៅអង្គុយពីក្រោយខ្នងម្តាយ លាក់មុខមួយចំហៀង លួចមើលដារិនភ្លៀកៗ ។ យូរៗម្តង នារីឃើញដារិនងើបមុខឡើង សម្លឹងមករកនាង ហើយញញឹមយ៉ាងបំព្រង ទំនងហាក់ដូចជាចង់ ប្រាប់នាងថា គេមានសេចក្តីសុខក្នុងចិត្តក្រៃលែងចំពោះភាពរមនា ក្នុងគ្រួសាររបស់ធីតា ។

ភ្លាមនោះ ស្រស់ឆោមនិងដារីក៏ច្រៀងបន្ទរដារិនឡើង ។ នៅ កៀនម្ខាង សុធនអង្គុយត្របោមជង្គង់ នៅស្ងៀមតែម្នាក់ឯង មិន ឃើញសម្តែងទឹកមុខសប្បាយរីករាយអ្វីនឹងគេទេ ។ ដារិនឃើញ ដូច្នោះ ក៏ទប់ហ្គីតាហើយសួរថា ៖

- សុធន! បងសិលាដែលបង្រៀនអោយប្អូនលេងភ្លេងទេ?

សុធនគ្រវីក្បាល ៖

- បងសិលារវល់ណាស់ មិនដែលមានពេលបង្រៀនខ្ញុំទេ ។
- អញ្ចឹង ចង់រៀនទេ? បងបង្ហាត់!
- សុធនចេះតិចៗដែរ! បងដារិនចង់ស្តាប់ទេ?
- ចង់! អញ្ចឹងលេងអោយបងស្តាប់មក៏!

ដារិលើកហ្គីតាហុចទៅអោយសុធនភ្លាម ស្រាប់តែអ៊ំសារីមាន ប្រសាសន៍ថា ៖

- កុំទៅលេងរំខានបងប្រុសបងស្រីអីសុធនអើយ! ឯងចេះវាយ ហ្គីតាប៉េះប៉ោះអញ្ចឹង ស្តាប់ទើសត្រចៀកណាស់ ។

ឮភ្លាម សុធនបាក់ទឹកចិត្តគ្រហេត ហុចហ្គីតាអោយដារិនវិញ រួចហើយធ្វើភ្នែកក្រហាមរកចង់យំ បន្តិចមកក៏ដើបដើរចូលបន្ទប់ ។ ដារិនស្រែកឃាត់ យ៉ាងរហ័ស៖

- ម៉ាក់និយាយលេងនឹងប្អូនតើហ៎ សុធន! ព្រោះគាត់ចង់សាក ល្បងនូវភាពរឹងប៉ឹងរបស់សុធននោះអី ក្រែងថ្ងៃក្រោយសុធនបាន ឡើងឆាក ត្រូវទស្សនិកជនបង្អាប់ ប្អូនមិនទន់ខ្សោយចាញ់ពាក្យ បង្អាប់របស់គេហើយរត់ចោលឆាក ឈប់លេង ។ ដូច្នេះ សុធនត្រូវ បង្ហាញនូវភាពរឹងប៉ឹង មិនស្រកស្រុតកម្លាំងចិត្តដោយការបន្តុះ បង្អាប់ទេ គឺប្អូនត្រូវហ៊ានបង្ហាញសមត្ថភាពយ៉ាងក្លាហានបំផុត ។

សុធនមុចដឹក់ បែរមើលមុខដារិន រួចហើយក៏ញញឹម ៖

- បងមានប្រសាសន៍ត្រូវណាស់ ។ អញ្ចឹងសុំហ្គីតាមក៏!

គេក៏ដាក់ខ្លួនអង្គុយចុះវិញ ទាញហ្គីតាពីដារិន ហើយចាប់ដេញ យ៉ាងរហ័ស ធ្វើអោយអ្នកទាំងអស់ចំហមាត់អង្គុយស្តាប់ទាំងភ្ញាក់ ផ្អើលក្នុងចិត្ត ដែលយុវជនយើងចេះលេងបានយ៉ាងស្ទាត់ជំនាញ ។ សូម្បីតែសិលាក៏ភ្ញាក់ផ្អើលដែរដែលឃើញប្អូនចេះលេងស្ទាត់ជំនាញ ល្មមអាចឡើងវេទិកាបាន ។ អ៊ំសារីដែលទៅធ្វើការរកស៊ីបាត់ៗមិន សូវនៅផ្ទះ ជិតដិតនឹងកូន

មិនសូវបានឃើញថាកូនធ្វើអ្វីខ្លះក្នុង ជីវិត
ចេះតែសន្មតថាកូនមិនដឹងនេះមិនចេះនោះតាមតែគាត់គិត ។
លុះឃើញសុធនចេះលេងហ្គីតាយ៉ាងជំនាញ គាត់ភ្ញាក់ក្រញាងដូច ធ្លាក់ពីចុងឈើ
ហើយនឹកស្ដាយក្នុងចិត្ត ដែលបន្តុះបង្អាប់អោយកូន អាក់ទឹកចិត្តអំបាញ់មិញនេះ ។

ទាំងអស់គ្នាក៏ទះដៃហ៊ោរកញ្ជៀវខ្ញៀវខ្ញាឡើង ។ អ៊ំសាឡាង សង្កេតឃើញថា វត្តមានរបស់ដាវីដនិងនារីពីររូបទៀតមកចូលក្នុង រង្វង់គ្រួសាររបស់គាត់ពីរថ្ងៃនេះ បាននាំការផ្លាស់ប្ដូរនិងភាពរមនា ដល់គ្រួសារគាត់ គួរឲ្យកត់សំគាល់ណាស់ ។ ពេលនោះ គាត់លួចតាមសង្កេតបុគ្គលិកលក្ខណៈរបស់ដាវីដ ប្អូនស្រីនិងមិត្តនី កាន់តែ ហ្មត់ចត់ឡើងហើយ ។ យូរៗម្តង គាត់លួចសង្កេតមើលកូនស្រី របស់គាត់ដូចគ្នា ប្រហែលជាគាត់កំពុងចាប់ភ្លឹកអំពីអារម្មណ៍សម្ងាត់ ផ្ទាល់ខ្លួនរបស់កូនចៅហើយមើលទៅ ។

CHANBOKEO.COM

## រាត្រីជុំគ្រួសារ

ព្រះចន្ទ័យាងរះឱភាសថ្លា　　នាំអោយចិន្តារីករាយក្រៃ
ពេលយល់សំណើចសើចសប្បាយ　　បងប្អូនគ្រប់កាយមានក្តីសុខ ។
ពុកម៉ែញញឹមកូនសោមនស្ស　　អារម្មណ៍ហើរហោះរសោះទុក្ខ
គ្រួសារជុំគ្នាក្នុងសំបុក　　កក់ក្ដៅយល់សុខចិត្តរមនា ។
សូរសៀងសំណើចលាន់រំពង　　អង្រួនបេះដូងដួងទ័យា
រំភើបហាក់យល់ស្ថានសួគ៌ា　　សប្បាយរមនាលែងគិតអ្វី ។
សំនៀងសំនួនជូនប្អូនបង　　ជូនពុកម៉ែផងញាតិប្រុសស្រី
ផ្ញើសៀងមង្គលតាមតន្ត្រី　　ស្នាដៃកវីតន្ត្រីស្នេហ៍ ។

យប់បន្តិច អ្នកទាំងបីជំរាបលាចាស់ៗត្រឡប់ទៅវិញ បន្ទាប់ពី សំណេះសំណាលគ្នាយ៉ាងសប្បាយអស់ជាយូរម៉ោង ។ មុននឹងដាវីដ ឡើងឡាន សុធនដើរទៅជិត ហើយស្រដីខ្សិបៗដាក់សុធនថា ៖

- ខ្ញុំសុំទោស ដែលព្រឹកមិញ ខ្ញុំនិយាយឆ្គាំឆ្គងដាក់បង ព្រោះពេល នោះ ខ្ញុំនៅពុលជាតិស្រវឹងក្នុងខ្លួននៅឡើយ ។

ដារិនងបែរក្រោយមកនិយាយជាមួយសុធនវិញថា ៖

- អូហ៍មិនអីទេ! បងមិនបានគិតទុកនៅក្នុងចិត្តទេ ។ ពេលប់នេះ បងឃើញសុធនបន្ទូរការតានតឹងក្នុងចិត្ត ទៅក្នុងបទចម្រៀងបាន បងពិតជាមានមោទនភាពណាស់ ។ ថ្ងៃក្រោយទំនេរ លេងភ្លេង ល្អៗដូច្នេះអោយបងស្តាប់ទៀតណ៎ា ។

- បាទ! ហើយថ្ងៃណាបងមកលេងប្អូនទៀត ?

- គឺ... បើបងចង់មករាល់ថ្ងៃ... តើគ្រួសារប្អូនមើសទាល់ទេ ?

សុធនបែរមើលទៅឪពុកម្តាយដែលឈរមើលពីចម្ងាយមក រួច ហើយក៏បែរទៅដារិនង ស្រដីថា ៖

- ម៉ាក់ទៅលក់ឥវ៉ាន់តាំងពីព្រហាមរហូតពេលប់ងងឹត ។ ប៉ានៅផ្ទះ ម្នាក់ឯង ប្រហែលជាគាត់អផ្សុកណាស់ ។ បើសិនបានបងមកលេង ប្រហែលជាគាត់សប្បាយចិត្តស្លាប់ហើយ ។

- អញ្ចឹង ចាំបងមកលេងប្អូន ពេលម៉ោងប្អូនចេញពីរៀន ។

- បាទ!

ដារិនញញឹម ហើយបររថយន្តដឹកនារីរូបស្រស់ទាំងពីរចេញ ទៅ ទាំងចិត្តរំភើបដោយឃើញសុធនកំពុងតែឈានផ្លាស់ប្តូរមករក ផ្លូវល្អវិញ ។

នៅក្នុងផ្ទះអ៊ំសាឡាង...

អ៊ំសារីអុជធូបថ្វាយព្រះមុនចូលដំណេក ស្រាប់តែប្រទះនឹងផ្កា ឈូកមួយទងនៅក្នុងថូ មុខបល្ល័ង្កដំកល់បដិមារ ។

- កូនដា! ហេតុអីក៏ថ្ងៃនេះ ទិញតែផ្កាឈូកមួយទង មកថ្វាយព្រះ អញ្ចឹងកូន ?

ធីតាឆ្លើយពីក្នុងបន្ទប់មកថា ៖

- កូនបានទិញទេម៉ាក់! គឺបងដារិនគាត់បេះពីបឹងថ្ងៃមិញយកមក អោយខ្ញុំ ទើបខ្ញុំដាក់ថ្វាយព្រះទៅ ។

CHANBOKEO.COM

អ៊ំសារីឮដូច្នោះក៏ចោលកន្ទុយភ្នែកដាក់អ៊ំសាឡាង ស្រាប់តែគាត់ អង្គុយញញឹមធ្វើមិនដឹង ។ បន្តិចមក អ៊ំស្រីក៏ទៅកេះសួរថា ៖

- កំពុងគិតរឿងអីហ្នឹង ប៉ាវ៉ា ?
- គិតរឿងល្អខ្លះៗ ហ្នឹងណា ?
- រឿងអ្វីទៅដែលល្អនោះ ?
- គឺរឿងអ្នកក្រអត់វណ្ណៈដូចយើង មានអ្នកខ្ពស់ណាគេមករាប់ ?
- ប៉ុន្តែ មិនដឹងថា គេរាប់អានដោយបរិសុទ្ធឬយ៉ាងណាតេ ព្រោះ មើលទៅគ្រួសារយើងគ្មានអ្វីអោយគេបេះបោចជាប្រយោជន៍សោះ ក្រៅតែពី...
- ក្រៅពីស្អីម៉ាក់វ៉ា ?
- កូនក្រមុំយើងនោះអី ? នេះប៉ាវ៉ាឯងកំពុងពាយនាយលក់កូន ស្រីមែនទេ ?
- កុំនិយាយអញ្ចឹងមើល៍ ពិបាកស្តាប់ណាស់ម៉ាក់វ៉ា! គេមកដោយ ត្រង់ យើងទទួលគេដោយត្រង់ជាញាតិទេតើហ៍!
- អោយតែមែនអញ្ចឹងចុះ! ខ្ញុំមិនចង់ជាប់ឈ្មោះលក់កូនស្រីដើម្បី លុយ ដើម្បីមុខមាត់ជាម៉ែក្មេករបស់កូនប្រសារអ្នកមានឬកូនប្រសារ ជាអនិកជនពីអាមេរិកទេ ។

អ៊ំសារីមានប្រសាសន៍ហើយក៏ពន្លត់ភ្លើងចូលសម្រាន្តទៅ ។

ថ្ងៃត្រង់ នៅមុខមហាវិទ្យាល័យភូមិន្ទ...

ធីតាឈរវេរា ចាំបងប្រុសមកទទួល យូរពេក ក៏ដើរទៅរកម៉ូតូ ឌុបបំរុងជិះត្រឡប់មកផ្ទះ ស្រាប់តែ...ទីន! ទីន!

- សួស្តី ធីតា! ម៉ោះ! ឡើងឡានមក បងជូនទៅផ្ទះ!
- បងដាវិដ ? ឯណាបងដារីនិងបងឆោម ?
- គេដើរតាមបែបស្រីៗអស់ហើយ នៅសល់តែបងទេដែលទំនេរ រកគ្នាដើរជាមួយមិនបាន ។

បន្តិចមក ដាវិដក៏ជូនធីតាដល់ផ្ទះ ៖

- បង សុំបាយម៉ាពេលផងណា៎ធីតា!

ធីតាញញឹម ឆ្លើយថា ៖

- បងប្រុស ទៅសុំប៉ាសិនទៅ ។

CHANBOKEO.COM

ដាវីឌញញឹមពព្រាយឡើង ដោយដឹងថា នារីមិនមានចិត្តទើស ទាល់ចំពោះរូបនាយ ។ ថ្ងៃនោះ ដាវីឌនៅបរិភោគបាយជាមួយអ៊ំ សាឡាននិងធិតា
ព្រោះសមាជិកគ្រួសារជាប់រវល់ការងារទាំងអស់ គ្នា ។ បន្តិចមក
ដាវីឌបានបង្ហាញក្រដាសស្នាមមួយសំណៅដល់អ៊ំ សាឡាននិងធីតា ៖

- ក្រដាសអីហ្នឹង បងដាវីឌ ?
- គឺជាក្រដាសប្រលងភាសាអង់គ្លេស សំរាប់ចូលរៀនកម្មវិធីអនុ បណ្ឌិតនៅអាមេរិក ។ បងយកមកអោយធីតាបំពេញ ។
- អូហ៍ ? អោយបំពេញធ្វើអ្វី កាលបើខ្ញុំមិនមានថវិកាឬអារូបករណ៍ អីឯណាជួយខ្លួនឯងសោះអញ្ចឹង ?
- គ្រាន់តែបំពេញទៅបានហើយ !

ធីតាសម្លឹងមុខឪពុក រួចសម្លឹងមុខដាវីឌធ្វើងឿងឆ្ងល់ ៖

- បងដាវីឌកំពុងធ្វើអីហ្នឹង ?

ដាវីឌមើលមុខធិតាហើយញញឹម ៖

- ដា មិនចង់ទៅរៀននៅអាមេរិកទេ ?
- ចឹមិនចង់ ! ប៉ុន្តែ គ្មានលុយបង់សាលាទេបង !
- នោះហើយ ! បងកំពុងដើររកលុយជួយដាហ្នឹងណា៎ ! នែ៎បំពេញ សិនទៅ កុំអាល័យសង្ស័យច្រើន ! បងទៅអាមេរិកវិញក្នុងពេល ពីរអាទិត្យខាងមុខនេះ ។ ដាគ្មានពេលគិតច្រើនទេ ។

ធីតាក៏ចាប់ក្រដាសយកមកសរសេរបំពេញ ។ អ៊ំសាឡាននៅ ស្ងៀម រង់ចាំមើលស្ថានការណ៍ ។ យូរៗម្តង គាត់លើកសន្លឹក ឯកសារយកមកអាន តែអានមិនដាច់ ព្រោះសុទ្ធតែជាភាសាជាតិគេទាំងអស់ ។ ចំណែកធីតាវិញ ហាក់ដូចជាភ័យផង អរផង ល្ងួច សង្ស័យផង
ថាហេតុអ្វីដាវីឌផ្តល់ការចាប់អារម្មណ៍ពិសេសចំពោះ នាងដល់ម្ល៉ឹង
កាលបើគេទើបតែស្គាល់គ្រួសាររបស់នាង មិនបាន មួយអាទិត្យផង ។ ទោះជាយ៉ាងណា
ក៏នារីបំពេញក្រដាសរហូតដល់ ចប់ចុងចប់ដើម ក្នុងចិត្តបែបន់អោយក្តីស្រម័យរបស់នាងក្លាយជាការពិត ។ បន្តិចមក ដាវីឌក៏សុំអនុញ្ញាតពីអ៊ំសាលាដនាំធីតាទៅ
ទាក់ទងកន្លែងប្រឡងអង់គ្លេសដើម្បីទៅរៀននៅអាមេរិក ។

ធីតាលួចគយគន់ដាវីឌមិនដាក់ភ្នែក ត្បិតចម្លែកចិត្តដែលបុរស

CHANBOKEO.COM

មានទឹកចិត្តចំពោះនាងខុសធម្មតា ។ ការពិតទៅ នាងមិនដែល
ឃើញបុរសណាផ្តល់ការចាប់អារម្មណ៍ ហើយសម្តែងទឹកចិត្តចំពោះ នាងដល់ម្លឹងទេ
ក្នុងមួយជីវិតនេះ ។ កាន់តែគិត ធីតាលួចរំភើប ចិត្តតែម្នាក់ឯង ។

រំពេចនោះ បុគ្គលិកម្នាក់ចេញមកសួរធិតាថា ៖

- ប្អូនចេះអង់គ្លេសកំរិតណាដែរ ?
- ចាស! រៀនបានបីឆ្នាំហើយ ។
- ចង់សាកប្រឡងទេហ៏ ?

ធីតានៅអេះអុញ ព្រោះនាងមិនបានប្រៀង ជាពិសេសរឿង លុយកាក់ ។
ស្រាប់តែដារិននិយាយថា ៖

- បើសាកត្រូវបង់លុយប៉ុន្មានដែរ ហើយត្រូវរង់ចាំពេលប៉ុន្មានថ្ងៃ ទើបដឹងលទ្ធផល ?

បុគ្គលិកនោះក៏ពន្យល់យ៉ាងក្បោះក្បាយ ។ បន្តិចមក ដារិនសួរ ធីតាថា ៖

- ដាហ៊ានសាកមើលទេ ? បងថា ដារៀនអង់គ្លេសបីឆ្នាំនៅមហា វិទ្យាល័យ
ប្រហែលជាគ្រប់គ្រាន់សំរាប់ប្រឡងហើយ ។
- ប៉ុន្តែ ខ្ញុំមិនមានលុយបង់ថ្លៃប្រឡងនោះទេ ។
- មិនអីទេ! បងបានបង់អោយគេហើយ គ្រាន់តែដាត្រូវរើសថ្ងៃ ប្រឡងប៉ុណ្ណោះ ។

បន្តិចមក ដារិនក៏រើសថ្ងៃប្រឡងមួយអោយធីតា ។ តាមផ្លូវ ត្រឡប់មកវិញ ធីតាសួរថា ៖

- ហេតុអ្វីបងដារិនដឹងប្រវត្តិខ្ញុំម្ល៉េះ ថាខ្ញុំរៀនដល់ណា ចេះ អង់គ្លេសដល់ណា ?
- គឺសិលាគេនិយាយប្រាប់នោះអី! បងស្គាល់សិលាយូរហើយតើហ៏
មានតែស្រស់ឆោមនិងដាវីទេដែលទើបស្គាល់សិលាប៉ុន្មានថ្ងៃនេះ ។
ហើយសិលាគេចូលចិត្តអួតពីប្អូនស្រីរបស់គេ រហូតដល់បងដារិន គេងលែងលក់តែម្តង
ចង់តែទៅជួបមុខ ព្រោះឮល្បីថាឆ្លៀវឆ្លាត ប្លែកបងប្អូនទាំងបីនាក់ខ្លាំងណាស់ ។

ធីតាញញឹមទ្រង់អៀន កាលបើឮដារិនសរសើរ ។

- អញ្ចឹងបងមកលេងស្រុកខ្មែរច្រើនដងហើយមែនទេ ?
- មែនហើយ ។
- មានបងប្អូននៅទីនេះមែនទេ ?
- មាន... គឺប៉ារបស់បង ។
- ចុះម៉ាក់វិញ ?

CHANBOKEO.COM

- គាត់អនិច្ចកម្មយូរហើយ ។ ប៉ាវិលពីអាមេរិកមកធ្វើការស្រុកខ្មែរ នេះ ហើយបានរៀបការមានគ្រួសារថ្មី ។ សព្វថ្ងៃបងនៅអាមេរិក តែពីរនាក់ដាវីទេ ។ ដាវីបានរៀនចប់អនុបណ្ឌិតឆ្នាំនេះ ។ ចំណែក បងវិញក៏កំពុងបញ្ចប់ការសិក្សាដែរ ។

- អូហ៍! ក្រែងបងធ្វើការមិនមែនទេ ?

- បាទ ធ្វើ! ប៉ុន្តែនៅរៀនផង ។

- អញ្ចឹង ដាសូមយកបងដាវិដជាគំរូហើយ ។ ពេលនេះ បង រៀនបញ្ចប់សញ្ញាបត្របណ្ឌិត ខាងចិត្តវិទ្យាមែនទេ ?

- ម៉េចក៏អូនដាដឹង ?

- គឺ ព្រោះឃើញបងមានទ្រឹស្តីចិត្តវិទ្យាអោយរូដូចទឹក ជាពិសេស ជាមួយសុធន ដូច្នេះមានន័យថា បងរៀនបានខ្ពង់ខ្ពស់ណាស ។ ។

ដាវិដសើចខឹកៗ ហើយឆ្លើយថា ៖

- ដាឈ្លាសវៃណាស់តើហ៍!

ដាវិដក៏បរនាំធិតាឆ្លងស្ពានជ្រោយចង្វារទៅខាងកើត...

- បងចង់ទៅណាហ្នឹង ?

- នាំដាទៅដើរលេងម៉ាស្របក់បានទេ ?

បន្តិចមក គេបាននាំនារីដល់ចំការពោតមួយនៅម្តុំវត្តបាក់ខែង ព្រែកលាប ។

- បងចង់ញុំាពោតអាំងយូរហើយ ប៉ងតាំងពីនៅអាមេរិក ប៉ុន្តែមិន ដែលមានគ្នាកំដរមកលេងដល់ទីនេះ ។ ដាវីនិងឆោមស្រស់គេមិន ចូលចិត្តកន្លែងរបៀបនេះទេ គេចូលចិត្តដើរផ្សារ ម៉្លោះហើយ... ឲ្យ តែមកស្រុកខ្មែរម្តងៗ បងអផ្សុកណាស់ ដឹងទេ ?

ដាវិដនិយាយផង នាំមុខធីតាផង សំដៅរោងស្បូវសំរាប់ភ្ញៀវ មកអង្គុយលំហែកាយ បរិភោគអាហារប្លែកៗដែលអ្នកស្រុកម្តុំនោះ គេលក់ ។

- អរគុណណាស់ ដា ដែលមកកំដរបងដើរលេង ។

ធិតាញញឹម មិនហ៊ានស្តី ។ ការពិត នាងកំពុងរំភើបរំជួលចិត្ត យ៉ាងណាមិនដឹងទេ ដែលបានដើរទន្ទឹមបុរសយើង ។ រំពេចនោះ ដាវិដស្រវាចាប់ដៃនារីកាន់នារីហើយស្រដីថា ៖

- ដាចុះដើរទៅលេងចំការពោត ចំការផ្កាឈូករត្ន័ខាងនោះទេ ? មើលទៅវាលចំការខៀវស្រងាត់ ហាក់ដូចជាសប្បាយដល់ហើយ !

CHANBOKEO . COM

# វាលស្នេហ៍

វាលអើយវាលវែងខៀវស្រងាត់ ខ្យល់បក់ផាយផាត់វាលខៀវខ្ចី
ក្រោមពន្លឺថ្លាសែងសុរិយ៍ បក្សាបក្សីច្រៀងខៀវខ្ចា ។
កាន់ដៃត្រសងបងនឹងពៅ វាលស្រែវាលស្រូវវាលចំការ
វាលវែងចារចាំវាលសង្សារ វាលព្រេងវាសនាគូនិស្ស័យ ។
វាលវែងជិតឆ្ងាយស្នាមនៃបនិត្យ វាលស្នេហ៍វែងស្ថិទ្ធផ្ចិតហឫទ័យ
បេះដូងកាត់ផ្ញើវាលខៀវខ្ចី ភ្ជាប់ស្នេហ៍និស្ស័យអមតៈ ។
វាលអើយវាលវែងវែងស្រណោះ វាលផ្ចិតសម្ពស្សស្នេហ៍ប្រត្យក្ស
វាលស្នេហ៍ភក្ដីគូរួមរក្ស វាលស្មោះវាលស្មគ្រ័អមតៈអើយ ។

ធីតាក្ដៅមុខភាយៗ នឹកខ្មាសតែក្នុងចិត្តមិនហ៊ាននិយាយអ្វីទេ ចេះតែបណ្ដោយអោយបុរសកាន់ដៃ ដើរកាត់ចំការពោត មើល ក្មេងៗកាច់ពោតយកទៅស្ងោរលក់ និងដើរមើលអ្នកស្រុកដែល កំពុងមុជដើបធ្វើការក្នុងចំការ មានពោត មានបន្លែផ្សេងៗដូចជា ត្រាវ សណ្ដែក ជាដើម ។ ពេលនោះ ធិតាសង្កេតឃើញថា ដារីង ហាក់ដូចជាមានលាក់ភាពក្រៀមក្រំមួយនៅលើផ្ទៃមុខ ប៉ុន្តែលុះដល់ ប្រទះចំក្រសែភ្នែកមាណវីយើង គេក៏ផ្លាស់ទឹកមុខហើយបែរញញឹម ដាក់នាងដូចធម្មតាវិញភ្លាម ។ បន្តិចមក គេក៏នាំធីតាដើរត្រឡប់មក វិញ ហើយសួរថា ៖

- ដា ដែលមកលេងទីនេះទេ ?
- ចាំស! អត់ទេ (ធីតាគ្រវីក្បាល) ខ្ញុំមិនសូវបានទៅណាទេ ព្រោះអាល័យរៀន ពេលទំនេរ ទៅជួយលក់អីវ៉ាន់នៅផ្សារឬក៏នៅ មើលថៃប៉ា មិនដែលបានដើរចេញក្រៅផ្ទះដូចក្មេងៗយុវជនយុវតី ទូទៅទេ ។ ណាមួយខ្ញុំគ្មានម៉ូតូគ្មានកង់ជិះផង ចង់ទៅណាមកណា ក៏មិនបានដូចចិត្តដែរ ។
- អញ្ចឹង ដាមិនអផ្សុកទេ ?
- អត់ទេ ព្រោះបើសិនអផ្សុក ខ្ញុំយកសៀវភៅពីបណ្ណាល័យសាលា អានទៅ បាត់អផ្សុកហើយ ។ ជួនកាលបងសិលានាំដើរតាមម្ដង មួយយាម ពេលគាត់ទៅសម្ដែងនៅពេលបុណ្យកន្លែងណាមួយ ។

CHANBOKEO.COM

- ហើយដាដែលមានមិត្តប្រុសសំខាន់ណាម្នាក់នៅក្នុងចិត្តទេ ?

ធិតាភ្ញាក់ព្រើត ដែលបុរសសួរនាងដូច្នេះ ។ នាងក៏កន្ត្រាក់ដៃ រឹងចេញពីដៃរបស់នរៈ ហើយគេចដើរយ៉ាងលឿនទំនងអៀនខ្មាស សំដៅទៅរោងស្បូវ ។ ដារិនភ្ញាក់ព្រើត ក៏ស្ទុះដើរតាមក្រោយ ៖

- ខឹងនឹងបងហ្អែស ដា ?
- គឺ... មិនចូលចិត្តដែលបងដារិនសួរច្រើនពេក ។
- អញ្ចឹងបងឈប់សួរហើយ ។ មោះ ! អង្គុយចុះមក ! សាកពោត អាំងពីរបីសិន ចាំទៅផ្ទះ ។
- ចាស !

ធីតាញ៉ាំពោតបណ្ដើរលួចគេចបែរមុខចេញបណ្ដើរ ព្រោះដារិន មិនព្រមដាក់ក្រសែភ្នែករបស់គេចេញពីនាងសោះ ។ ប៉ុន្តែនៅក្នុង ចិត្ត ធីតារំភើបនឹងការចាប់អារម្មណ៍របស់មាណពចំពោះរូបនាង ណាស់ ។ នាងមិនដែលមានបុរសណា យកចិត្តយកថ្លើមនាងដល់ ម្លឹងដែរ ។ ពេលនោះ ដារិនក៏ហាក់ដូចជាបាត់បង់ពាក្យសំដីសំរាប់ សន្ទនាជាមួយនារីទៅដែរ ព្រោះបេះដូងរបស់គេហាក់ដូចជារំដើប រំជួលពុះកញ្ជ្រោលខ្លាំងក្លាក្រៃខុសធម្មតា នៅពេលគេប្រទះក្រសែ ភ្នែករបស់ធីតាម្ដងៗ ។

នៅក្នុងផ្ទះរបស់អ៊ីសាឡាង...

ធីតាអង្គុយស្ងៀមនៅមុខបល្ល័ង្កព្រះ ដែលម្ដាយឪពុកនាងតម្កល់ ថ្វាយបង្គំរាល់យប់ថ្ងៃ ។ មាណវីយើងលួចបន់ស្រន់តែក្នុងចិត្ត៖

- សូមអោយចំណងសម្ពន្ធ័ដែលបងដារិនផ្ដល់មកអោយខ្ញុំពេលនេះ មានភាពល្អបរិសុទ្ធដូចផ្កាឈូកមួយទង ដែលបងបានបេះអោយខ្ញុំ កាលពីថ្ងៃមុន ។ សូមអោយខ្ញុំមានឱកាសបានទៅរៀននៅអាមេរិក នឹងគេផង ។

រាត្រីនោះ ធិតាចូលនិទ្រាទាំងចិត្តរសាប់រសល់ចម្លែក ខុសពី ពេលណាទាំងអស់ ។ ឯស្រមោលរបស់ដារិនចេះតែអណ្ដែតមក លងអារម្មណ៍របស់នារីយើងពេញមួយយប់ទល់ភ្លឺ គ្មានស្រាកស្រាន្ត...

ព្រហាមឡើង...

CHANBOKEO.COM

សិលាជាស្រួលខ្លួនគ្រាន់បើហើយ ក៏ឡើងម៉ូតូបំរុងឌុបប្អូនទៅ សាលា ស្រាប់តែដារិងបើកឡានមកដល់ ។ សិលាបែរមកមើលធីតា ហើយស្រដីថា ៖

- ជំនួយការថ្មីមកដល់ហើយ បងគិតសុំទៅសំរាកវិញហើយណា៎!

រួចហើយ គេមិចភ្នែកដាក់ប្អូន ហើយអូសម៉ូតូចូលផ្ទះទៅ ។ ធិតាញញឹមដាក់បងប្រុស ហើយក៏ឡើងរថយន្តទៅជាមួយដារិង ចេញទៅ ។

- យប់មិញ មានគេងនឹកបងខ្លះទេ ដា ? (ដារិងសួរ)

ធិតាភ្ញាក់ព្រើត កាលបើបុរសសួរត្រង់ៗ ។ នាងនិយាយបន្លប់ ទៅវិញថា ៖

- ចឹមិននឹក! នឹកថា បងដារិងនឹងជួយដាទៅរៀននៅអាមេរិក ។

- ចុះមាននឹកបងលើសពីនោះទៀតទេ ?

គេស្រដីផង លូកស្រវាចាប់ដៃធីតាកាន់ផង ធ្វើអោយមាណវី ភ្ញាក់ក្រញាង ប៉ុន្តែ គេបែរជាកាន់តែក្ដាប់ដៃរិតតែណែនជាងមុន ហើយស្រដីថ្នមៗថា ៖

- តែបងនឹកដាណាស់ នឹកដាពេញមួយយប់ ចង់មករកដាវិញទាំង អាធ្រាត តែមិនហ៊ាន ព្រោះខ្លាចចិត្តចាស់ៗ ។

ធីតារំជួលគ្រលួចក្នុងចិត្ត កាលបើឮប្រយោគនោះ ។ ការពិត នាងក៏លួចគេងនឹកដារិងមិនខុសគ្នាប៉ុន្មានទេ គ្រាន់តែនាងជាស្រី ធ្វើម្ដេចឡើយនឹងហ៊ានបើកចំហដួងចិត្តអោយបុរសបានឃើញដោយ ងាយនោះ ។ កំពុងតែបណ្ដើរអារម្មណ៍អោយសន្ទនាឆ្លើយឆ្លងតាម រយៈក្រសែភ្នែក និងកំដៅបាតដៃដែលគេក្ដាប់គ្នាទៅវិញទៅមក ស្រាប់តែ... ទីនៗ!

ដារិងនិងធីតាក្រឡេកទៅ ឃើញរថយន្តមួយបរមកឈប់ង៉ក់ កាត់ទទឹងរផ្លូវឡានដារិង រាំងមិនអោយបរទៅមុខរួច ។ រំពេច នោះ អ្នកទាំងពីរប្រទះឃើញនារីរូបស្រស់សោភាម្នាក់ និងស្ត្រី ចំណាស់ម្នាក់អង្គុយនៅបាំងក្រោយ មានសូហ្វ័របរជូនដំណើរ ។ ជា ដំបូង នារីសោភានោះញញឹមដាក់ដារិង ប៉ុន្តែលុះឃើញធីតាជិះរថ យន្តទន្ទឹមដារិងនៅក្នុងឡាន ស្រាប់តែចងចិញ្ចើមក្រញូវភ្លាមតែ ម្ដង ។ នាងក៏ហក់ចុះពីឡានដើរមករកដារិង ព្រមទាំងស្រដីថា ៖

- បងដារិង! ហេតុអ្វីបានជាយកឡានខ្ញុំ ទៅដឹកស្រីស្នេហ៍ អង្កាច់អង្កោចដើរលេងដូច្នេះទៅវិញ ?

CHANBOKEO.COM

នារីនោះនិយាយដោយសម្លេងហឹង្សា និងការប្រមាថក្នុងចិត្ត ។ ភ្លាមនោះ នាងនិយាយបន្តថា ៖

- ដាក់នាងនោះចុះភ្លាម ទើបខ្ញុំអោយខ្ចីឡានប្រើ បើមិនដូច្នេះទេ ខ្ញុំយកឡានវិញហើយ មិនអោយបងយកទៅដឹកស្រីស្នេហ៍ នាំតែ ចង្រៃឡានខ្ញុំទេ ។

ឮសំដីប្រមាថកាតទាននោះ ធីតាអន់ចិត្តស្រឡេតតែម្តង ។ នាងក៏រលាស់ដៃភឹងចេញពីដាវិឌ ទាញសំពៀតរៀន ស្ទុះបើកទ្វារ ឡានចុះចេញទៅរកម៉ូតូឌុបជិះយ៉ាងរហ័ស ដោយមិនស្រដីលាដាវិឌ អ្វីមួយម៉ាត់ ។

- ដា! ឈប់សិន!

ឃើញទឹកមុខធីតា ដាវិឌដឹងភ្លាមថានាងកំពុងមានអារម្មណ៍មិនល្អចំពោះពាក្យជៀមដាមរបស់នារីសោភា ។ គេក៏ប្រញាប់ដោះខ្សែ ក្រវាត់ឡានចេញពីខ្លួន ហើយក៏ហុចកូនសោឡានអោយនារីសោភា នោះ ព្រមទាំងស្រដីថា ៖

- នេះ សោឡាន! សុផានី យកឡានវិញចុះ! អរគុណណាស់ដែល បានអោយខ្ញុំខ្ចីប្រើឡានប៉ុន្មានថ្ងៃ ។

ថាហើយ គេក៏រត់តាមធីតារឹង ប៉ុន្តែនាងបានឡើងម៉ូតូឌុបចេញ ទៅហើយ ។ នរៈក៏បក់ដៃហៅម៉ូតូឌុបមួយទៀត បរតាមពីក្រោយ ធីតាយ៉ាងលឿន ទុកអោយសុផានីនិងស្ត្រីចំណាស់ដែលនៅក្នុងឡាន នោះឈរមើលពីក្រោយ ទំនងឆ្ងល់ផង អន់ចិត្តផងដែលដាវិឌមិន ផ្តល់ការចាប់អារម្មណ៍មកលើពួកគេអ្វីបន្តិច ។

មកដល់មាត់ទ្វារមហាវិទ្យាល័យ ម៉ូតូឌុបទាំងពីរក៏បានមកដល់ ទាន់ៗគ្នា ។ ធីតាស្ទុះរឹងដើរឈ្ងោកមុខគេចពីដាវិឌទៅយ៉ាងលឿន ប៉ុន្តែនរៈរត់យកខ្លួនទៅពាំងពីមុខមិនអោយនាងដើរចូលសាលា ៖

- ដា! ស្តាប់បងនិយាយមួយម៉ាត់សិនបានទេ?

- សូមទោស! ខ្ញុំដល់ម៉ោងចូលរៀនហើយ!

- តែបងដឹងថា ដាកំពុងខឹង...! បងមិនចង់អោយដាមានអារម្មណ៍ ល្អក់កករ ពេលរៀនទេ ។

- បើបងដឹងដូច្នោះហើយសូមចៀសផ្លូវ ឈប់រំខានខ្ញុំទៅ!

CHANBOKEO.COM

- អត់ទេ! បងមិនអោយដាទៅទេ ទាល់តែប្រាប់បងសិនមក ថា ដាមិនខឹងនឹងបង ហើយអនុញ្ញាតអោយបងជួបដាទៀត ។

ធីតាងើបមុខឡើង សម្លឹងមុខនរៈ ហើយស្រដីថា ៖

- ថៃដន្យ ដាមិនមែនជាស្រីស្នេហ៍របស់នរណា អោយគេមកឈរ ចង្អុលមុខជេរលេង កណ្តាលក្រុងភ្នំពេញនោះទេ ។

- បងសុំទោសណាំដា! បងសុំទោស! ថ្ងៃក្រោយចាំបងឈប់ខ្ចី ឡានគេហើយ ។ ចាំបងជួលឡានគេវិញ ឬក៏ជិះម៉ូតូឌុបក៏បានដែរ អោយតែដាសប្បាយចិត្តមកវិញ ។

- យើងគ្រាន់តែមនុស្សស្គាល់គ្នាពីរបីថ្ងៃ បងដាវិនមិនចាំបាច់បត់បែនជីវិតសំរាប់ខ្ញុំអីដល់ម្លឹងទេ ។ ទុកអោយខ្ញុំរស់តាមរបៀបអ្នក ក្រដូចដើមចុះ ។ ដាលែងចង់ជិះឡានហើយ ព្រោះមនុស្សដូចខ្ញុំ គ្មានវាសនា គ្មានតម្លៃ គ្មានកិត្តិយសគ្រប់គ្រាន់នឹងជិះរថយន្តរបស់ នរណាទៀតទេ ។ សូមទោស ដែលថ្ងៃមុន ខ្ញុំភ្លេចខ្លួន ភ្លេចវណ្ណៈ របស់ខ្លួនឯង ឡើងជិះឡានរបស់អ្នកដទៃ ធ្វើអោយគេដៀលត្មះ ដោយពាក្យមិនគប្បី ។

- ដា! ដាវិនសូមទោសដាពិតមែន គឺសូមទោសពីបេះដូងណាំដា! កុំខឹងអ្នកដទៃ ហើយជះកំហឹងមកលើបងអី! យើងនិយាយស្តាប់ គ្នាណាំ! ណាំ! ដាស្តាប់បងណាំ! ពេលអូនចេញពីរៀន បងនឹងចាំ អូនទីនេះ ។ ចាំយើងនិយាយគ្នាទៀត! បាត់ខឹងទៅដា ដើម្បីឲ្យមានអារម្មណ៍ល្អ ក្នុងថ្នាក់រៀនព្រឹកនេះ!

ធិតាសម្លឹងមុខដាវិន ដោយក្រសែភ្នែកយ៉ាងមុត ហាក់ចង់នឹង ជំរៅចិត្តរបស់នាយ ប៉ុន្តែនរៈមិនខ្លាចក្រសែភ្នែកនារីយើងទេ ។ គេសម្លឹងតបមកវិញ សម្តែងនូវអារម្មណ៍ផ្ទាល់របស់គេចំពោះនាង តាមក្រសែភ្នែកដ៏ស្រទន់ ធ្វើអោយធីតារំជួលក្នុងបេះដូងភ្លាមតែ ម្តង ។ បន្តិចមក នាងក៏ដាក់ភ្នែកចុះ ដើរចូលទៅក្នុងសាលាដោយ ស្ងៀមស្ងាត់ ទុកអោយដាវិនឈរសម្លឹងនាងពីក្រោយដោយដួងចិត្ត ប្រកបដោយទុក្ខកង្វល់ ។

- នរណាគេហ្នឹងដា ? ម៉េចក៏គេមានឫកពាហាក់ដូចជាជិតដិតនឹង ឯងម្លេះ ? (ចាន់ណា មិត្តស្រីម្នាក់លួចខ្សិបសួរធីតា)

- ឈ្មោះដាវិន ជាពួកម៉ាកបងសិលា!

CHANBOKEO.COM

- ពួកម៉ាកបងសិលា ហេតុអ្វី គេរត់មកនិយាយជាមួយអាដាឯង ?
គេកំពុងសុំស្នេហ៍អាដាមែនទេ ?
- និយាយផ្តាស ! ម៉ោះចូលថ្នាក់ ។
ធីតាស្រវាអូសដៃមិត្តចូលថ្នាក់ តែចាន់ណាមិនអស់ចិត្តក៏លួច
បែរក្រោយឃើញដារិងឈរមើលធីតាតាមចន្លោះទ្វាររបងពីចម្ងាយ
ធ្វើរេវៗមិនព្រមដើរចេញទៅណាទេ ។

ថ្ងៃត្រង់មកដល់...
ដារិងលើកដៃមើលនាឡិកាជាញឹកញាប់ ។ សិស្សចេញបន្តៗគ្នា
ប៉ុន្តែបាត់ធីតាមិនឃើញចេញមកវិញសោះ ។ ភ្លាមនោះ ដារិង
ក្រឡេកឃើញចាន់ណាដែលជាមិត្តស្រីរបស់ធីតា ក៏ស្ទុះទៅសួរ ៖
- អត់ទោស ប្អូន ! ធីតាគេចេញមកហើយបៗនៅ ?
ចាន់ណាភ្ញាក់ព្រើតឆ្លើយយ៉ាងរហ័ស ៖
- ចាំស ! អាដាមិនស្រួលខ្លួន ចេញទៅផ្ទះតាំងពីម៉ោង១០ម្ល៉េះ !
- អរគុណប្អូន !
ថាហើយបុរសយើងក៏ឡើងម៉ូតូឌុបចេញទៅ មួយសន្ទុះ ដារិង ក៏មកដល់ផ្ទះរបស់អ៊ំសាឡាង
ឃើញគាត់នៅផ្ទះតែម្នាក់ឯង ៖
- ជំរាបសួរអ៊ំ ! ដាមិនទាន់មកផ្ទះទេហ៍ ?
- នៅទេ ក្មួយដារិង ! ដាទូរសព្ទ័មកផ្ទះប្រាប់ថា នាងមកផ្ទះវិញ
នៅពេលព្រលប់ឯណោះ ។
ព្រឺងច្រោះ គេក៏សំពះលាអ៊ំសាឡាងចេញមកវិញយ៉ាងរហ័ស ។
- យី ! មកក៏តក្កហល ចេញទៅវិញក៏តក្កហល ! គេមានការអ្វីទៅ ហ្នឹង ?
(អ៊ំសាឡាងអេះត្រចៀក នឹកឆ្ងល់នឹងកិរិយារបស់ដារិង)
ដារិងដើរចេញមករកម៉ូតូឌុបធ្វើដំណើរចេញទៅ ក្នុងចិត្តគិតតែ ម្នាក់ឯងថា ៖
- ដា ! ពេលនេះ អូនគេចទៅឯណា ?

CHANBOKEO.COM

ភ្លាមនោះ គេនឹកដល់ចំការពោតនៅជិតវត្តបាក់ខែង នឹកទៅ ដល់បឹងឈូកតាមផ្លូវទៅប្រាសាទភិមានសួគ៌ថ្មី ដែលគេធ្លាប់នាំនារី ទៅលេង ។ ទីបំផុត គេក៏អោយម៉ូតូឌុបដល់បឹងឈូកដែលគេធ្លាប់ អុំទូកបេះផ្កាជាមួយធីតាកាលពីប៉ុន្មានថ្ងៃមុននេះ ។

មកដល់ខ្ទមស្បូវម្ចាស់ទូក ដារិដចុះពីម៉ូតូដើរសំដៅមីងម្ចាស់ ខ្ទមនោះភ្លាម ឃើញគាត់កំពុងអង្គុយបត់ត្របកផ្កាឈូកជាក្បាច់ យ៉ាងស្អាតវិចិត្រ ។ គ្រាន់តែក្រឡេកឃើញមុខមាណពភ្លាម មីង ម្នាក់នោះស្រែកវ៉ាវមកថា ៖

- អន្ទិតឯងមកតាមប្រពន្ធមែនទេ ? នោ៎ះ ! ឃើញនាងរត់មកពួន សំកុកលើទូកនៅឯបឹង លួចស្រក់ទឹកភ្នែកយំពេញម៉ាព្រឹកហើយ ហៅមកបរិភោគបាយក៏មិនឡើងមកដែរ សុខចិត្តនៅអង្គុយហាល ថ្ងៃតែម្នាក់ឯង ។ អានាងឯងធ្វើអីអោយគេខឹងហ្ន៊ែស បានជា... ?

ដារិដមិនរង់ចាំអោយមីងសួរអ្វីទាន់ទេ ។ កាលបើគេដឹងថាធីតា មកដល់ទីនោះ គេក៏ស្ទុះរត់រឹងចុះច្រាំងសំដៅបឹងក្រោយខ្ទមស្បូវ នោះ ហើយដើរសួរតាមស្ពានរហូតមកដល់ទូកដែលដាក់ចតចោល កណ្ដាលថ្ងៃក្ដៅ ។ ពេលនោះ បុរសយើងឃើញធីតាអង្គុយត្របោម ជង្គង់ក្រាបមុខលើដៃ ទំនងកំពុងសំរក់ទឹកភ្នែក ។

ពេលឃើញទឹកភ្នែកអូន

ពេលឃើញអូនយំស្រក់ទឹកភ្នែក ទ្រូងបងរហែកឈឺខ្លោចផ្សា
ចង់យំជំនួសពៅជីវ៉ា អោយមុំធិតាស្បើយអារម្មណ៍ ។
ឃើញទឹកភ្នែកអូនស្រក់លើថ្ពាល់ បងព្រួយកាយកលអួលទ្រូងធំ
ចង់ស្ទុះទៅជូតទឹកភ្នែកមុំ អោយអូនឈប់យំព្រួយចិន្តា ។
ពេលឃើញរូបអូនស្រពោនចិត្ត ឱរាបងរិតលង់ទុក្ខា
ចង់ស្ទុះថ្នាក់ថ្នមបមកាយា ឲ្យពៅស្នេហាក្សាន្តហឫទ័យ ។
បងជូតទឹកភ្នែកអោយណា៎ពៅ ថ្ងៃនេះតទៅផ្លាស់ជាថ្មី
លែងឲ្យទឹកភ្នែកនារីងរៃ បងថៃពិសីសុខរៀងទៅ ។

- ដា ! (ដារិដហៅនាងខ្សិបៗ)

ធីតាភ្ញាក់ព្រើតងើបមុខឡើងឃើញដារិដកំពុងដាក់ខ្លួនសន្សឹមៗ អង្គុយចុះក្បែរនាង ។ មាណវីក៏គេចមុខភ្លាមយ៉ាងរហ័ស យកដៃ ជូតទឹកភ្នែកពីរង្វង់មុខ ។

CHANBOKEO.COM

- ដា! បងបារម្ភពីដាណាស់នឹងទេ ដែលអូនគេចពីសាលា... គេច
ពីផ្ទះ... ដោយមិនមានដំណឹង...

ធីតាឈ្ងោកមុខនៅស្ងៀម ។ ដាវិនក៏និយាយបន្តថា ៖

- បងដឹងណា៎ ថាអូនដាឈឺចិត្តព្រោះពាក្យប្រមាថដ៏អសុរសរបស់ សុផានី ។ ឯបងក៏មិនសប្បាយចិត្តដូចគ្នាដែលគេបញ្ចេញឥរិយាបថ និងសំដីដូច្នេះចំពោះបងនិងចំពោះដា ព្រោះជាការបង្ហាញនូវការ ប្រមាថកិត្តិយសរបស់ដា និងរបស់បងពេញទី ។ មួយប្រយោគ ដែលគេជេរដាមនោះ គឺជាការមើលស្រាលថា បងជាមនុស្សមាន ចរិតពាលា...បងក៏ឈឺឆ្អាលក្នុងបេះដូងមិនខុសពីដាទេ... នឹងទេ ?

ធីតានៅស្ងៀមយ៉ាងយូរទើបស្រដីថា ៖

- ដូច្នេះ យើងគួរតែឈប់ទៅមកនឹងគ្នាទៀតទៅ!

ដាវិនភ្ញាក់ព្រើត សួរភ្លាមថា ៖

- ហេតុអ្វីទៅ ដា ?

- ព្រោះយើងជាមនុស្សមានវណ្ណៈពីរខុសគ្នា មានជញ្ជាំងខណ្ឌមិន អោយយើងសេពគប់គ្នាទៅមកឡើយ ហើយខ្ញុំក៏មិនចូលចិត្តឲ្យ មនុស្សវណ្ណៈម្ខាងទៀត ជេរខ្ញុំយ៉ាងអាសោច ដូច្នោះទេ ។

- ខុសហើយដា! ភាពថ្លៃថ្នូរបស់មនុស្សមិនមែនស្ថិតនៅលើទ្រព្យ សម្បត្តិទេ គឺស្ថិតនៅលើមារយាទឥរិយាបថ និងការប្រព្រឹត្តរបស់ គេ ។ ហើយ... ក្នុងកែវភ្នែករបស់បង អូនជានារីដ៏ប្រពៃម្នាក់...

មាណពទុចដ៏ក់ មិនបានបញ្ចប់ប្រយោគ ។ ធីតាងើបមុខឡើង បែរសម្លឹងនរៈហាក់ដូចជាប្រាថ្នាស្ទង់ទឹកចិត្តរបស់នាយ ។ រំពេច នោះ ដាវិនលេបទឹកមាត់ផ្សើមបំពង់ក ហើយក៏ស្រដីបន្តថា ៖

- ហើយបើដាត្រូវខូចឈ្មោះដោយសារបង... បងក៏បានទទួលខុស ត្រូវជីវិតរបស់ដាដែរ! បងបានសន្យា! ដាជឿបងចុះ!

ធីតាឮហើយ បើកភ្នែកមូលក្រឡង់ ទំនងភ្ញាក់ផ្អើល រួចឧទាន ឡើងថា ៖

- យើងទើបតែស្គាល់គ្នាមិនប៉ុន្មានថ្ងៃទេ ហេតុដូចម្ដេច បងដាវិន បានប្ដេជ្ញាដល់ម្លឹង ? ហើយ..ចំពោះដាវិញ តើអោយដាទុកចិត្តបង យ៉ាងណា បើដាមិនស្គាល់ប្រវត្តិរបស់បង និងក្រុមគ្រួសាររបស់បង អ្វីបន្តិចផងនោះ ?

CHANBOKEO.COM

- អញ្ចឹង អូនរៀនស្គាល់បងទៅ សង្កេតថាបងជាមនុស្សយ៉ាងម៉េច
ហើយប្រវត្តិគ្រួសារបងយ៉ាងម៉េច... បងនឹងចំហឱកាសជូនអូនសព្វ យ៉ាង អូនសុខចិត្តទេ ដា ?
ចំពោះបងវិញ... បងមានសំណូមពរ
តែមួយគត់ចំពោះអូន ។
- ជាអ្វីទៅ ?
- ងាយទេ បើសិនអូនជាស្មគ្រ័ពិចារណារូបបង!
- អញ្ចឹង បងប្រាប់ដាសិនមក៍!
- គឺសុំអោយអូនរៀនដល់ចប់បរិញ្ញា ។ អូនជាក្មេងល្អរបស់ឪពុក ម្តាយ ជាសិស្សឆ្លៀវឆ្លាត...
អូនកុំអោយអារម្មណ៍មួម៉ៅវាងណ្តប់ចិត្ត ភ្លេចការសិក្សាអស់អញ្ចឹងណា៎!

រំពេចនោះ ធីតាធ្វើមុខស្រងូត ឆ្លើយថា ៖
- អញ្ចឹង ស្អែក ខ្ញុំទៅរៀនវិញហើយ! សុំទោសណា៎ដែលថ្ងៃនេះ ដាមានអារម្មណ៍មិនល្អ
ធ្វើអោយល្អក់កករសម្ពន្ធ័របស់យើង ។
- ដាសុំទោសបងធ្វើអ្វី ? គឺបងទេតើហ៏ដែលត្រូវសុំទោសដាដោយ
បងបណ្តោយអោយគេម្នាក់មកមើលងាយអូន... ថ្ងៃក្រោយ បង សន្យាថា
មិនអោយមានរឿងហេតុដូច្នេះកើតឡើងទៀតទេ ហើយ
បងក៏ឈប់ខ្ចីឡានរបស់គេនោះប្រើដែរ ។
- ចុះក្រែងគេជាសង្សារបង មិនមែនទេ ?
- នរណាថា ? សុផានីគ្រាន់តែជាសាច់ញាតិ៧សន្តានរបស់អ្នកស្រី ពិសី
ភរិយាថ្មីរបស់លោកប៉ាបងតើហ៏!
- ប្រហែលជាក្រុមគ្រួសាររបស់បងជាអភិជន ឬជាមន្ត្រីហើយ បានជាមានឫកពាឆ្មើងកន្ត្រើង
មើលងាយអ្នកក្រដល់ម្លឹង ?
- ពួកគេនោះមានទ្រព្យពិតមែន ប៉ុន្តែមិនមានទឹកចិត្តនិងវិជ្ជាទេ ។
គេចូលចិត្តយកលុយទិញសញ្ញាបត្រ័ដើម្បីតាំងបង្អួតគេ ចូលចិត្តទិញ ឡានតាំងធ្វើរបង
ទិញមាសស្រោបខ្លួនអោយស្អាត ប៉ុន្តែគេភ្លេចគិត ថា ក្នុងខ្លួនរបស់គេ
ខ្វះទឹកចិត្តនិងសីលធម៌នោះឡើយ ។ រូបបង និងដារីវិញ
គ្រាន់តែជាបំណែកគ្រួសារដែលគេខំប្រឹងរាប់រក ព្រោះ
គេប្រាថ្នាទាញយកប្រយោជន៍ពីយើងតែប៉ុណ្ណោះ ។

CHANBOKEO.COM

- ប្រយោជន៍ ? ប្រយោជន៍អ្វីទៅ ?

- ប្រយោជន៍ដែលថា បងនិងដារីមានសញ្ជាតិអាមេរិកនោះអី! គេ កំពុងចង់ចាប់បង ចងភ្ជាប់ជាមួយនារីដែលជាកូនចៅសាច់ញាតិ របស់ គេនោះរៀបការ ដើម្បីធានាយកទៅនៅអាមេរិក ។ ចំណែក ដារីវិញក៏ដូច្នោះដែរ ។ នាងកំពុងត្រូវម្តាយចុងរបស់បង បញ្ចុះ បញ្ចូលអោយបោះបង់សង្សាររបស់នាង ហើយរៀបការជាមួយ បុរសនៅភ្នំពេញនេះ ព្រោះគេជាអភិជន មានទ្រព្យដាក់ដៃអោយនាងច្រើនកប់ខ្លួនឯណោះ ។

ភ្លាមនោះ ធីតាបើកភ្នែកធំៗ លាន់មាត់ថា ៖

- អញ្ចឹង បងត្រូវជាគូដណ្តឹងរបស់នារីម្នាក់នោះមែនទេ ?

- មិនចំជាអញ្ចឹងទេ! គឺជាគំរោងរបស់ចាស់ៗ ចង់អោយបងធ្វើ ដូច្នោះ ប៉ុន្តែ បងមានជីវិតជារបស់ខ្លួនឯង ។ បងមិនបណ្តោយឲ្យ សង្គមជុំវិញខ្លួនប្រើអំណាចកៀបបងអោយធ្វើតាមគេទេ ។ បងរស់ នៅអាមេរិកយូរហើយ... បងទទួលការអប់រំគំនិតនិងការប្រព្រឹត្ត បែបអាមេរិកាំង ដែលជ្រើសរើសផ្លូវជីវិតខ្លួនឯងដោយគ្មាននរណា បង្ខិតបង្ខំ ។ ដូច្នេះ ពិតជាមិនអាចទៅរួចទេ ដែលបងអោយគេ បង្ខំរៀបការនឹងមនុស្សដែលបងមិនពេញចិត្តនោះ ។

- ប៉ុន្តែទីនេះជាស្រុកខ្មែរណា៎បង! ស្រុកខ្មែរគេមានទំនៀមទម្លាប់ ខុសពីអាមេរិក ។ បើបងដើរខុសគន្លងគេ គេច្បាស់ជាដើរជាន់បង ស្លាប់មិនខាន ។

- តែបងក៏មានច្បាប់អាមេរិកការពារសុវត្ថិភាពបងដូចគ្នា ។ គេ មិនអាចដើរជាន់បងអោយស្លាប់បានទេ ។

- ប៉ុន្តែ នារីណាដែលមានចំណងសម្ពន្ធ័ជាមួយបង ទើសផ្លូវរបស់ គេ ច្បាស់ជាត្រូវប្រឈមមុខចំពោះការដើរជាន់របស់គេហើយ ។

- អូនដាខ្លាចហ្ន៎ស ?

- បើសិនជាគេប្រើអំណាចកម្លាំងបាយនិងចុងកាំភ្លើង ដាពិតជា ខ្លាចណាស់ ។ ប៉ុន្តែ បើនិយាយរឿងប្រជែងដោយសតិប្រាជ្ញ និង ភាពថ្លៃថ្នូរ ដាមិនខ្លាចអ្វីសោះឡើយ ។

ដារិដ ញញឹមឡើង ហើយលូកដៃចាប់ដៃនារីយកមកកាន់ ៖

- ចុះបើយើងដើរព្រមគ្នា ពុះពារទាំងអស់គ្នា ឆ្លាក់ទឹកឡើងគោក ជាមួយគ្នា ដាសុខចិត្តដើរផ្លូវជីវិតជាមួយបងទេ ?

CHANBOKEO.COM

ធីតាសម្លឹងមុខនរៈមួយស្របក់ក៏ឆ្លើយថា ៖

- ទុកពេលអោយខ្ញុំស្គាល់បងជាងនេះបានទេ ? ចាំខ្ញុំនឹងឆ្លើយតាម ក្រោយទៀត ។
- បាន ! តែអូនដាក់កុំទុកអោយបងចាំយូរពេកណា៎ !

មាណវីក៏ញញឹមឡើងចំពោះដារិងយ៉ាងបំព្រង ។ បន្តិចមក គេក៏ដើរកាន់ដៃគ្នាត្រឡប់មកផ្លូវធំវិញ ។ មីងអ្នកលក់ផ្កាឈូកឃើញ អ្នកទាំងពីរដើរកាន់ដៃគ្នាញញឹម ក៏ស្រដីថា ៖

- មកនេ៎ះ ! មីងអោយផ្កាឈូកម៉ាបាច់ ជូនពរអន្ទិតឯងនិងប្រពន្ធ ដែលត្រូវរ៉ូវគ្នាវិញ ។ សូមអោយស្នេហាឯងបានសុខរហូតគ្មានថ្ងៃ របូតរបេះទៅណាបានឡើយ !

ធីតាព្រួងច្មោះ ក៏លួចចោលកន្ទុយភ្នែកដាក់ដារិង ហើយបែរមុខ ចេញ ធ្វើអឹមអៀន ។ ដារិងក៏ឱនខ្សិបដាក់ត្រចៀកនាងថា ៖

- សូមអោយដូចពាក្យដែលមីងជូនពរនោះកុំខាន សាធុ !

ធីតាព្រួងច្មោះក៏លូកដៃក្តិចចង្កេះដារិង ប៉ាត់ ។ ដារិងអត់មិន បានក៏ស្រែកលលេងឡើងថា ៖

- អ៊ីយ៉ូយ ! បែកគ្នាម៉ាដើ ម៉េចក៏ប្រចណ្ឌបងម្លេ៉ះអូន ?

មីងលក់ផ្កាឈូក ព្រួហើយសួរភ្លាមថា ៖

- អូហ៍ ! ប្រចណ្ឌឯណាក៏ប្រចណ្ឌ អាណិតកុំតែប្រចណ្ឌដាក់មីងបាន ហើយ ! (មីងនិយាយលេង)
- បាទ ! គឺនាងប្រចណ្ឌដាក់មីងហ្នឹងណា៎ ព្រោះមីងចិត្តល្អនោះអី ធ្វើអោយខ្ញុំស្រឡាញ់មីងដល់ហើយ ។
- យី ! និយាយតែផ្តាសមែនអាអន្ទិត តិចមីងខឹងឯងម្នាក់ទៀត ឥឡូវ ! ចាំមែន !

ទាំងអស់គ្នាក៏សើចកខឹកឡើង ។ ដារិងទទួលផ្កាឈូកមួយបាច់ នោះពីមីងម្ចាស់ខ្ទម ដោយដួងចិត្តសែនសោមនស្សរំភើប ។

តាមផ្លូវ ពេលអ្នកទាំងពីរដើរទៅរកម៉ូតូឌុប...

ដារិងហុចផ្កាឈូកទៅអោយធីតា ហើយស្រដីថា ៖

- ធីតាជាផ្កាឈូកនៅក្នុងបេះដូងបងណា៎ ដឹងទេ ?

ធីតាញញឹម លូកដៃទទួលផ្កាឈូកពីនរៈ ។ ដារិងនិយាយបន្ត ទៅទៀតថា ៖

- ហើយផ្កាឈូកមួយបាច់ដែលមីងម្ចាស់ទូកចងដៃជូនពរយើងទាំង ពីរនាក់អំបាញមិញ ក៏ជាពរដ៏បរិសុទ្ធរបស់អ្នកក្រអត្តខាត់ខ្វះមុខខ្វះ ក្រោយ ។ គាត់ខ្វះខាតប៉ុនហ្នឹងហើយ

CHANBOKEO.COM

នៅខំឆ្លៀតសំដែងទឹកចិត្ត របស់ខ្លួនចំពោះញាតិ សូម្បីតែមិនដែលស្គាល់គ្នាពីមុនមក ។ បង គិតថា ពររបស់គាត់ពិតជាមានតម្លៃខ្ពស់អនេកអនន្ត វាស់មិនបាន ឡើយ ។

ធីតាក៏តបវិញថា ៖

- ខ្ញុំមិននឹកស្មានសោះ ថាអនិកជនអាមេរិក ចេះស្គាល់តម្លៃទឹកចិត្ត របស់អ្នកក្រនឹងគេដែរ ។

- នរណាថា អ្នកអាមេរិក មិនស្គាល់តម្លៃទឹកចិត្ត ? ការពិតនៅ ស្រុកអាមេរិក ពលរដ្ឋភាគច្រើន ច្រើនមានទឹកចិត្តចំពោះគ្នាណាស់
ហើយមិនសូវមើលបំណាំទេ ។ បងចង់ឃើញសង្គមខ្មែររៀនត្រង
ត្រាប់ភាពប្រពៃនៃសង្គមអាមេរិក មកដាក់សង្គមយើង ជាជាង
ចម្លងយកវប្បធម៌ចិញ្ចើមថ្ពាល់របស់ជនពាលតាមចិញ្ចើមថ្ពាល់ មក ដាក់ពេញស្រុក
ដូចជាការស្លៀកខោធ្លាក់គូថ ដំណើរជើងកាងដីស្មើ ដើររលាក់ សំដីច្រឡោងខាម
ការស្លៀកពាក់សំយេះបិទមុខ បិទក្រោយមិនជិត ដើម្បីបង្ហាញម៉ូដសាក់ស្បែកនៅកន្លែង
ពិសេសៗ  ។ល ។ បងពិតជាសោកស្តាយណាស់ ដា ដែលក្មេងៗ
សម័យឥឡូវចម្លងតែចរិតពាល សំដីពាល ប៉ុន្តែមិនព្រមចម្លងភាព
ថ្លៃថ្នូររបស់សង្គមអាមេរិកជាន់ខ្ពស់មកចែកគ្នាឲ្យចេះដឹងសោះ ។

- ខ្ញុំថា បើសិនជាក្មេងជាន់ក្រោយបានចេញទៅរៀនស្រុកគេអោយ បានកាន់តែច្រើន គេច្បាស់ជានាំនូវការចេះដឹងល្អមកចែកស្រុក យើងវិញមិនខានឡើយ ណា៎បង ។

- អញ្ចឹងអូនដាខំរៀនទៅណា៎ ដើម្បីចម្លងគំរូល្អចែកចាយទៅ យុវជនយុវតីជាន់ក្រោយផង ។

- ចា៎ស ! បើសិនមានលទ្ធភាពនិងឱកាស ដានឹងចាប់មិនអោយ របូតបានឡើយ ។

- បងជឿទុកចិត្តថាដា ថាអូនពិតជាអាចធ្វើបាន ។

ភ្លាមនោះ អ្នកទាំងពីរក៏ញញឹមដាក់គ្នាជាថ្មី រួចហើយក៏ហៅម៉ូតូ ឌុបជិះត្រឡប់ទៅផ្ទះវិញ ទាំងចិត្តរីករាយ ដែលបានយល់ចិត្តថ្លើម គ្នាកាន់តែច្បាស់ជាងមុន ។

oooooooooooooooooooooooo

CHANBOKEO.COM

# វគ្គទី៥
# រលកជីវិត

នៅវិឡារបស់លោកដាវុធ...

- កូនទើបតែមកពីណា ដាវិឌ ? ហើយចុះឯណាដារី និងពួកម៉ាក ស្រីរបស់គេ ?
- គឺមកពីដើរលេងមាត់បឹងមាត់ទន្លេ លោកប៉ា! ចំណែកស្រីៗគេ ដើរផ្សារទិញឥវ៉ាន់ ។
- ហើយម៉េចកូនមិននាំនាងសុផានីដើរលេង ជាមួយផងទៅ ដើម្បី បានជាគ្នា កុំអោយអផ្សុក ។
- កូនធ្លាប់ដើរតែម្នាក់ឯង មិនមានអផ្សុកអីទេ លោកប៉ា!

ស្រាប់តែមានសំដីមួយហើរកាត់ការសន្ទនារបស់អ្នកទាំងពីរ ។

- កុំកុហក! ព្រឹកមិញ មីងឃើញឯកយកឡានសុផានី ដឹកស្រី ដើរលេងទៀតផង!

ដាវិឌងាករឹង ឃើញអ្នកស្រីពិសីដើរចូលមកជាមួយសុផានី ។

- គេជាមនុស្សល្អ មិនមែន ស្រីៗស្ទីៗនោះទេ ។
- ម៉េចឯងដឹងថាជាមនុស្សល្អកើត បើឯងទើបតែមកដល់ស្រុកខ្មែរ មិនទាន់បានមួយអាទិត្យផងនោះ ?

ដាវិឌនៅស្ងៀមមិនតបតទេ ប៉ុន្តែនៅក្នុងចិត្តលួចគិតថា ៖

- ហើយចុះសុផានីវិញ ខ្ញុំទើបតែជួបនាងម្តងពីរ តើអោយខ្ញុំទុក ចិត្តនាងម៉េចទៅ ថានាងជាមនុស្សល្អសំរាប់ខ្ញុំរៀបការជាមួយ ? អត់ផ្លូវទេ! ការរៀបការដោយសម្ពន្ធ័និស្ស័យ និងការរៀបការ ដោយការចាប់ផ្តុំបង្ខំ ជីវិតគូស្រករមានអត្ថរសខុសគ្នាឆ្ងាយណាស់!

សុផានីក៏ដើរមកជិតលោកដាវុធហើយរអ៊ូថា ៖

- លោកអ៊ំមើលចុះ បងដាវិឌយកឡានខ្ញុំទៅប្រើ ហើយដឹកស្រីញី បញ្ឈឺចិត្តខ្ញុំទៀត ។ មិនតែប៉ុណ្ណោះ គាត់បោះសោរអោយខ្ញុំនៅ កណ្តាលផ្លូវ

CHANBOKEO.COM

អោយបើកឡានយកមកផ្ទះវិញដោយខ្លួនឯង ។ គាត់
មិនព្រមបើកយកមកសងខ្ញុំវិញអោយត្រឹមត្រូវទេ ។

ដារិនខំធ្មេញ លួចគិតតែម្នាក់ឯងទៀតហើយ ៖

- ស្មានថា ខ្ញុំពេញចិត្តណាស់ហើយឬ ដែលនាងប្រើចរិតក្មេង៨ឆ្នាំ ប្ដឹងលោកប៉ារបស់ខ្ញុំ ? ត្រង់ណាទៅដែលបង្ហាញថា នាងផ្ដល់ កិត្តិយសអោយខ្ញុំជាបុរស ឬជាប្ដីអនាគត ? ការពិត នាងកំពុងរក ក្បួនគ្របដណ្ដប់ជីវិតរបស់ខ្ញុំ ដោយអំណាចទ្រព្យលុយឡាន ឬ ដោយអំណាចគ្រួសារ យកលោកប៉ាខ្ញុំមកសម្លុតអោយខ្ញុំធ្វើតាម ទេតើ ? កុំសង្ឃឹមឡើយសុផានីអើយ នាងចុះចតយន្តហោះខុស ចំណតហើយ! សូមទោស! បេះដូងរបស់ខ្ញុំពេលនេះលែងទំនេរ សំរាប់សុផានីហើយ មិនបាច់ប្រើល្បិចកុមារដ្ឋាន ដើម្បីដណ្ដប់ជីវិត របស់ខ្ញុំទេ ។

ដារិនឈ្ងោកមុខដើរចេញ ធ្វើមិនដឹងមិនឮនិងសំដីញ៉ិកញ៉ក់ របស់សុផានី ជាមួយឪពុកនិងម្ដាយចុងរបស់នាយឡើយ ។ លោក ដាវុធសម្លឹងមើលតាមកូនពីក្រោយ រួចហើយលួចជ្រួញចិញ្ចើម ទំនងយល់នូវកិរិយារបស់កូន ថាគេកំពុងមានអារម្មណ៍យ៉ាងណា ។ លោកក៏បែរដើរចេញពីបន្ទប់ទទួលភ្ញៀវនោះទៅដែរ ព្រោះមិនចង់ នៅស្ដាប់ពាក្យបញ្ចុះបញ្ចូលរបស់អ្នកស្រីពិសី ។

យប់បន្តិច ដារី និងស្រស់ឆោមក៏មកដល់ ដោយនាំសំណើច សើចលាន់ឮរអឹកមកជាមួយផង ។

- មកពីណា ដារី ? ម៉េចបណ្ដោយអោយពួកម៉ាកដឹកច្រមុះដើរ លេងភ្លេចអស់ថាខ្លួនត្រូវធ្វើអ្វីខ្លះអញ្ចឹង ?

ស្រស់ឆោមភ្ញាក់ព្រើត ដែលឮសំដីដៀមដាមអោយនាងបែប នោះ ។ មាណវីងើយមើលទៅម្ចាស់សម្លេង ក៏ឃើញអ្នកស្រីពិសី ដើរចុះជណ្ដើរមក ព្រមទាំងស្រដីបន្តថា ៖

- ដឹងទេដារី ថាថ្ងៃនេះ លោកណារ៉ាត់ គេមកអង្គុយចាំជួបនាង ពេញមួយថ្ងៃ តែនាងដើរបាត់ ។ ទូរសព្ទ័ក៏មិនព្រមយកតាមទៀត គេខកចិត្តក៏ត្រឡប់ទៅវិញទាំងហ្មួហ្មង ។

- ចាស៎អ្នកមីង! ថ្ងៃនេះ ខ្ញុំមិនមានណាត់ជាមួយលោណារ៉ាត់នោះ ឯណា! ធ្វើម៉េចនឹងខ្ញុំដឹងកើតថា លោកមកអង្គុយចាំខ្ញុំនៅទីនេះ ?

- ឯងមិនបានណាត់ តែមីងណាត់! ហើយមីងក៏បានប្រាប់អោយ ឯងនៅផ្ទះ ។

CHANBOKEO.COM

- ពុទ្ធោមីង! ខ្ញុំមានច្បាប់មកលេងស្រុកខ្មែរតែបីអាទិត្យទេ អោយ ខ្ញុំមកអង្គុយសំកុកនៅផ្ទះ ឯកកចាំមើលផ្លូវភ្ញៀវមកលេងម៉េចនឹង កើត ? បំណងរបស់ខ្ញុំដែលមកលេងស្រុកខ្មែរ គឺដើរលេង មិន មែនមកធ្វើកុកចាំបបក់ត្រីទេ ។

- យើ! មាត់បានណាស់!

ដារីញាក់មុខ ដើរចេញធ្វើមិនដឹង ។ ស្រស់ឆោមក៏ដើរឡើង ជណ្តើរតាមក្រោយ ។ស្រាប់តែ អ្នកស្រីពិសីស្រដីថា ៖

- នាងក៏អញ្ចឹងដែរ! ផ្ទះមានម្ចាស់ មានវិន័យ មិនមែនជាផ្ទះ សំណាក់សណ្ឋាគារដែលនាងអាចដើរហើរចេញចូលម៉ាសេរីបានទេ! នាងត្រូវរៀនខ្លាចចិត្តម្ចាស់ផ្ទះខ្លះផង ។ កាលបើគេប្រដៅកូនចៅ របស់គេ ចូរនាងកុំជួយពន្យុះអោយគេប្រព្រឹត្តឆ្គើនចិត្តមនុស្សចាស់ អោយសោះ ។

ស្រស់ឆោមភ្ញាក់ព្រើតដែលឮសំដីម្ចាស់ផ្ទះដូច្នោះ ។ នាងនៅ ស្ងៀមមួយស្របក់ មិនឃើញអ្នកស្រីពិសីនិយាយអ្វីទៀត ក៏រត់ ឡើងតាមក្រោយដារីចូលបន្ទប់ទៅ ។

នៅសណ្ឋាគារមួយ នាមាត់ទន្លេ ជិតមុខវាំង...

ស្រស់ឆោមអូសវ៉ាលីសដើរចូលទៅកន្លែងទទួលភ្ញៀវ ។ ដារី ដើរតាមពីក្រោយមុខស្អុយប៉ែ ៖

- កុំធ្វើអញ្ចឹងមើល៍ ស្រស់ឆោម! ឯងមកនៅសណ្ឋាគារតែម្នាក់ ឯង មិនមានសុវត្ថិភាពទេ (ដារីនិយាយ)

ស្រស់ឆោមគ្រវីក្បាល ហើយឆ្លើយថា ៖

- នៅផ្ទះឯង ក៏មិនមានសុវត្ថិភាពអីដែរ ព្រោះមានយក្ខណីយេរ ច្រត់ចង្កេះបញ្ចេញចង្កូមដាក់ខ្ញុំព្រឹកល្ងាច ឃើញហើយតក់ស្លុត គេងមិនលក់ទេ ខ្ញុំ! សុខចិត្តមកនៅសណ្ឋាគារចុះ ស្ងប់ចិត្តហើយ មានសេរីភាពផង ។ បើឯងព្រួយពីសុវត្ថិភាពរបស់ខ្ញុំ ឯងមកគេង កំដរខ្ញុំទីនេះមក ដើម្បីអោយបានជាគ្នា ។

កំពុងតែឈរចុះឈ្មោះ ស្រាប់តែអ្នកទាំងពីរឃើញដារិនដើរ ចុះជណ្តើរមក ៖

- បងដារិន ?

ទាំងពីរនាក់ខមានឡើងព្រមគ្នា ។ ដារីរត់ត្រុយទៅចាប់ដៃបង ប្រុសសួរ ៖

- ហេតុអ្វីបានជាបងមកនៅទីនេះទៅវិញ ?

- គឺបងមកជួលបន្ទប់សំណាក់នោះអី ?

CHANBOKEO.COM

- ពីអង្កាល់ ?
- អំបាញ់មិញហ្នឹង!
- អូហ៍! សង្ស័យតែបងត្រូវនាំបងអ្នកស្រីពិសីហើយ...
- មិនមែនទេ! បងធុញសុផានីទេតើហ៍!
- អញ្ចឹងទេហ៍ បង ?
- មែនហើយ! ហើយចុះអ្នកទាំងពីរវិញនោះ ?
- ក៏មានហេតុផលស្រដៀងគ្នាហ្នឹង ណា៎បង!
- បើដូច្នោះ អ្នកទាំងពីរនៅស្នាក់ទីនេះហើយ បានជាគ្នានឹងបង មិនសូវអផ្សុកផង ។

ស្រស់ឆោមលើកដៃមើលនាឡិកា រួចនិយាយថា ៖

- នេះម៉ោង១០យប់ទៅហើយ មើលទៅសិលាគេនៅលេងភ្លេង ឬទេហ្ន៎ ?
- សិលាមិនទាន់មកធ្វើការទេ ព្រោះគេមិនទាន់អាចឈរស្ដាយ ហ្គីតាយូរបាន ។ គេនៅផ្ទះនៅឡើយទេ ។ ឆោមចង់ទៅលេងគេ មែនទេ ? (ដាវីឌនិយាយ)
- ចា៎សមែនហើយ! ប៉ុន្តែយប់ជ្រៅបន្តិចហើយ ទៅលេងដូចជា មិនសមរម្យទេនឹង ?
- តែយើងជាអនិកជន ដេកថ្ងៃដើរយប់ ព្រោះយើងផ្លាស់ប្ដូរខ្លួន តាមម៉ោងពិភពលោកមិនទាន់ ប្រហែលជាគេមិនប្រកាន់យើងទេ
នឹង ? (ដាវីឌតប)
- អឺហ៍ ពេលនេះដាវីគិតថា បងដាវីឌរសើបជើងចង់ទៅផ្ទះនោះ ជាងឆោមទៅទៀត ព្រោះមានម្ចាស់បេះដូងនៅរង់ចាំ...!

ដាវីឌញញឹម ឆ្លើយវិញថា ៖

- បើនឹងហើយ កុំជាន់កែង តិចពិបាកបងនឹកគេកាន់តែខ្លាំង!

ស្រីៗទាំងពីរក៏ចំអន់ដាវីឌរហូតទាល់តែក្រហមមុខអាំងនិយាយ លែងចេញតែម្ដង ។

នៅមាត់ទន្លេ...

អ្នកទាំងបីដើរយឺតៗ ស្រូបយកអាកាសមាត់ទន្លេផង ជជែកគ្នា ផង ។ ស្រស់ឆោមនិយាយមុនគេ ៖

- គិតទៅ ក្នុងចំណោមបីនាក់យើងនេះ ខ្ញុំដូចជាចង្អៀតក្នុងចិត្ត ជាងគេ ព្រោះខ្ញុំគ្មានបងប្អូនសាច់ញាតិនៅស្រុកខ្មែរសោះ ។ ពេល មកដល់ស្រុកខ្មែរ និយាយខ្មែរហើយ

CHANBOKEO.COM

ក៏នៅតែមានអារម្មណ៍ថាខ្លួន នៅឆ្ងាយពីស្រុកដដែល... ព្រោះខ្ញុំគិតអ្វីនិយាយអ្វីមិនដូចខ្មែរទូទៅនៅទីនេះ អ្វីបន្តិចសោះ ។

- ខុសហើយឆោម! ខ្ញុំទេដែលចង្អៀតចិត្តជាងគេ ព្រោះអីគ្រាន់តែ មកដល់ភ្លាមមានគេកៀបយកសេរីភាពរបស់ខ្ញុំអស់រលីងតែម្តង ។ នេះខ្ញុំអាយុ២៦ឆ្នាំហើយ ប៉ុន្តែអ្នកផ្ទះវិញគេកៀបអោយខ្ញុំក្លាយជា កុមារីដែលមានម្តាយត្រួតត្រាឃុំគ្រងព្រឹកល្ងាចមិនអាចគិតអ្វីធ្វើអ្វី ដោយសេរីដូចខ្លួនធ្លាប់ធ្វើនៅអាមេរិកទេ ។ ថ្វីបើខ្ញុំមានការសិក្សា ខ្ពស់មានការងារជាគ្រូគេទៅហើយក្តី ក៏អ្នកផ្ទះស្រុកខ្មែរមិនព្រមអនុញ្ញាតអោយខ្ញុំធ្វើជាម្ចាស់ជីវិតរបស់ខ្លួនដែរ ។ ម៉្លេះៗ គេខិតខំគូរគម្រោងជីវិតអោយខ្ញុំដើរតាមគន្លងដែលគេគូរនោះជានិច្ច ។ លុះខ្ញុំប្រឹងរើបម្រះរកសេរីនិងជីវិតដែលជារបស់ខ្លួនឯង គេថាខ្ញុំព្រហើន មិនស្តាប់ចាស់រហូតដល់មើលមុខគ្នាសឹងលែងចំទៅហើយ ។

- នរណាទៅពិបាកជាងខ្ញុំនោះ ? (ដាវិឌនិយាយ) ជាប្រុស មិនសូវហ៊ាននិយាយលើសខ្វះជាមួយនរណាក្នុងផ្ទះទេ គឺប្រឹងទប់ជានិច្ច មិនតបត ទោះបីខុសក្តីត្រូវក្តី ។ អ្នកទាំងពីរសំណាងហើយដែល សង្សាររបស់អ្នកទាំងពីរនៅអាមេរិកមិនបាច់ពិបាកគេងគិតរក មធ្យោបាយការពារ ។ ចំណែកខ្ញុំ... ខ្ញុំព្រួយបារម្ភជាងគេ ព្រោះអីសង្សារខ្ញុំនៅស្រុកខ្មែរ ខ្លាចនាងត្រូវទទួលរងគ្រោះពីសុផានីនិងម្តាយចុងរបស់ខ្ញុំដោយការចរចៃអាននិន្ទា ព្រោះខ្ញុំមិនព្រមទទួល សំណើធ្វើជាគូគ្រងរបស់សុផានីដើម្បីអោយនាងបានទៅរស់នៅ អាមេរិក ។

- អូហ៍ បងដាវិឌ មកស្រុកខ្មែរមិនទាន់ម៉ាអាទិត្យផង មានសង្សារ ទៅហើយ ? នេះបងយល់ចិត្តគ្នាហើយមែនទេ ? (ដាវីឌទាន)

មាណពងក់ក្បាល ៖

- មែនហើយ! បងគិតថា យើងយល់ចិត្តគ្នាទៅវិញទៅមកយ៉ាង ច្បាស់លាស់ហើយ ។

- ហើយចុះបងមានប្រាប់រឿងរបស់បង ឲ្យនាងដឹងហើយឬនៅ ?

- នៅទេ! មិនទាន់មានឱកាស! ប៉ុន្តែប្រហែលប្រាប់នាងស្អែកៗ នេះហើយ ។

ភ្លាមនោះ ស្រស់ឆោមនិយាយថា ៖

- បងដាវិឌឆាប់ប្រាប់គេទៅ កុំអោយគេយល់ច្រឡំថាបងលាក់ នឹងគេនោះគេនឹងខឹងស្អប់បងណា៎! ។

CHANBOKEO.COM

- អឺ! បងដឹងហើយ ។ អរគុណណាស់ ប្អូនដ៏ល្អទាំងពីររបស់បង ដែលជួយលើកទឹកចិត្តបងរហូតមក...!

ដាវីនិងស្រស់ឆោមញញឹមឡើងយ៉ាងបំព្រង ។

- សូមជូនពរអោយបងបានជួបនឹងការសំរេចដូចប្រាថ្នា ។

ព្រឹកស្អែកឡើង...

ធីតាចេញពីរៀនមុនម៉ោង ព្រោះមានគ្រូម្នាក់ឈឺមិនបានមក បង្រៀន ។ នារីក៏នឹកភ្នកចង់ចូលផ្សារទៅលេងម្តាយដែលនៅលក់ ដូរឥវ៉ាន់ផង ហើយចង់ទិញផ្លែឈើផ្ញើឪពុកផង ។ ទៅដល់ផ្សារ នាងនៅសំណេះសំណាលជាមួយម្តាយមួយស្របក់ ក៏ចុះដណ្តើរមក វិញ ដើម្បីទៅរកទិញផ្លែឈើ ស្រាប់តែប្រទះនឹងមនុស្សម្នាក់កំពុង ធ្វើកិរិយាអើតអើមរកដោះខ្សែកកុមារីតូចមួយ អាយុប្រហែលប្រាំឆ្នាំ កំពុងតោងដៃម្តាយដែលឈរបែរខ្នងរើសផ្លែឈើ ។

- នែ៎! មកធ្វើស្អីកូនក្មេងហ្នឹង ? (ធីតាស្រែកឡើង)

ស្រីនោះភ្ញាក់ព្រើត កញ្ឆក់ខ្សែករឹង ពីនាងតូចនោះ បណ្តាល អោយកុមារីដួលផ្ងារពោះច្រងាប់ច្រងិលទៅដី ស្រែកយំវ៉ាឡើង ។ ស្រីចោរក៏រត់គេចទៅម្ខាងយ៉ាងរហ័ស ។ ស្ត្រីរូបស្អាតដែលជាម្តាយ ក្រឡេកឃើញចោរនោះភ្លាម ក៏ព្រលែងដៃកូនស្រី ហើយរត់ស្រវា ចាប់ចោរ ចាប់ផុតៗពីរបីសាទើបចាប់បាន ក៏បង្កជាការប្រវា ប្រវាយគ្នាដណ្តើមខ្សែកមកវិញ រហូតដល់ថ្នល់ដែលមានចរាចរ ខ្វែងខ្វាត់ ។ ម៉ូតូមួយហោះរឹងពីខាងណាមិនដឹងមកបុកអ្នកទាំងពីរ ដួលគ្រាំងទៅម្ខាង ទទួលមានរថយន្តមួយមកពីក្រោយចាប់ហ្វ្រាំង មិនទាន់ ក៏កៀរអ្នកទាំងពីរអូសពីរបីម៉ែត្រទៀត បង្កជាគ្រោះថ្នាក់ ផ្អើលពេញផ្សារតែម្តង ។

ធីតាស្រវាលើកកូនតូចនោះពឡើង លួងលោមកុំអោយនាងភិត ភ័យ ៖

- កុំយំអី នាងតូច! មិនអីទេណា៎! មិនអីទេ....!

តែនាងតូចនៅតែភិតភ័យដដែល ព្រោះឃើញម្តាយនាងត្រូវ របួសដួលនៅលើដីហូរឈាម ។ ភ្លាមនោះ កងប៉ូលីសក៏បានមក ដល់ធ្វើអន្តរាគមន៍ភ្លាមៗដែរ...

នៅក្នុងមន្ទីរពេទ្យ...

ធីតាអង្គុយអោបកូនតូចនោះ រង់ចាំនៅខាងក្រៅមាត់ទ្វាររង់ចាំ ការពិនិត្យរបស់ពេទ្យ ដើម្បីអោយដឹងថា ម្តាយនាងតូចមានស្ថាន ភាពអាការៈយ៉ាងម៉េច ។ ម្យ៉ាង នាងក៏នៅរង់ចាំមើល

CHANBOKEO.COM

ក្រែងមាន បងប្អូនសាច់ញាតិណាម្នាក់មកមើលអ្នកជំងឺ នឹងអាលមកទទួល យកនាងតូចទៅវិញ ។
ដោយរង់ចាំយូរពេក ធីតាក៏ដើរទៅសួរ
នាយប៉ូលីសពីរបីនាក់ដែលនៅចាំយកពត៌មានពីជនរងគ្រោះ ថា ៖

- ពូ! ប៉ូលីសទាក់ទងទៅក្រុមគ្រួសារសាច់ញាតិបានហើយនៅ ?
- នៅទេនាង!
- អូហ៍ ហេតុអ្វីក៏ដូច្នោះ ?
- ព្រោះពេលដែលម្តាយរបស់នាងតូចនោះដួលនៅលើថ្នល់ មានគេ ឆក់កាបូបរបស់នាងបាត់
ទើបយើងគ្មានអត្តសញ្ញាណឬលេខទូរសព្ទ័ អ្វីសំរាប់ទាក់ទងទៅគ្រួសាររបស់នាងនោះអី ។

ធីតាសម្លឹងមុខកុមារីតូចដែលនៅក្នុងដៃនាង រួចហើយបែរទៅ នាយប៉ូលីសសួរថា ៖

- ហើយចុះក្មេងតូចនេះ អោយខ្ញុំយកទៅណា ?
- មើលទៅ ប្រហែលជានាងត្រូវជួយយកអាសារមួយពេលហើយ
ទំរាំប៉ូលីសរកបងប្អូនរបស់ស្ត្រីរងគ្រោះឃើញ ។ នាងយកគេទៅ ផ្ទះសិនទៅ ។ យ៉ាងណាៗ
ចាំប៉ូលីសទាក់ទងទៅ ។
- ហើយចុះបើប៉ូលីសរកមិនឃើញរហូតទៅនោះ ?
- នោះអាស្រ័យនៅលើចិត្តសទ្ធារបស់ក្មួយស្រីហើយថាតើត្រូវជួយ សង្គ្រោះកុមារីនេះរហូត
ឬក៏ប្រគល់អោយទៅមជ្ឈមណ្ឌលកុមារ កំព្រា ។

ធីតាជ្រួញចិញ្ចើម ព្រោះនាងមិនគិតថា ថ្ងៃនេះ នាងត្រូវមក
ទទួលបន្ទុកមនុស្សធម៌ដូច្នេះទេ ។ គ្រួសាររបស់នាងវាអត្តខាត់ ពីបាកនឹងរស់ទៅហើយ
ហើយម្នាក់ៗរវល់ស្ទើរតែគ្មានពេលឃើញ មុខគ្នា
តើមានពេលឯណានឹងមើលថែរក្សាកុមារីតូចមួយនេះ ?

គិតចុះគិតឡើង នាងក៏ដាច់ចិត្តនាំកុមារីទៅផ្ទះ ព្រោះឃ្លាន បាយផង
ណាមួយខ្លាចឪពុកនាងបារម្ភចាំមើលផ្លូវនាងផង ណាមួយ
ត្រូវត្រឡប់ទៅសាលាវិញអោយទាន់ថ្នាក់ប្រលងផង ។ នាងក៏ស្រដី ទៅកាន់នាយប៉ូលីសនោះថា
៖

- ពូ! ខ្ញុំយកនាងតូចទៅផ្ទះខ្ញុំសិនហើយ ។ នេះអាសយដ្ឋានរបស់ ខ្ញុំ ។ បើមានការអ្វី
សូមទៅរកនាងតូចនៅផ្ទះខ្ញុំចុះ ។

CHANBOKEO.COM

- អឺ! អរគុណណាស់នាង! អូហ៎នែ៎! នេះខ្សែករបស់នាងតូច ដែលម្ដាយក្ដាប់ជាប់នៅនឹងដៃ ពេលនាងដួលបោកទៅនឹងថ្នល់ ។ នាងរក្សាអោយកុមារីនេះផង ក្រែងលោក្រុមគ្រួសារអាចចំណាំគ្នា បានដោយសារខ្សែកមួយនេះ ។

- ចា៎ស! ពូ!

ធីតាលូកដៃទទួលយកខ្សែកនោះមក ឃើញដាច់ជាពីរ មាន បន្ដោងប្រអប់ជារាងបេះដូង ។ មាណវីក៏ខ្ទប់បន្ដោងនោះទុកហើយ ក៏លើកពកុមារី ឡើងម៉ូតូឌុបចេញទៅ ។

នៅផ្ទះធីតា...

ថ្ងៃនោះ គ្មាននរណានៅផ្ទះទេ ក្រៅពីឪពុករបស់ធិតា ។

អ៊ំសាឡាដមានការភ្ញាក់ផ្អើលណាស់ ដែលឃើញធីតាពក្មេងមក ផ្ទះ ក៏មានប្រសាសន៍ថា ៖

- ជាការប្រសើរហើយដែលកូនប្រព្រឹត្តកិរិយាមនុស្សធម៌ ជួយយក អាសារក្មេងរងគ្រោះ ។ សង្ឃឹមថា ម្ដាយរបស់កុមារីនោះបានសុខ សប្បាយ ហើយសូមអោយក្រុមគ្រួសារមកទទួលយកកូនចៅរបស់ គេវិញឆាប់ ។

ដោយសាររវល់នឹងរឿងគ្រោះថ្នាក់ ព្រមទាំងជំពាក់នឹងរឿង ក្មេងតូចដែលនាងសង្គ្រោះមក ធីតាក៏ជាប់រវល់ពេញមួយថ្ងៃ រត់ ទៅសាលាបានមួយភ្លែត ក៏ត្រឡប់មកផ្ទះវិញ ។ ចំណែកនាងតូច វិញក៏ឃើញតែធ្វើមុខស្រងូត ព្រោះនឹកម្ដាយរបស់នាង ។ ម្យ៉ាង ទៀត កុមារីមិនដែលស្គាល់ក្រុមគ្រួសាររបស់ធីតាផង ធ្វើអោយនាង តូចខ្លាចចិត្ត មិនហ៊ានយំ មិនហ៊ានស្រដីនិយាយអ្វីទេ ឃើញតែ អង្គុយឈ្ងោកមុខធ្វើស្ងៀមស្ងាត់ ។ មិនតែប៉ុណ្ណោះ កុមារីក៏គ្រវី ក្បាលមិនព្រមទទួលទានចំណីអាហារអ្វីឡើយ ។

នៅក្នុងផ្ទះ ធីតាអង្គុយមើលមុខនាងតូចភ្លៀកៗ មិនអស់ចិត្ត ព្រោះមិនដឹងថា នាងត្រូវធ្វើអ្វីទៀត ដើម្បីអោយនាងតូចបរិភោគ បាយ ។ ភ្លាមនោះ ធីតានឹកទៅដល់ខ្សែករបស់កុមារី ក៏លូកស្រវា យកពីហោប៉ៅសំពៀតរៀនរបស់នាងចេញមកមើល ។ បន្ទាប់មក នាងក៏កេះបើកបន្ដោងប្រអប់នោះ ក្រែងឃើញមានរូបថតរបស់ ឪពុកម្ដាយនាងតូច ឬសញ្ញាសំគាល់គ្រួសារអ្វីមួយ ។ ភ្លាមនោះ ស្រាប់តែនាងប្រទះនឹងរូបថតបុរសនារីពីរនាក់ យ៉ាងស្រស់ស្អាត ។ រូបថតនារីគឺជារូបស្ត្រីរងគ្រោះនោះតែម្ដង ។ ឯរូបបុរសវិញ...

ធីតាបើកភ្នែកធំៗ ដោយការភ្ញាក់ផ្អើល ។ បេះដូងរបស់នាងក៏

CHANBOKEO.COM

រណ្តំឱបខាក់ៗឡើងយ៉ាងខ្លាំង ស្ទើរតែធ្លាយទ្រូងមកក្រៅ ។ មាណវី
លាន់មាត់ខ្សឹបៗតែម្នាក់ឯង ៖

- បងដាវិង ? ហេតុអ្វីក៏បុរសនៅក្នុងរូបនេះ មានមុខមាត់ដូចបង ដាវិងម្ល៉េះ ?

ភ្លាមនោះ ស្រាប់តែធីតានឹកឃើញទៅដល់ថ្ងៃមុន ពេលដាវិង នាំនាងត្រឡប់ពីបឹងឈូកវិញ មកដល់មុំចុងស្ពានជ្រោយចង្វារ ក៏ ប្រទះនឹងនារីរូបស្រស់ម្នាក់បើករថយន្តប្រឆាបគ្នានឹងដាវិង ហើយ បែរសម្លឹងមុខគ្នាទៅវិញទៅមក រួចហើយក៏បររថយន្តគេចគ្នាចេញ ទៅ ។
ធីតាគិតក្នុងចិត្តតែម្នាក់ឯង ៖

- តើបងដាវិងជាស្វាមីរបស់ស្ត្រីសោភានោះមែនទេ ? បងជាឪពុក
របស់កុមារីម្នាក់នោះមែនទេ ?

គិតចុះគិតឡើង ធីតាហាក់ដូចជាចង់ស្រក់ទឹកភ្នែកសាជាថ្មី ទៀតហើយ ៖

- ព្រះអើយ! ហេតុអ្វីក៏ជីវិតខ្ញុំត្រូវមកប្រទះនឹងភាពសាំញ៉ាំដូច្នេះ ផង ?
ហេតុអ្វីក៏ខ្ញុំមកមានចំណងចិត្តជាមួយបុរស ដែលមានគូ ស្រកររួចទៅហើយទៅវិញ ? ឱ!
ធីតាអើយ !

ធីតាទាញធូបបីសរសៃលើកប្រណម្យថ្វាយបង្គំព្រះ បន់ស្រន់ តែម្នាក់ឯងថា ៖

- ខ្ញុំម្ចាស់សូមអភ័យទោស! សូមកុំអោយខ្ញុំម្ចាស់ទទួលបាបដោយ
ការបំបែកបំបាក់ក្រុមគ្រួសាររបស់គេ ។ បើសិនជាការទទួលបន្ទុក រក្សាកុមារីតូចម្នាក់នោះ
ជាការលោះបាបដែលខ្ញុំម្ចាស់ជាចំណែកទីបី នៅក្នុងគ្រួសារនេះ
សូមព្រះអង្គជួយណែនាំផ្លូវខ្ញុំម្ចាស់ផង! !

ធីតាញាប់ញ័រក្នុងចិត្តតែម្នាក់ឯង នឹកខ្មាសខ្លួនផង នឹកស្ដាយ ក្រោយផង ដែលនាងធ្លាក់ខ្លួនជំពាក់ចិត្តចងស្នេហ៍ជាមួយដាវិង ។ ពេលនេះ នាងមានអារម្មណ៍ច្របូកច្របល់ណាស់ គិតមិនចេញទេ ថានាងត្រូវធ្វើយ៉ាងណា ។ ធីតាមានសាប់រសល់ក្នុងចិត្ត ចង់តែ រត់ ទៅលោតទឹកទន្លេលាងជំរះមន្ទិលក្នុងខ្លួន ប៉ុន្តែក៏ធ្វើមិនបាន ។ តើ នាងត្រូវសំរេចចិត្តយ៉ាងណាវិញ ? នេះ ធីតាទើបតែស្គាល់ដាវិង មិនបានប៉ុន្មានថ្ងៃផង ប៉ុន្តែ ហេតុអ្វីបានជាជីវិតរបស់នាងបែរជាមក មានចំណងជំពាក់ជំពិនជាមួយដាវិងដកចិត្តមិនរួចដូច្នេះ ? ទឹក ភ្នែកពីរដំណក់ក៏ហូរចាកនេត្រា មកប្រឡៀងថ្ពាល់ដ៏រលោងរបស់នារី
យើង យ៉ាងស្ងៀមស្ងាត់ ។

CHANBOKEO.COM

ភ្លាមនោះ នាងតូចយកដៃអង្អែលធីតា និយាយថា ៖
- មីង! វ៉ាន់ឈឺពោះ!
ធីតាភ្ញាក់ព្រើត យកដៃជូតទឹកភ្នែក សួរថា ៖
- នាងតូចឃ្លានបាយមែនទេ?
- ចា៎ស!
ធីតាក៏ចូលទៅដួសបាយសម្រួបទឹកឆា រួចហើយក៏លើកនាងតូច អោយអង្គុយលើភ្លៅ បម្រុងបញ្ចុក ស្រាប់តែកុមារីឧទានថា ៖
- អែយ៉ូយ!
ធីតាភ្ញាក់ព្រើត ចាប់លាត់អាវកុមារីឡើង ឃើញស្នាមជាំនិង ស្នាមកន្ទួលដោយមួលក្តិច ក្រោមក្លៀក ខ្នង និងកំប៉េះគូទ ជាច្រើន កន្លែង ។
- ពុទ្ធោ នាងតូច! នរណាធ្វើបាបនាងដល់ម្លឹង?
- គឺ... ម៉ាក់ ម៉ាក់វ៉ៃអូនវ៉ាន់...
- ហេតុម៉េចបានម៉ាក់វ៉ៃអូនវ៉ាន់?
- មកពីវ៉ាន់យំចង់ទៅរកប៉ា!
- ពុទ្ធោ នាងតូច!
ធីតាអាណិតនាងតូចណាស់ ក៏ទាញប្រេងកូឡាមកលាបអោយ ។
រំពេចនោះ ធីតាឮសម្លេងឪពុកនាងមានប្រសាសន៍ឡើង នៅឯ ខាងមុខផ្ទះ ថា ៖
- មក៎! ចូលលេងក្មួយ!
ធីតាចោលភ្នែកទៅក៏ប្រទះនឹងដារិទដែលជិះម៉ូតូឌុបមកដល់ ។ គ្រាន់តែក្រឡេកឃើញមុខដារិទភ្លាម នាងតូចនោះក៏ញញឹមឡើង ហើយរត់យ៉ាងលឿនសំដៅនរៈ ហើយស្រវា អោបកដារិទ ៖
- ប៉ា!
ដារិទភ្ញាក់ក្រញាងដែលឃើញវត្តមានរបស់កុមារី នៅក្នុងផ្ទះ របស់អ៊ំសាឡាង ។ គេលូកដៃត្រកងទទួលកូនស្រីពេញរង្វង់ដៃ ៖
- ដាវ៉ាន់! ហេតុអ្វីក៏កូនមកដល់ទីនេះ?
ដាវ៉ាន់មិនឆ្លើយទេ បែរជាស្រវាអោបកដារិទ ហើយទ្រហោយំ

CHANBOKEO.COM

តែម្តង ធ្វើអោយអ៊ីសាឡាងភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ដាវីឌយកដៃ ទទះខ្នងកុមារីបន្តើរៗ ដើម្បីលួងលោមនាងតូច ។ បន្តិចមក គេក៏ បែរមើលធីតា ឃើញនាងឈរធ្មឹង ធ្វើមុខស្ងួត មិននិយាយស្តីមិន ញញឹម មិនដឹងថានាងកំពុងគិតអ្វីទេ ។ ដាវីឌក៏ដើរទៅជិតនាង ហើយស្រដីថា ៖

- ដា! អោយបងសុំនិយាយអ្វីជាមួយអូនបន្តិចបានទេ?

ធីតាឈ្ងោកមុខនៅស្ងៀម ។ អ៊ីសាឡាង ហាក់ដូចយល់ស្ថាន ការណ៍ ក៏មានប្រសាសន៍ថា ៖

- បើកូនមានអ្វីត្រូវបំភ្លឺគ្នាទៅវិញទៅមក កូននិយាយគ្នាទៅ ។ ប៉ា ទៅថ្វាយបង្គំព្រះម៉ាភ្លែត ។ បន្តិចទៀត ចាំយើងនិយាយគ្នា ។

ពោលចប់ អ៊ីសាលាងក៏ដើរចូលទៅក្នុងផ្ទះបាត់ទៅ ។ ដាវីឌ ស្រវាចាប់កាន់ដៃធីតា ប៉ុន្តែ នាងរលាស់ចេញយ៉ាងលឿន ហើយក៏ ឈានថយក្រោយពីរជំហាន មិនអោយបុរសប៉ះនាងទេ ។

- ដា! កុំអាលយល់ច្រឡំពីបងអី នាំតែសៅហ្មងក្នុងចិត្ត! បងអាច ពន្យល់អ្វីៗអោយអូនស្រឡះអារម្មណ៍បាន ដើម្បីរក្សាពេលវេលា របស់យើងអោយមានតម្លៃចំពោះគ្នាជានិច្ច កុំឲ្យភាពសង្ស័យ និង ការមន្ទិលនាំភាពល្អក់កករ ដល់ចំណងសម្ពន្ធ័រវាងយើងទាំងពីរឲ្យ សោះណា៎អូន ។

ធីតាលេបទឹកមាត់ក្អឹក រំលត់ភាពញាប់ញ័រនៅក្នុងចិត្ត ហើយ នៅស្ងៀមមិននិយាយស្តី ។ ដាវីឌសម្លឹងមុខនារីមួយស្របក់ក៏មាន វាចាថា ៖

- អូនចង់សួរអ្វីពីបង សួរមកចុះ! បងរង់ចាំឆ្លើយតបអូនវិញគ្រប់ សំនួរដែលអូនចង់ដឹង!

ភ្លាមនោះ ធីតាសម្លឹងមុខនរ:សាជាថ្មី ហើយក៏ស្រដីថា ៖

- បងដាវីឌ មិនចង់ទៅមើលអាការ:ម្តាយរបស់នាងតូចទេ?

ដាវីឌព្ញុងច្មោះក៏សួរថា ៖

- ហើយចុះគេនៅឯណា?

- នៅមន្ទីរពេទ្យ... ពេលនេះ ប៉ូលីសកំពុងតាមស៊ើបរកសាច់ញាតិ របស់អ្នកជម្ងឺ ។

- អញ្ជឹង អូនជូនបងទៅបន្តិចណា៎!

- អត់ទេ! ដាចង់ត្រឡប់ទៅសាលាវិញ ។

- នេះ រសៀលម៉ោងជាងបួនហើយណា៎ ដា! ការពិតអូនកំពុងចង់ គេចពីបង មែនទេ?

- គឺ ព្រោះដាមិនចង់រំខានកិច្ចការនៅក្នុងគ្រួសាររបស់បង!

CHANBOKEO.COM

- ហើយចុះអូនដាមិនចង់តាមដានទេ ថាបងនិងម៉ាក់របស់ដារ៉ាន់ មានចំណងជីវិតនឹងគ្នាយ៉ាងណាទេ ហ្ហែស ?

ធីតានៅស្ងៀម ។ ដាវិដក៏អូសដៃនាងរឹងតែម្តង ៖

- តោះ! កុំប្រកែកច្រើន! ដាជូនបងទៅពេទ្យណា៎! បងនាំអោយអូនបានឃើញបានដឹងអ្វីៗដោយផ្ទាល់ភ្នែក ផ្ទាល់ត្រចៀកខ្លួនឯង ។

ភ្លាមនោះ ដាវិដក៏ទូរសព្ទ័ទាក់ទង ៖

- សូមពីងបន្តិចបានទេ ? ខ្ញុំត្រូវការរថយន្តឈ្នួលមួយប្រញាប់!

ដាវិដអោបកូនផង និយាយទូរសព្ទ័ផង កាន់ដៃធីតាជាប់ផង មិនអោយនាងរត់គេចពីនាយទេ ។ ធីតារលាស់ដៃ ស្រដីថា ៖

- លែងដៃខ្ញុំសិនទៅ..! នេះផ្ទះរបស់ខ្ញុំណា៎! ខ្ញុំមិនរត់ទៅណាទេ!

ប៉ុន្តែដាវិដធ្វើមិនដឹង ។ គេឈរកាន់ដៃនាងជាប់ រង់ចាំរហូតដល់ពេលរថយន្តឈ្នួលមួយបានលូនមកដល់មុខផ្ទះ ។

បន្តិចមក រថយន្តនោះក៏នាំអ្នកទាំងបីមកដល់មន្ទីរពេទ្យ ។

នៅលើគ្រែ...

អ្នកជំងឺស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរ បាត់ស្មារតីគេងស្តូកស្តឹង នៅឡើយ ។ ដាវិដសួរលោកគ្រូពេទ្យថា ៖

- តើមានសង្ឃឹមយ៉ាងណាទេ លោកគ្រូពេទ្យ ?

លោកគ្រូពេទ្យមានប្រសាសន៍តបថា ៖

- ប្រហែលជា៥០ភាគរយ...!

ដាវិដធ្វើមុខស្លូត សម្លឹងមុខអ្នកជម្ងឺ ហើយសម្លឹងមុខកូន ។ លោកគ្រូពេទ្យក៏ដើរចេញទៅទុកអោយអ្នកទាំងបីឈរស្ងៀមស្ងាត់ សម្លឹងអ្នកជម្ងឺ ។ បន្តិចមក ដាវិដក៏ដើរទៅជិតលូកចាប់ម្រាមដៃ អ្នកជម្ងឺហើយស្រដីថា ៖

- ភិសម័យ! សូមអោយនាងបានដឹងស្មារតី ហើយជាសះស្បើយ ឆាប់ៗ កុំខាន!

ទោះបីជាយ៉ាងណា ក៏ភីសម័យនៅតែគេងស្តូកស្តឹងស្ងៀមស្ងាត់ ដដែល មិនកំរើកអ្វីឡើយ ។ ដាវិដបែរក្រោយឃើញធីតាឈរនៅ ស្ងៀមធ្វើមុខក្រៀមៗ ក៏ចាប់ដៃនាងអូសចេញទៅក្រៅហើយ ស្រដីថា ៖

CHANBOKEO.COM

- ដា! ចង់ស្ដាប់រឿងបងទេ?

និតាសម្លឹងមុខបុរសហើយឆ្លើយថា ៖

- តើមានប្រយោជន៍អ្វីទៅដែលខ្ញុំត្រូវដឹងរឿងរបស់បងនោះ?

- ម៉េចក៏ថាមិនមាន? គឺដើម្បីអោយអូនមានអារម្មណ៍ជ្រះស្រឡះ ថា ដាវិឌជាមនុស្សបែបណា? ហើយហេតុអ្វីក៏ដាវិឌមានជីវិត ជំពាក់ជំពិននឹងម៉ាក់ដាវ៉ាន់?

នីតានៅស្ងៀម លែងប្រកែកតទៅទៀត ។

- អង្គុយចុះមក! ចាំបងនិយាយអោយស្ដាប់!

ដាវិឌទាញដៃនីតាអោយអង្គុយចុះក្បែរនាយ ហើយចាប់ដៃ នាងមកកាន់ ៖

- ដា! បងត្រូវការកម្លាំងចិត្តពីអូន... ផ្ដល់ភាពកក់ក្ដៅដល់ដួងចិត្ត បងផងណា៎ អូនដា! រឿងបងវែងឆ្ងាយណាស់! បងពិតជាត្រូវ ការរូបអូនអោយមកឈរក្បែរបង ដើម្បីអោយបងមានកម្លាំងចិត្ត នឹងតស៊ូជាមួយជីវិតតទៅទៀត ។

ឮប្រយោគនោះ នីតាក៏ទទួលយករង្វង់ដៃរបស់បុរសដែល ត្រកងស្មានាងពីក្រោយ អោយនាងផ្ដេកកេសានៅលើទ្រូងរបស់គេ ក្បែរនាងតូចដាវ៉ាន់ ហាក់ដូចជាចង់អោយនារីស្ដាប់ចង្វាក់បេះដូង របស់គេរៀបរាប់នូវអ្វីៗទាំងឡាយក្នុងជីវិត ជូនដល់នីតាយើងជា ជំនួសពាក្យសំដីទាំងឡាយដូច្នោះឯង ។

CHANBOKEO.COM

*ooooooooooooooooo*

*oooooo*

*o*

# វគ្គទី៦
# វិបត្តិដួងចិត្ត

កាលពី៦ឆ្នាំមុន...

នៅរដ្ឋមិនីសូតា សហរដ្ឋអាមេរិក...

ដារិនបញ្ចប់បរិញ្ញាបត្រចេញធ្វើការបានជាងមួយឆ្នាំ ក៏នឹកភ្នក ចង់ទៅលេងឪពុករបស់គេ ដែលវិលត្រឡប់ទៅធ្វើការនៅស្រុកខ្មែរ ហើយបានរៀបការថ្មីនៅទីនោះ ។ រីឯម្ដាយរបស់គេ បានអនិច្ចកម្ម ទៅយូរឆ្នាំហើយ ។

នៅវាលយន្តហោះភ្នំពេញ...

លោកដាវុធនិងអ្នកស្រីពិសីបានមកទទួលស្វាគមន៍ដារិនយ៉ាង អឹកធិក ព្រោះ លោកមានមោទនភាពណាស់ ដែលដារិនរៀនចប់ ដោយមិនបាច់មានការដាស់តឿនពីមុខពីក្រោយ ។ លោកដាវុធនិង ភរិយាថ្មីបានចាត់ចែងពិធីជប់លៀងមួយយ៉ាងធំ ស្វាគមន៍ទទួល ដារិនដែលបានមកលេងស្រុកខ្មែរ ជាលើកដំបូង ។

នៅក្នុងរាត្រីជប់លៀងនោះ...

អ្នកស្រីពិសីដើរមកជិតដារិន ស្រដីថា ៖

- ដារិន! មីងចង់ណែនាំ អោយកូនស្គាល់មិត្តនារីខ្លះនៅភ្នំពេញ នេះ ជាកូនចៅអភិជន មានវណ្ណៈ មានពូជអំបូរល្អ ក្រៃងលោក្មួយ ពេញចិត្តនរណាម្នាក់ ។

CHANBOKEO.COM

ដាវិងនៅក្មេងហើយសង្ហា ទើបតែរៀនចប់មានការធ្វើ មាន ឪពុកធ្វើការជាមន្ត្រីជាតិមួយរូប ម្ល៉េះហើយ គេមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ល្មមអោយនារីភ្លូកទឹកភ្លូកដី ចោមរោមទាក់ទងសុំស្នេហ៍ ដាវិងគ្រប់គ្នា ។ ដែលសំខាន់ជាងគេបំផុតនោះ គឺមាណពយើងជាបុរសមានសញ្ជាតិអាមេរិក ។ តើនារីទៅណាមិនប៉ុនប៉ងលើរូបគេ ?

រាត្រីនោះ ដាវិងបានរាំលេងជាមួយនារីសោភាជាច្រើននាក់ ។ ដោយសារភាពរួសរាយរបស់គេសមនឹងភាពសង្ហារបស់គេផង ដាវិងបានទទួលការចាប់អារម្មណ៍យ៉ាងពិសេសពីនារីជាច្រើនរាប់មិន អស់ ។ អ្នកស្រីពិសីបានដើរមកជិតដាវិង កេះប្រាប់ថា ៖

- ក្នុងចំណោមនារីទាំងអស់នេះ ដាវិងអាចជ្រើសរើសមួយណាក៏ បានដែរ ព្រោះមីងបានសម្រាំងរួចហើយ មុននឹងអញ្ជើញគេមក ចូលរួមពិធីស្វាគមន៍របស់ក្មួយ ។

ដាវិងមិនបានចាប់ភ្លឹកទេ ថាហេតុអ្វីអ្នកស្រីពិសីមានសន្តានចិត្ត ទូលាយចំពោះនរៈម្ល៉េះ ចំពោះរឿងគូស្រករបស់នាយ ។ គេគិត ត្រឹមតែថា គាត់ជាភរិយាដ៏ល្អរបស់ឪពុកខ្លួនតែប៉ុណ្ណោះ ។

ថៃដន្យ ដាវិងពេញចិត្តនារីគ្រប់គ្នាទាំងអស់ ព្រោះមួយណាក៏ ស្រស់ស្អាតដែរ ។ ប៉ុន្មានថ្ងៃក្រោយមក គេក៏សំរេចចិត្តតាមការ បញ្ចុះបញ្ចូលរបស់អ្នកស្រីពិសីទទួលយកនារីម្នាក់ដើម្បីភ្ជាប់ពាក្យជា គូដណ្តឹងនៅអាទិត្យក្រោយ ។ នាងមានឈ្មោះថា ម៉ារ៉ែន ។

គេបានដើរលេងជាមួយម៉ារ៉ែនបានពីរបីថ្ងៃ ស្រាប់តែមានរឿង មួយផ្ទុះឡើង ។ លោកដាវុឌ ហៅដាវិងមកប្រាប់ថា ៖

- ដាវិង! ប៉ាសោកស្តាយណាស់ ដែលប៉ាមិនអាចអោយកូនរៀប ការជាមួយនាងម៉ារ៉ែនបានទេ ព្រោះឆន្ទៈនយោបាយរវាងឪពុក របស់នាង និងប៉ាមិនចុះសម្រុងនឹងគ្នា ។ ម្យ៉ាងទៀត កាលពីថ្ងៃមុន ខាងស្រីគេយល់ព្រមអោយប្រាក់យើងច្រើនម៉ឺនដុល្លារ ដើម្បី ចងដៃកូនពេលរៀបការ ។ ពេលនេះ គេដូរចិត្តហើយ ។ គេចង់ អោយប៉ាចាយលុយច្រើនម៉ឺនដុល្លារ ដើម្បីបំពាក់បណ្ណាការកូនស្រី របស់គេ អោយសមនឹងឋានៈវណ្ណៈគ្រួសាររបស់គេ ។ មីងពីសីរបស់ឯងខកចិត្តណាស់ ដែលនិយាយរឿងបណ្ណាការមិនត្រូវគ្នា ដូច្នេះ រឿងរបស់ឯងនឹងម៉ារ៉ែនត្រូវបញ្ចប់ត្រឹមនេះហើយ ។

CHANBOKEO.COM

ដារិនភ្ញាក់ក្រញាងដូចធ្លាក់ពីចុងឈើ ។ គេប្រឹងលេបទឹកមាត់ រំលត់ភាពរន្ធត់ក្នុងចិត្ត ។ តាំងពីថ្ងៃនោះមក ចាស់ៗក៏បំបែកមិន អោយគេជួបនារីមួយរូបនោះតទៅទៀត ។ មិនបានប៉ុន្មានថ្ងៃផង អ្នកស្រីពិសីក៏ណែនាំនារីផ្សេងទៀត អោយដារិន ។ ដោយការទើស ទាល់ក្នុងចិត្តផង ដោយការតប់ប្រមល់ផង ដោយអផ្សុកផង ដារិន ក៏យល់ព្រមទទួលនារីម្នាក់ទៀត ឈ្មោះ ភីណា ។ ពិធីភ្ជាប់ពាក្យក៏ ចាប់ផ្តើមឡើង ស្រាប់តែ...

- ភ្ជាប់ពាក្យមិនបានទេ!

បុរសសង្ហាម្នាក់ដើរចូលមកដល់ ចំកណ្តាលរង្វង់ភ្ញៀវកុះករ ទម្លាក់កាំភ្លើងខ្លីមួយលើថាសដែលទ្រផ្កាស្លា ហើយក៏ចាប់ដៃនាង ភីណាដើរចេញពីចំណោមភ្ញៀវដែលកំពុងភ្ញាក់ស្រឡាំងកាំង ។ មុន នឹងបោះជំហានចេញទៅ បុរសនោះបែរក្រោយស្រដីថា ៖

- នេះ! ខ្ញុំជូនកាំភ្លើងទៅដៃលោកមេបាហើយ! បើសិនចង់ធ្វើ ឃាតខ្ញុំ ក៏ធ្វើមកចុះ ព្រោះខ្ញុំស្មគ្រ័ខ្លួនមកស្លាប់ថ្ងៃនេះហើយ គឺ ស្លាប់ដើម្បីភីណាដែលខ្ញុំស្រឡាញ់ ហើយដែលឪពុកម្តាយកំពុង ពង្រាត់នាងពីខ្ញុំទៅ ព្រោះរូបខ្ញុំក្រ គ្មានប្រាក់ធ្ងន់ដាក់ដៃជាបណ្ណាការ គ្មានសញ្ជាតិអាមេរិក សំរាប់ធានាអោយកូនស្រីរបស់លោកទៅនៅ បរទេសទេ ។ ខ្ញុំគ្មានអ្វីជាខន្ធស្លាសំរាប់ជូនលោកមេបា ដើម្បីរៀប ការនឹងភីណាទេ គឺមានតែជីវិតប៉ុណ្ណោះ ។ បើសិនលោកមេបា ត្រូវការ ខ្ញុំសូមប្រគល់ជីវិតជូលលោកដោយរីករាយបំផុត ។

ថាហើយ គេចាប់ដៃភីណាលុតជង្គង់សំពះចាស់ៗ ដែលកំពុង ភ្ញាក់ផ្អើលភាំងស្រឡាំងកាំងគ្រប់គ្នា ។ ដារិនសង្កេតឃើញថាភីណា ក៏ញញឹមទទួលបុរសសង្ហាម្នាក់នោះ ដោយសេចក្តីពេញចិត្តដូចគ្នា ដែរ ។ បន្ទាប់មក បុរសសង្ហាក៏ស្រវាចាប់ដៃភីណាដើរចេញទៅ ។

- ឈប់សិន! ទៅណាមិនទាន់បានទេ!

ឪពុកភីណាទាញកាំភ្លើងរួចស្ទុះក្រោកឈរឡើង ។ បុរសនោះ ទុកដឹក់ កាន់ដៃភីណាឥតរបេះ ។ ពពួកតម្រួតសន្តិសុខរត់ព្រូមក រកចាប់គ្រៀកបុរស ដែលមករំខានពិធីភ្ជាប់ពាក្យរបស់ដារិននិង ភីណា ។ ឃើញស្ថានការណ៍កាន់តែធ្ងន់ធ្ងរ ដារិនក៏ក្រោកឈរឡើង ស្រវាទាញកាំភ្លើងចេញពីដៃរបស់ឪពុកនាងភីណា រួចហើយដើរ សំដៅបុរសនោះ ។ ភ្ញៀវគ្រប់គ្នាភ្ញាក់ផ្អើលណាស់ តាមមើលមិន ពព្រិចភ្នែក ស្ទើរតែភ្លេចដកដង្ហើមគ្រប់ៗគ្នា ។ ពេលនោះ ម្នាក់ៗ

CHANBOKEO.COM

នឹកគិតថាប្រហែលជាដាវិនយកកាំភ្លើងទៅគម្រាមបុរសនោះហើយ
ព្រោះគេបានមកបំបាក់មុខដាវិនកណ្ដាលចំណោម ។
លុះដើរមកដល់មុខបុរសនោះ ដាវិនស្រដីថា ៖
- ខ្ញុំសូមស្ញើចសរសើរនូវភាពក្លាហានរបស់លោក ដែលចូលមក បង្ហាញភក្ដីភាពចំពោះគូស្នេហា នៅចំពោះមុខចំណោមចាស់ទុំនិង ភ្ញៀវទាំងឡាយថ្ងៃនេះ ។ណេះ! កាំភ្លើង! លោកយកវិញចុះ ហើយថែរក្សាភីណាអោយបានសុខតរៀងទៅ ។
ដាវិនហុចដងកាំភ្លើង អោយទៅបុរសនោះ រួចហើយ ហុចដៃ ស្ដាំទៅមុខ ជាសញ្ញាសុំចាប់ដៃជាមិត្តភាព ។ ឃើញដូច្នោះ បុរស នោះក៏ទទួលយកកាំភ្លើងវិញ ហើយស្រវាចាប់ដៃដាវិនយ៉ាងណែន ព្រមទាំងញញឹមហើយស្រដី ថា ៖
- សូមអរគុណចំពោះទឹកចិត្តជាកូនប្រុស ពិតប្រាកដ!
រលាក់ដៃគ្នារួចហើយ បុរសនោះក៏កាន់ដៃភីណាដើរចេញទៅ ទុកអោយចាស់ទុំនិងភ្ញៀវទាំងឡាយឈរមើលរហង់ និយាយមិន ចេញ...

នៅក្នុងវិឡារបស់លោកដាវុធ...
អ្នកស្រីពិសីដើរទៅដើរមកនៅក្នុងផ្ទះ សម្ដែងអាការៈម៉ួម៉ៅ ក្រៃលែង ៖
- ហេតុអ្វីបានជាក្មួយធ្វើអញ្ចឹង ដាវិន ? ដឹងទេ ថាធ្វើយ៉ាងនេះ វា បាក់មុខបាក់មាត់គ្រួសារយើងអស់រលីងណា៎!
- បាក់មុខរឿងអី អ្នកមីង ?
- គឺបាក់មុខមីងដែលខំរៀបចំពីធីធំដុំ ហៅភ្ញៀវសន្ធឹកសន្ធាប់ រួច ហើយស្រាប់តែកូនស្រីរត់ចោលពីធីទៅតាមកម្លោះដទៃកណ្ដាលរោង ចំណោម ធ្វើឲ្យខូចគម្រោងការមីងអស់ណា៎ដឹងទេ ?
- គម្រោងការ ? រឿងអី អ្នកមីង ?
- រឿងដែលគេថា ទិញវីឡាទិញផ្ទះអោយឯង ចែកដីចែកទ្រព្យ អីៗសន្ធឹកសន្ធាប់ទៀត ពេលនេះ ស្ទើម៉ាគ្រាប់ក៏មិនបានដែរ ។
- អូហ៍! ហើយបើឪពុកម្ដាយភីណាមិនបានចែក គឺខ្ញុំតើហ៍ដែល មិនបានទទួល ហេតុអ្វីបានជាមីងក្ដៅក្រហាយទៅវិញ ?
អ្នកស្រីពិសីភ្ញាក់ព្រើត បើកភ្នែកគ្រលួង ៖

CHANBOKEO.COM

- នេះដារិនល្ងង់មែន ឬក៏ធ្វើពើជាល្ងង់ហ្នឹង ? បើឯងរៀបការនឹង
កូនស្រីសេដ្ឋីអភិជនតួយ៉ាងនាងភីណានេះ ទាំងក្មួយ ទាំងមីង ទាំង
ប៉ារបស់ក្មួយសុទ្ធតែអាចកេងប្រយោជន៍ មកបានច្រើនណាស់ ទាំង ខាងបុណ្យសក្តិ ទាំងអំណាច
ទាំងទ្រព្យ អាចអោយយើងសប្បាយ ដេកស៊ីស្រណុកខ្លួនម៉ាជាតិ
ហើយម៉េចបានជាក្មួយធ្វើអោយរបូត លាភអស់រលីងយ៉ាងនេះ ?

ឮដូច្នោះ ដារិនស្រដីថា ៖

- សូមទោស អ្នកមីង! ខ្ញុំធ្វើតាមអ្នកមីងពីរដងហើយ ហើយក៏ជួប
ឧប្បត្តិហេតុកើតឡើងពីរដងដែរ ។ ម្យ៉ាងទៀត ខ្ញុំប្រាថ្នារៀបការ
ដោយមានការស្មគ្រ័ចិត្តពីសាម៉ីខ្លួនទាំងសងខាង មិនមែនដោយការ ចាប់បង្ខំទេ ។
ឥឡូវនេះជាសម័យសតវត្សរ៍ទី២១ហើយ អ្នកមីង ប្រើឥទ្ធិពលចាស់បុរាណនោះ
លែងមានប្រសិទ្ធិភាពទៀតហើយ ។ ពេលនេះ ខ្ញុំសូមជ្រើសរើសផ្លូវជីវិតរបស់ខ្លួនឯងហើយ
អ្នកមីង!

ថាហើយ ដារិនក៏ដើបដើរចេញទៅ ទុកអោយអ្នកស្រីពិសីឈរ ធ្វើមុខក្រញ៉ូវតែម្នាក់ឯង ។

ការពិត ដារិនស្ថិតនៅក្នុងវ័យមួយដែលសម្លឹងនិងវាស់តម្លៃ នារីជុំវិញខ្លួន
ដោយករិតសម្រស់សោភ័ណរូបកាយរបស់នាង ។ នារីណាក៏ដោយអោយតែស្រស់ស្អាត
ដារិនរំភើបពេញចិត្តទាំងអស់ រួមទាំងម៉ារ៉ែននិងភីណា ។ គេមិនបានគិតអ្វីច្រើនទេ អោយតែនារី
មានរូបស្អាត រាងរៅផ្គូផ្គងប្រដំប្រសងនឹងភាពសង្ហារបស់គេបាន
ដារិនពេញចិត្តទទួលយកមកពិចារណាគ្រប់គ្នា ។ គេមិនបានសម្លឹង
នារីអោយឆ្ងាយលើសពីរូបសម្បត្តិរបស់នាងឡើយ ។

មិនយូរប៉ុន្មាន ដារិនបានជួបកញ្ញាសោភាម្នាក់ឈ្មោះភិសម័យ នៅក្នុងពិធីបុណ្យមួយ ។
គេក៏ចាប់ផ្តើមទំនាក់ទំនងជាមួយនារីចាប់ តាំងពីថ្ងៃនោះមក ។
ភិសម័យជាបុត្រីអភិជនជាន់ខ្ពស់ម្នាក់ ចៃដន្យ គ្រួសាររបស់នាងមានឆន្ទៈនយោបាយ
ប្លែកគ្នាពីក្រុមគ្រួសាររបស់ លោកដារុធ ហើយមានការរកស៊ីប្រជែងជើងគ្នាជាមួយក្រុមហ៊ុន
របស់អ្នកស្រីពិសីទៀតផង ។ ចំណងទាក់ទងរវាងអ្នកទាំងពីរ ក៏ មានការរកាំរកូសជាច្រើន ។
- តើយើងគិតយ៉ាងណា បងដារិន ?

CHANBOKEO.COM

- ចាំបាច់ទៅគិតអី ភិសម័យ ? ពេលយើងរៀបការហើយ អូនក៏ ទៅរស់នៅអាមេរិកជាមួយបង នោះអូននឹងឈប់ឮពាក្យសំដីនិង ការអុជអាលទាំងឡាយនោះហើយ ។ ចង់គេនាំគ្នានិយាយអីក៏និយាយទៅ យើងកុំទៅរវល់ស្ដាប់គេធ្វើអ្វី ។

ប៉ុន្តែ អ្នកស្រីពិសីនូចជានៅមិនស្ងៀម នឹងរឿងរបស់ដារិង សោះ ចេះតែចង់យកឈ្នះចាញ់ មិននឹងថា ចង់បង្ហាញឥទ្ធិពលជា ម្ដាយចុងចំពោះកូនដើម ឬក៏ឥទ្ធិពលអ្នកមាន ប្រជែងនឹងបដិបក្ខ អ្នកមានរកស៊ីប៉ែងជើងគ្នាក្នុងផ្សារអភិជនឡើយ ។ លោកដាវុធខំប្រឹងធ្វើអន្តរាគមន៍ណាស់ មិនអោយអ្នកស្រីពិសីលូកដៃក្នុងរឿងកូន ចៅប៉ុន្មានទេ ប៉ុន្តែយាត់មិនជាប់សោះ ។ ការពិត អ្នកស្រីពិសីមិន មានកូនមួយគ្រាប់ទេ មានតែក្មួយៗដែលអ្នកស្រីចិញ្ចឹមជាកូនពីរបី នាក់ ប៉ុន្តែ គេទាំងនោះមានក្រុមគ្រួសារអស់ហើយ គឺសុទ្ធតែដោយ សារការផ្គូផ្គងរបស់អ្នកស្រីទាំងអស់ ។ ខ្លះក៏សុខនឹងគ្នា ខ្លះក៏បែកបាក់គ្នារប៉ាត់រប៉ាយ ។ អ្នកស្រីមិនទាន់ដែលជួបមុខដារីកូនទីពីរ របស់លោកដាវុធទេ ទើបតែជួបដារិង កូនច្បងជាលើកដំបូង នៅ ឆ្នាំនេះឯង ។

- ដារិង! មីងគិតថាភិសម័យសក្តិសមរៀបការជាមួយឯងទេ ។

អ្នកស្រីពិសីពោលទៅកាន់ដារិង ដែលកំពុងពាក់ស្បែកជើង បំរុងចេញទៅជួបភិសម័យ ។

- ហេតុអ្វី អ្នកមីងមានប្រសាសន៍ដូច្នោះ ?
- ព្រោះគ្រួសាររបស់គេរកស៊ី មិនសូវចេះយោគយល់នរណាទេ ដើរខ្សែលើគេរហូត ។
- ចុះរឿងរកស៊ីនោះទាក់ទងអ្វីនឹងខ្ញុំជាមួយភិសម័យទៅ ?
- គឺមីងមិនចង់អោយគេកោរក្បាលឯងអស់សក់នោះអី!
- គេមិនទាន់ដែលកោរអ្វីពីខ្ញុំមួយសរសៃទេមីង! កុំបន្ទោសគេ យ៉ាងនេះ!
- មិនទាន់ភ្ជាប់ពាក្យរៀបការផង កាន់ជើងគេទៅហើយហ្អែស ?
- មិនកាន់ទេ គ្រាន់តែចង់និយាយការពិត ។
- ប៉ុន្តែ មីងមិនអោយឯងរៀបការនាងទេ ។
- សូមទោសណា៎អ្នកមីង! ខ្ញុំធ្វើតាមអ្នកមីងមិនបានទេ ។

ថាហើយ នរៈដើរចេញទៅ ។ អ្នកស្រីពិសីក៏គំហកពីចម្ងាយ ទៅដារិងថា ៖

- អី! ធ្វើតាមចិត្តឯងទៅ! ហើយរៀបការអត់មេបាទៅ! កុំលូនមកហៅមីងនិងប៉ាឯងអោយទៅចងដៃឯងអោយសោះ ។

CHANBOKEO.COM

ដារិនឮហើយ ធ្វើមិនដឹង គិតតែដើរចេញពីផ្ទះសំដៅរថយន្ត មួយដែលចតចាំនាយនៅមុខផ្ទះ ក្នុងចិត្តគិតថា ៖

- ហេតុអ្វី ម្ដាយចុងរបស់ខ្ញុំប្រើអំណាចលើជីវិតរបស់ខ្ញុំម្ល៉េះ ? ខ្ញុំ ដូចជាមិនយល់សោះ! មួយថ្ងៃៗ ឃើញតែគាត់អង្គុយគុណលេខ រកចំណេញចូលហោប៉ៅរាល់ថ្ងៃ មិនដឹងថាជាចង់បានលុយយកទៅ ធ្វើអីទៀត កាលបើពេលនេះ អ្នកស្រីមានលុយចាយហៀរហូរយក មិនអស់ទៅហើយ ។ នេះឬការលោភលន់របស់មនុស្ស លោភ រហូតដល់គោរពលុយជាទេវតា ហើយភ្លេចនូវអារម្មណ៍និងសេចក្ដី សុខរបស់កូនចៅអស់រលីងយ៉ាងនេះ ? ចុះលោកប៉ាវិញ ហេតុ អ្វីក៏លោកខ្លាចអំណាចម្ដាយចុងរបស់ខ្ញុំម្ល៉េះ ? ឬមួយក៏លោកបាន ទទួលបុណ្យសក្ដិនៅក្នុងក្រសួង ដោយសារអំណាចប្រាក់របស់អ្នក មីងពិសី ? ចំណែកខ្ញុំវិញ ហេតុអ្វីក៏បណ្ដោយអោយគាត់ដឹកច្រមុះ បានដល់ទៅពីរដង ? ឯណាសតិប្រាជ្ញដារិន ? ឯណា មនសិការ របស់ដារិន ? ឯណាការចេះដឹងរបស់ដារិន ? ហេតុអ្វីក៏បណ្ដោយ អោយគេដឹកច្រមុះទៅខាងនេះខាងនោះ ស្រេចតែចិត្ត ? ឯណា ភាពរឹងប៉ឹងរបស់ដារិន ?

ពេលនោះ ដារិនតាំងចិត្តយ៉ាងដាច់ណាត់ថា គេនឹងរៀបការជា មួយភិសម័យ ដែលគេជ្រើសរើសដោយខ្លួនឯង ព្រោះនាងជានារី ស្រស់ស្អាតក្រៃលែង ហើយក៏ជាកូនស្រីពៅរបស់គ្រួសារអភិជន មួយដែលមានទ្រព្យគួរសមនឹងរស់ស្រួលមួយជីវិតដោយមិនពិបាក ធ្វើការនឿយហត់ ។ នៅផ្ទះភិសម័យ មានអ្នកបំរើឆ្វេងស្ដាំ មាន អ្នកថែផ្ទះថែសួន មានអ្នកដាំបាយ អ្នកបោកខោអាវ មានអ្នកដើរ តាមបំរើផ្ទាល់ខ្លួនរបស់កូនម្នាក់ៗ ។ ភិសម័យរស់នៅស្រណុកសុខ ស្រួលណាស់មិនដែលស្គាល់អ្វីថាលំបាកនឿយហត់ឡើយ ។ ចំណែក ឯក្រុមគ្រួសាររបស់ភិសម័យក៏សោមនស្សនឹងទទួលដារិន ដោយ សេចក្ដីពេញចិត្តដូចគ្នា ព្រោះដារិនមានរូបរាងសង្ហាស្អាតបាត សំដី សំដៅរួសរាយ មានបរិញ្ញាបត្រ័ ហើយជាពិសេសទៅទៀត គឺគេ មានសញ្ជាតិអាមេរិកាំង អាចធានាយកភិសម័យទៅរស់នៅសុខ សប្បាយលើដែនដីមាស ដែនដីសេរីភាព ។

- ភិសម័យ! តើអូនគិតយ៉ាងណា បើសិនយើងរៀបការដោយគ្មាន លោកមេបាខាងប្រុស ? (ដារិនសួរទៅនារីកំពូលស្នេហ៍)

- អោយតែម៉ាក់ប៉ាអូនយល់ស្រប អូនសុខចិត្តរៀបការជាមួយបង ជាស្វាមីភរិយារៀងទៅ ។

CHANBOKEO.COM

ដាវិឌត្រេកអរណាស់ ក៏លួចទៅជួបឪពុក សុំអោយលោកមក ចូលរួមចងដៃភិសម័យនិងមាណពនៅថ្ងៃមង្គលការ ។ លោកដាវុធ យកដៃអង្អែលក្បាលកូន ហើយមានប្រសាសន៍ថា ៖

- ចាំប៉ានិយាយជាមួយមីងពិសីរបស់ឯងសិន ។ ប៉ាមិនទាន់ហ៊ាន សន្យាទេ ថាតើប៉ាអាចទៅចូលរួមពិធីមង្គលការរបស់កូនបានដែរឬ យ៉ាងណា ។

ដាវិឌក៏សំពះលាឪពុកចេញទៅវិញទាំងដួងចិត្តស្រពោន ។

ថ្ងៃរៀបមង្គលការមកដល់...

ដាវិឌក្រាបក្បាលដល់ខ្នើយទន្ទឹមនឹងភិសម័យ ទទួលពរជ័យពី មាតាបិតាខាងស្រី ភ្នែករំពៃសម្លឹងរកមើលវត្តមានរបស់លោកដាវុធ មិនពព្រិចភ្នែក ។ ថ្ងៃនោះ ភាពញញឹមលើផ្ទៃមុខរបស់នរៈបាន បង្កប់នូវភាពសោកសៅយ៉ាងធំធេង ដែលលោកដាវុឌជាឪពុកមិន ព្រមបង្ហាញខ្លួនមកជូនពរកូនប្រុសរបស់លោកនៅថ្ងៃមង្គលការ ។

រាត្រីនោះ ដាវិឌឈរកាន់ទ្វាររបងរង់ចាំមើលផ្លូវឪពុករហូត យប់ជ្រៅ ក៏នៅមិនឃើញស្រមោលរបស់លោកមកជូនពររូបនាយ និងភិសម័យឡើយ ។ ដាវិឌឈរធ្វើទឹកភ្នែករលីងរលោង តែម្នាក់ ឯង នឹកស្រណោះដែលគ្មានចាស់ទុំណាមកចងដៃគេម្នាក់ ក្រៅពី សាច់ញាតិខាងស្រី...

ភិសម័យសង្កេតឃើញដាវិឌមានការទន្ទឹងរង់ចាំផ្លូវឪពុកខ្លាំង ពេក ក៏ដើរទៅជិត យកដៃបបោសខ្នងដាវិឌ លួងលោមថា ៖

- បងកុំគិតច្រើនអី! ប្រហែលជាលោកប៉ាមានកិច្ចការប្រចាំក្រសួង ដែលតម្រូវអោយលោកត្រូវមានវត្តមាននៅទីនោះជាចាំបាច់ ទើប លោកមិនអាចមកចងដៃយើងបាន ។ ប៉ុន្តែ មិនថ្វីទេ លោកអាច អញ្ជើញមកចងដៃយើង នៅថ្ងៃក្រោយទៀតក៏បានដែរ ពេលណា ដែលលោកមានពេលទំនេរ ។

ដាវិឌស្រវាកាន់ដៃភរិយាហើយញញឹមឡើង ៖

- អរគុណណាស់ ចំពោះពាក្យលើកទឹកចិត្តប៉ុន្មាននេះ ភិសម័យ!

ចាប់តាំងពីថ្ងៃនោះមក អ្នកទាំងពីរក៏រួមរស់ជាស្វាមីភរិយា យ៉ាងសុខសប្បាយបំផុត រហូតដល់ថ្ងៃមួយ ដែលភិសម័យត្រូវចេញ ទៅរស់នៅអាមេរិកជាមួយដាវិឌតែពីរនាក់ ។

CHIANBOKEO.COM

ក្រុងសេនផល រដ្ឋមិនីសូតា...

ធាតុអាកាសខែមករា ពិតជារងាសែនរងា ។ សីតុណ្ហភាពស្ថិត នៅប្រហែល២០ទៅ៣០អង្សាក្រោមសូន្យរៀងរាល់ថ្ងៃ ។ ព្រិល ធ្លាក់ដណ្តប់ទីក្រុងទាំងមូលឡើងសក្បុសដូចកំបោរ ទំដាប់នៅតាម តាមដំបូលផ្ទះ លើមែកឈើ លើទីធ្លា លើដីវាល បែរទៅទីណាៗ ក៏សុទ្ធតែព្រិលសក្បុសទាំងអស់ ។ មនុស្សម្នាត្រូវស្លៀកក្រាស់ៗ ជាទីបំផុតទើបអាចទប់ទល់នឹងធាតុត្រជាក់បាន ។ ទឹកនៅក្នុងបឹង នាៗ ក៏កកយ៉ាងក្រាស់បំផុត ដែលអាចអោយមនុស្សលេងកីឡា ប្រណាំងឡានលើផ្ទៃបឹងយ៉ាងសប្បាយ ។

ភិសម័យអង្គុយសម្លឹងមើលទេសភាពតាមបង្អួចកញ្ចក់ ក្នុងចិត្ត នឹកសង្វេគដល់ខ្លួនរបស់នាង ដែលបានមករស់នៅអាមេរិកតែម្នាក់ ឯង ឃ្លាតឆ្ងាយគ្រួសារនិងការរស់នៅស្រណុកសុខស្រួលសព្វបែប យ៉ាង ។ ពេលនេះ ដាវិដបានចូលទៅធ្វើការវិញហើយ ។ រៀង រាល់ថ្ងៃ ដាវិដក្រោកពីម៉ោង៥កន្លះ ដាំបាយធ្វើម្ហូបវេចដាក់ប្រអប់ យកទៅធ្វើការ ។ គេត្រូវចេញពីផ្ទះទៅអោយបានមុនម៉ោង៧ព្រឹក ដើម្បីអោយទៅទាន់ពេលធ្វើការនៅម៉ោង៨ ។ ក្រុងមិនីអាប៉ូលីស និងសេនផល ជាបុរីភ្លោះ ដែលមានផ្ទៃដីទូលាយ មានមនុស្សរស់ នៅស្ទែកស្ទះ ចរាចរស្ទះព្រឹកល្ងាច ។ ដាវិដត្រូវបើកឡានចម្ងាយ ប្រហែលជិត១០០គីឡូទៅមកក្នុងមួយថ្ងៃ ។ នៅរដូវទឹកកក ផ្លូវថ្នល់រអិលហើយគ្រោះថ្នាក់ណាស់ ម្ល៉េះហើយការធ្វើដំណើរចេញ ទៅណាមកណាតែងត្រូវការពេលវេលាយូរខុសធម្មតា ។

ភិសម័យ ត្រូវអង្គុយចាំរាល់ថ្ងៃ រហូតដល់ម៉ោង៨ទៅនយប់ ទើបដាវិដត្រឡប់មកដល់ផ្ទះវិញ ។ ព្រមជាមួយគ្នានោះដែរ ដាវិដ បានចូលរៀនកម្មវិធីសិក្សា អនុបណ្ឌិតខាងចិត្តវិទ្យាបន្តទៅទៀតនៅ មហាវិទ្យាល័យមិនីសូតា ។ ម្ល៉េះហើយ ថ្ងៃខ្លះ គេមកដល់ផ្ទះពេល យប់ជ្រៅហួសពេលបាយ ធ្វើឲ្យភិសម័យកើតការអផ្សុកធុញថប់ ក្នុងចិត្តក្រៃលែង ។ ឯទារកនៅក្នុងផ្ទៃពោះភិសម័យក៏កាន់តែធាត់ធំ ជាលំដាប់ ។ ដោយសារហេតុនោះហើយ ទើបភិសម័យរិតតែថ្នម ខ្លួនថែមទៀត មិនសូវហ៊ានដើរចេញក្រៅ ខ្លាចរអិលទឹកកកដួលដំ គ្រោះថ្នាក់ដល់រូបកាយនិងទារក ។

ជាធម្មតា ដាវិដធ្វើការមិនសូវនៅផ្ទះទេ ។ មួយថ្ងៃវាស់ល្ងាច គេធ្វើការបាត់ៗរហូត ។ ភិសម័យធ្លាប់រស់នៅក្នុងគ្រួសារ ដែល មានឈ្នួលបំរើស្ទែកស្ទះពីមុខពីក្រោយ ។ ពេលនេះ

CHANBOKEO.COM

មាណវីនៅ ម្នាក់ឯង ត្រូវធ្វើអ្វីៗដោយខ្លួនឯង តាំងពីដាំបាយ លាងចាន ដុសឆ្នាំង ជូតសំអាតផ្ទះ បោកខោអាវ ឈូសព្រិលតាមផ្លូវដើរ ពីផ្ទះទៅផ្លូវថ្នល់ ដើម្បីអោយអ្នករត់សំបុត្រចេញចូលយកសំបុត្រ មកអោយ ។ ម្យ៉ាងទៀត នាងមិនទាន់ចេះអង់គ្លេស ហើយមិន ដែលធ្វើអ្វីដោយខ្លួនឯង ម្ល៉ោះហើយ ពេលដាវិឌជំរុញអោយនាង រៀនជិះឡានក្រុងទៅសាលារៀនអង់គ្លេស ឬក៏ទៅជួបជុំញាតិនៅ មជ្ឈមណ្ឌលសហគមន៍ខ្មែរ ភិសម័យក្លាយជាអាក់អន់ស្រពន់ចិត្ត គិតថាប្ដីមិនថ្នាក់ថ្នមនាងដែលមានផ្ទៃពោះ ហើយចេះតែបង្ខំអោយ ចេញដើរក្រៅផ្ទះ ទាំងត្រជាក់រងា ទាំងមានផ្ទៃពោះ ។ លុះឃើញ នាងរអ៊ូរទាំច្រើនពេក ដាវិឌក៏អោយនាងសំរាកនៅផ្ទះ មិនអោយ ធ្វើអ្វីទាំងអស់ ។ គេសុខចិត្តក្រោកពីព្រឹក ដាំបាយទុកអោយនាង បរិភោគ បោកខោអាវ រៀបចំផ្ទះ ឈូសព្រិលចេញពីផ្លូវ ឬធ្វើអ្វីៗ ក្នុងផ្ទះសព្វយ៉ាង ដើម្បីថ្នមប្រពន្ធអោយនាងសប្បាយចិត្ត ប៉ុន្តែ មាណវីនៅតែមិនរីករាយដដែល ព្រោះនាងនៅផ្ទះម្នាក់ឯងរាល់ថ្ងៃ មិនមានអ្វីធ្វើក្រៅពីមើលទូរទស្សន៍ និងទូរសព្ទ័ទៅស្រុកខ្មែរយំរអ៊ូ រទាំដាក់ម្ដាយ ដាក់បងប្អូន រៀបរាប់អំពីភាពកណ្ដោចកណ្ដែង របស់នាង តាំងពីមករស់នៅអាមេរិកតែម្យ៉ាងប៉ុណ្ណោះ ។

យូរៗម្ដង ដាវិឌឆ្លៀតពេលទំនេរនាំប្រពន្ធ ដើរលេងទៅ មើលកុនឬទៅទីប្រជុំជនអាមេរិកាំង ។ ទោះជាយ៉ាងណាក៏ភិសម័យ នៅតែមិនសប្បាយចិត្តដដែល ព្រោះស្ដាប់ភាសាគេមិនបាន ។ ជួនកាល ដាវិឌនាំនារីទៅដើរទិញឥវ៉ាន់នៅហាងទំនិញធំៗ តែ ភិសម័យនៅតែម៉ូម៉ៅ ព្រោះដាវិឌកំណត់ប្រាក់ចំណាយរបស់នាង ការពិត ដាវិឌកំពុងនៅរៀនមិនចង់ចាយវាយខ្ជះខ្ជាយ ខ្លាចអស់ ប្រាក់សន្សំសំរាប់បង់សាលា ដែលត្រូវបង់ចំនួនដល់ទៅពីរម៉ឺន ដុល្លារក្នុងមួយឆ្នាំ ។

នៅវេលាថ្ងៃមួយ...

- អាឡូ! ម៉ាក់! នេះខ្ញុំ ភិសម័យ!
- អឺ សុខសប្បាយទេកូន?
- ចាស! គ្មានសេចក្ដីសុខទេ ម៉ាក់!
- ហេតុអ្វីទៅ?

CHANBOKEO.COM

- គឺកូនចង់សុំអោយម៉ាក់ផ្ញើលុយអោយកូនចាយថែមទៀត ព្រោះខ្ញុំ
ចាយលុយបងដាវីដមិនដាច់ទេ ។ គាត់គីរ៉ះណាស់ ! មុននឹងចាយ
គាត់តែងសូត្រធម៌កាយបញ្ជីអោយខ្ញុំមើលមិនឈប់ទេ ។ គិតទៅ ខ្ញុំស្តាយខ្លួនណាស់ម៉ាក់
ដែលខ្ញុំមករៀបការនឹងបុរសដែលមានតែ ខ្លួន គ្មានអ្វីអោយប្រពន្ធកក់ក្តៅក្នុងចិត្តសោះ ។ ការពិត
ពួក អាមេរិក គ្មានអ្វីគួរអោយអស្ចារ្យទេ ! ទិញឡានជំពាក់គេ បង់ខែ
បួនដប់ឆ្នាំទំរាំបង់ដាច់ឡានមួយ... ទិញផ្ទះបង់ខែសុទ្ធ តែ៣០ឆ្នាំ ទើបបង់ដាច់...
មានបរិញ្ញាបត្រមែន តែធ្វើការរហែមរហាមដូច អណ្តើកចូលភ្លើង បើកឡានឆ្ងាយ
ទៅធ្វើការតាំងពីព្រហាម មកផ្ទះ វិញពេលយប់ជ្រៅ មិនដែលបានបរិភោគបាយជុំគ្នាជាគ្រួសារ...
ចាយប្រាក់ទិញអ្វីៗសុទ្ធតែមានកំណត់ជានិច្ច បើមិនដូច្នោះទេ គេ
នឹងវណ្ឌ័កនៅពេលដាច់ខែម្តងៗ ។ មិនតែប៉ុណ្ណោះ នៅអាមេរិក នេះ
គ្មាននរណាម្នាក់មានសមត្ថភាពជួលឈ្នួលមកបំរើខ្លួនអោយ ស្រណុកសុខស្រួលបានឡើយ
សូម្បីតែបងដាវីដដែលមានចំណេះ ខ្ពស់មានការងារនៅការិយាល័យក៏ដោយ ។ ខ្ញុំគិតថា
ចង់ត្រឡប់ ទៅរស់នៅស្រុកខ្មែរវិញហើយ ។ ខ្ញុំនឹកស្តាយដល់ភាពស្រណុក
សុខសប្បាយរបស់ខ្លួនដែលធ្លាប់មាន ធ្លាប់ដើរលេងហ៊ឺហា មានគេ បំរើឆ្វេងស្តាំ ។ នៅទីនេះ
ក្រចកខ្ញុំសឹកអស់ហើយ ព្រោះត្រូវដុស ឆ្នាំងលាងចានដាំបាយដោយខ្លួនឯង ។ គ្រួសារនិមួយៗ
បើប្តីធ្វើការ តែម្នាក់ឯង ជីវភាពរបស់គេខ្វះខាតណាស់ មិនសំបូរសប្បាយដូច
ពួកយើងស្រុកខ្មែរធ្លាប់គិតនោះទេ ។ មើលទៅដាវីដប្តីរបស់ខ្ញុំចុះ មានបរិញ្ញាបត្រ័ពិតមែន
តែធ្វើការមួយអាទិត្យៗបាត់មុខរហូត ធ្វើ
អោយខ្ញុំនៅផ្ទះម្នាក់ឯងអផ្សុកតប់ប្រមល់ដល់សួរតែម្តង ។
- កុំទាន់មកផ្ទះវិញអីកូន ! ទ្រាំបន្តិចទៅ ! ពេលរលាយទឹកកក អស់ហើយ
ភិសម័យក៏ដល់ពេលសំរាលកូនរួចទំនេរខ្លួនដែរ ! ពេល នោះ កូនរៀនបើកឡាន
ចូលសាលារៀនអង់គ្លេសទៅ នឹងអាច បើកបរទៅដើរលេងនៅក្រៅ
ដូចកូនធ្លាប់ធ្វើនៅស្រុកខ្មែរអញ្ចឹង ដែរ ។ កូនច្បាស់ជាលែងអផ្សុកហើយ ។
ចាំស្អែកម៉ាក់ដាក់លុយ ផ្ញើអោយកូនសំរាប់ចាយវាយផ្ទាល់ខ្លួន... តើកូនចង់បានប៉ុន្មាន ?
ភិសម័យទម្លាក់ទូរសព្ទ័ទាំងចិត្តហ្មួហ្មង ។ ស្រាប់តែ នាងភ្ញាក់ ព្រើតនឹងវត្តមានរបស់ដាវីដ
ដែលនៅឈរក្បែរនាង តាំងពីអង្កាល់ ស្តាប់ឮការសន្ទនារបស់នាងជាមួយម្តាយអស់រលីង ។ ប៉ុន្តែ

CHANBOKEO.COM

គេមិន បានបញ្ចេញទឹកមុខកាយវិការអ្វីដែលថាគេខឹងនឹងនាងទេ ផ្ទុយទៅ វិញ
គេបែរជានិយាយថា ៖
- បងសុំទោសណាំភិសម័យ ដែលមិនសូវមានពេលសំរាប់អូន!
ចាំបងរៀបកាលវិភាគអោយយើងមានពេលវេលាជាមួយគ្នាខ្លះ មិន
អោយអូនអផ្សុកកណ្តោចកណ្តែងអញ្ចឹងទៀតទេ ។
    ដាវិដក៏ប្រឹងធ្វើតាមដែលគេសន្យា ដើម្បីផ្គាក់ផ្គមចិត្តប្រពន្ធដ៏ មានរូបឆោមសោភារបស់គេ
មិនអោយទាស់ចិត្ត ។
    មិនយូរប៉ុន្មាន ភិសម័យប្រសូត្របានកូនស្រីមួយយ៉ាងស្រស់ ស្អាតដាក់ឈ្មោះថា ដាវ៉ាន់ ។
ពេលនោះ ភិសម័យក៏ទំនេរខ្លួន... មេឃខាងក្រៅក៏អស់ទឹកកក...
ទីក្រុងក៏ទទួលពន្លឺថ្ងៃភ្លឺថ្លាសាជាថ្មី ស្លឹកឈើក៏លាស់បំព្រង ធ្វើអោយមាណវីនឹកចង់ត្រេកត្រអាល
ជីវិតក្រៅផ្ទះវិញម្តង ។
- បងដាវិដ! នៅថ្ងៃសៅរ៍ស្អែកនេះ នារីចំរៀង ឆេងសុវិយានិង អ៊ុំសុមាវតី ព្រមទាំងគង់ឌីណា
មកសម្តែងនៅក្រុងសេនផល មាន ការរាំកំសាន្តនិង ការជួបជុំញាតិផង ។ យើងទៅរាំលេងអោយ
សប្បាយម្តង បានទេបង ?
    ដាវិដកំពុងឈ្ងោកវាយឯកសារក្នុងកុំព្យូរទ័រ លុះឮភរិយាសួរ ដូច្នោះ គេក៏ឆ្លើយថា ៖
- ថៃដន្យ បងត្រូវធ្វើរបាយការណ៍សិក្សាជូនសាលាថ្ងៃចន្ទ័នេះ មិន អាចដើរលេងបានទេ ។
- ហើយចុះយូរណាស់ហើយ ម៉េចក៏បងមិនធ្វើរបាយការណ៍នោះ ទុកពីមុនមក ? ម៉េចចាំធ្វើ
ពេលកៀកថ្ងៃយ៉ាងនេះ ?
- ព្រោះបងអាល័យធ្វើការនោះអី គ្មានពេលទំនេរនឹងធ្វើការងារ សាលាអោយទាន់ពេល
ហើយអាល័យជួយធ្វើការនៅផ្ទះសំរាលដៃ
ជើងអូនផង ព្រោះអូននៅសរសៃខ្ចី ទើបរកពេលធ្វើមិនបាន ។
- អញ្ចឹង ស្អែកនេះ អូនសុំទៅដើរលេងម្នាក់ឯងបានទេ ? ចាំអូន
សុំពឹងមិត្តអោយគេមកដឹកខ្ញុំទៅជាមួយគេចុះ ។
    ដាវិដនៅស្ងៀម មិនហ៊ានមាត់ទេ ថ្វីបើក្នុងចិត្តមិនចង់អោយ
ប្រពន្ធដើរលេងម្នាក់ឯងក៏ដោយ ។ ប៉ុន្តែបើគេឃាត់ ខ្លាចប្រពន្ធ អន់ចិត្ត
ព្រោះគ្នានៅតែផ្ទះមិនសូវបានដើរទៅណា ។ ម្យ៉ាងទៀត ទារកក៏នៅខ្ចីផង
មិនអាចយកដើរលេងទៅទីរាំកំសាន្តបែបនោះ បានឡើយ ។ ចំណែកខ្លួន

CHANBOKEO.COM

គេក៏មានកិច្ចការត្រូវធ្វើជាចាំបាច់ ។ ទីបំផុត ដារិនត្រូវតែបង្ខំចិត្ត ឲ្យប្រពន្ធចេញទៅរាំកំសាន្តជាមួយ មិត្តភក្តិទៅ ទុកអោយនាយមើលកូននៅផ្ទះ តែម្នាក់ឯង ។

មានថ្ងៃមួយ ភិសម័យប្រាប់មាណពថា ៖

- បងដារិន! អូនចង់នាំកូនទៅលេងបងប្អូនឯស្រុកខ្មែរម្តង ។ បងដាក់ពាក្យសុំលិខិតឆ្លងដែនអោយអូនផងណា៎!

ដារិនមិនហ៊ានប្រកែកក៏ធ្វើក្រដាសស្នាមអោយប្រពន្ធភ្លាម ត្បិត ចង់អោយនាងសប្បាយចិត្ត ។ ថៃដន្យ ពេលបានសំបុត្រឆ្លងដែន ហើយ ភិសម័យបែរជាដូរចិត្តមិនចង់ទៅលេងស្រុកខ្មែរវិញ ព្រោះ នាងចាប់ស្គាល់មិត្តស្រី មិត្តប្រុសថ្មីៗវ័យស្រករនាងជាច្រើននាក់ ។ ភិសម័យបែកប្រាជ្ញដើររាំកំសាន្ត បរិភោគសុរា សប្បាយនឹងជីវិត ប្លែកៗ នៅក្រៅផ្ទះសឹងតែរៀងថ្ងៃ ពេលដារិនមិននៅ ដោយយក ទារកតូចទៅផ្ញើនឹងញាតិជិតខាងអោយគេជួយរក្សា ។

ថៃដន្យ នៅយប់មួយនោះ ពេលត្រឡប់មកពីដើរលេងវិញ មិត្តប្រុសរបស់ភិសម័យក៏ត្រូវប៉ូលីសចាប់ ព្រោះស្រវឹងស្រាបើក ឡានទើសទែងគេពេញផ្លូវបណ្តាលអោយមានគ្រោះថ្នាក់ ។ រីឯ ភិសម័យក៏ស្រវឹងទន់ខ្លួនដែរ ព្រោះសប្បាយជាមួយមិត្តជ្រុលមិន បានគិត ។ យប់នោះ ប៉ូលីសបានដកហូតរថយន្ត ហើយបញ្ជូនជើង អ្នកទាំងពីរ នៅមន្ទីរឃាត់ឃាំងអ្នកបើកបរស្រវឹងពេញមួយយប់ ដែរ ។ ដារិននៅអង្គុយទើសភ្លឺរង់ចាំមើលផ្លូវប្រពន្ធ ពុំឃើញនាង មកផ្ទះសោះ ។ លុះគេទូរសព្ទ័ខ្វាត់ខ្វែងទៅស្ថានីយ៍ប៉ូលីសជាច្រើន កន្លែង ទើបរកឃើញភិសម័យនៅកន្លែងឃាត់ខ្លួន ក៏ចេញទៅធានា យកនាងត្រឡប់មកផ្ទះវិញ ។

ចាប់តាំងពីថ្ងៃនោះមក អ្នកទាំងពីរចេះតែមានរឿងជជែកគ្នា មិនអស់មិនហើយ ព្រោះភិសម័យចេះតែកើតជម្ងឺអផ្សុក ចេញដើរ លេងញឹកញាប់ ទុកអោយដារិនមើលកូនតែម្នាក់ឯង ។ ជួនកាល នារីយកកូនតូចផ្ញើនឹងញាតិជិតខាង រហូតទាល់តែដារិនចេញពី ធ្វើការ ទៅទទួលយកកូនមកផ្ទះវិញ ។ គ្រាណា ដារិនហៅនិយាយ ភិសម័យតែងតែសម្តែងភាពហួងហែងចំពោះប្តី ហើយក៏តាំងយំស្រែក រកសម្លាប់ខ្លួន ។ ដោយភិតភ័យខ្លាចនាងធ្វើបាបខ្លួន ដារិនក៏ចេះតែ បណ្តោយនាងតាមតែដំណើរ ថ្វីបើក្នុងបេះដូងរបស់គេមានការធុញ ថប់ចំពោះការផ្លាស់ប្តូររបស់ភរិយា យ៉ាងណាក៏ដោយ ។

CHANBOKEO.COM

នៅថ្ងៃមួយ...

ដារិនមកដល់ផ្ទះ ឃើញប្រពន្ធកំពុងរៀបវ៉ាលីស ។

- អូនកំពុងចេញដំណើរទៅណា ភិសម័យ ? ឬក៏ទៅស្រុកខ្មែរ ?

មាណវីងាកមើលដារិន រួចហើយបែរមុខចេញ ស្រដីថា ៖

- ទៅកន្លែងណាដែលផ្តល់ភាពរស់រវើកដល់ជីវិត មិនមែនរស់នៅស្ងៀមស្ងាត់ឥតន័យដូចនៅក្នុងផ្ទះនេះទេ ។
- មានន័យថាម៉េចហ្នឹង អូនភិសម័យ ?
- រៀនដល់អនុបណ្ឌិត ស្តាប់ប៉ុនហ្នឹងមិនយល់ទៀតឬ ដារិន ?

ឃើញប្រពន្ធហៅឈ្មោះចំៗ លែងមានភាពផ្អែមល្ហែមដូចមុន ដារិនភ្ញាក់ព្រើត ឧទានថា ៖

- អូនកំពុងចាកចោលបងនិងកូនមែនទេ ?
- ស្រេចតែបងគិតចុះ !

ថាហើយ ភិសម័យក៏អូសវ៉ាលីសដើរចេញទៅ សូម្បីតែកូនស្រីដែលនៅគេងលក់ក្នុងគ្រែរបស់នាង ក៏មិនបែរមើលផង ។ ដារិន បែរសម្លឹងតាមមើលប្រពន្ធទាំងទឹកភ្នែករលីងរលោង ហើយស្រដី តែម្នាក់ឯងថា ៖

- ភិសម័យ! ជាកំហុសរបស់បង មែនទេ ដែលអូនដើរចេញពី ជីវិតរបស់បងយ៉ាងនេះ ? ប្រហែលជាបងផ្តល់សេចក្តីសុខដល់រូប អូនមិនគ្រប់គ្រាន់ហើយ បានជាអូនចេញស្វែងរកសុភមង្គលនៅ កន្លែងផ្សេងទៀត...! ប៉ុន្តែ... ហេតុអ្វីអូនមិនព្រមពិចារណាពីជីវិត របស់បងផង ? បងកំពុងខិតខំសព្វយ៉ាង គឺដើម្បីយើងទាំងពីរ នាក់...ព្រមទាំងកូនរបស់យើង... ហេតុអ្វីអូនមិនជួយលើកទឹកចិត្ត បងដែលកំពុងខំរៀនយកការសិក្សាជាន់ខ្ពស់ ? ហេតុអ្វីអូនមិនគិត ពីអនាគតរបស់គ្រួសារយើង ? ហេតុអ្វីអូនមិនគិតដល់កូនតូចរបស់ អូនដែលត្រូវការការថ្នាក់ថ្នមពីម្តាយ ?

ដារិនអង្អុយបីកូនស្រីនៅក្នុងដៃ លួចរំជួលចិត្តតែម្នាក់ឯង អាណិតកូនតូចដែលមានវ័យជាង៦ខែ បែរជាត្រូវឃ្លាតម្តាយទាំងខ្ចី សេចក្តី ។

និយាយពីភិសម័យវិញ...

CHANBOKEO.COM

- ភិសម័យ! ហេតុអ្វីចុះចេញមកតែខ្លួនអញ្ចឹង ?

មិត្តប្រុសរបស់ភិសម័យសួរ ។

- មានស្អីយកតាមខ្លួនកើត បើដារិនគ្មានអ្វីសោះក្រៅពីសញ្ញាបត្រ និងកូនស្រីមួយ ។

- គឺយកកូននោះអី! យកកូនមក ដើម្បីប្ដឹងយកថ្លៃប្រាក់ចិញ្ចឹមកូន ពីដារិន ។ ពេលដារិនរៀនចប់ គេនឹងមានប្រាក់ខែច្រើន រដ្ឋត្រូវកាត់ប្រាក់ខែរបស់គេសំរាប់ចិញ្ចឹមកូនចិញ្ចឹមប្រពន្ធ ហើយរដ្ឋនឹងផ្ញើប្រាក់នោះអោយភិសម័យរាល់ខែ ដូច្នេះអូនមិនបាច់ធ្វើការអ្វីទេ ដេកតែកើបប្រាក់ខែនោះចាយស្រណុកខ្លួនទៅបានហើយ ។

- អូហ៍! តើខ្ញុំអាចធ្វើដូច្នេះបានដែរ ?

- បានណា៎! ការដាក់ពាក្យសុំលែងលះនិងសុំទាមទារប្រាក់ចិញ្ចឹម កូននោះជាការងាយធ្វើបំផុត ។ មិនអីទេណា៎ ចាំបងជួយ!

ព្រដូច្នោះ ភិសម័យក៏រកមធ្យោបាយទៅលួចកូនស្រីពីដារិន ។ មិនយូរប៉ុន្មាន គេក៏លួចកូនស្រីបានដូចបំណង ហើយក៏នាំជិះរត់ទៅ រស់នៅរដ្ឋកាលីហ្វ័រញ៉ា បន្ទាប់មកក៏ដាក់ពាក្យប្ដឹងរដ្ឋសុំលះលែងនិង សុំទាមទារប្រាក់ខែចិញ្ចឹមកូនពីដារិនដែលរស់នៅឯមិនីសូតា ។

ដោយមូលហេតុនោះ ដារិនបានក្លាយជាបុរសខូចចិត្ត បែក អារម្មណ៍ រៀនស្ទើរតែមិនចប់ ។ ប៉ុន្តែ ដោយសេចក្ដីស្រឡាញ់ ចំពោះកូនស្រី នរ:សុខចិត្តចុះហត្ថលេខាកាត់ប្រាក់ខែ ចិញ្ចឹមកូន ចិញ្ចឹមប្រពន្ធ ដោយមិនប្រកែកមួយម៉ាត់ ព្រោះដើម្បីរក្សាសេចក្ដី សុខអោយប្រពន្ធនិងកូនស្រីជាទីស្រឡាញ់របស់គេ ។

មិនបានប៉ុន្មានខែផង ស្រាប់តែមានរឿងហេតុមួយកើតឡើង ។

ដោយការភ្លើតភ្លើនសប្បាយដើរលេងភ្លេចខ្លួន ភិសម័យមិន បានថែរក្សាដាវ៉ាន់អោយបានដិតដល់ឡើយ ។ ថ្ងៃមួយ ទារកតូច ដែល ភិសម័យយកទៅផ្ញើអ្នកជិតខាងនោះមានជម្ងឺគ្រុនក្ដៅប្រកាច់ ត្រឡប់ភ្នែក ។ អ្នកជិតខាងនោះក៏ទូរសព្ទ័ហៅឡានពេទ្យរដ្ឋ អោយ មកទទួលយកទារកនោះទៅព្យាបាល ព្រោះគេរកម្ដាយមិនឃើញ ។ ពេលនោះ ពេទ្យបានរកឃើញថា ដាវ៉ាន់បានទទួលរងគ្រោះដោយ រលាកបារី ដោយការវាយដំត្រូវរបួសជាំឆ្អឹងជំនីរ និងក្រឡុកឈាម ក្នុងខួរក្បាលដោយការចាប់បោកបោះដោយកម្លាំងបាយ ។ តុលាការ

រដ្ឋកាលីហ្វ័រញ៉ាបានចេញញត្តិតាមរកចាប់ម្តាយ និងមិត្តប្រុសរបស់ នាង ដែលជាជនសង្ស័យនៅក្នុងការធ្វើបាបកូនតូចនោះ ហើយ ក៏ចេញញត្តិតាមរកឪពុក អោយមកទទួលយកដាវ៉ាន់ទៅមើលថែ រក្សាវិញ ។

ទីបំផុត តុលាការរដ្ឋកាលីហ្វ័រញ៉ាក៏ផ្តល់សិទ្ធិទៅដាវិដជាអាណា ព្យាបាលទោល របស់ដាវ៉ាន់ ហើយក៏អនុញ្ញាត្តិអោយដាវិដទទួល យកកូនទៅចិញ្ចឹមនៅមិនីសូតាយ៉ាងត្រឹមត្រូវ ។ មិត្តប្រុសរបស់ ភិសម័យបានទទួលការកាត់ទោសអោយជាប់ឃុំ១២ឆ្នាំ ដោយការ បង្កគ្រោះថ្នាក់របួសដល់ទារកតូច ដែលមិនអាចការពារខ្លួនបាន ។ រីឯភិសម័យវិញបានត្រូវតុលាការដាក់ទោស អោយជាប់ឃុំបួនឆ្នាំ ដោយការធ្វេសប្រហែសមិនការពារកូន ឲ្យផុតពីការធ្វើបាបរបស់ មិត្តប្រុស និងដោយសារតែនាងមិនបានយកកូនទៅព្យាបាល នៅ ពេលដឹងថា ទារកបានទទួលរងការវាយដំរបស់មិត្តប្រុសស្រវឹង ។

CHANBOKEO.COM

បួនឆ្នាំកន្លងទៅ...

ដាវិដខំរៀនផង ខំធ្វើការផង ហើយខំចិញ្ចឹមរក្សាកូនស្រីរបស់ ខ្លួនតាមដែលអាចធ្វើបាន ។ ពេលទៅធ្វើការ គេផ្ញើដាវ៉ាន់ជាមួយ គ្រួសារខ្មែរម្នាក់ដែលរស់នៅជិតខាងគ្នា អាចទុកចិត្តបាន ។ រីឯ ដាវីជាប្អូនស្រី រស់នៅរដ្ឋម៉ាសាឈូសិត តែងតែមកលេងជាមួយ បងប្រុសនិងក្មួយស្រីមួយឆ្នាំម្តង រហូតដល់នាងរៀនចប់ ។

ឆ្នាំនេះ ដាវិដរៀនបញ្ចប់សញ្ញាបត្រ័បណ្ឌិត ខាងចិត្តវិទ្យា ។ ដោយសារតែគេមានប្រវត្តិវិបត្តិគ្រួសារ មានប្រវត្តិជាកូនដែលរស់ នៅកំព្រើកំព្រាឆ្ងាយឪពុកម្តាយតាំងពីក្មេងៗ គេបានសំរេចចិត្តរៀន មុខវិជ្ជានេះដើម្បីរកវិធីព្យាបាលចិត្តរបួសរបស់ខ្លួនឯងមុនគេ ។

ព្រមជាមួយគ្នានេះដែរ ដាវីក៏បញ្ចប់ការសិក្សារបស់នាងខាង កុំព្យូទ័រ ហើយក៏ដាក់ពាក្យផ្លាស់សុំមកធ្វើការនៅមិនីសូតាវិញ ដើម្បី អោយបានរនៅជិតបងប្រុសនិងក្មួយស្រី ។ ចំណែកឆោមស្រស់មិត្ត របស់ដាវីក៏វិលត្រឡប់ទៅរស់នៅជាមួយក្រុមគ្រួសារ ឯកាលីហ្វ័រញ៉ា វិញដែរ ។ ភាពសប្បាយរីករាយ ក៏បានវិលត្រឡប់មករកក្រុម គ្រួសាររបស់ដាវិដវិញ តាំងពីដាវីមករស់នៅជាមួយ ។ សព្វថ្ងៃ

នេះ ដាវិឌចាប់ផ្តើមចេះញញឹមរីករាយមកវិញបន្តិចៗហើយ ។
ក្រោយមក ដាវីនិងស្រស់ឆោមបានជួបសិលាតាមរយៈបន្ទប់សំណេះសំណាលក្នុងវិបសៃថ៍ខ្មែរតាមឥន្ទ្រីណិត ។ អ្នកទាំងពីរបានចាប់អារម្មណ៍ពីជំនាញរបស់សិលាខាងហ្គីតា ព្រោះដាវិឌបងប្រុស របស់ដាវីក៏ជាអ្នកជំនាញហ្គីតា និងជាអ្នកចំរៀងដ៏ឆ្នើមម្នាក់ដែរ ។ ដាវីក៏នឹកភ្នកចង់នាំបងប្រុសរបស់នាងទៅលេងស្រុកខ្មែរ ដើម្បី ផ្លាស់ប្តូរបរិយាកាស អោយបងប្រុសរបស់ខ្លួនមានអារម្មណ៍រីករាយ មកវិញ ។ ប៉ុន្តែ ដាវិឌហាក់ដូចជារាងចាលចំពោះអ្វីៗដែលគេបាន ទទួលពីស្រុកខ្មែរ ។ មាណពបានប្រកែកដាច់អហង្ការ ថាមិន ត្រឡប់ទៅស្រុកខ្មែរអោយនរណាឃើញមុខគេទៀតឡើយ សូម្បីតែ ឪពុករបស់គេ ។

ថៃ្ងដន្យ ភិសម័យក៏បានត្រូវដោះលែងពីមន្ទីរឃុំឃាំងមក វិញ ។ មាណវីបានធ្វើដំណើរមកដល់មីនីសូតា តាមមកសុំដាវិឌជួប កូន ។ ដោយសេចក្តីអាណិតអាសូរដែលខ្លួនធ្លាប់ជាប្តីប្រពន្ធនឹងគ្នា ដាវិឌក៏សុខចិត្តបណ្តោយអោយភិសម័យ នាំកូនស្រីទៅគេងលេង ជាមួយពីរថ្ងៃ ។ ប៉ុន្តែពីរថ្ងៃបានកន្លងទៅ ភិសម័យមិនបាននាំ ដាវ៉ាន់ត្រឡប់មកអោយដាវិឌដូចសន្យានោះទេ ។ មាណពបានរត់ ទៅស្នងការប៉ូលីសដាក់ពាក្យប្តឹង តាមរកដាវ៉ាន់ខ្វាត់ខ្វែងមួយ រំពេច ។ ពីរថ្ងៃក្រោយមក ប៉ូលីសក៏បានផ្តល់ដំណឹងថា ភិសម័យ បានប្រើលិខិតឆ្លងដែននាំដាវ៉ាន់ ឡើងយន្តហោះទៅស្រុកខ្មែរបាត់ ទៅហើយ ។ អាស្រ័យហេតុនោះហើយ ទើបដាវិឌសំរេចចិត្តវិល ត្រឡប់ទៅស្រុកខ្មែរជាថ្មីម្តងទៀត ដើម្បីទៅតាមរកដាវ៉ាន់ត្រឡប់ មកវិញ ។

មកដល់ភ្នំពេញកាលណា គេបានយកញត្តិតុលាការទៅប្តឹងទូត អាមេរិក អំពីរឿងភិសម័យចាប់ជំរត់ដាវ៉ាន់ប្រឆាំងនឹងញត្តិតុលាការ រដ្ឋកាលីហ្វ័រញ៉ា ដែលបានផ្តាច់សិទ្ធិនាងជាអាណាព្យាបាលរបស់ ដាវ៉ាន់មិនអនុញ្ញាត្តិអោយភិសម័យ លាក់កូនទុកក្នុងការឃុំគ្រង របស់នាងជាអចិន្ត្រៃយ៍ ។ ដាវិឌបានទៅដាក់ពាក្យប្តឹងនៅតុលាកា ភ្នំពេញ ដើម្បីទាមទារយកដាវ៉ាន់មកវិញ ។ សំណាងមិនល្អ ភិសម័យ បានប្រើអំណាចឥទ្ធិពលគ្រួសាររបស់នាង លាក់ដាវ៉ាន់ទុក

CHANBOKEO.COM

មិនឲ្យក្រុមមានសមត្ថកិច្ចចូលឆែកឆេរផ្ទះរបស់នាង បានឡើយ ។ ដោយប្រការនោះហើយ ទើបដារីងសុខចិត្តអោនលំទោនទៅរក ឪពុកវិញ ដើម្បីសុំឲ្យលោកជួយធ្វើអន្តរាគមន៍យកដារ៉ាន់មកវិញ តាមផ្លូវច្បាប់ ក្រៃងលោមានប្រសិទ្ធិភាព ។

*oooooooooooooooooo*

*ooooo*

*o*

CHANBOKEO . COM

# វគ្គទី៧
# គូប្រជែង

នៅក្នុងមន្ទីរពេទ្យ...

- លោកជាសាច់ញាតិអ្នកជំងឺមែនទេ ?
- បាទ!
- ពេលនេះ នាងដឹងខ្លួនហើយ!

លោកគ្រូពេទ្យម្នាក់ដើរមកប្រាប់ដំណឹងដល់ដារិននិងធីតា ដែលនៅអង្គុយរង់ចាំពីស្ថានភាពអ្នកជំងឺ ។ ដារិនលើកកូនស្រីពឡើង ហើយស្រវាក្តាប់ដៃធីតាដើរចូលទៅរកភិសម័យ ដែលកំពុងគេង ស្តូកស្តឹងនៅលើគ្រែ ។ មើលទៅអាការៈរបស់នាង ហាក់ដូចជា ចង្កៀងដែលកំពុងតែអស់ប្រេងដូច្នោះឯង ។

- ភិសម័យ...!

ដារិនហៅនារីខ្សិបៗថ្នមៗ ។ មាណវីបើកភ្នែកឡើង ឃើញ ដារិននិងកូនស្រីរបស់នាង ក៏ស្រដីខ្សាវៗឡើងថា ៖

- ដារិន...! ខ្ញុំ... សូម...ទោស... សូមផ្ញើ...វ៉ាន់...ផង!

ភិសម័យនិយាយទាំងដង្ហក់ៗ ស្ទើរស្តាប់ស្ទើរមិនឮ ។ ដារិនក៏ដាក់ដាវ៉ាន់អោយអង្គុយជិតនាង ហើយចាប់ដៃដាវ៉ាន់អោយកាន់ដៃ ម្តាយរបស់គេ ។ ភិសម័យញញឹមស្ងួតដាក់ដាវ៉ាន់ហើយក៏ធ្មេចភ្នែក ទៅវិញ...

CHANBOKEO.COM

ដារិនឈរស្ងៀមស្ងាត់ សម្លឹងភិសម័យដោយដួងចិត្តរន្ធត់ញាប់ ញ័របំផុត បន្ទាប់មកក៏ស្រដីខ្សឹបៗថា ៖

- ភិសម័យ! សូមអោយនាងបានចាកផុតគ្រោះថ្នាក់កុំខាន ។

មួយសន្ទុះក្រោយមក ដារិនលើកកូនស្រីពចេញទៅ ។ រីឯធីតាវិញក៏ហាក់ដូចជារន្ធត់ចិត្តយ៉ាងណាមិនដឹង ដែលនាងបានមកប្រឡូកហេតុការណ៍ថ្ងៃនេះដោយផ្ទាល់ភ្នែក ។ កាលបើឃើញដារិន មានកិរិយាសោកសៅ ធីតាក៏មិនហ៊ានមាត់កអ្វីមួយម៉ាត់ដែរ ចេះតែ ដើរតាមពីក្រោយដោយស្ងៀមស្ងាត់ ។

- ឯងយកចៅស្រីរបស់យើងទៅណាមិនបានទេ!

អ្នកទាំងពីរភ្ញាក់ព្រើត បែរមើលម្ចាស់សម្លេងដែលគំហកខ្លាំងៗ ឃើញស្រីចំណាស់មួយរូបក្នុងសម្លៀកហ៊ីហាមានតម្លៃ កំពុងដើរចូល មក ដោយមានមនុស្សហែហមពីក្រោយពីរបីនាក់ផង ។ អ្នកស្រី យកដៃចង្អុលមុខដារិន ស្រដីថា ៖

- អោយនាងតូចមកយើងវិញភ្លាម! ហើយចេញទៅចុះ!

កុមារីក្រឡេកឃើញមុខស្ត្រីចំណាស់នោះពេលណា ក៏យំវ៉ាឡើង ស្រវាអោបកឪពុកយ៉ាងណែន ។ ដារិនយកដៃបបោសខ្នងកូន កុំឲ្យ នាងភិតភ័យ ហើយក៏ស្រដីថា ៖

- សូមអភ័យទោស! ខ្ញុំជូនកូនវ៉ាន់ទៅអ្នកស្រីមិនបានទេ!
- កុំមកចេះហៃហៃ តិចយើងហៅប៉ូលីសអោយមកចាប់!

ដារិនញញឹមហើយឆ្លើយថា ៖

- នោះក៏ល្អដែរ! ព្រោះខ្ញុំកំពុងចង់វែកមុខអ្នកដែលចាប់ជំរត់ក្មេងផង ថាតើគួរដាក់ទោសយ៉ាងណា!

ការពិត នោះគឺអ្នកស្រីម៉ារី ម្តាយរបស់ភិសម័យ ដែលទើបតែ ទទួលដំណឹងថា កូនស្រីមានគ្រោះថ្នាក់ ។ ពេលឮសំដីរបស់ដារិន ដូច្នោះ អ្នកស្រីម៉ារីភ្ញាក់ព្រើត បើកភ្នែកធំៗ ប៉ុន្តែក៏ឈប់មាត់តទៅ ទៀត បណ្តោយអោយដារិនពកូនដើរចេញទៅ ។ លុះឃើញនរៈនាំកូនឡើងរថយន្តដែលគេជួលជិះនោះចេញទៅ អ្នកស្រីក៏បែរក្រោយ បញ្ជាទៅអ្នកហែហមប៉ុន្មាននាក់នោះថា ៖

- តាមវាភ្លាម!

រួចហើយអ្នកស្រីក៏ស្ទុះចូលទៅក្នុងបន្ទប់ ដើម្បីសួរសុខទុក្ខ ភិសម័យ ។

CHANBOKEO.COM

    តាមផ្លូវ ដារិនសង្កេតឃើញមានរថយន្តបើកតាមពីក្រោយ ។
- មានគេតាមយើងហើយអូនដា! ពេលនេះ យើងត្រូវការជំនួយ ហើយ ។
- បងគិតទៅណាហ្នឹង ?
- ទៅផ្ទះលោកប៉ារបស់បង!
- អញ្ចឹង បងទម្លាក់ដាតាមផ្លូវសិនទៅ ចាំខ្ញុំជិះម៉ូតូឌុបទៅផ្ទះ ។
- ប៉ុន្តែ ខ្លាចមិនស្រួលទេដឹង មិនដឹងជាអ្នកដែលតាមយើងមាន បំណងយ៉ាងណាទេ ។
បងបារម្ភពីសុវត្ថិភាពរបស់ដា...!
    ធីតាញញឹមដាក់ដារិន ហើយស្រដីថា ៖
- មុខព្រួញរបស់គេ គឺដាវ៉ន់ មិនមែនដាទេ ។
- តែគេក៏អាចចាប់ដាជាចំណាប់ខ្មាំង ប្តូរគ្នាជាមួយដាវ៉ាន់ ក៏ថា
បានដែរ ។
    ធីតាភ្ញាក់ព្រើតនឹកភើតពោះតែម្តង ។ ឃើញមាណវីធ្វើទឹកមុខ ទំនងភ័យ
ដារិនក៏និយាយកម្លាចិត្តនាងវិញ ៖
- ប៉ុន្តែ បងមិនអោយនរណាធ្វើបាបដាបានទេ អូនកុំភ័យអី ។
    គេក៏ស្រវាចាប់ដៃនារីកាន់យ៉ាងណែន ដើម្បីផ្តល់សេចក្តីកក់ក្តៅ ដល់អារម្មណ៍របស់នាង ។
បន្តិចមក គេក៏បានមកដល់វីឡារបស់ លោកដាវុធ ។ ដារិនដឹកដៃនាំកូនស្រីនិងធីតា
ដើរចូលទៅក្នុងផ្ទះ ស្រាប់តែសុផានី បើករថយន្តនាំអ្នកស្រីពិសីមកដល់ ព្រមគ្នាពី ក្រោយនរៈដែរ
៖
- ទៅណាមកណា ដារិន ? ហើយនាំនរណាគេមកហ្នឹង ?
    ដារិនលើកដៃប្រណម្យឡើង ៖
- ជំរាបសួរអ្នកមីង! ខ្ញុំនាំចៅនិងអនាគតកូនប្រសាររបស់អ្នកមីង មកលេង ។
    ធីតាភ្ញាក់ក្រញាង កាលបើឮដារិនពោលដូច្នោះ ។ ចំណែកអ្នក
ស្រីពិសីនិងសុផានីក៏ភ្ញាក់ផ្អើលមិនខុសគ្នាឡើយ ។ អ្នកស្រីបើក ភ្នែកធំៗសម្លឹងធីតាយ៉ាងមុត
ធ្វើអោយនារីយើងនឹករអៀសខ្លួនក្តៅ មុខក្តៅមាត់យ៉ាងណាមិនដឹង ។
នាងក៏លើកដៃប្រណម្យសំពះអ្នក ស្រីនិងសុផានីភ្លាម ជាការគោរពគួរសមចំពោះម្ចាស់ផ្ទះ ។
- យើងមិនទទួលភ្ញៀវចម្លែកទេ ដារិន!

CHANBOKEO.COM

អ្នកស្រីដើរចូលទៅក្នុងផ្ទះធ្វើឫកតោះតើយដាក់ធីតា ក្នុងកិរិយា ស្អប់ខ្ពើម ។ ប៉ុន្តែ ដារិនបែរជាដឹកដៃធីតាចូលផ្ទះ ធ្វើមិនដឹងទៅ វិញ ថ្វីបើធីតាសម្តែងអាការៈខ្លាចចិត្តម្ចាស់ផ្ទះយ៉ាងណាក៏ដោយ ។ អ្នកស្រីពិសីបែរក្រោយឃើញអ្នកទាំងបីដើរត្រសង តាមក្រោយ ចូលមកក្នុងផ្ទះ ក៏គំហកថា ៖

- នែ៎ ដារិន! មីងប្រាប់ហើយតើហ៎ថាផ្ទះមីងមិនស្វាគមន៍មនុស្ស ចម្លែកទេ ។

ដារិនញញឹមហើយឆ្លើយថា ៖

- ខ្ញុំមិនបាននាំមនុស្សចម្លែកមកផ្ទះអ្នកមីងនិងលោកប៉ា ឯណា ?
- ហើយចុះពីរនាក់ដែលដើរតាមឯងត្រុកៗនោះ ?
- គេជាកូន និងជាអនាគតភរិយារបស់ខ្ញុំតើហ៎!
- តែគេជាមនុស្សចម្លែកចំពោះមីង!
- អញ្ចឹង អ្នកមីងបែរមុខមកមើលនាងទៅ ដើម្បីអោយបានស្គាល់ នាងច្បាស់ នោះនាងលែងជាមនុស្សចម្លែកចំពោះអ្នកមីងហើយ ។
- នេះជាផ្ទះរបស់មីង! អ្វីៗជាការសម្រេចចិត្តរបស់មីង ។ ពេល នេះមីងមិនស្វាគមន៍នរណាទេ ។ ឯងនាំគេចេញទៅវិញចុះ ។

ដារិនភ្ញាក់ព្រើត ដែលត្រូវអ្នកស្រីពិសីបណ្តេញ ។ គេក៏នៅ ស្ងៀម បែរមើលមុខដាវ៉ាន់ ហើយមើលមុខធីតា បន្ទាប់មក គេក៏ បោះជំហានបែរក្រោយរកចេញទៅវិញ ស្រាប់តែ ៖

- ដារិន!

សម្លេងបុរសម្នាក់ស្រែកហៅ ។ ដារិនងាកក្រោយឃើញឪពុក ចុះជណ្តើរសំដៅមករកនាយ ព្រមទាំងមានប្រសាសន៍បន្តថា ៖

- មកដល់នេះហើយ កូនមិនចូលមកជំរាបសួរប៉ាទេហ្អែស ?
- លោកប៉ា!

ដារិនស្ទុះរឹងទៅជំរាបសួរឪពុក រួចហើយក៏ដឹកដៃកូនស្រីទៅ ជួបលោក ៖

- ជំរាបសួរលោកតាទៅកូន!
- ជំរាបសួរលោកតា!

លោកដាវុធលើកចៅពញ្ជើងដោយសេចក្តីស្រឡាញ់ ៖

- សូមអោយចៅតាអាយុវែងណា៎ចៅ!

CHANBOKEO.COM

បន្ទាប់មក លោកក៏បែរសម្លឹងទៅធីតា ។ ដាវុធឃើញហើយក៏ អូសដៃនារីមកបង្ហាញខ្លួន ៖
- នេះធីតា ជាអនាគត... របស់កូន!
ធីតានឹកអៀនខ្មាសក្នុងចិត្តណាស់ ដែលដារិនដើរប្រកាសយ៉ាង ដូច្នេះ ។ នាងមិនដឹងធ្វើយ៉ាងម៉េចអោយសមរម្យ ក៏លើកដៃសំពះ ប្រណម្យគោរពលោកដាវុធ ។ លោកក៏យកដៃត្រងទទួល ហើយក៏ មានប្រសាសន៍ថា ៖
- ល្អហើយកូន! សូមអោយកូនទាំងពីររក្សាគ្នា មានសេចក្តីសុខ រហូតទៅ ហើយសូមអោយស្រឡាញ់គ្នាជានិច្ច មិនថាក្តៅរងា មិន ថាឈឺជា មិនថាមានក្រ សុខឬលំបាកយ៉ាងណាឡើយ!
ដារិនអោនកេសាទទួលពរពីឪពុកដោយដួងចិត្តរំភើប រហូត ដល់ទឹកភ្នែករលីងរលោងតែម្តង ។ មែនហើយ! គេកំពុងតែនឹក ស្រណោះខ្លួន ព្រោះនៅក្នុងពិធីមង្គលការលើកទីមួយ គេមិនបាន ទទួលពរពីឪពុករបស់គេសោះ ។ ប្រហែលជាដូច្នេះទេដឹង ទើប គេត្រូវបណ្តាសា ធ្វើអោយជីវិតគ្រួសាររបស់គេប្រេះឆា ផ្សាភ្ជាប់គ្នាវិញមិនកើត ។ ពេលនោះ ស្រាប់តែគេមានចិត្តរីករាយមកវិញខុស ធម្មតា ព្រោះគេបានទទួលពរជ័យដល់ទៅពីរដង ក្នុងរយៈពេល ប៉ុន្មានថ្ងៃដែលគេចាប់ស្គាល់ធីតាមក ។ លើកទីមួយ គេបានទទួល ពរពីម៉ីងលក់ផ្កាឈូក ។ លើកទីពីរ ពីឪពុករបស់គេ ថ្វីបើគេមិនទាន់បានគិតគូររៀបចំអ្វីជាមួយធីតាអោយសមរម្យតាមប្រពៃណីនៅ ឡើយក៏ដោយ ។ គិតចុះគិតឡើង ស្រាប់តែដារិនមានកម្លាំងចិត្ត ប្រឹស ដើបមុខញញឹមយ៉ាងក្លាហាន ៖
- អរគុណលោកប៉ា! កូនស្រឡាញ់លោកប៉ាណាស់ ។
ដារិនក៏ស្រវាអោបឪពុក ដោយដួងចិត្តរំភើបហួសព្រំដែន ។ លោកដាវុធក៏ញញឹមទទួលកូនក្នុងរង្វង់ដោយក្តីញាប់ញ័រ ។ បន្តិច មក លោកក៏បែរមកធីតា ហើយក៏លាតដៃឡើង ៖
- អោយប៉ាសុំអោបកូនទាំងពីរនិងចៅ ផ្តល់សេចក្តីកក់ក្តៅបន្តិច ណា៎! យើងឃ្លាតឆ្ងាយគ្នាយូរហើយ! សូមអោយចិត្តយើង បេះដូង យើងវិលត្រឡប់មករកគ្នាជិតស្និទ្ធិវិញ ដើម្បីអោយប៉ាមានសេចក្តី កក់ក្តៅក្នុងចិត្តដូចកូនដែលកំពុងទទួលសុភមង្គលដូច្នេះដែរ ។
ធីតាភ្ញាក់ផ្អើលណាស់ តែក៏រីករាយសោមនស្សណាស់ដែលដឹង ថាលោកដាវុធគ្មានការស្អប់ខ្ពើមរូបនាង មិនតែប៉ុណ្ណោះទទួលនាង យ៉ាងពេញមុខ ។

មាណវីក៏ដើរចូលទៅជិតលោក ទទួលយករង្វង់ ដៃអោបរិតរបស់លោក ដែលក្រសោបអ្នកទាំងបីបញ្ចូលព្រមជាមួយ គ្នា យ៉ាងកក់ក្ដៅក្រៃលែង ។ នៅពីក្រោយខ្នង អ្នកស្រីពិសីនិង សុផានីឈរមើលពីក្រោយដោយទឹកមុខស្ងួតព្រោះអ្នកទាំងពីរកំពុង ចុះចាញ់ស្ថានការណ៍ ។ ស្រាប់តែ...

- ទោះជាយ៉ាងណា ក៏ខ្ញុំមិនទទួលស្គាល់មនុស្សអង្កាច់អង្កោច ចូល មកក្នុងគ្រួសាររបស់ខ្ញុំដែរ ។

អ្នកស្រីពិសីឈរក្រពាត់ដៃដើយមើលមេឃពេបមាត់ សម្ដែង កិរិយាមាក់ងាយធីតា ។ រំពេចនោះ ដាវិដបែរមើលនារីយើងឃើញ នាងធ្វើទឹកមុខមិនសូវស្រួល ក៏សំពះឪពុកស្រដីថា ៖

- សូមអនុញ្ញាត្តលោកប៉ាមួយភ្លែតបាទ!

បន្ទាប់មក នរៈព្រលែងដៃពីធីតានិងកូន ហើយក៏ដើរទាជិត អ្នកស្រីពិសី ស្រដីតបដោយសម្លេងខ្សិបៗ តិចៗ ថា ៖

- មនុស្សអង្កាច់អង្កោចដែលអ្នកមីងមានប្រសាសន៍នោះពិតជាសក្តិ សមនិងបុរសមានបេះដូង មានរាសីអង្កាច់អង្កោចដូចខ្ញុំនេះណាស់ អ្នកមីងមិនឃើញទេហ៍ ថាមួយជីវិតខ្ញុំនោះ បានទទួលបរាជ័យរឿង ជីវិតគូស្រករប៉ុន្មានដងហើយ ? ពីរដងដែលអ្នកមីងជាអ្នកជួយផ្ទុង ផ្ដើមខ្ញុំ ដើម្បីអោយបានទទួលអ្នកមានឋានៈខ្ពង់ខ្ពស់ជាគូ បែរក្លាយ ជាត្រូវបរាជ័យទាំងពីរដង ។ ម្ដងទៀតដែលដាវិដជ្រើសរើសខ្លួន ឯង ដើម្បីអោយបានទទួលរាសីអ្នកខ្ពង់ខ្ពស់ ក៏ក្លាយជាបរាជ័យសា ជាថ្មីដដែល ។ គិតទៅរាសីខ្ញុំពិតជាមិនសក្តិសមនឹងទទួលអ្នកមាន ឋានៈវណ្ណៈរាសីខ្ពង់ខ្ពស់បានឡើយ ព្រោះទេវតាបានរុញខ្ញុំទម្លាក់បី ដងហើយ ។ លើកទីបួននេះ ខ្ញុំមិនចង់ឡើងខ្ពស់ហើយធ្លាក់ចុះវិញ ទេ ព្រោះវាឈឺណាស់... ហើយឈឺតែម្នាក់ឯងទៀតផង ព្រោះគ្មាន នរណាគេមកជួយឈឺជាមួយដាវិដសោះ ពេលដាវិដស្រក់ទឹកភ្នែក មានតែអ្នកដែលគិតចាំត្រងប្រយោជន៍ពីដាវិដតែប៉ុណ្ណោះ ។ ដោយ ហេតុនេះហើយ ដាវិដសូមដើរលើដីរាបស្មើៗក្នុងឋានៈជាជនអង្កាច់ អង្កោចចុះ ដើម្បីកុំអោយពិបាកធ្លាក់ឈឺខ្លួន ឈឺចិត្តដូចលើកមុន ទៀត ។ ពេលនេះ បើអ្នកមីងពិតជាមានទឹកចិត្តខ្វាយខ្វល់ ចង់ អោយដាវិដបានទទួលសេចក្ដីសុខ រួចហើយឈប់បរាជ័យតទៅ ទៀត សូមអ្នកមីងមេត្តាជួយជូនពរក្មួយផងណា៎អ្នកមីង!

ថាហើយ គេក៏លើកដៃសំពះអ្នកស្រីពិសី ប៉ុន្តែអ្នកស្រីបែរគេច ចេញយ៉ាងរហ័សមិនព្រមទទួលយកនូវការសំពះនោះឡើយ ។

បន្តិចមក គេក៏ងាកមកសុផានីហើយស្រដីថា ៖

CHANBOKEO.COM

- សុផានីមានរូបស្អាត មានឋានៈល្អ មានទ្រព្យសម្បត្តិ ដូច្នេះផ្លូវដើរក្នុងជីវិតរបស់សុផានីពិតជាទូលំទូលាយណាស់ ។ ខ្ញុំសង្ឃឹមថា សុផានីមិនទម្លាក់ខ្លួនចុះមករកដើរប្រជ្រៀតផ្លូវតូចចង្អៀត ដែល អ្នកអង្កាច់អង្កោចនិងអ្នកបរាជ័យគេដើរនោះទេ ។ បើមិនដូច្នោះទេ អ្នកស្រុកគេច្បាស់ជាឆ្ងល់គ្រប់គ្នាហើយ ថាហេតុអ្វីសុផានីចុះមកប្រឡូកជាមួយហ្វូងអ្នកបរាជ័យធ្វើអ្វី ឬក៏អ្នកនាងជានារីដែលមាន ប្រវត្តិបរាជ័យពីមុនមក...

ភ្លាមនោះ សុផានីបើកភ្នែកមូលក្រឡង់ ព្រោះភ្ញាក់ផ្អើលនឹង ការវែកញែករបស់នរៈយើង ។ នារីសោភា ឈានថយក្រោយមួយ ជំហានហើយឆ្លើយថា ៖

- នែ៎! និយាយអ្វីផ្ដេសផ្ដាសហ្នឹង ? នរណាគេចង់ទៅប្រដេងផ្លូវ ជាមួយអ្នកអង្កាច់អង្កោចនោះ ?

- អញ្ចឹង ដារិនសូមជួយត្រេកអរសុផានីផង ដែលមិនទម្លាក់ខ្លួនមកដើរផ្លូវតូចអង្កាច់អង្កោចដូចខ្ញុំនេះ ។

សុផានីញាក់ស្មា បែរមុខចេញ ព្រោះរកពាក្យឆ្លើយមិនបាន ។

ដារិននិងធិតា ព្រមទាំងដាវ៉ាន់លើកដៃផ្គុំសំពះលោកដាវុឌ និងអ្នកស្រីផានីត្រឡប់ចេញទៅវិញ ។

នៅក្នុងរថយន្ត...

- ចុះឯណាដែលថា បងមកសុំអោយលោកប៉ាអោយការពារយើងពីការប្រទុស្តរបស់គ្រួសារអ្នកនាងភិសម័យនោះ ?

- បងសុំហើយតើហ៎ ហើយក៏បានគ្នាការពារមកដែរ ។

ធីតាបើកភ្នែកមូលក្រឡង់ ទំនងឆ្ងល់ ៖

- ម៉េចក៏មិនឃើញកងកម្លាំងការពារ ?

- បងមានគ្រប់គ្រាន់ហើយឈប់ភ័យទៅ...

ធិតាបែររកមើលជុំវិញឡានដែលកំពុងបើកបរ...

- អូនដាមិនបាច់ងាករកទេ ព្រោះកងការពារនោះគ្មានរូបអោយ នរណាមើលឃើញឡើយ ។

- តើជាអ្វីទៅ បងដារិន ?

- គឺកម្លាំងចិត្តនិងពរជ័យរបស់លោកប៉ានោះអី! ពេលនេះ ទេវតា តាមថែរក្សាយើងហើយកុំបារម្ភអី ។

ឮដូច្នោះ ធីតាក៏ញញឹមឡើង ៖

- ពរជ័យលោកប៉ាបងពូកែណាស់ហ្ន៎! មានប្រសាសន៍តែមួយម៉ាត់ កូនប្រុសបាត់ខ្លាចសត្រូវរលីងតែម្តង ។

ដាវីឌមិនឆ្លើយទេ បែរជាញញឹមដាក់នាង ហើយក៏លើក ទូរសព្ទ័ចុចហៅគ្នា ៖

- ដាវី! ឆោម! បងមានការសុំអោយប្អូនជួយបន្តិច... ជួយពង្វាង ដានចោរបន្តិច... បងអរគុណហើយណាំ!

ដាវីឌទម្លាក់ទូរសព្ទ័ចុះ ។

- មានការអ្វីហ្នឹង បងដាវីឌ ?

- គ្រាន់តែប្រុងប្រៀបជើងព្រួលខ្លះៗ ។

- រឿងអ្វីទៅ ?

- គឺតាមអង្កេតអ្នកដែលកំពុងតាមដានយើង ។

ធីតាបើកភ្នែកម្ងួលក្រឡង់ ព្រោះមិនដឹងថា ដាវីឌកំពុងមាន គម្រោងអ្វី ។

ព្រលប់ថ្ងៃដដែល...

នៅផ្ទះរបស់អ៊ំសាឡាង...

នៅចំពោះមុខអ៊ំសាឡាង និងអ៊ំសារី ដាវីឌបត់ជើងលើកដៃ សំពះឡើង ៖

- មិនដឹងនិស្ស័យអ្វីទេ ដែលនាំជីវិតដាវីឌអោយមកជំពាក់ជាមួយ ក្រុមគ្រួសាររបស់លោកអ៊ំ ។ ពេលនេះ ដាវីឌសូមចូលខ្លួនសារភាព ខ្លួនជូនលោកអ៊ំពិចារណា ថាបើសិនណាដាវីឌសូមខ្លួនធ្វើជាកូន ប្រសារប្រុសក្នុងផ្ទះនេះ តើលោកអ៊ំតម្រូវអោយដាវីឌធ្វើយ៉ាងណា ដើម្បីអោយសមរម្យសមចិត្តចាស់ទុំនិងកូនស្រី ព្រមទាំងសមាជិក ក្រុមគ្រួសារទាំងមូល ។ កន្លងមក ខ្ញុំពុំមានប្រវិត្តិស្អាតស្អំប៉ុន្មានទេ ប៉ុន្តែ ដាវីឌសន្យាសុំឱកាសកែឆ្នៃ មិនអោយជីវិតធ្លាក់ក្នុងគន្លង បរាជ័យដូច្នោះទៀតឡើយ ។

អ៊ំសាឡាងនិងអ៊ំសារីមើលមុខគ្នា ។

បន្តិចមក អ៊ំសាឡាងក៏ឆ្លើយទៅវិញថា ៖

- ប៉ាមិនថាអ្វីទេកូន អោយតែកូនយល់ចិត្តគ្នាទៅបានហើយ ។ ការ ពិត វណ្ណៈទ្រព្យសម្បត្តិ វាគ្រាន់តែជាស្រមោលបង្កក្តីស្រម័យដល់ មនុស្សខ្លះៗតែប៉ុណ្ណោះ ប៉ុន្តែ វាមិនមែនជាគ្រឹះម៉ាំនៃសុភមង្គល គ្រួសារទូទៅ គ្រប់គ្នាដែរ ។ ប៉ាថា កូនសួរចិត្តធីតាចុះ ។ បើកូន ទាំងពីរអាចចុះសម្រុងគ្នាបាន ប៉ារីករាយនឹងទទួលកូនថៃមម្នាក់

CHANBOKEO.COM

ទៀតមកក្នុងគ្រួសាររបស់យើង ។ ចំពោះរឿងខន្ធ័ស្លាវិញ ប៉ាតម្រូវ សុំយកតែក្តីស្មោះត្រង់
និងការថែទាំគ្នាដោយកក់ក្តៅតែប៉ុណ្ណោះ យ៉ាងណាៗ សុំអោយតែឪតាបានរៀនចប់សិនណ៎ាកូន ។

ដាវិឌត្រេកអរណាស់ ដែលគេបានទទួលនូវការស្វាគមន៍យ៉ាង
កក់ក្តៅពីអ៊ំសាឡាននិងប្រពន្ធរបស់គាត់ ។ ម្យ៉ាងទៀត មើលទៅ គាត់ហាក់ដូចជាយល់ចិត្តនរៈ
ច្រើនជាងនាយយល់ចិត្តខ្លួនឯងទៅ ទៀត ។ ល្ងាចនោះ
អ៊ំសាឡាននិងអ៊ំសារីបានឃាត់ដាវិឌនិងដាវ៉ាន់
អោយនៅបរិភោគបាយហើយនៅសំណាក់ទីនោះជាមួយគ្នា ដើម្បី សំណេះសំណាលប្រវត្តិគ្រួសារ
អោយបានស្គាល់គ្នាទៅវិញទៅមក រិតតែច្បាស់លាស់ឡើង ។

ក្នុងផ្ទះអ៊ំសាឡាន...

នៅរាត្រីដដែលនោះ...

សុធនហាក់ដូចជាមានក្តីរំភើបចំពោះដាវិឌណាស់ ដែលនរៈជិត
បានក្លាយជាសាច់ញាតិរបស់ខ្លួន សប្បាយរហូតដល់ទាញហ្គីតាមក ដេញជាបទភ្លេងយ៉ាងពិរោះ
កំដរបរិយាកាសគ្រួសារ ដោយមាន នាងតូចដាវ៉ាន់ ឡើងរាំកាច់ក្បាច់យ៉ាងស្អាត
ធ្វើអោយទាំងអស់គ្នា សប្បាយក្អាកក្អាយក្រៃលែង ។

សិលាអង្គុយក្បែរដាវិឌយូរហើយ ក៏លួចកេះហើយខ្សឹបថា ៖

- នែ៎ះ បងដឹងច្បាស់ហើយឬថានាងដាគេពេញចិត្តបងដាវិឌឯង ?
- បាទ! មែនហើយ!
- ហើយចេះក្បួនអីសក្តិសិទ្ធិម្ល៉េះ បានជាជួបនិយាយគ្នាពីរបីដង ស្រាប់តែត្រូវរ៉ូវគ្នា ?
មានសល់ក្បួនហ្នឹងទេ ចែកខ្ញុំប្រើខ្លះមក៎ ?
- នេះ សិលាពេញចិត្តនរណាគេមែនទេ ?
- មិនទាន់ទេ គ្រាន់តែលួចមើលគេភ្លៀកៗ មិនហ៊ាននិយាយអ្វី
ព្រោះមិនទាន់រកក្បួនឃើញសំរាប់ទាក់ទងគេ ។
- នរណាគេ ? ដាវីឬក៏ឆោម ?
- បងដាវិឌជួយគិតមើល ថាមួយណាសមនឹងខ្ញុំជាងគេ ?
- មិនដឹងទេ ព្រោះនោះសំរេចពីការពេញចិត្តផ្ទាល់ខ្លួន ។
- អញ្ចឹងជួយប្រាប់បានទេ ថាដាវីគេមានសង្សារហើយឬនៅ ?

CHANBOKEO.COM

- ឮថា គេមានហើយណា៎!
- ហើយចុះស្រស់ឆោមវិញ ?
- ក៏មានដែរ!
- តែ ប៉ុននេះ សិលាស្ទកស្ទើរអស់ស្រេច!

ដាវិដសើចខឹកៗឡើង ស្រដីលើកទឹកចិត្តទៅវិញថា ៖

- ថាមិនត្រូវទេ! ជួនកាលបុរសដែលនាងទៅមកនោះមានឋានៈត្រឹមតែជាមិត្តផងក៏មិនដឹង ។ ដំណើរជីវិតមើលមិនឃើញទេ ដូច តែខ្ញុំនិងអូនដាអញ្ចឹង មិនដែលស្គាល់គ្នាសោះ ដល់ស្គាល់គ្នាស្រាប់ តែមានចំណងចិត្តជំពាក់នឹងគ្នាភ្លាម ។ ដូច្នេះសិលាមិនត្រូវបោះ បង់ក្តីសង្ឃឹមទេណា៎ ។ ហើយនេះសិលាពេញចិត្តនរណាមួយក្នុងនារីរូបស្អាតពីរនាក់នោះ ?
- ខ្ញុំថា ពិបាករើសណាស់បើសម្លឹងលើតែរូបម្យ៉ាង ព្រោះគេមានសោភ័ណស្រស់ស្អាតមិនចាញ់គ្នាទេ ។ ប៉ុន្តែ បើនិយាយពីនិស្ស័យ ខ្ញុំថាខ្ញុំចូលចិត្តស្រស់ឆោមណាស់ គ្រាន់តែគេមានការចេះដឹងខ្ពស់ ជាងខ្ញុំ មិនដឹងថាគេយកភ្នែកមើលខ្ញុំដែលជាមនុស្សតូចទាបនេះ ដែរឬយ៉ាងណា...
- អ្នកស្រុកអាមេរិក គេមិនប្រកាន់ទាបខ្ពស់អ្វីទេ អោយតែគេពេញ ចិត្តស្រឡាញ់គ្នាដោយចិត្តនិងចិត្តនោះគ្រប់គ្រាន់ហើយ ។
- បើដូច្នេះមែន សិលាលួចសាងសេចក្តីសង្ឃឹមក្នុងចិត្តបន្តិចៗ សិនចុះ ក្រែងលោមានលាភ ។ អូហ៍! និយាយអញ្ចឹង អូនដា សារភាពហើយមែនទេ ថានាងក៏ជំពាក់ចិត្តលើបងដាវិដឯងដែរ ?
- អត់ទេ!
- អូហ៍ បើអញ្ចឹង បងដាវិដគិតតែម្នាក់ឯងទេ ?
- គឺ... ដាវិដមានទេវតាចាំគូសផ្លូវ ដាក់ជញ្ជាំងនាំមុខអូនដានោះអីមិនអោយនាងប្រទះបុរសណាទេក្រៅពីដាវិដឡើយ ។
- យី! ហេតុអ្វីក៏មានជំនឿម្ល៉េះ ?
- មកពីទេវតាបាននាំមាត់មនុស្សពីរនាក់ហើយ អោយមកជូនពរយើងទាំងពីរជាគូស្វាមីភរិយាតាំងពីយើងមិនទាន់ភ្ជាប់ពាក្យ ។
- មែនហ្ស៎ ?
- ហ្នឹងហើយ! ថាមិនជឿមិនបានទេ ។ សូម្បីតែល្ងាចនេះ ពេលខ្ញុំ

ទៅក្រាបបង្គំសុំខ្លួនធ្វើកូនប្រសារពីប៉ាម៉ាក់របស់សិលា ខ្ញុំក៏បាន
ទទួលការយល់ព្រមយ៉ាងស្រួលពីលោកដែរ ។ ចំណែករឿងដាវ៉ាន់ ក៏ដូចគ្នា.. សុខៗស្រាប់តែទេវតានាំមុខអោយអូនដាទៅជួបដាវ៉ាន់ នាំមកផ្ទះដោយស្រួលតែម្តង ។ ហេតុដូច្នេះ ខ្ញុំគិតថា ទេវតាបាន ត្រាយផ្លូវជីវិតអោយយើងជាគូនឹងគ្នាហើយ!

- អញ្ចឹង ខ្ញុំក៏សូមចូលដៃជាមួយទេវតាម្នាក់ទៀតចុះ ជូនពរអោយ បងចាប់ដៃគ្នាជាមួយអូនដាជាគូជីវិតយ៉ាងមានសេចក្តីសុខបំផុត!
- អរគុណសិលា ។

អ្នកទាំងពីរក៏ចាប់ដៃគ្នាឡើងយ៉ាងណែនសម្តែងនូវការរាប់អាន យ៉ាងជ្រាលជ្រៅរវាងគេទាំងពីរ ។

នៅម្ខាងទៀត ធីតានៅអង្គុយជិតម្តាយ ទះដៃបន្ទរឲ្យដាវ៉ាន់រាំ លេងយ៉ាងសប្បាយ ។ ដាវិនលួចអង្គុយគយគន់នាងយ៉ាងភ្លន់ភ្លឹក ឃើញ ធិតាសម្តែងចេញនូវសេចក្តីស្រឡាញ់ចំពោះដាវ៉ាន់ ដោយ សមានចិត្ត មិនមែនប្រឹងធ្វើព្រោះផ្គាប់ចិត្តនរៈយើងទេ ។ ពេលនេះ គេមានអារម្មណ៍ថា បេះដូងរបស់គេកំពុងទទួលឱសថទិព្វព្យាបាល បំណែករបួសឈឺចាប់នោះ អោយជាសះស្បើយមកវិញហើយ ។ ភ្លាមនោះ បេះដូងរបស់គេកំពុងរណ្តំប្រគំបទភ្លេងស្នេហាមួយបទ យ៉ាងរមណីយវិសាល... រកពាក្យអ្វីថ្លែងអោយ សមស្មើមិនបាន ឡើយ ។

អ្វីដែលគេសប្បាយបំផុតនោះគឺការផ្លាស់ប្តូររបស់សុធន ដែល ប្រែពីក្មេងចម្លងចរិតពាល មកជាកូនល្អរបស់ក្រុមគ្រួសារសាជាថ្មី ។ គេលួចរំភើបចិត្តម្នាក់ឯង កាលបើដឹងថា ការនិយាយដាស់តឿន សតិក្មេងអោយបានយល់ពីតម្លៃសីលធម៌និងវិន័យ បានធ្វើអោយ ក្មេងចេះគិតហើយចេះផ្លាស់ប្តូរមករកល្អវិញ ។ ពេលនោះ ដាវិន នឹកសរសើរសុធនតែក្នុងចិត្ត ព្រោះសុធនឆ្លៀវឆ្លាតឆាប់គិតយល់នូវ អត្ថន័យសំដីរបស់មាណព ហើយចេះកែប្រែខ្លួនបានឆាប់រហ័ស ។ ដាវិនគិតថា បើក្មេងទូទៅ អាចគិតឃើញហើយកែប្រែបានឆាប់ រហ័សនោះ មិនដឹងជាប្រទេសខ្មែរសង្គមខ្មែរមានបរិយាកាសល្អ រមនាយ៉ាងណា ។ ជាពិសេសទៅទៀតនោះ បើសិនជាក្មេងស្រុក ខ្មែរបានទទួលនូវឥទ្ធិពលថ្លៃថ្នូរពីអាមេរិក អំពីការសិក្សា អំពីវិន័យ

CHANBOKEO.COM

អំពីការសម្តែងសមានចិត្តចំពោះមនុស្សដូចគ្នា ការស្គាល់សីលធម៌ វិន័យច្បាស់លាស់ ស្គាល់តម្លៃគ្រួសារ ស្គាល់តម្លៃមនុស្សភាព នោះ ប្រហែលជាកូនខ្មែរមានការវិវត្តន៍ចំរើនទៅមុខ មិនចាញ់ល្បឿន អារ្យប្រទេសលើពិភពលោកនោះឡើយ ។

អ៊ំសាឡាងនិងអ៊ំសារីក៏ហាក់ដូចជាត្រៀមចិត្តទទួលស្គាល់ដាវីដ និងកូនស្រីរបស់គេ ចូលក្នុងចំណោមគ្រួសាររបស់គាត់ដោយមិន មានការទើសទាល់អ្វីដែរ ព្រោះគាត់គិតថា គ្រួសាររបស់គាត់មិន មែនជាអភិជនដែលគួរវាយឫកស្អូប់ខ្ពើមដាវីដឡើយ ។ ម្យ៉ាងទៀត វត្តមានរបស់ដាវីដមកក្នុងគ្រួសារ បានកែប្រែសុធនអោយភ្ញាក់ខ្លួន ចេះបែរត្រឡប់មករកក្រុមគ្រួសារវិញ ។ នោះជាកត្តាវិសេសបំផុត ដែលធ្វើអោយអ៊ំទាំងពីរគិតថា ដាវីដក៏មានលក្ខណៈសម្បត្តិល្អមួយ ដែលគាត់អាចទុកចិត្តបានជាកូនជាចៅយ៉ាងពេញមុខ ។

*ooooooooooooooooooo*

*ooooo*

*o*

CHANBOKEO.COM

# វគ្គទី៨
# វិវាទ

ពីរថ្ងៃបន្ទាប់មក...

ទាំងអស់គ្នាចេញប្រកបការងារដូចធម្មតា ។ អ៊ំសាឡានដែល តែងតែនៅចាំផ្ទះម្នាក់ឯង ក៏សុំឃាត់អោយដារ៉ាន់នៅលេងជាមួយ គាត់មួយថ្ងៃ ទុកអោយដាវិនជូនធីតាទៅសាលា ។

គ្រាន់តែបររថយន្តមកដល់មុខសាលា មិនទាន់ចតស្រួលបួល ផង ស្រាប់តែមានរថយន្តប៉ូលីសមកពទ្ធ័ឡានអ្នកទាំងពីរតែម្តង ៖

- មានរឿងអ្វីហ្នឹងបងដាវិន ?

ធីតាសួរទាំងភ្ញាក់ផ្អើល ។

- បងមិនដឹងទេ! យើងចេញទៅក្រៅស្តាបស្ថានការណ៍សិនទៅ!

អ្នកទាំងពីរក៏ចុះចេញពីរថយន្ត ស្រាប់តែប្រទះនឹងមេកង វរសេនីយ៍មួយរូបដែលយកដីការតុលាការមកហុចអោយអ្នកទាំងពីរ ហើយមានប្រសាសន៍ថា ៖

- យើងសូមឃាត់ខ្លួនអ្នកទាំងពីរមួយគ្រាសិន ។
- មានការអ្វីទៅលោកវរសេនីយ៍ ?
- គឺមានគេប្តឹងថា លោកកំពុងចាប់ជំរត់កូនក្មេង ដែលជាសាច់ ឈាមរបស់អ្នកស្រីម៉ារី ។ ចំណែកអ្នកនាង ខាងនេះ ត្រូវឃាត់ខ្លួន ពីបទឃុបឃិតអំពើឃាដកម្ម ដោយបានបង្កអោយមានជាលក្ខណៈ ឧប្បត្តិហេតុ ដើម្បីបំបាត់ដាន ។

ដាវិននិងធីតាបែរសម្លឹងមុខគ្នា ដោយការភ្ញាក់ផ្អើលបំផុត ។ បន្តិចមក ដាវិនស្រដីថា ៖

CHANBOKEO.COM

- ខ្ញុំសូមសួរលោកមេកងនូវសំណួរខ្លះៗសិនបានទេ ?

- បាទ បាន! អញ្ជើញ!

ដាវិតបែរមើលជុំវិញខ្លួន ក៏ឃើញមនុស្សម្នារត់មកចោមមើល គេទាំងពីរនាក់យ៉ាងអ៊ូអរ រួមទាំងសិស្សនិស្សិតនិងអ្នកស្រុកសាមញ្ញ ទូទៅ ។ គេក៏ហារមាត់និយាយឮៗ ទំនងចង់អោយអ្នកស្រុកបាន ឮដែរ ថា ៖

- លោកបានទទួលពាក្យបណ្ដឹងថា ខ្ញុំចាប់ពង្រាត់ក្មេងមែនទេ ?

- មែនហើយ!

- ហើយធ្វើម៉េចនឹងដឹងថា តើអ្នកដែលទៅប្ដឹងនោះ និយាយការ ពិត ? តើហេតុអ្វីបានត្រូវឃាត់ខ្លួនខ្ញុំផង បើសិនជាលោកមិនដឹង ផង ថាខ្ញុំចាប់ជំរត់ក្មេងនោះមែនឬក៏អត់ ? បើសិនជាមិនដឹងទេ តើគួរឃាត់ខ្លួនខ្ញុំដោយការឃុំឃាំងឬទេ ? ចំពោះនារីមួយរូបនេះ ក៏ដែរ! សុខៗក៏មានពាក្យបណ្ដឹង ហើយស្រាប់តែមានការចាប់ខ្លួន ដោយសាម៉ីខ្លួនគ្មានឱកាសការពារខ្លួន នោះមានន័យថា ការចាប់ខ្លួន នេះ មិនមានលក្ខណៈត្រឹមត្រូវទេ ។ ដូច្នេះ ខ្ញុំសូមដាក់ពាក្យប្ដឹង បកទៅវិញថា ខ្ញុំមានដីការពីអាមេរិក ដែលត្រូវមករកចាប់ខ្លួនអ្នក ដែលចាប់ជំរត់កូនស្រីរបស់ខ្ញុំ និងសូមប្ដឹងពីមនុស្ស ដែលឃុបឃិត លាក់ក្មេងហើយវាយធ្វើបាបដោយកម្លាំងកាយ ថែមទាំងលាក់មិន អោយអាជ្ញាធរចូលឆែកឆេររកក្មេងនោះ ដើម្បីយកមកប្រគល់ អោយអ្នកអាណាព្យាបាលរបស់គេវិញតាមច្បាប់ ។ ដូច្នេះសូមលោក វរសេនីយ៍កត់ហេតុហើយសូមទៅឃាត់ខ្លួនមនុស្សនោះអោយខ្ញុំផង ដើម្បីបង្ហាញយុត្តិធម៌ចំពោះអ្នកប្ដឹងគ្រប់គ្នា មិនថាដើមចោទឬចុង ចោទទេ ។

ភ្លាមនោះ ពួកកាសែតលើកកាម៉េរ៉ាយ៉ាងច្រើនច្រុះតែម្ដង ។ បន្តិចមក ដាវិដក៏បន្តទៀតថា ៖

- ខ្ញុំសប្បាយរីករាយនឹងទទួលទោស បើសិនណាជាបានប្រព្រឹត្ត ខុសពិតមែន ។ សូមបងប្អូនទាំងឡាយជួយធ្វើជាសាក្សីផង ។ លោកវរសេនីយ៍ សូមនាំខ្លួនខ្ញុំនិងនារីនេះ ទៅតុលាការដើម្បីជួប មុខអ្នកដែលប្ដឹងនោះ បានទេ ?

- គឺយើងត្រូវឃាត់ខ្លួនលោកសិន ទំរាំតុលាការបើកសវនា (លោក មេកងឆ្លើយ)

- ម៉េចចាំបាច់ឃាត់ខ្លួនផង បើលោកមិនដឹងផងថា ខ្ញុំជាមនុស្ស ទុច្ចរិតចាប់ជំរត់ក្មេងមែនឬក៏អត់ ? ហើយបើលោកស្ដាប់តែអ្នកប្ដឹង រួចមកចាប់ខ្ញុំនោះ

CHANBOKEO.COM

នោះខ្ញុំក៏សូមប្តឹងអ្នកម្ខាងនោះម្តង អោយលោក ទៅឃាត់ខ្លួនម្ខាងទៀតដូចគ្នា ទើបត្រឹមត្រូវស្មើភាព ។

- ប៉ុន្តែ គេមានកាន់ឯកសារមកប្តឹង ព្រោះគេមានលិខិតឆ្លងដែន មានសំបុត្រកំណើតរបស់ក្មេង ដែលមានឈ្មោះម្តាយត្រឹមត្រូវជា អាណាព្យាបាល (លោកមេកងឆ្លើយ)

- ល្អណាស់! បើដូច្នោះមែន ខ្ញុំក៏មានឯកសារដូចគ្នាសំរាប់បង្ហាញ នៅទីនេះតែម្តង ដោយមិនចាំបាច់ទៅដល់តុលាការទេ ហើយខ្ញុំក៏ សូមអញ្ជើញបងប្អូនដែលឈរនៅទីនេះទាំងប៉ុន្មានជួយធ្វើជាសាក្សី ផ្តល់យុត្តិធម៌អោយខ្ញុំ ដោយមិនចាំបាច់ចូលតុលាការ ។

ថាហើយ ដាវិនក៏លើកទូរសព្ទ័ឡើង ៖

- ដាវី! ឆោម! បងត្រូវការជំនួយពីស្ថានទូតអាមេរិក ត្បិតមាន គេកំពុងចង់រំលោភសិទ្ធិរបស់បងហើយ ។

ធិតានៅឈរកៀននោះសម្លឹងតាមដាវិនឥតព្រិច ឃើញគេមាន ភាពក្លាហាន មិនតក់ស្លុតខ្លាចការចោមរោមរបស់ប៉ូលីសសោះ ។ ចំណែកលោកវរសេនីយ៍ឈរនៅស្ងៀម ទំនងរង់ ចាំស្តាប់ការបំភ្លឺ របស់នរៈ ត្បិតមិនចង់ឲ្យខូចកិត្តិយសជាប៉ូលីស ចាប់មនុស្សខុស ។

រំពេចនោះ ដាវិនក៏ទាញក្រដាសមួយសំណៅលើករលាស់ឡើង ទៅលើអាកាស ហើយស្រែកប្រកាសថា ៖

- មានបងប្អូនណាមានកាម៉ារ៉ា ចង់ថតសំណៅនេះទុកទេ ?

រំពេចនោះ ស្រាប់តែមានសម្លេងមួយគំហកមកថា ៖

- ព្រហើន! ហ៊ានយករឿងសម្ងាត់ក្នុងគ្រួសារមកបកអាក្រាត នៅ កណ្តាលចំណោម មិនចេះអាមាស់!

ទាំងអស់គ្នា ភ្ញាក់ក្រញាង បែរមើលទៅម្ចាស់សម្លេងឃើញ អ្នកស្រីម៉ារីដើរចូលមក ដោយមានបុរសមាឌធំៗហែហមពីរបីនាក់ មកផង ។ លុះមកដល់ចំពោះមុខធីតានិងដាវិនហើយ ក៏ស្រដីថា ៖

- មុខក្រាស់! ទាំងប្រុស ទាំងស្រី!

រួចហើយ អ្នកស្រីក៏ស្ទុះទៅកញ្ឆក់យកក្រដាសពីដៃដាវិនយក ទៅហែកចោលខ្ទេកៗតែម្តង ។ ភ្លាមនោះ ដាវិនស្រដីថា ៖

CHANBOKEO.COM

- លោកវរសេនីយ៍ឃើញហើយឬនៅ ? ថាខ្ញុំកំពុងត្រូវគេប្លន់សិទ្ធិ យកអស់រលីង ?
សូម្បីតែក្រដាស ក៏គេប្លន់ពីខ្ញុំដែរ ។ ពេលនេះ
តើនរណាជាអ្នករងគ្រោះ ពិតប្រាកដ ?

លោកវរសេនីយ៍ និងក្រុមប៉ូលីសឈរទ្រឹង ហាក់ដូចជាខ្លាច អំណាចអ្នកស្រីម៉ារីណាស់
មិនឃើញមាននរណាហើបមាត់ទេ ។ ភ្លាមនោះ អ្នកស្រីលើកដៃចង្អុលមុខដាវីដ សម្តុតថា ៖

- ឯងដឹងទេ ថាទីនេះជាស្រុកខ្មែរ ! មនុស្សកំសុយដូចឯងនេះ កុំ
ចង់លេងជាមួយយើងអោយសោះ ។ លោកមេកង ! ចាប់ខ្លួនអ្នក ទាំងពីរទៅតុលាការ ។
យើងនឹងជួបគ្នាទីនោះ ក្នុងរយៈពេលមួយ ម៉ោងទៀត ។

ថាហើយ អ្នកស្រីក៏ដើរចេញទៅ ។

- សូមទោសណាំលោកដាវីដ ! ពេលនេះ ដើម្បីរក្សាការងារដែល ចិញ្ចឹមពោះខ្ញុំនិងក្រុមគ្រួសារ
ខ្ញុំត្រូវបង្ខំចិត្តចាប់លោកនិងអ្នកនាង ខាងនេះ ទៅតុលាការពេលនេះហើយ ។ កុំខឹងនឹងខ្ញុំអីណាំ !

លោកវរសេនីយ៍មានប្រសាសន៍ហើយ ក៏នាំខ្លួនដាវីដនិងធីតា ចេញទៅ ។ អ្នកស្រុក
អ្នកកាសែតជាច្រើនឆ្ងើលឈរទៅរកមើល គេកាត់ក្តីអ្នកទាំងពីរនៅក្នុងតុលាការ ។ ថៃដន្យ
ពេលទៅដល់ កង រក្សាសន្តិសុខមិនអនុញ្ញាតអោយអ្នកស្រុក ឬអ្នកកាសែតណាអាច
ចូលទៅក្នុងសាលជំនុំជំរះនោះឡើយ ក្រៅពីសាមីខ្លួនដែលទាក់ទង នឹងសាច់រឿងតែប៉ុណ្ណោះ ។

នៅក្នុងសាលជំនុំជំរះ...

អ្នកស្រីម៉ារីអង្គុយឆ្ងើមុខក្រញ៉ូវនៅទិសម្ខាងនៃសាលក្រម ។ រី
ឯដាវីដនិងធីតាត្រូវគេនាំចូលទៅអង្គុយនៅម្ខាងទៀត ។ លោកចៅ ក្រមក៏អញ្ជើញចូលមកដល់ ។

ភ្លាមនោះ អ្នកស្រីម៉ារីបានយកសំណៅឯកសារទៅបង្ហាញ តុលាការ បញ្ជាក់ថា
អ្នកស្រីបានទទួលសិទ្ធិពេញទីពីម្តាយរបស់ ដាវ៉ាន់
ដែលស៊ីញេប្រគល់សិទ្ធិមកអ្នកស្រីក្នុងការចិញ្ចឹមថែរក្សា
ដាវ៉ាន់ជាអាណាព្យាបាលអចិន្ត្រៃយ៍តែម្នាក់គត់ ។ បន្ទាប់មក អ្នកស្រី
ក៏ហុចក្រដាសដែលតុលាការខ្មែរផ្តាច់សិទ្ធិរបស់ដាវីដ ជាឪពុករបស់ ដាវ៉ាន់
ព្រោះខ្លួនមិនបានបំពេញនាទីត្រឹមត្រូវជាឪពុកនិងជាស្វាមី របស់គ្រួសារ
ថែមទាំងមានការបោះត្រាត្រឹមត្រូវពីតុលាការផង ។

CHANBOKEO.COM

អ្នកស្រីម៉ារីបានរៀបរាប់នូវការឈឺចាប់ ដែលភិសម័យកូនស្រី របស់អ្នកស្រីបានទទួលពេលនាងរស់នៅជាមួយដារិន ឯសហរដ្ឋ ។ អ្នកស្រីពោលរៀបរាប់ទាំងទឹកភ្នែកទឹកសំបោរ អាណិតស្រណោះកូន ដែលធ្លាប់រស់នៅស្រណុកសុខស្រួល រួចហើយក៏ក្លាយជាកូនសត្វ ជាប់ទ្រុងមិនអាចទៅណាមកណាបានក្រៅតែពីពឹងប្ដីអោយជួយ តែ ដារិនបែរជាព្រងើយកន្តើយនឹងការទទួលខុសត្រូវ ។ ម៉្វៃៗដារិន ចេះតែធ្វើអ្វីដើម្បីដារិនតែម្នាក់ ប៉ុន្តែមិនដែលខ្វល់បំពេញចិត្តអ្នក ដែលរស់នៅជាមួយជាប្រពន្ធ រហូតដល់នាងត្រូវបង្ខំចិត្តរត់ចោល ផ្ទះ នាំកូនត្រឡប់មកស្រុកខ្មែរវិញ ។

ដារិនអង្គុយស្ដាប់ការរៀបរាប់របស់អ្នកស្រីម៉ារី រហូតដល់ចប់ ចុងចប់ដើម ថែមទាំងនឹកសង្វេគក្នុងចិត្តថា ៖

- កាលយើងស្រឡាញ់គ្នា យើងថ្នាក់ថ្នមចិត្តគ្នាសព្វយ៉ាង ។ ប៉ុន្តែ នៅពេលយើងឈប់ស្រឡាញ់គ្នាវិញ ក៏ស្រាប់តែទៅជាអាក្រក់នឹង គ្នា លើសពីអ្នកដទៃដែលមិនធ្លាប់ស្គាល់គ្នាទៅទៀត ។ គិតទៅ មនុស្សយើងនេះមុខក្រាស់ចម្លែកណាស់... ដើម្បីឈ្នះ គេអាច គ្រលាស់អណ្ដាតពត់បែរទៅទិសណាស្រេចនឹងចិត្តគេតែម្ដង ថ្វីបើ ត្រូវមួលបង្កាច់ការពិតខ្លះៗក៏គេហ៊ានធ្វើដែរ ព្រោះតែដើម្បីឈ្នះ ម្យ៉ាងគត់ ។ តើគេយកឈ្នះមកធ្វើអ្វី ? តើការឈ្នះរបស់គេអាចនាំ អោយកូនចៅមានសេចក្ដីសុខជាងមុនទេ ? ហេតុអ្វី គេគិតតែពី អារម្មណ៍របស់មនុស្សចាស់ តែមិនគិតពីអារម្មណ៍របស់ក្មេង ? តើ គេមានដែលគិតទេថា ដាវ៉ាន់មិនដែលរស់នៅជាមួយម្ដាយរបស់ នាង តាំងពីយូរមកហើយ ? តើគេមានដឹងទេ ថាភិសម័យបាន ប្រព្រឹត្តអំពើមិនគប្បី ខុសសីលធម៌គ្រួសារ ? ហេតុអ្វីគេស្ដាប់ឮតែ សាច់រឿងខាងបដិបក្ខ ប៉ុន្តែ បិទភ្នែកមិនព្រមវិភាគសាច់រឿង របស់កូនចៅខ្លួន ថាតើការពិតវាយ៉ាងណាទៅវិញ ?

កំពុងតែពិចារណា ដារិនបានឃើញអ្នកស្រីម៉ារីលើកដៃចង្អុល មុខធីតា ហើយឡើងប្រកាសថា ៖

- ស្រីមួយរូបនេះ ជាបក្សពួករបស់នាយដារិន ដែលមានគម្រោង មកចាប់ជំរត់ចៅស្រីដាវ៉ាន់យកទៅអាមេរិកវិញ ។ ស្រីនេះបាន ឃុបឃិតទទួលលុយកាក់ ដើម្បីមកបង្កហេតុការណ៍អោយក្លាយទៅ ជាឧប្បត្តិហេតុ

CHANBOKEO.COM

ធ្វើអោយគ្រោះថ្នាក់ដល់ជីវិតរបស់ភិសម័យកូនស្រីខ្ញុំ រួចហើយឆ្លៀតឱកាសនោះ
ឆក់យកដាវ៉ាន់គេចពីពួកយើង ដោយ មិនបណ្តោយអោយប៉ូលីសចាត់ការតាមផ្លូវច្បាប់ ។
ពេលនេះ កូន ស្រីរបស់ខ្ញុំរបួសធ្ងន់នៅគេងពេទ្យ មានសង្ឃឹមតែពាក់កណ្តាលទេ
សូមតុលាការមេត្តាចាត់ការស្រីយាដករម្នាក់នេះផង ។

កាន់តែស្តាប់យូរទៅ ធីតាកាន់តែភ្ញាក់ផ្អើលឡើងដែលអ្នកស្រី
បង្កើតការមួយបង្កាច់យ៉ាងសមហេតុផលមួយ ដែលធ្វើអោយនាង
ក្លាយទៅជាមនុស្សអាក្រក់ដោយមិនដឹងខ្លួន ។

ពេលនោះ ដាវិដក៏បានត្រូវតុលាការហៅអោយឡើងទៅបក
ស្រាយការពារសាច់រឿងរបស់ខ្លួន ។ ដាវិដមិនទាន់បាននិយាយអ្វី មួយម៉ាត់ផង
ដាវីនិងស្រស់ឆោមក៏បានចូលមកដល់ដោយមាននាំ
អ្នកដំណាងមកពីទូតអាមេរិកមួយរូបមកជាមួយ ។ ភ្លាមនោះ អ្នក
តំណាងបានយកញត្តិតុលាការរបស់រដ្ឋកាលីហ្វ័រញ៉ា ព្រមទាំង សំណៅឯកសារកាត់ក្តីរបស់ភិសម័យ
កាលពីបួនឆ្នាំមុន យកប្រគល់ ជូនតុលាការខ្មែរពិនិត្យបន្ថែមទៀត ។

- នាងខ្ញុំសូមជំទាស់ !

អ្នកស្រីម៉ារីងើបឈរឡើង រួចហើយ ស្រដីថា ៖

- នោះគឺជាឯកសារបរទេស មិនអាចយកជាការនៅក្នុងតុលាការ ខ្មែរបានទេ
ព្រោះឯកសារដើមត្រូវបានហែក....

លោកចៅក្រមមានវាចាកាត់ភ្លាម ៖

- សូមរក្សាវិន័យផង អ្នកស្រីម៉ារី ! អ្នកស្រីអាចឡើងនិយាយបាន
ពេលណាតុលាការមានសំនួរចំពោះអ្នកស្រីតែប៉ុណ្ណោះ ។

អ្នកស្រីក៏អង្គុយទៅវិញធ្វើមុខក្រញ៉ូវ ។ លោកចៅក្រមបានរក ឃើញថា
ឯកសារដែលតុលាការអាមេរិកបានបញ្ជូនមកជាឯកសារ ពិតប្រាកដឥតក្លែងបន្លំ
បានបញ្ជាក់ថាភិសម័យទើបតែចេញពីមន្ទីរ ឃុំឃាំងកាលពីកន្លះខែមុននេះ ។ នៅក្នុងនោះ
តុលាការអាមេរិក បានដាក់បំរាមមិនឲ្យភិសម័យរក្សាកូន បានលើសពីពីរថ្ងៃក្នុងមួយ ខែ
បើសិនជាមិនទៅបន្តការព្យាបាលរោគចិត្តវិបត្តិ សតិវិបត្តិនិង
រោគកម្រោលបង្កដោយការញៀនស្រាញៀនថ្នាំញៀន ។

CHANBOKEO.COM

- ល្អ! (អ្នកស្រីម៉ារីនិយាយកាត់តុលាការ) បើដាវិដបណ្តោយឲ្យ ភិសម័យមើលកូនលើសពីពីរថ្ងៃ នោះមានន័យថា ដាវិដមិនគោរព តាមញត្តិរបស់តុលាការអាមេរិក ដូច្នេះ គឺគេទេដែលត្រូវទទួលទោស មិនមែនភិសម័យទេ ។

- អ្នកស្រីម៉ារី! ទីនេះ មិនមែនផ្ទះអ្នកស្រីអោយអ្នកស្រីចេចចាច តាមចិត្តនោះទេ ។ សូមរក្សាវិន័យភ្លាម (លោកចៅក្រមហាម)

- បើដូច្នោះ លោកមិនបាច់កាត់ក្តីរឿងដាវ៉ាន់និងដាវិដក៏បានដែរ ប៉ុន្តែ សូមតុលាការដាក់ទោសនារីមួយរូបនេះ ដែលបានបង្កហេតុ អោយកូនស្រីរបស់នាងខ្ញុំត្រូវរបួសជាទម្ងន់ ដើម្បីលួចយកដាវ៉ាន់ ទៅ ។

ពេលនោះ លោកចៅក្រម ហាក់ដូចជាមានការធុញទ្រាន់ណាស់ ដែលលោកត្រូវស្ត្រីមួយរូបតែងខ្លួនស្អាត យកសំដីជាអំណាចមក បង្គាប់លោកអោយធ្វើដូច្នេះ ធ្វើដូច្នោះតាមតែចិត្ត ។ លោកក៏បែរ មកសួរធីតាម្តង ។ នារីយើងក៏រៀបរាប់តាមតែដំណើរដែលនាង បានប្រទះ ថែដន្យ នាងមិនបានចាំថា នាយប៉ូលីសមួយរូបនោះ ដែលអនុញ្ញាត្តិអោយនាងយកដាវ៉ាន់មកផ្ទះនោះមានឈ្មោះអ្វី កាន់ នាទីជាអ្វី ដែលជាហេតុធ្វើអោយនាងស្ថិតនៅក្នុងចំណុចសង្ស័យ ព្រោះ ធីតាបានយកក្មេងដើរចេញពីម្តាយរបស់គេមក ដោយគ្មាន ច្បាប់ទម្លាប់ ។

អ្នកស្រីម៉ារីអង្គុយញញឹម ព្រោះឃើញធីតារកចម្លើយសមសួន មកបកស្រាយមិនបាន ។ បន្តិចមក តុលាការក៏សំរេចអោយធីតា ប្រគល់ក្មេងមកអោយតុលាការដើម្បីពិនិត្យតទៅទៀត ។ មិនបាន កន្លះម៉ោងផង សិលាក៏នាំនាងតូចដាវ៉ាន់មកដល់សាលជំនុំ ។ គ្រាន់ តែក្រឡេកឃើញមុខមនុស្សចម្លែកនៅទីនោះ ដាវ៉ាន់ក៏ទ្រហោយំ ឡើង ហើយរត់ទៅស្រវាអោបកឪពុករបស់នាងយ៉ាងណែន ។

តុលាការបែរមើលកិរិយារបស់កុមារីដោយស្ងៀមស្ងាត់ ។ បន្តិច មក តុលាការក៏បង្គាប់អោយកុមារីទៅសំពះសួរអ្នកស្រីម៉ារី ប៉ុន្តែ កុមារីបែរជាគ្រវីក្បាល ហើយលួចមើលអ្នកស្រីម៉ារីតាមកន្ទុយភ្នែក បញ្ចេញអាការៈហាក់ដូចជាខ្លាចអ្នកស្រីណាស់ ។ បន្ទាប់មក លោក ចៅក្រមសួរនាងតូចថា ៖

- នាងតូចស្គាល់បងស្រីខាងនេះទេ ?

លោកចៅក្រមចង្អុលទៅធីតា ។ ដាវ៉ាន់ងក់ក្បាល ។ លោក ចៅក្រមសួរទៀតថា ៖

CHANBOKEO.COM

- តើនាងតូចត្រូវបងស្រីខាងនេះ ធ្វើអ្វីខ្លះដល់នាងទេ ?
- គឺអោយបាយញុំា (នាងតូចឆ្លើយ)
- រួចហើយធ្វើអ្វីទៀត ?
- មុជទឹក ហើយលាបប្រេងកូឡាអោយ ។
- អូហ៍ ហេតុអ្វីចាំលាបប្រេងកូឡាផង ?
- ព្រោះវ៉ាន់ត្រូវម៉ាក់វ៉ៃ ។
- ម៉ាក់វ៉ៃ ?
- ចាំស !
- ត្រូវត្រង់ណាខ្លះ ?
- កាប៉េះគូថ ខ្នង និងក្រោមក្លៀក ។

លោកចៅក្រមក៏ងក់ក្បាល អោយប៉ូលីសនារីម្នាក់ចាប់នាងតូច យកទៅឆែកខ្លួន បន្តិចក៏ត្រឡប់មកវិញងក់ក្បាល ជំរាបតុលាការថា បានឃើញស្នាមរបួសពិតមែន ។ លោកចៅក្រមក៏សួរទៀតថា ៖

- ចុះពេលម៉ាក់វ៉ៃ មាននរណានៅខ្លះ ?
- មានលោកយាយ...
- លោកយាយណា ?

ដាវ៉ាន់ដៀងភ្នែកទៅរកអ្នកស្រីម៉ារី ហើយក៏នៅស្ងៀម ។

- ហើយចុះលោកយាយធ្វើយ៉ាងម៉េចទៀត ?
- លោកយាយថា វ៉ៃវាអោយងាប់ទៅ បើវាទារទៅឪវាវិញ ។
- កុហក ! (អ្នកស្រីម៉ារីស្ទុះងើបចង្អុលមុខចៅ) ហ៊ានបង្កាច់យើង ផង នាងល្អិត ?

ដាវ៉ាន់ភ័យណាស់ ងាកគេចមុខចេញទាំងភិតភ័យ ។

- សូមស្ងាត់អ្នកស្រីម៉ារី ! (លោកចៅក្រមគោះតុ រួចហើយបែរទៅ កុមារីសួរបន្តទៀត) ហើយថា យ៉ាងម៉េចទៀត ?

ដាវ៉ាន់បែរជាឆ្លើយថា ៖

- ថាច្រើន តែវ៉ាន់អត់ចាំទៀតទេ ។

ដាវ៉ាន់និយាយផង លួចដៀងភ្នែកទៅលើអ្នកស្រីម៉ារីមិនឈប់ ទេ ។ ពេលនោះ លោកចៅក្រម ក៏បែរទៅអ្នកស្រីម៉ារី រួចសួរថា៖

CHANBOKEO.COM

- តើអ្នកស្រីមានពាក្យពន្យល់ទេ ?

- ចឹក៏មិនមានលោកចៅក្រម! ពីរនាក់នេះបានយកក្មេងទៅពីរថ្ងៃ មិនដឹងថា បានបង្ហាត់អ្វីខ្លះដល់ក្មេង ទើបគេចេះបង្កាច់បង្ខូចជីដូន ទាំងរស់ដូច្នេះ ?

- ក្មេងគ្មានប្រាជ្ញដូចមនុស្សចាស់អាចក្រឡិចក្រឡុចបង្ខូចមនុស្ស ចាស់បានទេ អ្នកស្រីម៉ារី ។

- ម៉េចក៏ថាមិនបាន បើឪវាក៏ខូច នរណាៗដែលវាសេពគប់ក៏សុទ្ធ ទើបក្មេងវាខូចយ៉ាងហ្នឹង ។

- ថៃដន្យ តុលាការបានសំរេចចិត្តហើយថា យើងនឹងដោះលែង ដាវិឌនិងធីតាពេលនេះ ហើយក៏ដោះលែងដាវ៉ាន់អោយទៅឪពុក របស់គេដែរ ។

- មិនបានទេ! តុលាការអយុត្តិធម៌ ហេតុអ្វីកាន់ជើងជនបរទេស មើលងាយខ្មែរគ្នាឯង ? កាត់ទោសអោយជាតិឯងចាញ់គេដូច្នេះ ?

- អ្នកស្រីម៉ារី! ដាវិឌក៏ជាខ្មែរដែរ ថ្វីបើគេសញ្ជាតិអាមេរិក ។ តុលាការកាត់ទោសមានយុត្តិធម៌ហើយ ព្រោះមួយថ្ងៃមកនេះ យើង បានឃើញនឹងភ្នែកនូវសំដីដែលប្រកបដោយហឹង្សា និងការសម្លុត គម្រាមរបស់អ្នកស្រី លើជនស្លូតត្រង់សាមញ្ញ សូម្បីតែនៅចំពោះ មុខតុលាការ ។ មើលចុះ សូម្បីតែកុមារីតូចមួយ ក៏នាងដឹងថា នាង គ្មានសេចក្តីសុខដែរ ពេលគេនៅជាមួយអ្នកស្រី ។ កន្ទុយភ្នែកនិង កិរិយារបស់គេ បានបង្ហាញយ៉ាងជាក់ច្បាស់ថា គេស្រឡាញ់នរណា ខ្លាចនរណា ស្អប់នរណា ហើយអាចស្វែងសេចក្តីសុខបានជាមួយ អាណាព្យាបាលបែបណា ។ ពេលនេះ តុលាការសង្ឃឹមថា អ្នកស្រី នឹងទម្លាក់ចោលហឹង្សាចំពោះក្មេង ថ្វីបើឪពុកម្តាយរបស់គេមិនត្រូវ គ្នាក៏ដោយ ។ សូមមេត្តាកុំបង្រៀនអោយក្មេងយល់ភាពស្អប់ខ្ពើម ឪពុកម្តាយគេនៅក្នុងចិត្ត ព្រោះទោះជាយ៉ាងណា ទាំងសងខាងសុទ្ធ តែជាសាច់ឈាមរបស់ក្មេងស្មើៗគ្នា ។ សូមបង្រៀនឲ្យគេស្រឡាញ់ សាច់ឈាម មិនថាខាងឪពុកឬខាងម្តាយទេ... ឲ្យគេស្គាល់ថា ជីដូន ជីតាជាម្លប់ត្រជាក់របស់ចៅ កុំអោយការខឹងគុំគួនរវាងមនុស្សចាស់ នោះ ក្លាយជាកំណល់នាំចិត្តយើងអោយចង្អៀតបង្កគំនុំគុំគួន ហើយ ប្រព្រឹត្តហឹង្សាដាក់គ្នានៅចំពោះចៅតូចៗយ៉ាងនេះឡើយ ។ សូម អ្នកស្រី រំសាយកំហឹងនិងការគុំគួនស្អប់ខ្ពើមនោះទៅ!

តុលាការក៏បានរំសាយធីតាចេញពីក្តីដែរ ព្រោះនាងមិនបាននាំ នាងតូចរត់គេចពីកន្លែងកើតហេតុទេ ។ ផ្ទុយទៅវិញ នាងបានតាម

CHANBOKEO.COM

ទៅដល់មន្ទីរពេទ្យអង្គុយចាំរាប់ម៉ោង ចាំអាណាព្យាបាលអោយមក ទទួលក្មេង ដោយមានប៉ូលីសនិងគ្រូពេទ្យច្រវាត់ច្រវែងពេញមន្ទីរ ពេទ្យ ។ បើសិនជានាងមានគំរោងការពិតមែន ធីតាច្បាស់ជាមិន មកចំណាយពេលសំកុននៅមន្ទីរពេទ្យរាប់ម៉ោងដូច្នោះឡើយ ។

បន្តិចមក សាលក្រមក៏បិទសវនា ។ អ្នកទាំងឡាយក៏ថយចេញ ទៅអស់ នៅសល់តែអ្នកស្រីម៉ារីតែម្នាក់ដែលនៅឈរសំកុកក្ដាប់ដៃ ខាំធ្មេញតែម្នាក់ឯង...

ooooooooooooooooo

oooooo

o

CHANBOKEO . COM

# វគ្គទី៩
# ផ្សារនិស្ស័យ

នៅមាត់ទន្លេ...

ស្រស់ឆោមអង្គុយខាំអំពៅសាងបណ្តើរ ជជែកគ្នាបណ្តើរជា មួយសិលា ។ នៅម្ខាងទៀត ដារីកំពុងអង្គុយកាយផ្កាចំប៉ាក្នុង កន្ទោងដែលក្មេងស្រីតូចៗម្នាក់ដើរទូលលក់នៅម្តុំៗនោះ ។

- សិលាដែលនឹកប្រាថ្នាចង់ទៅឃើញអាមេរិកទេហ៎ ?

ស្រស់ឆោមសួរ ។

- ចឹមិនចង់ ប៉ុន្តែ មនុស្សដូចខ្ញុំ សំណាងអីទៅ ? លុយកាក់ក៏ គ្មាន តម្រេះក៏គ្មាន ជំនាញអ្វីក៏គ្មាន តើឲ្យទៅអាមេរិកយ៉ាងណា ?
- ម៉េចក៏ថាអត់ ? ចុះជំនាញខាងហ្គីតានោះ ?
- ហ៊ឺ! ជំនាញកំប៉ិកកំប៉ុកដូចខ្ញុំនេះ តើមាននរណាទៅគេមកកត់ សំគាល់នោះ ?
- គឺស្រស់ឆោមនោះអី! ប៉ុន្មានថ្ងៃនេះ សិលាអាល័យឈឺមិនបាន ទៅធ្វើការ ធ្វើអោយខ្ញុំនឹកស្នាដៃសិលាដល់ហើយ ។
- មែនហ្អែស ?
- មែនណា៎!
- អញ្ចឹង យប់នេះទៅមើលខ្ញុំកុំខាន ព្រោះខ្ញុំចូលសម្តែងវិញហើយ
- ច្បាស់ហើយ! សិលានឹងបានទទួលការលើកទឹកចិត្តពីស្រស់ ឆោមមុនគេ ។

សិលាញញឹមឡើងយ៉ាងស្រស់ ហើយស្រដីថា ៖

- ខ្ញុំច្បាស់ជារីកថ្លើមមិនខាន បើបាននារីសហរដ្ឋមកលើកទឹកចិត្ត!

CHANBOKEO.COM

ស្រស់ឆោមក៏ញញឹមដាក់វិញ ។ រំពេចនោះ ដារីក៏មកដល់ ហុចផ្កាអោយស្រស់ឆោម ៖

- យកចងសក់ខ្លះទៅ ឆោម ? នេះនែ៎ ផ្កាចំប៉ាក្រអូបណាស់! ខ្ញុំអោយក្មេងដល់ទៅម៉ាឌុល្លារឯណោះ ។
- ស្លាប់ហើយ! ទិញផ្កាចំប៉ាប្អូនប្រាំទង ហេតុអ្វីក៏អោយដល់ទៅ ម៉ាឌុល្លារ (សិលាលាន់មាត់)

ដារីក៏ឆ្លើយវិញថា ៖

- ឃើញគ្នាក្រនោះអី! មើលចុះអាយុមិនទាន់៧ឆ្នាំស្រួលបួលផង ដាក់ចង្អេរដើរទូលផ្កា ទូលនំលក់ សឹកក្បាលទំពែករកសក់ដុះមិន ឃើញផង... សាលាក៏មិនបានចូលរៀន ខោអាវស្លៀកពាក់ក៏រហែក ស្ទើរបិទខ្លួនមិនជិត ឃើញហើយគួរអាណោចអាធម្មណាស់...អោយម៉ាឌុល្លារក៏មិនសមនឹងភាពកំសត់របស់គេទេ ជាពិសេសបំផុតនោះ គឺគេមិនដើរលើកដៃសំពះសុំទានគេ ។ គេសុខចិត្តរកស៊ីដោយ កម្លាំងស្មារតីសុចរិត នោះជាតម្លៃគំរូល្អមួយដែលមនុស្សចាស់ខ្លះ គួរយកគម្រូតាម មិនគួរណានឹងដើរលើកដៃសំពះសុំទានគេទេ ។
- ហ៊ឺ! បងប្អូនគេពីរនាក់នេះ ទាំងបងដាវិឌ ទាំងដារី សុទ្ធតែ កំពូលអ្នកប្រាជ្ញខាងសង្គមហើយ ឃើញអ្វីៗវិភាគមិនឲ្យសល់សោះ
- គ្រាន់តែគិតលេងៗទៅណា៎!
- បើអាល័យតែគិតយ៉ាងហ្នឹង សប្បាយអ្វីទៅ ?
- គឺគិតលេងទៅ ក្រែងលោត្រឡប់ទៅអាមេរិកវិញ ដើរអង្គាសលុយយកមកជួយក្មេងក្រៗអោយបានរៀនសូត្រ ។ មើលតែស្រុក អាមេរិកចុះ គេបញ្ជូនក្មេងទៅរៀនតាំងពីតូចៗ ។ រីឯឪពុកម្តាយ ដែលមិនបញ្ជូនកូនទៅរៀន ក៏ត្រូវចាប់ផ្តន្ទាទោស ។ ដូច្នេះហើយ បានជាពលរដ្ឋស្រុកគេចេះអក្សរមានវិជ្ជាគ្រប់គ្នា មិនថាអ្នកមាន ឬអ្នកក្រទេ ។
- សង្ឃឹមថ្ងៃណាមួយ ប្រទេសយើងនឹងចម្លងអារិយធម៌នេះមក ស្រុកខ្មែរ ដើម្បីក្មេងៗបានចូលរៀនគ្រប់គ្នាហើយ (សិលាពោល)
- ខ្ញុំថា បើជាតិយើង ផ្ទុងផ្តើមបណ្តុះការងារសំរាប់មនុស្សពេញវ័យ កាត់ភាពក្រីក្របាននោះ គ្រួសារនិងមានជីវភាពប្រសើរជាងមុន ។ ពេលនោះ ឪពុកម្តាយមិនចាំបាច់បញ្ជូនកូនអោយដើរលក់នំ លក់ផ្កា ទេ រួចពួកគេច្បាស់ជាបានចូលរៀនមិនខាន (ស្រស់ឆោមពោល)

CHANBOKEO.COM

- យី! ហេតុអ្វីថ្ងៃនេះ ឆោមក្លាយជាវិរជនស្នេហាជាតិប្លែកម្ល៉េះ ?
នេះប្រហែលជាជាប់ស្នេហ៍ភ្នំពេញហើយទេដឹង ? (ដាវីចំអន់)

ស្រស់ឆោមលួចចោលកន្ទុយភ្នែកដាក់សិលា ហើយក៏ស្រដីថា៖

- មកពីអ្នកភ្នំពេញគួរឲ្យស្រឡាញ់ហ្នឹងណា៎ បានជាខំលួចស្នេហ៍ លេងៗទៅ ។

សិលាឮហើយ នឹករអៀសខ្លួន ស្លឹកត្រចៀកឡើងក្រហមឆ្អាំង តែម្ដង ។

ថ្ងៃបន្ទាប់មក...

ដារិនាំដារ៉ាន់មកដល់ផ្ទះអ៊ំសាឡាង ។

- ជំរាបសួរ បាទ!
- អឺ! ចូលមកដារិន! ថ្ងៃនេះ ធីតាមិនស្រួលអារម្មណ៍សោះ តាំង ពីមកដល់ពីសាលាវិញ ។
- អូហ៍... មានរឿងអ្វីទៅ ?
- គឺ ប្រហែលជារឿងរៀនសូត្រហើយ ឃើញយំឡើងក្រហមភ្នែក ឯណោះ ។

ដារិនផ្ញើដារ៉ាន់អោយនៅលេងជាមួយអ៊ំទាំងពីរ រួចហើយក៏ ដើរទៅរកធីតា ឃើញនាងអង្គុយសំកុកត្របោមជង្គង់នៅមាត់ទ្វារ បន្ទប់ ៖

- ដា! មានរឿងអ្វីហ្នឹង ?

ដារិនស្រដីផង ដាក់ខ្លួនអង្គុយក្បែរនាងផង ។

- គឺ... ដាប្រឡងធ្លាក់...
- មែនឬដា! គួរអោយសោកស្ដាយណាស់ ។ នេះប្រហែលមកពី ប៉ុន្មានថ្ងៃនេះ ដាមានជំពាក់ជាប់រវល់នឹងរឿងដារិនច្រើនពេកទេ ដឹង ទើប...

មែនហើយ! ការពិតគឺដូច្នោះមែន ។ ពីរបីថ្ងៃដែលធីតាប្រទះ នឹងរឿងរបស់ដារិន ក៏ជាពីរថ្ងៃដែលនាងត្រូវមានថ្នាក់ប្រលងដែរ ប៉ុន្តែធ្វើម្ដេច បើស្ថានការណ៍វាទាញផ្លូវជីវិតនាងទៅបែបនោះទៅ ហើយ ។

ដារិនសម្លឹងមុខធីតាមួយស្របក់ក៏លូកដៃជូតទឹកភ្នែកឲ្យនារី ៖

- មិនអីទេដា ! ធ្លាក់លើកនេះ នៅមានលើកក្រោយទៀត ដែល អូនអាចមានឱកាសអាចទៅប្រឡងម្ដងទៀតបាន ។
- តែឱកាសនោះ មានដល់ទៅឆ្នាំក្រោយឯណោះ ។ ដាត្រូវរៀន យឺតដល់ទៅមួយឆ្នាំទៀតហើយ ។
- យឺតក៏ប្រសើរជាងខានដែរ ណា៎ដា ។ ការពិត អ្វីៗទាំងអស់នេះ

CHANBOKEO.COM

ជាកំហុសរបស់បងទេ ។ មិនគួរណាបងនាំទុក្ខដល់អូនសោះ ។

- មិនមែនកំហុសនរណាទេ បងដារិន! វាជាដំណើរជីវិត ដែល
ទេវតាបានចារកំណត់មកយ៉ាងដូច្នេះទៅហើយ ។

រំពេចនោះ ស្រាប់តែដារិនញញឹមឡើង ៖

- បើដូច្នេះមែន អូនឈប់ស្រក់ទឹកភ្នែកទៅ ហើយញញឹមទទួល ដំណើរជីវិតនោះទៅណា៎
រួចហើយដើបតស៊ូសាជាថ្មី....
- បងដារិន មិនខកចិត្តទេឬ ដែលដាប្រឡងធ្លាក់ ?
- ខកចិត្តរឿងអ្វីទៅ ?
- ព្រោះបងត្រូវជួយរកអាហារូបករណ៍ អោយដាទៅរៀនបន្ត នៅ អាមេរិកនោះអី ។
បើដាប្រឡងធ្លាក់ តើនរណាគេអោយប្រាក់ទុន សំរាប់ដារៀនបន្តទៅទៀត ?
- ទោះអូនប្រឡងធ្លាក់ ក៏អូននៅតែបានទៅរៀនអាមេរិកដដែល ហ្នឹង!
- ម៉េចអញ្ចឹងទៅវិញ ?
- ព្រោះអាហារូបករណ៍នោះប្រើសំរាប់តែជួយអូនដាម្នាក់គត់ ។
- មានន័យថាម៉េច បងដារិន ?
- គឺបងជាអ្នកធានាអូនអោយទៅរៀននៅទីនោះ នោះអី ។

ស្រាប់តែ ធីតាជូតទឹកភ្នែក ហើយបើកភ្នែកមូលក្លំដាក់ដារិន៖

- ពន្យល់ខ្ញុំបានទេ បងដារិន ?
- គឺបងបានជំរាបប៉ាម៉ាក់អូនហើយ ថាបងនឹងធានាយកអូនទៅ រៀននៅទីនោះ
ដើម្បីអោយអូនមានឱកាសឆក់យកវិជ្ជាស្រុកគេ ផង មានឱកាសរៀនទម្លាប់ខ្លួនរស់នៅឆ្ងាយផ្ទះ
ហើយអាចបត់បែន តាមសង្គមគេទាន់ផង រួចជាពិសេសទៅទៀត...
- ពិសេស ?
- ហ្នឹងហើយ... ពិសេសជាងគេ គឺបងចង់អោយដាយកពេលមើល
បង ហើយពិចារណារូបបងខ្លះ ថាតើយើងអាចក្លាយជាគូជីវិតនឹង គ្នាបានដែរឬយ៉ាងណា ។ ដា!
ដឹងទេ! បងបានទទួលបរាជ័យម្តង ហើយអំពីជីវិតគូស្រករ ព្រោះកាលនោះ
បងមិនបានគិតវែងឆ្ងាយ អ្វីទេ ។ បងគិតតែម្យ៉ាង គឺចង់បានប្រពន្ធស្រស់ស្អាតសោភា ។
កាលនោះ បងក៏បានរៀបការជាមួយនារីសោភាពិតមែន ប៉ុន្តែ ជីវិតគ្រួសាររបស់បង
មិនបានទទួលសុភមង្គលឡើយ ។ ទីបំផុត បងក៏ក្លាយជាអ្នកបំរើគ្រួសារ

CHANBOKEO.COM

ផ្គាប់ចិត្តប្រពន្ធគ្រប់យ៉ាងហើយនៅតែ ខុសដដែល ។ ចំណែកកូនវិញ
ក៏ក្លាយជាក្មេងខ្វះការកក់ក្ដៅ ព្រោះ ម្ដាយរបស់គេ
មិនអាចទ្រាំទ្រនឹងការផ្លាស់ប្ដូរក្នុងជីវិតរបស់នាង បាន ។ បងមិនបន្ទោសនាងទេ...
បងបន្ទោសខ្លួនឯងដែលមិនបាន គិតវែងឆ្ងាយ មិនបានត្រៀមខ្លួនចំពោះសភាពផ្លាស់ប្ដូរនោះ ។
គេ មិនធ្លាប់រស់នៅធ្វើអ្វីដោយខ្លួនឯង គេមិនធ្លាប់នឹងជីវិតគ្រួសាររបស់ អ្នកធ្វើការផង
អ្នករៀនសូត្រផង ដូចបងនេះ... គេមិនធ្លាប់ពុះពារ មិនធ្លាប់ហត់នឿយ
ពោលគឺគេធ្លាប់រស់នៅក្នុងជីវិត ដែលមានគេ ផ្គាប់ចិត្តព្រឹកល្ងាច ធ្លាប់មានប្រាក់ចាយវាយ
ដើរលេងមានសេរីភាព សព្វបែបយ៉ាង... ប៉ុន្តែ ពេលគេមកដល់អាមេរិក បងបំពេញតាម
ចំណង់របស់គេមិនបាន.... ពេលនោះហើយដែលគេក៏បែរខ្នង ដើរ ចេញពីជីវិតបងទៅ
ដោយឥតអាល័យ....

ដារិនរលីងរលោងទឹកភ្នែក ដាក់មុខជ្រប់ ។ ធីតាឃើញដូច្នោះ
ក៏ពោលកម្លាលើកទឹកចិត្តឡើងថា ៖

- ជួនកាល ការចែកផ្លូវគ្នាដើរក្នុងជីវិត វាប្រសើរជាងការរស់នៅ រួមជីវិតជាមួយគ្នា
រកាំរកូសរាល់ថ្ងៃដែរ ។ ជួនកាល ការបែកគ្នាជា ចំណុចផ្លាស់ប្ដូរ
ដើម្បីអនុញ្ញាតអោយមនុស្សរាវរកផ្លូវថ្មី ឆ្ពោះទៅ រកសុភមង្គលថ្មី ដែលពុំមានការរកាំចិត្ត
ពុំមានវិស្ថានតទៅទៀត ក៏មិនដឹង ។

ដារិនសម្លឹងធីតាដោយក្រសែភ្នែកយ៉ាងស្រទន់ ៖

- អូនដានិយាយត្រូវណាស់ ។ ការចែកផ្លូវគ្នាដើរ គឺជាចំណុចផ្លាស់
ប្ដូរដើម្បីអោយយើងមានឱកាសកែស្ថានភាពក្នុងជីវិតសាជាថ្មី បែរ
ជ្រើសរើសគូស្រករដែលសក្តិសមគ្នាដោយសម្បទា ដោយចិត្តគំនិត ដោយការប្រព្រឹត្ត
ដោយការពិសោធន៍ មិនមែនស្ថិតនៅលើតែរូប សម្បត្តិតែម្យ៉ាងនោះទេ ។ ពេលនេះ
បងបានគិតគូរគម្រោងជីវិតថ្មី ហើយ មិនអោយមានកំហុសវេទនាដួងចិត្តដូចលើកមុនឡើយ ។

ធីតាសម្លឹងមុខនរៈដោយក្រសែភ្នែកយ៉ាងមុត សួរថា ៖

- ហើយគម្រោងថ្មីរបស់បងនោះ មានដំណើរយ៉ាងម៉េចដែរ ?
- គឺបងចង់ធានាអូនដាជាសិស្សនិស្សិត ចូលរៀនបន្តនៅមហា វិទ្យាល័យ
អោយអូនមានឱកាសស្គាល់ជីវិតទីនោះអោយបានច្រើន ដោយខ្លួនឯង ដឹងក្ដៅដឹងត្រជាក់
មិនអោយអូនដាក្លាយជាបន្ទុក របស់បងដូចកុមារីម្នាក់ឡើយ ។ បងចង់អោយដារីងប៉ឹងហើយចេះ

CHANBOKEO COM

ជួយខ្លួនឯង ។ បងនឹងទំនុកបំរុងលុយកាក់ខាងការសិក្សា ប៉ុន្តែ ដា ត្រូវស្វែងរកជោគជ័យ ដោយសមត្ថភាពរបស់ដាផ្ទាល់ ។ រួចហើយ យើងនឹងយកឱកាសមើលគ្នាទៅវិញទៅមក ថាតើជីវិតរបស់យើង អាចចុះសម្រុងនឹងគ្នាឬយ៉ាងណា ។ បងមិនចង់រៀបការជាមួយគ្នា ហើយ ត្រូវខកចិត្តក៏ចែកផ្លូវគ្នាវិញទេ ។ វាឈឺចាប់ណាស់ ពេល ណាជីវិតគូស្រករត្រូវដើរដល់ផ្លូវបំបែក ។ ប៉ុន្តែ បើសិនជាយើង យល់ពីគ្នា ដោយយកលក្ខណៈគុណសម្បត្តិច្រើនយ៉ាងជាគោល លើសពីរូបសម្បត្តិ ហើយសំរេចចិត្តរៀបការនឹងគ្នានោះ បងយល់ ថាជីវិតគ្រួសាររបស់យើងនឹងមានលំនឹង ហើយមានសុភមង្គលជាទី បំផុត ព្រោះយើងយល់ទុក្ខធុរៈរបស់គ្នាទៅវិញទៅមក ។

- ហើយបងនឹងគិតយ៉ាងណា បើសិនដារៀនមិនបានជោគជ័យដូច បំណងដែលបងគិត ?
- ប្រឹងតាមតែសមត្ថភាពទៅ ។ អោយតែបងបានឃើញការប្រឹង ព្យាយាមរបស់ដា ទោះជាប់ឬក៏ធ្លាក់ ក៏បងពេញចិត្តទទួលលទ្ធផល នោះដែរ ព្រោះបងស្រឡាញ់ដា ទាំងពេលដែលដាជោគជ័យ ទាំង ពេលដែលដាធ្លាក់រាសី ។ បងនឹងផ្តល់កម្លាំងចិត្តអោយដា រហូតដល់ ថ្ងៃមួយដែលដាអាចក្រោកឡើងរៀនរហូតដល់ជោគជ័យម្តងទៀត ។ សូមតែម្យ៉ាង គឺកុំអោយតែលះបង់ការសិក្សា ហើយភ្លើតភ្លើនក្នុង សង្គមឈាមរាវបានហើយ ។
- ចុះបើដាទទួលជោគជ័យហើយ ប៉ុន្តែ ដាទទួលឥទ្ធិពលថ្មី រួច ហើយដើរចេញពីជីវិតបងទៅវិញនោះ បងមិនខកចិត្តទេឬ ?
- ចឹក៏មិនខក! ប៉ុន្តែ ក៏ប្រសើរជាងរៀបការរួចហើយបែកគ្នាដែរ ថ្វីបើបងនឹងត្រូវឈឺចាប់ក្នុងចិត្តខ្លះក៏ដោយ ។ ប៉ុន្តែ បងជឿថា មនុស្សដូចអូនដា ដែលមានចិត្តរឹងប៉ឹងយ៉ាងនេះ ប្រាកដជាមិន ទទួលឥទ្ធិពលជីវិតថ្មី ហើយដើរធ្លាក់ខុសផ្លូវ វង្វេងពីបងទេ ។
- តើហេតុអ្វីទៅដែលធ្វើអោយបងហ៊ានប្រថុយយកជីវិតមកអោយ ដាជ្រើសរើសដោយមិនខ្លាចខកចិត្ត ?
- ប្រហែលជាមកពីនិស្ស័យទេដឹង ? គឺបងពេញចិត្តដា តាំងពី ពេលបងឃើញដា លើកដំបូងម្ល៉េះ... ប៉ុន្តែ បងក៏មិនទាន់សុំដា រៀបការភ្លាមដែរ... ថ្វីបើបងបានសុំដណ្តឹងអូនពីប៉ាម៉ាក់អូនមែន គឺ បងចង់ទុកពេលអោយអូនគិត...ក្នុងខណៈដែលយើងនៅជាគូដណ្តឹង នឹងគ្នា

CHANBOKEO.COM

ប្រសើរជាងបង្ខំអោយអូនរៀបការតាមអារម្មណ៍ស្នេហារបស់ បង...
បងចង់ទុកពេលអោយអូនមើលបងអោយបានច្បាស់ !

- តើបងជឿជាក់ទេ ថាយើងអាចក្លាយជាគូជីវិតនឹងគ្នា ?
- បងជឿដល់ទៅ២០០ភាគរយឯណោះ !
- ហេតុអ្វីទៅ ?
- ព្រោះយើងមានចិត្តគំនិតដូចគ្នានោះអី ហើយអូនក៏ធ្លាប់ឆ្លងកាត់ ជីវិតតស៊ូប្រឹងធ្វើអ្វីៗដោយខ្លួនឯង ដោយគ្មានគេបំរើ យកការ សិក្សាជាគោល ស្រឡាញ់គ្រួសារ មិនខ្ជះខ្ជាយ មិនភ្លើតភ្លើន តាមសង្គមយុវវ័យ មិនទទួលឥទ្ធិពលពិសពុលសង្គមឈាមរាវ... នោះគឺជាកត្តាគុណសម្បត្តិដ៏ល្អប្រសើរបំផុត ដែលបងចង់បាន ។
- ជួនកាលមនុស្សយើងអាចផ្លាស់ប្តូរបានដែរ ពេលខ្លួនដើរចូល រង្វង់សង្គមថ្មីមួយទៀត បន្ទាប់មកក៏ភ្លេចដានចាស់...
- អ្នកដែលផ្លាស់ប្តូរយ៉ាងចម្លែកនោះ គឺអ្នកដែលខ្វះភាពរឹងប៉ឹងក្នុង ជីវិត ជាពិសេសអ្នកដែលមានជីវិតពឹងលើលុយនិងបុណ្យសក្តិតែ ម្យ៉ាង ។ កាលបើគេបានប្រទះជីវិតមួយដែលគ្មានលុយ គ្មានបុណ្យ សក្តិគ្មានអំណាច គេមិនអាចទ្រាំទ្របានទេ ។ គេនឹងរកមធ្យោបាយ ថ្មីហើយធ្វើយ៉ាងណាអោយបានលុយឆាប់ៗ ដើម្បីទិញភាពស្រណុក សុខសប្បាយរបស់គេបន្តទៅទៀត ។ ពេលនោះហើយដែលគេ វង្វេង... ព្រោះគេធ្វើអ្វីៗដើម្បីលុយតែម្យ៉ាង ដោយមិនគិតពីភាព ថ្លៃថ្នូរ ។ ចំពោះអ្នកដែលរឹងប៉ឹង ចេះរស់ដោយពឹងលើកម្លាំង សមត្ថភាពខ្លួនឯង គេតែងយកសេចក្តីថ្លៃថ្នូរជាគោល ប្រព្រឹត្តអ្វី គិតអ្វី តែងយកសតិប្រាជ្ញជាគោល... បងថាដាពិតជាមិនមើល រំលងបងទេ ។
- ថាមិនត្រូវទេ... នៅអាមេរិកធំដល់ម្លឹង ខ្វះអ្វីបុរសល្អ ដែលអាច អោយដាសម្លឹងនោះ ?

ដារិដញញឹម ហើយឆ្លើយថា ៖

- នោះហើយដែលបងចង់បាន គឺបងផ្តល់សិទ្ធិអោយអូនសម្លឹង បុរសគ្រប់គ្នា ពេលអូនទៅដល់អាមេរិក ហើយអោយសម្រេចចិត្ត ដោយខ្លួនឯង ។ បងសន្យាថា នឹងប្រកួតជាមួយបុរសទាំងនោះ តាមរបៀបអ្នកកីឡា ចង់ដឹងថា តើបេះដូងរបស់ដាពេលនោះ នឹង ដេញតន្ត្រីបទចំរៀងអ្វី ដើម្បីនរណា នៅពេលអូនរៀនចប់ ។

ធីតាបែរសម្លឹងកែវភ្នែកដារិដ ដែលកំពុងសម្លឹងមកនាងយ៉ាង ភ្លឺថ្លា រួចហើយស្រដីសួរទាំងអៀនប្រៀនថា ៖

CHANBOKEO.COM

- បងដារិងជឿជាក់ទេ ថាបងនឹងបានទទួលពិន្ទុលើសគេដើម្បីទិញ សំបុត្រចូលស្តាប់តន្ត្រីដែលប្រគំក្នុងបេះដូងរបស់ដា ?

- អូនចង់សាកទេ ថាបងជឿជាក់ខ្លាំងមហិមាប៉ុនណា ?

ភ្លាមនោះ គេញញឹមដាក់នារីយ៉ាងបំព្រងតែម្តង រហូតដល់នារី នឹកអៀនក្រសៃភ្នែកបុរសរួចហើយក៏គេចមុខចេញភ្លាម មិនឲ្យ នរៈចាប់ចំណុចខ្សោយក្នុងដួងចិត្តរបស់នាងបាន ។ ដារិដក៏ស្រដី បន្តទៅទៀតថា ៖

- ប៉ុន្តែចំពោះបេះដូងរបស់បងវិញ មានតន្ត្រីប្រគំរួចហើយ រង់ចាំតែម្ចាស់បទគេមកច្រៀងបន្ទរតែប៉ុណ្ណោះ ! ដាចង់ដឹងទេ ថាម្ចាស់បទចម្រៀងមួយនោះជានរណា ?

មួយឃ្លានេះ រិតតែធ្វើអោយធីតារិតតែអៀនឡើងក្រៃណា រក ពាក្យឆ្លើយមិនរួចក៏ដើបរត់គេចចេញទៅ ទុកអោយដារិងបែរតាម មើលពីក្រោយក្នុងក្រសៃភ្នែករំភើបដោយក្តីស្នេហា ។

*oooooooooooooooo*

*ooooo*

*o*

CHANBOKEO . COM

# វគ្គទី១០
# ខ្ទក់ចិត្ត

ព្រឹកស្អែកឡើង...

ដាវិនដឹកដៃកូនឡើងរថយន្តជូនធីតាទៅដាក់ពាក្យសុំសម្ភាសន៍ នៅទូតអាមេរិក
ដើម្បីចូលរៀននៅមហាវិទ្យាល័យមីនីសូតា ។ លុះ ត្រឡប់ចេញមកវិញ
ស្រាប់តែប្រទះនឹងបុរសម្នាក់ដែលមកចាំស្ទាក់ ផ្លូវអ្នកទាំងពីរ ។ ដាវិនភ្ញាក់ក្រញាង ៖

- បងប្រុសមានការអ្វីដែរ ?
- មានគេផ្ញើសំបុត្រជូនលោក!

ដាវិនលើកដៃទទួល ។ បុរសនោះក៏ឡើងម៉ូតូចេញទៅ ។

- សំបុត្រអ្វីគេហ្នឹង បងដាវិន ? (ធីតាសួរ)
- បងមិនដឹងទេ អូនដា ។

ដាវិនស្រដីផង ហែកសំបុត្រអានផង មានសេចក្ដីថា ៖

- ដាវិន! ភិសម័យសូមជួបកូនមួយភ្លែតបានទេ មុននឹងបងឡើង យន្តហោះ
នាំដាវ៉ាន់ទៅអាមេរិកវិញ នៅរវាងពីរបីថ្ងៃទៀតនេះ ?
សុំជួយបំពេញបំណងចុងក្រោយរបស់ភិសម័យផងណា៎បង!

ដាវិនសម្លឹងមុខធីតា រួចហើយសម្លឹងមុខដាវ៉ាន់ បន្តិចមក ក៏ ស្រដីថា ៖

- យើងទៅមន្ទីរពេទ្យមួយភ្លែត បានទេដា ?

ធីតាមិនហ៊ានប្រកែកទេ ប៉ុន្តែ ក្នុងចិត្តហាក់ដូចជាគ្មានអារម្មណ៍ ល្អអ្វីបន្តិចសោះ ។
មួយស្របក់ក្រោយមក អ្នកទាំងបីក៏បានមកដល់ មន្ទីរពេទ្យ ស្រាប់តែលោកគ្រូពេទ្យប្រាប់ថា

CHANBOKEO.COM

អ្នកជម្ងឺបានត្រូវក្រុម គ្រួសារយកទៅផ្ទះ ដើម្បីអោយគ្រូពេទ្យប្រចាំគ្រួសារផ្ទាល់ខ្លួនជាអ្នកថែរក្សា ។

- យើងមិនគួរទៅផ្ទះគេទេនឹង បងដាវិង ?
- ប៉ុន្តែ វាជាបំណងចុងក្រោយរបស់ភិសម័យ ដើម្បីជួបមុខកូនស្រី របស់គេណា៎អូនដា ។ បើយើងមិនធ្វើតាមដូចជាអាក្រក់មើលពេក!
- ប៉ុន្តែដាមានប្រផ្នូលមិនល្អក្នុងចិត្តសោះ ។
- បងថាមិនអីទេ ព្រោះតុលាការបានជំរះក្ដីជ្រះស្រឡះហើយ ។ ទោះយ៉ាងណាក៏គេមិនហ៊ានចាប់ដាវ៉ាន់ជំរត់ដែរ ។

ថាហើយ ដាវិងក៏បញ្ជាឲ្យអ្នកបើកបរនាំគេទាំងបីចេញទៅផ្ទះ អ្នកស្រីម៉ារី ។ នៅក្នុងរថយន្ត ធីតាអង្គុយធ្វើទឹកមុខហ្មួហ្មងដែលគេ នឹងដាវិងនិយាយមិនត្រូវគ្នាជាលើកទីមួយ ។

មកដល់មុខវិឡាអ្នកស្រីម៉ារី ដែលមានអ្នកយាមប្រចាំការនៅ យាមម្នាក់ ស្លៀកពាក់ឯកសណ្ឋានយ៉ាងស្អាតបាត រត់ទទួលដាវិង និងនាងតូច ស្រាប់តែគេឃាត់ធីតាមិនអោយចូលទៅក្នុងផ្ទះរបស់ អ្នកស្រីម៉ារីទេ តែឲ្យនាងនៅអង្គុយចាំក្នុងសួនច្បារមុខផ្ទះ ។ ដោយ ទើសទាល់ ធីតាក៏ដាក់ខ្លួនអង្គុយចុះលើកៅអីថ្មរង់ចាំ ។ ដាវិង ឃើញដូច្នោះ ក៏ងាកមកផ្ដាំនារីថា ៖

- ដា! បងទៅតែម៉ាភ្លែតទេ បន្តិច បងមកវិញហើយណា៎ ។

ធីតាងក់ក្បាល ហើយបែរសម្លឹងតាមដាវិងនិងនាងតូច ។

តាមប្រឡោះទ្វារដែលបើកយ៉ាងទូលាយ ធិតាឃើញគេរុញ ភិសម័យក្នុងរទេះអ្នកជំងឺមកជួបដាវិង ។ ភ្លាមនោះ នាងឃើញ ភិសម័យស្រវាអោបនាងតូច មួយស្របក់មកក៏និយាយជាមួយ ដាវិង រួចហើយអ្នកទាំងពីរក៏ស្រវាអោបគ្នាយ៉ាងណែន ។ ភ្លាមនោះ ធីតាជ្រួញចិញ្ចើម រួចហើយក៏លែងមានអារម្មណ៍ល្អតែម្ដង ។ មាណវីដើបឈរឡើង បំរុងនឹងដើរចេញទៅហើយ ស្រាប់តែ ឮសម្លេងស្ត្រីម្នាក់ស្រដីខ្លាំងៗ នៅក្នុងផ្ទះថា ៖

- បើឯងចង់ទៅវិញក៏ទៅចុះ តែត្រូវទុកដាវ៉ាន់នៅទីនេះ!
- សូមទោស បាទ! ដាវ៉ាន់ជាកូនរបស់ខ្ញុំ ខ្ញុំត្រូវតែយកនាងទៅ វិញ ។

ធីតាងាកក្រោយ ឃើញអ្នកស្រីម៉ារីឈរច្រត់ចង្កេះចង្អុលមុខ ដាវិង ៖

- ដាវ៉ាន់ក៏ជាកូននាងភិសម័យដែរ ។ កាលបើឯងកំពុងមានស្រីថ្មី ឯងត្រូវតែទុកដាវ៉ាន់នៅទីនេះ ព្រោះយើងមិនចង់អោយម៉ែចុង វាធ្វើបាបដាវ៉ាន់ចៅរបស់យើងទេ ។ អាជាតិស្រីរហេមរហាមដូច

CHANBOKEO.COM

ឈ្លើងតាមគោងប្រុសអ្នកមាន ដើម្បីក្រេបជញ្ជក់ឈាមនោះ យើង ស្គាល់មារយាទពួកវាណាស់ ។ យើងមិនអោយនាងដារ៉ាន់វាទៅ តាមឯង នាំតែវេទនាទេ ។

ប៉ុន្តែ ដារិនធ្វើមិនឮ បែរជាលើកដៃសំពះអ្នកស្រីម៉ារីហើយក៏ ចាប់ដៃកូនដើរចេញមកក្រៅ ។

- ដារិន! ឯងព្រហើនណាស់! ឆាប់ទុកដារ៉ាន់ភ្លាម!

ដារិនបែរក្រោយក៏ភ្ញាក់ក្រញាង ដែលអ្នកស្រីដកកាំភ្លើងភ្ជង់ គម្រាមដារិន ទាំងទឹកភ្នែកទឹកសំបោរ មកថា ៖

- រាសីរបស់ឯងមិនមែនចេះតែខ្ពស់រហូតឈ្នះរហូតទេ ។ នឹងទេ ថាអ្នកស្រីម៉ារីនេះមិនសូវយោគយល់នរណាដែរ ជាពិសេសអ្នក ដែលធ្វើអ្វីទើសមុខយើង ។ ជាយូរមកហើយដែលយើងរង់ចាំឯង ដើម្បីប្រដៃប្រដៅឯងខ្លះ ព្រោះឯងបានធ្វើអោយកូនស្រីនិល្លរបស់ យើងក្លាយជាមនុស្សជាប់គុកជាប់ច្រវាក់ ខូចឈ្មោះ ខូចកិត្តិយស គ្រួសារយើង.. នោះគឺព្រោះតែឯង... ទើបយើងអាមាសមុខ ដល់ ថ្នាក់នេះ! ព្រោះតែឯង ទើបកូនស្រីយើងទៅជាបែបនេះ!

ផាំង! អ្នកស្រីម៉ារីបាញ់បង្ហុស ដើម្បីសម្លុតអារម្មណ៍របស់ដារិន យើង ។ ភ្លាមនោះ នាងតូចដារ៉ាន់យំវ៉ាឡើង ស្រវាអោបកឪពុក ដោយក្ដីភិតភ័យយ៉ាងតក្កមា ។ ដារិនលើកកូនព ហើយដើរគេច ចេញមកក្រៅកាន់តែលឿន ។

ផាំង! មួយគ្រាប់ទៀត ប្រឆាបប្រឆិតៗក្បាលដារិន ។ ប៉ុន្តែ នាយយើងមិនព្រមឈប់ដដែល ។ គេស្ទុះមកកញ្ឆក់ធីតារត់ចេញ ភ្លាម ។ អ្នកស្រីម៉ារីគំហកពីក្រោយមកថា ៖

- យើងថា អោយដាក់ដារ៉ាន់ចុះ!

- ម៉ាក់!... កុំ!

ភិសម័យស្រែកពីខាងក្នុងផ្ទះមកយ៉ាងគ្រលួច ហើយស្ទុះលោត ពីរទេះអ្នកជំងឺទៅអោបចង្កេះម្ដាយ ធ្វើអោយអ្នកស្រីម៉ារីច្រឡោត ខ្លួនទៅមុខរកដួល ហើយក៏ច្រឡំរាលកៃ ធ្លាយមួយគ្រាប់ហោះទៅ ត្រូវកំភួនជើងធីតា ផាំង! នាងក៏ដួលប្រួសទៅដីព្រួស ។

- អូនដា!

ដារិនស្ទុះទៅលើកគ្រាហ៍ត្រកងនាងឡើងយ៉ាងលឿន ដៃម្ខាង កាន់កូន ដៃម្ខាងគ្រាហ៍ធីតាចេញទៅរកថ្នល់ធំ ។

CHANBOKEO.COM

នៅឯមាត់ទ្វារវីឡាដ៏ស្តុកស្តម្ភ កូននឹងម្តាយប្រវាយគ្នាដណ្តើម កាំភ្លើង ។ ភ្លាមនោះ គ្រាប់កាំភ្លើងក៏លាន់ផ្ទុងផាំងៗ ថែមទៀតមិន ដឹងថា បានរាលកែប៉ះនរណាខ្លះឡើយ ។

នៅមន្ទីរពេទ្យ...

ឧត្តមសេនីយ៍សត្រា ដើរចុះមកពីរថយន្តដោយមានកូនចៅហែ ហមមកច្រើននាក់ផង ៖

- មានរឿងអ្វីទៅលោកគ្រូពេទ្យ ?
- គឺអ្នកស្រីរាលកែកាំភ្លើងត្រូវចំបន្ទាត់ពោះខ្លួនឯង មានរបួសសើ ស្បែកត្រូវដេរ២២ថ្នេរ ។ ។ ចំណែកកូនស្រីរបស់លោក ត្រូវគ្រាប់ ផ្លាតគ្រាប់ឆាកស្មាឆ្វេង ខ្លោចស្បែកតែមិនធ្ងន់ធ្ងរទេ ។ ចំណែក អ្នករងគ្រោះម្នាក់ទៀតជាស្រីក្មេង ត្រូវគ្រាប់ឆាកកំភួនជើង ដេរជិត ជិត១០ថ្នេរដែរ ។

លោកសត្រាដើររឹងទៅរកអ្នកស្រីម៉ារី ដែលកំពុងសំរាន្តស្ងៀក នៅលើគ្រែមួយធ្វើមុខស្អុយប៉ែ ។ លោកក៏មានប្រសាសន៍ថា ៖

- មិនគួរអោយជឿសោះ ថាអូនធ្វើអោយបងជាប់ឈ្មោះនៅទំព័រ ទីមួយក្នុងកាសែត ដោយសារតែភាពកម្រោលហឹង្សារបស់អូនដែល ប្រឹងយកឈ្នះលើស្ថានការណ៍ដោយអំណាច ។ ដឹងទេថា បងគួរ ឆ្លើយនឹងអ្នកកាសែតថាយ៉ាងណាដែរ ចំពោះរឿងនេះ ? តើពេល ណាទៅ ទើបអូនរៀនរំសាយចិត្តស្អប់ ចិត្តខឹងនោះអស់ពីខ្លួន ?

ស្រាប់តែអ្នកស្រីស្រក់ទឹកភ្នែក តំហកវិញថា ៖

- ព្រោះអូនឈឺចិត្ត ដែលវាធ្វើបាបកូនស្រីយើង អោយខូចមនុស្ស ខូចម្នាអស់ រហូតដល់ធ្លាក់ខ្លួនជាមនុស្សជាប់គុក ញៀនអាភៀន...
- ហើយចុះអូនមានដែលគិតទេ ថាកូនរបស់យើងក៏មានចំណែក ខុសខ្លះៗដែរ ?
- មិនមែនទេ គឺខុសមកតែមកពីអាប្តីមិនបានការនោះអី !
- ប៉ុន្តែ បើដឹងថា ប្តីនោះមិនល្អទៅហើយ ហេតុម្តេចក៏ភិសម័យ មិនធ្វើខ្លួនអោយល្អទៅ ពេលដើរចេញពីជីវិតប្តីនោះមក ?
- គឺមកពីគ្មានជិតរកផ្លូវដើរមិនឃើញ !
- ឯជិតស្អីទៅ ? បើអាចរត់ពីមិនីសូតាដល់កាលីហ្វ័រញ៉ាបាន ហេតុ ម៉េចក៏មិនរត់អោយដល់ស្រុកខ្មែររកម៉ែឪអោយជួយ ? ម៉េចបានជា ធ្វើខ្លួនជាមនុស្សខ្វាត់ព្រាត់អត់ម៉ែឪ អត់ផ្ទះនៅ អត់ផ្លូវដើររលីង អញ្ជឹង ?

CHANBOKEO.COM

ឈប់បន្ទោសគេតែម្ខាងទៅ ម៉ារី! ការខឹងគុំគួនវាមិន ចំណេញអីជាជាងធ្វើបាបខ្លួនឯង អោយតក្កហលក្តៅក្រហាយថែម ទៀតនោះទេ ។ មិនតែប៉ុណ្ណោះ គឺថែមទាំងនាំសេចក្តីក្តៅក្រហាយ នោះដល់នរណាទាំងអស់ ដែលនៅជុំវិញខ្លួនយើង ដូចជាបង កូន ភិសម័យ កូនចៅយើងក្នុងផ្ទះ ព្រមទាំងចៅដារ៉ាន់របស់យើង ផង ។ ឥរិយាបថប្រកបដោយហឹង្សាបែបនេះ ធ្វើអោយក្មេងខ្លាច យើងណាស់! តើមានចៅណាមួយទៅដែលចូលចិត្តរស់នៅជាមួយ ជីដូនដែលមានចិត្តជាភ្លើងដូច្នេះ ? ម៉ារី សូមកុំចូលចិត្តបន្ទោស ទម្លាក់ កំហុសទៅលើគេតែម្ខាងដោយភ្លេចមើលភាគីខាងខ្លួនឯង អី... រៀនពន្លត់ចិត្តខឹងនោះខ្លះទៅ នោះជីវិតនឹងទទួលសេចក្តីសុខ ខ្លះៗ ។ ឃើញទេ ហឹង្សានិងការគុំគួនរបស់អូនចំពោះដារិង តើ ពេលនេះមានលទ្ធផលយ៉ាងម៉េចដែរ ? តើអូនក្លាយជាអ្នកឈ្នះទេ បន្ទាប់ពី ប្រើអំណាច ប្រើហឹង្សា ប្រើអាវុធរួចហើយ ? គេងគិត ទៅណា៎ ម៉ារី! ពេលអូនចេញពីពេទ្យវិញ បងសង្ឃឹមថាអូនទម្លាក់ ជំងឺខឹង ជំងឺស្អប់ និងជំងឺគុំគួនសងសឹកនោះ នៅមន្ទីរពេទ្យនេះ អោយអស់ ហើយសង្ឃឹមថា ម៉ារីត្រឡប់ទៅផ្ទះដោយនាំខ្លួនភរិយា ដ៏ល្អម្នាក់ផ្ញើបង និងផ្ញើគ្រួសារយើងវិញមិនខាន ។

មានប្រសាសន៍ហើយ ឧត្តមសេនីយ៍សត្រា ចាប់ដៃភរិយាកាន់ រួចមានប្រសាសន៍បន្តថា ៖

- ត្រូវការសៀវភៅអានខ្លះទេ ? អានដើម្បីអោយអារម្មណ៍ត្រជាក់ បន្តិច ? បងមានយកមកតាមមួយក្បាលដែរ ។ ពេលបងអាល័យ ជាប់ធ្វើការមិនបានមកកំដរអូននៅមន្ទីរពេទ្យ អូនអានសៀវភៅ នេះលេងៗទៅ កំដរពេលទំនេរកុំអោយអផ្សុក ។ ការអាននឹងធ្វើ អោយពេលវេលាដើរទៅមុខឆាប់រហ័ស ហើយបាត់ហ្មួហ្មងផង ។

ពេលនោះ លោកសត្រាក៏ដកសៀវភៅធម៌គហិបដិបត្តិមួយជូន ភរិយា ព្រមទាំងញញឹមយ៉ាងស្រស់ថា ៖

- ឆាប់ជាណា៎អូន! ជាទាំងរបួសកាយ ជាទាំងរបួសចិត្ត ។

លោកសត្រាក៏ដើរចេញទៅ ទុកអោយអ្នកស្រីម៉ារីអង្គុយកាន់ សៀវភៅមួយច្បាប់នោះ ជ្រួញចិញ្ចើមគិតតែម្នាក់ឯង ក្នុងបន្ទប់... បន្តិចមក អ្នកស្រីក៏ចាប់សៀវភៅ បើកទំព័រម្តងមួយៗ...

នៅផ្ទះអ៊ំសាឡាង...

ដារិងបីធីតាចូលផ្ទះ ៖

CHANBOKEO.COM

- យ៉ាងម៉េចហ្នឹងកូន ? (អ៊ំសាឡាងសួរ)

- បាទ! គឺជាកំហុសរបស់ខ្ញុំទេ ប៉ា! (ដាវិនឆ្លើយទាំងបារម្ភ)

អ៊ំសាឡាងសង្កេតឃើញធីតាចងចញ្ចើមមិនយល់សោះ មិនដឹង ថានាងធ្វើមុខងូច្ចោះ ព្រោះតែមានរបួសនៅជើង ឬមកពីរឿងអ្វី ឡើយ ។ ឯដាវិនក៏ហាក់ដូចជាយកចិត្តទុកដាក់នឹងសុខទុក្ខរបស់ ធីតាណាស់ដែរ ប៉ុន្តែ លើកនេះ នាងហាក់ដូចជាមានកិរិយាព្រងើយ មិនសួរស្តី មិនចាប់អារម្មណ៍នឹងនរៈអ្វីបន្តិចសោះ ។ កិរិយានោះ បានធ្វើអោយអ៊ំសាឡាងរិតតែសង្ស័យឡើង ។ បន្តិចមក អ៊ំក៏កេះនាំ ដាវ៉ាន់ចេញទៅក្រៅ ដើម្បីអោយកូនចៅនិយាយគ្នា ៖

- អ៊ំចេញទៅក្រៅសិនហើយ ។ ឯងនៅនិយាយគ្នាចុះ!

ការពិត អ៊ំសាឡាងជាមនុស្សសម័យថ្មី ថ្វីបើគាត់ជាមនុស្ស ចាស់ពិការនៅក្នុងផ្ទះពិតមែន ។ ពីដើម គាត់ធ្លាប់ធ្វើការមានមុខ មាត់គួរសមក្នុងក្រសួងដែរ ប៉ុន្តែ តាំងពីមានគ្រោះថ្នាក់ពិការមក គាត់ក៏ចូលនិវត្តន៍ រស់នៅស្ងាត់ស្ងៀម មើលកូនមើលចៅថែផ្ទះ ទុក អោយប្រពន្ធចេញរកស៊ីតែម្នាក់ឯងរហូតដល់ត្រូវជំរុញអោយសិលា ឈប់រៀនហើយចេញរកការធ្វើដើម្បីផ្គត់ផ្គង់គ្រួសារ ។ គាត់មិនសូវ ជាតឹងតែងក្នុងការអប់រំកូនទេ តែចូលចិត្តផ្តល់សេរីភាពក្នុងការគិត និងការប្រព្រឹត្តរបស់គេ ។ ណាមួយ តាំងពីគាត់ចាស់ពិការមក គាត់ តែងតែមានអារម្មណ៍ថា គាត់ជាបន្ទុករបស់កូនរបស់ប្រពន្ធ ម្ល៉ោះ ហើយចេះតែខ្លាចចិត្ត មិនហ៊ាននិយាយស្តីអ្វីថាអ្វី អោយអ្នកក្នុងផ្ទះ ធុញនឹងគាត់ដែលជាមនុស្សអាសារឥតការនោះឡើយ ។ ផ្ទុយទៅ វិញ គាត់បានទទួលភារៈដូចជាម្តាយ ដាំបាយធ្វើម្ហូប ថែផ្ទះសម្បែង ពេលកូនចៅទៅរៀនឬទៅធ្វើការ ផ្តល់ភាពកក់ក្តៅដល់កូនប្រពន្ធ មិនរអ៊ូរទាំនឹងភារៈរបស់គាត់ទេ ។ ម្យ៉ាងទៀត ចំពោះធីតា នាងជា មនុស្សចំណាប់ចំនួនខាងការសិក្សាជាងគេក្នុងគ្រួសារ មិនដែលធ្វើ អ្វីអោយឪពុកម្តាយអំពល់ទុក្ខដោយសារ ម្ល៉ោះហើយ អ៊ំសាឡាង ហាក់ដូចជាទុកចិត្តកូនស្រីណាស់ ថាគេអាចគ្រប់គ្រងជីវិតរបស់គេ បានដោយមិនបាច់គាត់ចូកចែវច្រើន ។

ឃើញអ៊ំសាឡាងចេញទៅ ដាវិនក៏ស្រដីឡើងថា ៖

- អោយបងសូមទោសណ៎ាដា ដែលរាសីបងមិនល្អ ចេះតែនាំរឿង អំពល់ដល់ដាជានិច្ច ។

CHIANBOKEO.COM

ធីតាឈ្ងោកមុខនៅស្ងៀម ។ ដារិនយកដៃស្ទាបស្ទាមរបួសនៅ លើជើងនារីបន្ថើរៗ
ហើយវាចាបន្តថា ៖

- សូមអោយអូនដាឆាប់ស្រួលបួលវិញកុំខាន នឹងអាលបានដើរទៅ
សម្ភាសន៍នៅទូតអាមេរិកបីថ្ងៃទៀត ។

ស្រាប់តែធីតាឆ្លើយថា ៖

- ចៃដន្យ ដាឈប់ចង់ទៅអាមេរិកហើយ ។

ដារិនភ្ញាក់ព្រើត ៖

- ម៉េចអញ្ចឹងដា ?

នារីមិនឆ្លើយទេ បែរជាចងចិញ្ចើមសាថ្មី ទំនងដូចជាម៉ួម៉ៅនៅ ក្នុងចិត្ត ។ ការពិត
ធីតាមិនសប្បាយចិត្ត តាំងពីឃើញដារិនស្រវា ឱបភិសម័យនៅក្នុងផ្ទះនោះម្ល៉េះ ។
នាងមានហាក់ដូចជាធុញថប់ ក្នុងចិត្តយ៉ាងណាមិនដឹង លួចនឹកតែក្នុងចិត្តថា ៖

- ហេតុអ្វីខ្ញុំមកដើរតួជាកង់សីគួរអោយគេអញ្ជឹង ? នេះគេធ្លាប់ជា ប្តីប្រពន្ធនឹងគ្នា...
គេមានកូនជាមួយគ្នា... មានអនុស្សាវរីយជាមួយ គ្នា... នៅស្រឡាញ់គ្នា...
នៅមានទំនាក់ទំនងទៅមកនឹងគ្នា...ពេល ជួបមុខគ្នា
នៅតែបង្ហាញនូវសេចក្តីស្រណោះអាណិតចំពោះគ្នា.. រួច
ហើយគេព្រងើយទុកយើងអោយនៅក្រោយខ្នង... គេបានសម្តែង
ហាក់ដូចជាមិនគិតពីអារម្មណ៍របស់យើងបន្តិចទេ... តើយើងទៅ គិតពីគេធ្វើអ្វី ?
យើងទើបតែស្គាល់គេពីរបីថ្ងៃ ធ្វើម្តេចឡើយនឹង មានតម្លៃស្មើនឹងសម្ពន្ធ័
ដែលគេធ្លាប់មានចំពោះម្តាយដាវ៉ាន់នោះ ? គឺពិតជាមិនអាចប្រៀបបានទេ... ដូច្នេះ
តើយើងប្រឹងស្រវាតោង គេ ដើម្បីអ្វី ? សេចក្តីស្នេហា ? តើយើងស្រឡាញ់គេប៉ុនណាដែរ ?
ចុះគេវិញ ស្រលាញ់យើងវិញប៉ុនណា ? ឬក៏គេខ្ចីយើងទ្រាប់ខ្នង កំដៅមួយពេលៗ
ដែលបេះដូងគេរងា ? លុះដល់គេជួបនារីដែល គេស្រឡាញ់ គេក៏ឈប់រងា
ហើយក៏ឈប់នឹកនាយើងទៅ... យើង ក៏លែងមានតម្លៃតទៅទៀត... មិនតែប៉ុណ្ណោះ ប៉ុន្មានថ្ងៃនេះ
រាសី យើងធ្លាក់ចុះ ធ្លាក់ដោយសារតែបុរសម្នាក់នេះ... តើយើងប្រឹងតស៊ូ ដើម្បីគេធ្វើអ្វី ?
ដើម្បីអនាគតហ្អែស ? អនាគតដែលមិនដឹងថា យ៉ាងម៉េច ? នៅឯណា ? តើយើងគួរពឹងទេ ?
នេះយើងនៅក្មេង ណាស់... ហេតុអ្វីបានជាយើងយកចិត្តមកចងជំពាក់នឹងបុរសពោះ
ម៉ាយម្នាក់នេះទៅវិញ ? តើយើងចំណេញអ្វី ? ទទួលផលអ្វីពីការ ដែលយើងបូជាដើម្បីរូបគេ ?

CHANBOKEO.COM

ធីតាគេងពិចារណាមិនអស់មិនហើយសោះ ចាចង់យំក៏យំមិន ចេញ ចាចង់និយាយជាមួយដាវីដក៏និយាយមិនរួច ចាចង់គេចមុខ គេ ប៉ុន្តែក៏ចេះតែនឹកគេ... នឹកគេងមិនលក់ទាល់តែសោះ...

ឃើញធីតានៅស្ងៀមស្ងាត់ធ្វើទឹកមុខចម្លែក រួចហើយសម្តែងកិរិយាហាក់ដូចជាតោះតើយចំពោះខ្លួន ដាវីដក៏ដាក់ខ្លួនអង្គុយចុះក្បែរមាណវីកំពុងគេងដណ្តប់ផាហ៊ំលើការឿ សណ្តូកជើងរបួស លើខ្នើយមួយ ។

- អូនដា ? មានអ្វីរំខានចិត្ត អូននិយាយចេញមក ក្រែងបានធូរ ក្នុងទ្រូងខ្លះ!

ធីតាចោលកន្ទុយភ្នែកសម្លក់នរៈបន្តិច ក៏ធ្មេចភ្នែកធ្វើមិនដឹង ។ ដាវីដក៏និយាយទៀតថា ៖

- ដា! ថ្ងៃនេះជាការពិសោធន៍លើកដំបូងរបស់យើងហើយ ថា តើយើងអាចយល់ពីគ្នាអាចនិយាយគ្នា ពិគ្រោះគ្នាបានឬទេ ពេល ណាយើងមានកង្វល់ក្នុងចិត្ត ? បងដឹងថាដាប្រហែលជាកំពុងមាន អារម្មណ៍មិនល្អដោយសាររឿងរបស់បង ថ្ងៃនេះ ។

ធិតាដកដង្ហើមយូ យ៉ាងវែង ។ បន្តិចមក ដាវីដក៏ស្រដីបន្ត ទៅទៀតថា ៖

- មនុស្សយើង បើនឹងអាចយល់គ្នាបាន គឺយើងត្រូវបើកចិត្តចំពោះ គ្នាទៅវិញទៅមកប្រាប់អោយគេដឹងនូវអារម្មណ៍របស់យើង ដឹង ថាយើងសប្បាយរឿងអ្វី កើតទុក្ខរឿងអ្វី ខឹងរឿងអ្វី ។ បើយើង ចេះតែលាក់ទុកអ្វីៗនៅក្នុងចិត្ត ហើយរង់ចាំអោយភាគីម្ខាងទៀតយល់ដោយឯកឯងនោះ ពិតជាពិបាកណាស់ ព្រោះគេមិនអាចទាយ អ្វីៗត្រូវសព្វរឿងបានទេ ។ សេចក្តីសុខនៅក្នុងចិត្តអាចកើតមាន បាននៅពេលណាដែលមានគេយល់ចិត្តយើង ហើយនឹងអោយគេ យល់ចិត្តយើងបាន ទាល់តែយើងសម្តែងចិត្តយើងនោះចេញមក... បើដាលាក់ជិតនូវអារម្មណ៍របស់ខ្លួនយ៉ាងនេះ ដាវីដពិតជាមិនអាច យល់ចិត្តដាបានច្បាស់ទេ ។ ពេលនេះ បងនៅក្បែរអូនហើយ រង់ ចាំអូនដានិយាយប្រាប់បង ថាដាកំពុងខឹងនឹងបងរឿងអ្វី ។

ថ្វីបើនរៈមានសំដីផ្អែមស្រទន់យ៉ាងណា ក៏ធិតានៅតែមិនបាត់ ខ្នក់ចិត្តដែរ ។ នាងនៅតែស្រម័យឃើញដាវីដស្រវាឱបភិសម័យ ពេញរង្វង់ដៃ នៅស្រស់ៗនឹងភ្នែកនៅឡើយ ឃើញគេសម្តែងក្តី បារម្ភចំពោះភិសម័យនិងកូនចំពោះមុខនាង ដោយមិនខ្លាចចិត្ត.... ឃើញកិរិយារបស់គេយ៉ាងស្និទ្ធស្នាលចំពោះភិសម័យ ធីតានឹកខ្នាញ់ តែម្នាក់ឯងដែលនាងមិនបានទទួលចំណាប់អារម្មណ៍យ៉ាងជ្រាល ជ្រៅបែបនោះ ។ នឹកដល់រូបភាពភិសម័យនិងដាវីដកាលណា ធីតា ខ្នក់ខ្នាញ់ ចង់តែទន្ទ្រាំជើងយំស្រែក តែក៏មិនអាចធ្វើបាន... នាងក៏សុខចិត្តនៅស្ងៀម មិនស្តីមិនតបអ្វីទាំងអស់ទៅដាវីដវិញ ។

CHANBOKEO.COM

លុះអង្គុយចាំយូរហើយ មិនឃើញនាងនិយាយស្ដីអ្វី ដារិនក៏ ស្រដីថា ៖

– ប្រហែលជាដាត្រូវការពេលវេលាផ្ទាល់ខ្លួនហើយ ។ ដូច្នេះ បង សុំខ្លួនាំកូនដាទៅវិញសិនហើយ ចាំស្អែក បងមកមើលថៃអូនវិញ...

ថាហើយ គេក៏យកដៃអង្អែលកេសានាងបន្តើរ សម្ដែងនូវ អារម្មណ៍ប្រតិពទ្ធ័ចំពោះនារី ហើយក៏ដើបដើរចេញទៅ...

ពេញមួយយប់នោះ ធីតាធ្មេចមិនលក់មួយស្រឡេតសោះ គិត ចាក់ស្មុគតែម្នាក់ឯង ។ ពីរអាទិត្យដែលនាងចាប់ស្គាល់គ្នាជាមួយ ដារិន អ្នកទាំងពីរក៏ផ្ដើមមានសម្ពន្ធ័ផ្លូវចិត្តចំពោះគ្នាយ៉ាងឆាប់រហ័ស ដូចផ្លេកបន្ទោរ ប៉ុន្តែ ពីរអាទិត្យនេះ ក៏បានផ្លាស់ប្ដូរដំណើរជីវិត របស់ធីតា ឲ្យបែរទិសខុសការគ្រោងទុករបស់នាងពីមុនមកអស់រលីង ។ ពីរអាទិត្យនេះ នាងបានប្រឡងធ្លាក់អស់ពីរមុខវិជ្ជា ។ ពីរអាទិត្យ នាងមានរឿងឡើងតុលាការ មានរបួសដោយហឹង្សា មានគេជេរថាជាស្រីអង្កាច់អង្កោច... មានគេមកនាំនាងទៅប្រឡង ភាសាអង់គ្លេសត្រៀម សំរាប់ការសិក្សាក៏រិតអនុបណ្ឌិត... មានគេជួយដាក់ពាក្យសុំទិដ្ឋាការដើម្បីទៅរៀនបន្តនៅអាមេរិក...មានបុរស សុំចូលដណ្ដឹងជាគូ... មានក្មេងដែលបំរុងខ្លួនមកជាកូនស្រីរបស់ នាង... ។ រឿងប្លែកៗទាំងនេះបានចូលមកដល់ក្នុងជីវិតរបស់នាង ឆាប់រហ័សពេក ពេលនេះ នាងកំពុងឈានទៅដល់ចំណុចមួយ ដែលថា ភ្ញាក់ផ្អើលនឹងការផ្លាស់ប្ដូរលឿនពេក ត្រៀមខ្លួនមិនទាន់ ជាពិសេស អ្វីដែលនាងមិនអាចទទួលបានគឺ... នាងជាកង់សីគួរ!

គិតទៅគិតមក ធីតាចង់តែយំស្រែក តែក៏យំមិនចេញ ទឹកភ្នែករបស់នាងបែរជាស្ងួតរលីងពីភ្នែកមិនដឹងមកពីហេតុអ្វី ។ មួយ យប់ទល់ភ្លឺ ធីតាគេងស្ដាប់សៀងតុកកែបូលយំស្មើយៗពីផ្ទះអ្នកជិត ខាង ធ្វើអោយចិន្តានឹកព្រឺព្រួចអាល័យខ្លួនកាន់តែខ្លាំងឡើងៗ ។

បែរទៅដារិនវិញក៏ដូចគ្នា...

គេគេងរសាប់រសល់ពេញមួយយប់ទល់ភ្លឺ ដែលគេបាននាំធីតា ដើរចូលទៅក្នុងជីវិតរបស់នាយដែលមានសុទ្ធតែរឿងសិយ ធ្វើឲ្យ ធីតាភ្ញាក់ផ្អើលរៀបខ្លួនទទួលស្ថានការណ៍ទាំងឡាយនោះមិនទាន់ ។ ម្យ៉ាងទៀត នាងជានៅក្មេងហើយនៅលីវ មិនទាន់មានការ ពិសោធន៍ក្នុងរឿងជីវិតគ្រួសារ

ពិតជាមិនអាចទទួលបានទេ ពេល នាងឃើញគេនៅទៅមកទាក់ទងគ្នាជាមួយភិសម័យ... ឱ! មែន ហើយ! ភិសម័យ! ធីតាប្រាកដជាខ្ពក់ចិត្តអំពីរឿងភិសម័យពិត ប្រាកដណាស់ ប្រសិនបើដារិនផ្ដល់ការចាប់អារម្មណ៍លើភិសម័យ ខ្លាំងជាងធីតា ។ ប៉ុន្តែ តើអោយធ្វើយ៉ាងណា បើហេតុការណ៍វា តម្រូវដូច្នេះទៅហើយ ? ការពិត គេមិនបានបែរទៅរកភិសម័យ វិញទេ គ្រាន់តែជួបនាង ផ្ដល់នូវភាពជាមិត្ត មុននឹងនាំកូនចាក ចេញទៅអាមេរិកតែប៉ុណ្ណោះ ។

ពេលនេះ ធីតាបានក្លាយទៅជាជនរងគ្រោះ ដោយសារការចង សម្ពន្ធ័ជាមួយដារិន ។ តើនាងឈឺចិត្តយ៉ាងណា... ? កាន់តែគិត ដារិនកាន់តែអាណិតធីតាយើងឡើង ដែលនាងបានដើរធ្លាក់ក្នុងផ្លូវ ជីវិតជាមួយនាយ ដែលប្រកបដោយភាពរញ៉ីមរញ៉ាំក្នុងយ៉ាងច្រើន រាប់មិនអស់...

ដូច្នេះ តើដារិនត្រូវធ្វើយ៉ាងណាដើម្បីអោយនាងស្រឡះចិត្ត ធូរ ស្បើយអារម្មណ៍ លែងមានការខ្ពក់ចិត្ត នឹកខ្លាញ់ចំពោះនាយតទៅ ទៀត ?

oooooooooooooooooo

oooooo

o

CHANBOKEO . COM

# វគ្គទី១១

## ពរ

CHANBOKEO.COM

ព្រហាមមិនទាន់ ដារិនស្ទុះទៅដាស់ដារីអោយទៅគេងកំដរ ដាវ៉ាន់ ហើយក៏ដេញអ្នកបើកបរចេញពីឡាន ទាញកូនសោរហើយ ហក់ឡើងឡានវិញ បរទាំងព្រលឹម សំដៅផ្ទះអ៊ំសាឡាង ។

- ធីតាទើបតែចេញពីផ្ទះទៅមុននេះឯង ដារិន ។

អ៊ំសាឡាងមានប្រសាសន៍ ។

- នាងទៅរៀនមែនទេ ប៉ា ? តើជើងរបស់នាងយ៉ាងណាទៅ ហើយ ?
- ឃើញដើរបុំងខ្ញើតៗ តែមិនឃើញរអ៊ូថាឈឺអ្វីទេ ទើបនាងចេញ ទៅរៀនបាត់ទៅ ។
- ហេតុអ្វីនាងចេញទៅព្រឹកម្លេះ បាទ ?
- ប្រហែលជាទៅជួបមិត្តភក្តិសុំកិច្ចការ ដែលនាងខកខានមិន បានធ្វើនោះហើយ ។

ដារិនសំពះលាអ៊ំសាលាង ធ្វើដំណើរទៅរកធីតានៅសាលា ។ គេបានអង្គុយគន់រកនារីពេញមួយព្រឹកហើយ តែក៏មិនប្រទះឃើញ ស្រមោលនារីសោះ ។

- ដា! អូនទៅណា ? អូនកំពុងខឹងអ្វីនឹងបងមែនទេ ?

គេតាមរកធីតារហូតទៅដល់បឹងឈូក ដែលនាងធ្លាប់ទៅលួច ពួនយំ ទៅចំការពោតដែលគេធ្លាប់នាំនារីទៅលេង ទៅកន្លែងនានា ដែលគេចាំបានថា នាំនាងដើរលេង ប៉ុន្តែ ក៏មិនបានការដដែល ។ គេក៏ត្រឡប់មកសណ្ឋាគារអង្គុយសំកុកយ៉ាងយូរ ស្រាប់តែឃើញ សិលា ស្រស់ឆោម និងដារីនាំដាវ៉ាន់មកគោះទ្វារ ៖

- សួស្តីបងដារិន! (ទាំងបីនាក់ស្រែកឡើងព្រមគ្នា)

ដារិនងើបមើលមុខអ្នករាល់គ្នា រួចហើយញញឹមស្ងួត ។

- មុខស្អុយម្លេះ បងដារិន ? មានរឿងអ្វីហ្នឹង ? (ឆោមសួរ)

តែដាវិដមិនឆ្លើយទេ បែរជាងាកទៅសិលាហើយសួរថា ៖

- សិលា! ដឹងទេ ថាថ្ងៃនេះ អូនដាគេទៅណា ?

សិលាញញឹមឆ្លើយថា ៖

- ថីមិនដឹង!

ដាវិដភ្ញាក់ព្រើតសម្ដែងភាពត្រេកអរនៅលើមុខភ្លាម ។ សិលា ក៏បន្តថា ៖

- ថ្ងៃនេះ ប្រហែលជានាងត្រូវការកម្លាំងចិត្តពីបងហើយ ។

- អូហ៍ រឿងអ្វីទៅសិលា ?

- គឺនាងទៅយកលទ្ធផលប្រឡងភាសាអង់គ្លេស ដើម្បីត្រៀមទៅ រៀននៅឯអាមេរិកនោះអី ។ ឮថានាងមានណាត់ជួបទូតអាមេរិក នៅម៉ោង២កន្លះរសៀលនេះផង ដើម្បីសុំទិដ្ឋាការ ។

- ពុទ្ធោអើយ! ម៉េចបានខ្ញុំគិតអត់ឃើញអញ្ចឹង ? (ដាវិដលាន់ មាត់ឡើង) អរគុណសិលា ។

ថាហើយ គេក៏បែរមកដារី ៖

- ផ្ញើកូនវ៉ាន់ម៉ាសន្ទុះទៀតសិនណ៍ ដារី! ល្ងាចបន្តិច បងមក ទទួលវិញហើយ ដើម្បីអោយប្អូនទំនេរបានដើរលេង ។

ដាវិដហក់រឹងចេញទៅរកធីតានៅសាលាប្រឡង ប៉ុន្តែ អ្នកធ្វើ ការនៅទីនោះប្រាប់ថា នាងបានចេញទៅវិញហើយ ។ ដាវិដរត់ រឹងទៅដល់ស្ថានទូតអាមេរិក ប៉ុន្តែ នៅតែមិនជួបនាងដដែល ។ ដាវិដក៏រត់ត្រឡប់ទៅផ្ទះធីតា អ៊ំសាឡាដប្រាប់ថា នាងមិនទាន់ត្រឡប់មកផ្ទះទេ ។ ពេលនេះ ដាវិដអស់កម្លាំងចិត្តស្រឡេតពីពោះ តែម្ដង ។ គេមិនដែលធ្វើដូច្នោះចំពោះនារីណាទេ ប៉ុន្តែចំពោះធីតា គេបែរជាខ្វល់ខ្វាយខុសធម្មតា ។ កាលគេជួបភិមសម័យលើកដំបូង វាងាយអើយសែនងាយ គ្រាន់តែស្គាល់គ្នាភ្លាម ដើរលេងរាល់ថ្ងៃភ្លាម មិនពិបាករវល់រឿងរៀន ឬកាលវិភាគអ្វីទេ ។ ទៅណា មកណា ភិសម័យប៉ាវចេញលុយគ្រប់ទាំងអស់ ។ កន្លែងណា សប្បាយៗ ភិសម័យនាំដើរគ្មានសល់ទេ មិនតែប៉ុណ្ណោះ ពេលមក ដល់ផ្ទះវិញ ក្រុមគ្រួសារភិសម័យយកចិត្តយកថ្លើមនាយ ដូចកូនស្ដេចមួយរូបអញ្ចឹង ។ មិនបាន១០ថ្ងៃផង គេក៏រៀបការនឹងគ្នា ។ កាលណោះ គេទៅដាក់ពាក្យធានាតែជាងពីរខែ ភិសម័យក៏បាន ទទួលទិដ្ឋាការចូលទៅរស់នៅសហរដ្ឋអាមេរិក ។ អ្វីៗក៏ហូរចូល ដោយស្រួល ដោយមិនពិបាកដាវិដព្រួយគិតរឿងអ្វីឡើយ ។

CHIANBOKEO.COM

ថៃដន្យ លើកនេះ ដារិនដើរផ្លូវជីវិតថ្មី ជួបធីតាមិនបានពីរថ្ងៃ ក៏ស្រឡាញ់គេងប់មុខមិនខុសលើកមុនប៉ុន្មានដែរ ។ ថៃដន្យ ពេល នេះ គឺនាយជាអ្នករត់តាមគេ ថ្នមគេ យកចិត្តគេម្តង... មិនតែ ប៉ុណ្ណោះ ហេតុការណ៍ជាច្រើនបានកើតឡើង បណ្តាលអោយដារិន រិតតែជំពាក់ចិត្ត ជំពាក់អារម្មណ៍ជាមួយធីតាកាន់តែខ្លាំងឡើងរៀង រាល់ថ្ងៃ មិនដឹងមកពីហេតុអ្វីទេ... គេចេះតែមានអារម្មណ៍ថា គេ ស្រឡាញ់នាង ត្រូវការនាង ចង់តែនៅជិតនាង បាត់មុខ មិនបាន...

- ដា! អូនកំពុងគេចមុខពីបងរឿងអ្វី ?

ទីបំផុត គេក៏ធ្វើដំណើរទៅបឹងឈូក ដែលជាទីដែលគេបាន ទទួលភាពរមនាក្នុងចិត្ត ពេលគេបានជួបធិតាលើកដំបូង ។

- មកទៀតហើយឬអន្ទិត ? ព្រឹកមិញមកម្តងហើយហោះទៅវិញ ភ្លាម ។ ឥឡូវមកម្តងទៀត បានន័យថា រកប្រពន្ធមិនទាន់ឃើញទេ មែនទេ អានាង ?

ដារិននៅស្ងៀម ធ្វើមុខស្ងួតជាចម្លើយ ។ ស្រាប់តែមីងនោះ ហុចផ្កាឈូកមួយបាច់មកអោយ ហើយស្រដីថា ៖

- ណេះ! យកម៉ាបាច់ទៅថ្វាយបង្គំព្រះទៅ នោះឯងរកប្រពន្ធ ឃើញវិញហើយ ។

ដារិនទទួលយកផ្កាឈូកហើយ ក៏ដកលុយពីហោប៉ៅជូនទៅ គាត់វិញ ស្រាប់តែគាត់គ្រវីក្បាល ហើយឆ្លើយថា ៖

- នេះ មីងអោយឯងទេ គឺដើម្បីជូនពរអោយគ្រួសាររបស់ឯង ត្រជាក់រមនាដូចជាទឹកក្នុងបឹងឈូកនេះ ហើយសូមឲ្យស្នេហារបស់ ឯងទាំងពីរស្រស់ថ្លាដូចសោភ័ណផ្កាឈូកនេះដូចគ្នាដែរ ។

ថាហើយ គាត់ក៏ញញឹមដាក់ដារិនដោយទឹកមុខប្រកបដោយ ភាពស្មោះត្រង់និងការមានសទ្ធាបរិសុទ្ធ ។ ភ្លាមនោះ គាត់ក៏បួញ មាត់ ធ្វើដៃស៊ីញ៉ូទៅខាងក្រោយខ្នម ។ ដារិនសម្លឹងតាមដៃរបស់ គាត់ ស្រាប់តែប្រទះឃើញនារីម្នាក់ទម្លាក់កេសាអន្លាយ អង្គុយលើ ទូកដែលចតនៅក្រោមម្លប់ដើមអំពិលទឹក កំពុងអង្គុយកាច់ត្របក ផ្កាឈូកជាក្បាច់ ។ ភ្លាមនោះ ដារិនក៏ញញឹមឡើងដូចគេជប់តែ ម្តង ៖

- អូនដា! (ដារិនឧទានឡើង)

គេក៏ហក់យ៉ាងរហ័សទៅដាក់ខ្លួនអង្គុយកៀកជិតធីតា ធ្វើអោយ

CHANBOKEO.COM

នាងភ្ញាក់ក្រញាង ៖

- បងដារិន ?

- មែនគឺបង! ម៉េចក៏ថ្ងៃនេះ អូនដារត់គេចពីបងពេញមួយថ្ងៃ ? នឹងទេ ថាបងតាមរកដា សឹងសោះខ្យល់អស់ទៅហើយ ? ដាខឹង នឹងបងរឿងអ្វីមែនទេ ?

ធីតានៅស្ងៀមមិនឆ្លើយ ។ ឃើញដូច្នោះ ដារិនក៏លូកដៃស្រវា ក្រៀកចង្កេះធីតាឱ្យបខ្លួននារីនិងរូបគេអោយផ្ទិតរកគ្នាយ៉ាងណែន ធ្វើ អោយធីតានឹកអៀនខ្លួន លូកដៃក្តិចនរ:យើង ៖

- បងដារិន! លែងដាមើល៍! ខ្មាសគេ!

- ខ្មាសអ្នកណា ?

- ខ្មាសអ្នកណាដែលធ្វើដំណើរតាមផ្លូវនេះ!

- តែបងមិនខ្មាសទេ ព្រោះបងចង់អោយគេដឹង

- ដឹងរឿងអី ?

- ដឹងថា ដាជារបស់បងហើយ មិនអោយនរណាមកកាត់មុខបង ទៀតបានទេ ។

- តែផ្តាស!

- មិនផ្តាសទេ! បងនិយាយការពិត ។

ធីតាចោលកន្ទុយភ្នែកសម្លក់នរ: ដោយក្រសែភ្នែកខ្ញក់ខ្ញាញ់ ។ ទ្រាំនឹងកិរិយានោះមិនបាន គេក៏លួចឆ្មក់យកនាសាទៅផ្ទិតលើថ្ពាល់ ធិតាយ៉ាងរហ័ស ធ្វើអោយនាងភ្ញាក់ផ្ញាកក្រោយស្ទើរធ្លាក់ពីទូក ។ ដារិនឃើញហើយ ក៏លូកត្រកងនាងអោយងើបមកវិញ ហើយក៏ លូកដៃម្ខាងទៀតស្រវាយកផ្កាឈូកមួយបាច់ ដែលគេបានទទួល ពីមីងម្ចាស់ខ្ទមអំបាញមិញមកហុចអោយធីតា ថែមទាំងពោលថា ៖

- ដា! បងមានអារម្មណ៍ថា ដាមានអារិចិត្តចំពោះបង! ពេលនេះ បងសុំយកផ្កានេះមកលន់តួសុំទោសអូន អំពីអ្វីដែលបងបានធ្វើឆ្គាំ ឆ្គង នាំអោយអូនមិនសប្បាយចិត្ត ។ ទទួលយកទៅណា៎ ដើម្បីឲ្យ បងដឹងថា ដាអភ័យទោសអោយបង ហើយយើងបែរមកល្អនឹងគ្នា វិញដូចដើម ។

ធិតាងើបមុខឡើងសម្លឹងកែវភ្នែកមាណព ឃើញគេញញឹម ដាក់នាងវិញយ៉ាងស្រស់ថ្លា ហាក់ដូចជាគ្មានលាក់អាថ៌កំបាំងក្នុងចិត្ត ក៏សុខចិត្តលើកដៃត្រងយកបាច់ផ្កាពីមាណពថ្នមៗ ។

CHANBOKEO.COM

- ដា! បើអូនមិនចង់ប្រាប់បងក៏បានដែរ ថាអូនខឹងស្អប់បងរឿង អ្វី ប៉ុន្តែ
បងសុំអូនតែរឿងម្យ៉ាងទេ ។
- រឿងអ្វីទៅ ? (ធីតាសួរ)
- កុំងឹក់ដើរគេចមុខពីអោយបងព្រួយបារម្ភទ្ធេះទៀត ។
- នរណាគេងឹក់ដើរគេចពីបង ?
- គឺនរណាងឹក់ដាក់បងតាំងពីយប់មិញរហូតដល់ថ្ងៃនេះនោះអី!
- នោះព្រោះដាឈឺចិត្ត...
- ឈឺចិត្ត ? ឈឺចិត្តរឿងអ្វី ?

ធីតាភ្ញាក់ព្រើត ឈប់និយាយ ។ ដារិនសម្លឹងមុខធិតា ទំនងជា យល់នូវជំរៅចិត្តនាង ។ គេក៏ភ្ញើយចង្កានាងឡើងអោយមើលមុខ គេហើយស្រដីថា ៖

- ស្តាប់បងណ៎ាដា! ភិសម័យគ្រាន់តែជាស្រមោលអតីតកាលរបស់
បងប៉ុណ្ណោះ ។ យើងលែងមានចំណងអ្វីនឹងគ្នា ជាងបួនឆ្នាំមក ហើយ ។
អ្វីដែលធ្វើអោយយើងនៅទាក់ទងខ្លះនោះ គឺកូនវ៉ាន់ ។
ថ្វីបើបងនិងភិសម័យបានផ្តាច់ចំណងពីគ្នាមែន ប៉ុន្តែ ដាវ៉ាន់មិន
អាចផ្តាច់និស្ស័យជាកូនពីម្តាយរបស់គេបានទេ ។ គេគួរតែស្គាល់ថា ម្តាយរបស់គេជាអ្នកណា ។
ហើយការដែលកូនរក្សាភ្ជាប់និស្ស័យជា មួយម្តាយ
ជាការបណ្តុះកម្លាំងចិត្តមួយអោយគេទទួលស្គាល់ឫស កែវកំណើតរបស់គេបានច្បាស់លាស់ ។
ថ្វីបើម្តាយរបស់គេបាន ប្រព្រឹត្តកំហុសខ្លះៗពីអតីតកាល ប៉ុន្តែគួរណាតែយើងទុកឱកាសឲ្យ
ក្មេងបានអហោសិកម្មចំពោះម្តាយ ហើយអោយម្តាយទទួលដឹងថា
តើកូនខ្វះការកក់ក្តៅយ៉ាងណាបើគេខ្វះម្តាយ ។ បងដឹងថាភិសម័យ បានទទួលស្គាល់ការពិតហើយ
ថានាងមិនបានប្រព្រឹត្តខ្លួនជាម្តាយដ៏ ល្អសម្រាប់កូន ។ សង្ឃឹមថា ការជួបដាវ៉ាន់លើកនេះ
ធ្វើអោយគេ រៀនផ្លាស់ប្តូរខ្លួន ដើម្បីក្លាយជាមាតាដ៏ល្អសំរាប់កូនដទៃទៀត ពេល
ណាគេរៀបការមានគ្រួសារថ្មីទៅ ។ ចំណែកដាវិញ... អូនជា បេះដូង ជាជីវិតបច្ចុប្បន្នរបស់បង...
បងមិនសុខចិត្តព្រលែង បច្ចុប្បន្នដ៏ស្រស់ថ្លារបស់បងចោលហើយ វិលទៅរកចាប់អតីតកាល
ដ៏ខ្មៅងងឹតនោះទៀតឡើយ ។ បងបានទទួលមេរៀនហើយ ហើយ បងក៏រាងចាលដែរ ។
ពេលនេះ ដាយល់ចិត្តបងហើយនៅ ?... បើយល់ហើយញញឹមឡើងណ៎ា!

CHANBOKEO.COM

ញញឹមផ្តល់កម្លាំងចិត្តដល់បង រួច ហើយញញឹមដើម្បីសុភមង្គលរបស់យើងទាំងពីរនាក់...
ណា៎អូន !

ពូវាចាទន់ភ្លន់ផ្អែមល្ហែម ធីតាទ្រាំមិនបានក៏ញញឹមយ៉ាងស្រស់
លាយនឹងភាពអៀនប្រៀនបន្តិចនៅលើផ្ទៃមុខ ធ្វើអោយបេះដូង ដារិទរីកប៉ុនចង្អេរតែម្តង ។
បន្តិចមក ដារិទស្រដីថា ៖

- ចុះការប្រឡងរបស់អូនដា យ៉ាងណាហើយ ?

ធីតាញញឹមមិនឆ្លើយទេ គ្រាន់តែគ្រវីក្បាល ។

- ចុះការសម្ភាសន៍ជាមួយមន្ត្រីអន្តោប្រវេសក៍អាមេរិកនោះ ?

នាងញញឹមហើយគ្រវីក្បាលដដែល ។ ទ្រាំមិនបាន ដារិទក៏ និយាយថា ៖

- នេះប្រហែលជាដាចង់អោយបងចាប់គ្រញិចថើបហើយ បានជា
មិនព្រមឆ្លើយយ៉ាងនេះ ?

នរៈស្រដីផង យកនាសារុញជ្រមុលរកថ្ពាល់នារីផង ។ ធីតាស្ទុះ គេចរឹង
បែរខុសលំនឹងក៏ធ្លាក់ចេញពីទូកចូលទឹកបឹងប្រូង ដោយ នាំទាំងដារិទទៅក្នុងទឹកជាមួយផង ។
ទាំងពីរនាក់ក៏ផ្ទុះសំណើច ឡើងយ៉ាងក្អាកក្អាយ ព្រមជាមួយដៃបាចទឹកដាក់គ្នាទៅមកទាំង
ឃ្នាន់ខ្នាញ់ផង រំភើបក្នុងចិត្តផង រៀងៗខ្លួន ។

បន្តិចមក ដារីទក៏ដឹកដៃធីតាដើរឡើងគោកវិញ ។

- សូមទោសណា៎ដា ដែលបងធ្វើអោយដាធ្លាក់ទឹក ។ ចាំទៅផ្ទះវិញ
បងយកអាល់កុលលាងស្នាមឆ្កេររបួសអោយ កុំអោយឆ្លងមេរោគ នាំអោយមានកុំខ្ទុះ ។

មែនហើយ ធីតាកំពុងមានរបួសនៅកំភួនជើងផង បើត្រូវទឹក យ៉ាងនេះ
ប្រហែលជានឹងឈឺនរមកវិញក៏មិនដឹង ។ ភ្លាមនេះ ដារិទក៏យកលេស
លើកធីតាបីត្រកងក្នុងរង្វង់ដៃភ្លាម មិនអោយ នាងដើរដោយខ្លួនឯង
ធ្វើអោយមាណវីនឹកអៀនក្រសៃភ្នែកអ្នក ស្រុកម្តុំនោះឡើងរឹងខ្លួន ។

- បងដារិទ ! លេងអីអាក្រក់មើលម្ល៉េះ ?
- មិនអាក្រក់ទេ ! ធ្វើយ៉ាងនេះ អ្នកស្រុកសប្បាយភ្នែករីករាយក្នុង ចិត្តណាស់
ព្រោះគេមិនងាយឃើញទស្សនីយភាពយ៉ាងនេះ ញឹក ញាប់ឯណា នៅក្នុងជីវិតរបស់គេ ។
- តែផ្តាស !

CHANBOKEO.COM

ទោះជាយ៉ាងណាក៏ដាវិនមិនដាក់ធីតាចុះពីដៃដែរ ។ គេដើរបី នាងយកទៅដាក់ឡានធ្វើព្រងើយ ហាក់មិនបានឃើញក្រសែភ្នែក របស់មីងលក់ផ្កាឈូកនិងញាតិទាំងឡាយ ដែលឈរមិញផ្កាឈូកនោះសោះឡើយ ។

លុះត្រឡប់មកផ្ទះវិញ គេបានបើកឡានឈៀងចូលទៅផ្ទះ លោកដាវុធ ដែលទើបតែមកដល់ផ្ទះពីធ្វើការ ។ គេបាននាំធីតា ទៅលុតជង្គង់មុខលោក ជំរាបថា ៖

- កូនត្រឡប់ទៅអាមេរិកខានស្អែកនេះហើយលោកប៉ា! ហើយកូននឹងមានពិធីមង្គលមួយនៅផ្ទះអូនដាវេលាស្អែកដែរ ។ កូនមកជំរាប សុំពរពីលោកប៉ា ក្រែងលោលោកប៉ារវល់ មិនអាចចូលរួមបាន ។

ឮដូច្នោះ លោកដាវុធក៏ចាប់ដៃកូនទាំងពីរផ្គុំគ្នាឡើង ៖

- មិនថាកូនធំអាយុប៉ុន្មានទេ ប៉ានៅតែស្រឡាញ់ហើយបារម្ភពីកូន ជានិច្ច ។ ពេលនេះកូនរៀបការមានគូស្រករ ប៉ាក៏សូមជូនពរឲ្យ កូនជួបតែសេចក្ដីសុខរៀងរហូតទៅ ហើយបើមានពេល មកលេង នឹងប៉ា អោយប៉ាឧស្សាហ៍បានឃើញមុខកូនផង ។

លោកដាវុធស្រដីទំនងអួលៗ ដោយក្ដីអាណិតចំពោះកូន ។ មួយស្របក់ក្រោយមក អ្នកទាំងពីរក៏លាលោកដាវុធចេញមកវិញ ។

- បងដាវិនជំរាបលោកប៉ាបង អំពីពិធីមង្គលអ្វី ?

ពេលនេះដល់វេនដាវិនម្ដងហើយ ។ គេញញឹមខ្ជិបខិទមាត់ ឈឹងមិនព្រមឆ្លើយ ។

- បងដាវិន ? ឆ្លើយមើល៍...

គេមិនឆ្លើយដដែល ។ ទ្រាំមិនបាន ធីតាក៏ចាក់ក្រឡេកដាវិន ធ្វើអោយនរៈឆ្លាយសំណើចកក្អឹកឡើងយ៉ាងសប្បាយ ។

ព្រលប់នោះ ដាវិនមានអារម្មណ៍ថា មេឃាភ្នំពេញស្រស់ស្អាត ខុសធម្មតា ។ ឯបាយដែលគេកំពុងបរិភោគនៅជាមួយក្រុមគ្រួសារ របស់អ៊ំសាឡាដក៏មានរសជាតិផ្អែមខុសប្រក្រតី ។ ចំណែកភាព រមនាក្នុងគ្រួសាររបស់ធីតា បានធ្វើអោយការជួបជុំរបស់គេ ដាវី ដាវ៉ាន់ និងស្រស់ឆោមជាមួយទាំងអស់គ្នា ក្លាយទៅជាពិភពមង្គល មួយដ៏ល្អត្រកាល មិនចាញ់ស្ថានសួគ៌ត្រៃត្រឹង្សឡើយ ។

ព្រឹកស្អែកឡើង...

អ៊ំសាឡាងនិងអ៊ំសារី ទាញអំបោះសចងដៃដារិននិងធីតា ។ អ៊ំ សាឡាងមានប្រសាសន៍ថា ៖
- ប៉ាម៉ាក់ជាមនុស្សសាមញ្ញ មិនចង់បានអ្វីធំដុំជាទ្រនាប់ដៃពីកូន ទេ ហើយក៏គ្មានអ្វីចែកកូនវិញ ក្រៅពីអំបោះសចងដៃកូនថ្ងៃនេះ ព្រមទាំងពាក្យជូនពរដល់កូន អោយអ្នកទាំងពីរយល់តែភាពរុងរឿងក្នុងជីវិត ។ ពិធីថ្ងៃនេះសន្មតថា ជាការភ្ជាប់ពាក្យយ៉ាងត្រឹម ត្រូវរវាងកូនទាំងពីរហើយ ។ ចូរកូនរក្សាសេចក្ដីស្មោះស្មគ្រ័ចំពោះ គ្នាអោយបានប្រពៃបំផុតណាំកូនណាំ ។

អ្នកទាំងពីរក៏ក្រាបទទួលការប្រស់ព្រំពីឪពុក កេសាដល់កំរាល..
ដារិនលួចចោលកន្ទុយភ្នែកដាក់នារី ឃើញនាងញញឹមដាក់គេវិញ យ៉ាងស្រស់បំព្រង ។ បេះដូងរបស់គេក៏រណ្ដំចង្វាក់តន្ត្រីរមនាមួយ បទយ៉ាងពិរោះញាប់ញ័រ ។

រំពេចនោះ ស្រាប់តែមានរថយន្តថ្មីស្រឡាងមួយមកដល់...

ទាំងអស់គ្នាក៏បែរមើលស្រោច ទៅលើបុរសម្នាក់ដែលកំពុងចុះ ពីរថយន្តចេញមក ។
- លោកប៉ា! (ដារិនលាន់មាត់ ហើយក៏ស្ទុះក្រោកទៅទទួលលោក)

លោកដារុធមានប្រសាសន៍ថា ៖
- លើកមុន ប៉ាខកខានមិនបានជូនពរកូនត្រឹមត្រូវក្នុងពិធីមង្គល... ទើបជីវិតគូស្រករបស់កូនមិនបានជោគជ័យ ។ លើកនេះ ប៉ាបាន សម្រេចចិត្តថាសុខចិត្តប្ដូរពេលមួយថ្ងៃ ប្រឆាំងនឹងអារម្មណ៍អ្នកផ្ទះ ដើម្បីជូនពរដល់កូនទាំងពីរឲ្យជួបតែសុភមង្គលមួយជីវិត ។

ដារិននិងធីតាសម្លឹងមុខគ្នា សម្ដែងក្ដីរំភើបក្នុងចិត្ត បន្តិចមក ក៏លុតជង្គង់អោនកេសាទទួលយកនូវការប្រស់ព្រំប្រសិទ្ធិពរជ័យ ពីលោកដារុធ ដោយដួងចិត្តរំជើបរំជួល ។
- បងធ្វើបែបនេះមិនបានទេ!

សម្លេងស្ត្រីមួយរូបស្រដីកាត់បរិកាសដែលម្នាក់ៗកំពុងឆ្លង់ឆ្ងោត ស្មារតីលើគូស្រករថ្មី ធ្វើអោយអ្នកទាំងអស់គ្នាភ្ញាក់ក្រញាងបែរមើល យ៉ាងរហ័ស ក៏ប្រទះឃើញអ្នកស្រីពិសីកំពុងដើរចូលមក ។ ដារិន និងធិតាថ្លោះទឹកមុខភ្លាម ត្បិតនឹកមិនយល់ថា ហេតុអ្វីអ្នកស្រីមក ដល់ទីនេះដែរ ? តើអ្នកស្រីមានបំណងយ៉ាងណា ? ភ្លាមនេះ អ្នក ស្រីបានមកដល់ចំពោះមុខដារិននិងធីតា ដាក់ខ្លួនក្បែរលោកដារុធ ហើយមានប្រសាសន៍ថា ៖
- តើកូនចៅនឹងមានសុភមង្គលអីទៅ បើអ្នកជូនពរនោះបែកបាក់ មែកធាង ? នឹងអោយមានសុភមង្គលគ្រប់គ្រាន់ ទាល់តែទទួលពរ ពីអ្នកដែលមានគូ មានសុភមង្គលគ្រប់គ្រាន់

CHANBOKEO.COM

ទើបការប្រស់ព្រាំពរ ជ័យនោះមានប្រសិទ្ធភាពពេញលក្ខណៈ មែនទេ បងដារ៉ុធ ? មែន ទេ អ្នកដន្លង ?

អ៊ំសាឡាងនិងអ៊ំសារីភ្ញាក់ព្រើត បែរមើលមុខគ្នា ដែលឃើញ អ្នកស្រីពិសីហៅគាត់ថា អ្នកដន្លង ។ ប៉ុន្តែ អ្នកស្រីពិសីធ្វើមិនដឹង បែរមករកដារិដនិងពិសី ហើយស្រដីថា ៖

- មីងឃើញដារិដតាំងចិត្តរឹងត្អឹង ក្នុងការជ្រើសរើសគូស្រករ មិនអោយនរណាមកជួយសម្រេចចិត្តជំនួសខ្លួន មានន័យថា ដារិដមាន ការជឿជាក់ក្នុងចិត្ត ក្នុងការទទួលធីតាជាគូគ្រង ។ មីងវិញក៏គ្មាន សមត្ថភាពនិងបំបែកអ្នកទាំងពីរបានដែរ ព្រោះចិត្តអ្នកទាំងពីរបាន ចងភ្ជាប់សម្ពន្ធ័មេត្រីយ៉ាងណែនចំពោះគ្នារួចទៅហើយ ។ ដូច្នេះ មីងសម្រេចចិត្តថា មកលើកទឹកចិត្តអ្នកទាំងពីរទៅចុះ អោយអ្នកទាំងពីរកាន់តែមានចំណងជីវិតស្និតរមួតរឹងមាំតរៀងទៅ ។ យ៉ាង ណាៗ ក៏ឯងជាកូនរបស់បងដារ៉ុធ ដែលគាត់មិនអាចកាត់ផ្ដាច់ ចំណងជាឪពុកកូនចេញពីជីវិតបាន ។ ឯមីង ក៏សូមទទួលស្គាល់ ចំណងនោះដែរ ព្រោះមីងមិនចង់អោយចំណងនោះក្លាយជាខ្សែព្រ័តប្រទាញប្រទង់យកបងដារ៉ុធ អោយចាកឆ្ងាយពីជីវិតរបស់មីង ដូចគ្នា ។ ដូច្នេះ សូមដារិដទទួលស្គាល់ចំណងដែលបងដារ៉ុធត្រូវ រក្សាដើម្បីមីងផង យល់ទេកូន ?

ប្រយោគមួយនេះ បានធ្វើអោយដារិដញញឹមឡើងទាំងរំភើប ចិត្ត ហើយក៏ចាប់ដៃធីតាលំទោនទទួលយកពរជ័យពីអ្នកស្រីពិសី ភ្លាម ៖

- អរគុណណាស់ អ្នកមីង ដែលមានចិត្តអាណិតមេត្តាដល់ខ្ញុំនិងអូន ធីតា ។ សូមអរគុណចំពោះពរជ័យរបស់អ្នកមីងថ្ងៃនេះ !

ស្នូរទះដៃក៏លាន់រំពងឡើងយ៉ាងខ្លាំងជាលើកដំបូងបង្អស់នៅផ្ទះ អ៊ំសាឡាង រហូតដល់ធ្វើអោយអ្នកជិតខាងរត់មករកមើលរហង់ ។

នៅឯបឹងឈូកវិញ...

រសៀលថ្ងៃដដែល...

មីងលក់ផ្កាឈូក កំពុងឡើងពីទូក ត្រកងកញ្ច្រែងផ្កាដែលទើប នឹងកាត់ហើយ ដើរឡើងច្រាំង ស្រាប់តែប្រទះមនុស្សប្រុសមួយ ហ្វូងកំពុងនាំគ្នារុះរើខ្ទមស្បូវកញ្ជាស់របស់គាត់ ។

- នែ៎! ធ្វើអីហ្នឹងអានាង ? ហេតុអីមករើខ្ទមមីងអញ្ជឹង ?

បុរសម្នាក់ឆ្លើយថា ៖

CHANBOKEO.COM

- ខ្ញុំយកដៃអង្រួនលេង ស្រាប់តែខ្ទមនេះវាជ្រុះស្បូវ បាក់ដំបូល មកលើក្បាលខ្ញុំ ទើបខ្ញុំរើវាទៅ ។

មីងនោះ ក៏ស្រែកទ្រហោឡើងថា ៖

- មីងជំពាក់អីឯង បានជាមករើខ្ទមកញ្ជាស់របស់មីងយ៉ាងនេះ ? តើមីងបានអីជ្រកពួនទៅ ?

ស្រាប់តែបុរសម្នាក់ទៀតមកស្រវាអោបគាត់ចេញទៅ ថែម ទាំងស្រដីថា ៖

- មានគេបញ្ជាមកថាអោយមីងឈប់មាត់ បើពុំនោះសោតមីងនឹង មានរឿងហើយ ។
- មានរឿងទៅ អានាង ? មីងលក់តែផ្កាឈូកចិញ្ចឹមជីវិត មិន ដែលរករឿងនរណា ហេតុអ្វីក៏ព្រះដាក់បណ្តាសាមីងដូច្នេះ ?
- នរណាថាមីងត្រូវបណ្តាសាព្រះ ? ការពិតមីងកំពុងត្រូវបណ្តាសា មនុស្សលោកទេតើហ៏ ?
- ហ៊្ហស ? ថាម៉េច ? មីងមិនយល់ទេ ។
- ពីរបីម៉ោងទៀតមីងនឹងយល់ហើយ ។

បុរសនោះក៏បាននាំមីងមកដល់មន្ទីរស្នាក់ការប្រចាំឃុំ រួចហើយ ហុចក្រដាសអោយមីងស៊ីញ៉េទទួល ៖

- មីងមិនចេះស៊ីញ៉េស្អីទេ បើមិនចេះអក្សរម៉ាម៉ាត់ផង !
- អញ្ចឹង ផ្តិតមេដៃ !
- ផ្តិតធ្វើអី ?
- ថាអោយផ្តិតមក... កុំទីមទាម !

បុរសនោះក៏ចាប់ដៃអោយមីងផ្តិតទឹកខ្មៅលើក្រដាស ។ មីង ព្រមធ្វើទាំងខ្លាច ព្រោះមិនដឹងពួកគេមានបំណងអ្វី ។ បន្តិចមក គេក៏ហុចក្រដាសនោះទៅមីងមួយសន្លឹក ដំកល់នៅសាលាឃុំមួយ សន្លឹក រួចហើយក៏នាំមីងមកដល់កន្លែងដើម ស្រាប់តែមីងភ្ញាក់ ក្រញាង ព្រោះឃើញមានរោងធំមួយទើបសង់ហើយ មានជញ្ជាំង ឈើប្រក់សង្កសី មានទំហំធំជាងខ្ទមចាស់របស់គាត់ដល់ទៅពីរបី ដង មានបន្ទប់សំរាប់គេង ហើយមានរានហាលសំរាប់ដាក់ផ្កាលក់ ព្រមទាំងមានទីក្រាលកន្ទេលអង្គុយលេងផង ។

- នេះជាផ្ទះរបស់មីងហើយ !

សម្លេងបុរសម្នាក់ស្រដីពីក្រោយខ្នង ។ មីងយើងងាក់មើលផាំង ឃើញដារីដដឹកដៃធីតានិងដាវ៉ាន់ដើរចូលមកជិត ។

- ការពិត គឺអន្ទិតឯងទេ ដែលអោយគេមករើខ្ទមកញ្ជាស់របស់ មីងថ្ងៃនេះ ?

CHIANBOKEO.COM

- សូមទោសណាមីង! ខ្ញុំជ្រុលដៃរុះរើខ្ទមរបស់មីង! ប៉ុន្តែខ្ញុំសង ម៉ាខ្ទងវិញហើយ មិនអោយមីងសំរាន្តមើលមេឃមើលផ្កាយទេ ។

- ពុទ្ធោអើយ អាអន្ទិត! ឯងធ្វើបែបនេះ មីងភ័យលោះព្រលឹង ណាស់នឹងទេ?

ដាវិឌនិងធីតាក៏ញញឹមដាក់គាត់ទាំងពីរនាក់ ។ បន្តិចមក ដាវិឌ ក៏យកថាសមួយដែលមានផ្កាឈូក ធូបទៀន ស្លាធមិ និងកញ្ចប់ អីវ៉ាន់ខ្លះទៀត មកជូនមីង ហើយស្រដីថា ៖

- ទឹកចិត្តរបស់មីងចំពោះយើងទាំងពីរត្រជាក់ត្រជុំរមនា ដូចទឹក បឹងនេះណាស់ ។ ពេលនេះ ក្មួយទាំងពីរសូមចូលខ្លួនមកជូនពរមីង អោយមីងរកស៊ីមានបាន ចិញ្ចឹមកូនស្ងួនចៅសុខសប្បាយត្រជាក់ ត្រជុំរៀងទៅ ។

ភ្លាមនោះ ស្រាប់តែមីងយើងទ្រហោយំឡើង ៖

- អានាងអើយ! មីងអរគុណឯងណាស់ ។ សមត្ថភាពដូចមីង រក ថៃមមួយជាតិទៀត ក៏ស្រម័យរកផ្ទះមួយប៉ុននេះមិនបានដែរ ។ ពេលនេះ កូនមីងមានកន្លែងដេក មិនបាច់រងទឹកភ្លៀងរងាដូចមុន ទៀតហើយ ។

ថាហើយ គាត់ក៏លើកដៃសំពះមេឃ ហើយស្រដីថា ៖

- មីងសូមជូនពរអោយក្មួយទាំងពីរមានសុភមង្គលរហូតរៀងទៅ!

ដាវិឌនិងធិតាក៏អោនទទួលយកពរជ័យពីមីងម្នាក់នោះ ដែល បានយកផ្កាឈូកទៅជ្រលក់ទឹកបឹងមកប្រស់ព្រំលើកេសាអ្នកទាំងពីរ ថែមទាំងស្រដីថា ៖

- ថ្វីបើទឹកបឹងនេះពុំមែនជាទឹកថ្លាដែលបញ្ចេញពីក្បាលម៉ាស៊ីនមក ប៉ុន្តែ ជាទឹកបឹងបរិសុទ្ធដែលធម្មជាតិផ្តល់មកអោយយើង ជាទឹក ដែលមានទេវតាអារុក្ខអារក្សអ្នកតា វិញ្ញាណក្ខន្ធ័សក្តិសិទ្ធិថែរក្សា ។ ដូច្នេះមីងសូមយកទឹកបឹងនេះប្រស់ព្រំអ្នកទាំងពីរ សូមអោយបារមី ទឹកបឹងដ៏ត្រជាក់ត្រជុំរមនានេះ កំចាត់អពមង្គលទាំងឡាយក្នុងជីវិត ហើយសូមឲ្យ ក្មួយជួបតែភាពសំបូរសប្បាយហើយមានគ្រួសារ សុខសុខុមត្រជាក់ដូចទឹកបឹងនេះតរៀងទៅ ។

ដាវិឌនិងធីតាបែរមើលមុខគ្នា រួចហើយក៏អោយសិរសាទទួល យកពរសាធុការពីមីងអ្នកលក់ផ្កាឈូក ដោយក្តីសោមនស្សរំភើប ក្រៃលែង ។

CHANBOKEO.COM

*oooooooooooooooo*

*oooooooooo*

*o*

CHANBOKEO.COM

# វគ្គទី១២
# តន្ត្រីបេះដូង

នៅវាលយន្តហោះអន្តរជាតិភ្នំពេញ...

សិលាទាញរទេះមួយអូសវ៉ាលីសរបស់នារីសោភា ស្រស់ឆោម និងដារីយកចេញពីរថយន្ត សំដៅមាត់ទ្វារច្រកចូលពិនិត្យឥវ៉ាន់មុន នឹងឡើងយន្តហោះ ។ នៅម្ខាងទៀត សុធននិងដារិងក៏កំពុងលើក វ៉ាលីសចេញពីគូថឡានដាក់រទេះដូចគ្នា ។ ធីតាដើរកាន់ដៃដាវ៉ាន់ចុះចេញពីរថយន្ត នាំមុខអ៊ំសាឡាងនិងអ៊ំសាវីដែលអញ្ជើញមកជូន ដំណើរអនាគតកូនប្រសារឡើងយន្តហោះត្រឡប់ទៅអាមេរិកវិញ ថ្ងៃនេះ ។

ទាំងអស់គ្នាឈរសម្លឹងគ្នាមួយស្របក់ សម្ដែងដួងចិត្តអាល័យ ដែលត្រូវបែកគ្នាថ្ងៃនេះ ។ មើលទៅម្នាក់ៗហាក់ដូចជាប្រឹងញញឹម ណាស់
តែក៏គ្មាននរណាអាចលាក់មិនជិតនូវភាពក្រៀមក្រំនិងការ អាឡោះអាល័យក្នុងចិត្តរបស់គេឡើយ ។

ភ្លាមនោះ សុធនក៏ដើរមកជិតដារិង ដោះមួកចេញពីក្បាល រួចហើយស្រដីថា ៖

- បងដារិង! ខ្ញុំមានសេចក្ដីត្រេកអរណាស់ដែលខ្ញុំបានស្គាល់បង ហើយបានស្ដាប់សំដីបងដាស់តឿន ។ ពាក្យទាំងប៉ុន្មានដែលបង ក្រើនរំលឹក បានដាស់សតិរបស់ខ្ញុំអោយភ្លឺជាងមុនច្រើនណាស់! ចាប់ពីថ្ងៃនេះទៅ ខ្ញុំមិនដើរធ្លាក់ផ្លូវចាស់ទៀតទេ! ពេលបងមក ស្រុកខ្មែរវិញសាក្រោយ សុធននិងធ្វើអោយបងភ្ញាក់ផ្អើលចំពោះ លទ្ធផលនៃការកែប្រែរបស់ខ្ញុំមិនខាន ។ ពេលនេះ ខ្ញុំមានមោទន ភាពឧត្តុង្គឧត្តមណាស់ ដែលបានទទួលបងជាបងប្រុសម្នាក់ក្នុង គ្រួសាររបស់យើង ។

គេក៏អោនសំពះដារិងដោយក្ដីគោរពពីក្នុងចិត្ត ។ ដារិងយកដៃ ទះស្មានាយ បន្ថើរៗ ហើយស្រដីថា ៖

CHANBOKEO.COM

- បងក៏មានមោទនភាពខ្ពស់ខ្លាំងដូចគ្នា កាលបើប្អូនមានប្រាជ្ញា ឈ្លាសវៃ
អាចឆាប់យល់អំពីអ្វីដែលខុស អ្វីដែលត្រូវ ហើយកែខ្លួន មកល្អវិញទាន់ពេលវេលា ។
ចាប់ពីថ្ងៃនេះទៅ ជីវិតរបស់ប្អូនមាន តែភាពភ្លឺថ្លាតែប៉ុណ្ណោះ ។

នៅម្ខាងទៀត សិលា ស្រស់ឆោម និងដាវីសំណេះសំណាលផ្តាំផ្ញើមិនចេះអស់មិនចេះហើយ ។
- ឆោមនិងដាវី កុំភ្លេចសរសេរអ៊ីមែលមកលេងខ្ញុំអោយបានញឹក ញាប់ផងណា៎! (សិលាពោល)
- ដាវីប្រហែលជាទុកដាក់ការសរសេរនោះឲ្យឆោមហើយ ព្រោះគេ ទំនេរជាងខ្ញុំ
(ដាវីឆ្លើយញ៉ោះមិត្តរបស់ខ្លួន)
- ទំនេរស្អី ដាវី ? ខ្ញុំត្រូវចូលធ្វើការវិញហើយ! (ឆោមឆ្លើយ)
- ទំនេរព្រោះឯងមិនទាន់មានម្ចាស់ចិត្តនោះអី ។ ចំពោះដាវីវិញ
បែកសង្សារបីអាទិត្យ កំពុងតែនឹកគ្នាណាស់ មិនអាចមានពេល សរសេរទៅមិត្តណាទេ ។ ដូច្នេះ
ឆោមសរសេរផ្ញើជំនួសខ្ញុំផង ។

ឮដូច្នោះ ឆោមក៏លូកដៃក្តិចដាវីមិនអោយនិយាយ ប៉ុន្តែមិនអាចលាក់ជិតពីក្រសែភ្នែករបស់សិលាបានឡើយ ។ គេក៏ញញឹមឡើងបញ្ចេញក្តីសង្ឃឹមនៅលើផ្ទៃមុខ ហើយវាចាថា ៖
- ពេលឆោមទៅដល់កាលីហ្វ័រញ៉ា អ៊ីម៉ែលប្រាប់សុខទុក្ខអោយខ្ញុំដឹង ផងណា៎!
ចាំខ្ញុំអ៊ីម៉ែលផ្ញើបទភ្លេងដែលខ្ញុំលេងខ្លួនឯងនោះអោយ ឆោមស្តាប់រាល់ថ្ងៃ កំដរអផ្សុក ។
- អូហ៍ តើជាបទភ្លេងដែលសិលាចង់ផ្ញើនោះជាបទភ្លេងបែបណា ដែរ ?
បើសិនជាម៉ូដរ៉េបដូចពួកអាគាំងខ្មៅ ខ្ញុំមិនយកទេ ។
- មិនមែនម៉ូដហ្នឹងទេ តែជាម៉ូដដែលឆោមស្តាប់ហើយត្រជាក់ចិត្ត!
- មែនហ្អែស ? ជាតន្ត្រីបែបណាវិញ ?
- ជាតន្ត្រីបេះដូង ស្តាប់កាលណា ស្រម័យនឹកសង្សារនោះអី!

ស្រាប់តែឆោមភ្ញាក់ព្រើត ៖
- តែផ្តាស! ខ្ញុំឯណាមានសង្សារនឹងស្រម័យនោះ ?
- បើមិនមានទេ សម្លឹងមួយទុកអោយហើយទៅ ទាន់គេកំពុង ស្មគ្រ័ចិត្ត (សិលាឆ្លើយ)
- សម្លឹងនរណាគេទៅ បើបីអាទិត្យនេះ មិនបានជួបកម្លោះណាផង ជួបតែម្នាក់គត់សោះហើយ ។

CHANBOKEO.COM

- អញ្ចឹង សម្លឹងម្នាក់គត់នោះទៅ គេរង់ចាំអោយឆោមសម្លឹងហើយ

ពេលនោះ ឆោមសើចញញឹមឡើង ៖

- ចុះម្នាក់ហ្នឹង គេសម្លឹងខ្ញុំវិញដែរទេ ?
- គឺ សម្លឹងយូរហើយ សម្លឹងឡើងស្ពកស្រូវរលីងហើយ តែគ្មាន នរណាគេនឹកនាចាប់អារម្មណ៍សោះ ។
- អញ្ចឹង សម្លឹងទៀតទៅណា៎... សង្ឃឹមថា បន្តិចទៀត មានគេ ចាប់អារម្មណ៍មិនខាន ។
- មែនហ្អេស៎ ?
- មែន !
- ម៉េចដឹង ?
- ព្រោះក្រសៃភ្នែកគេហ្នឹងមានមន្តស្នេហ៍សឹងអី ! ឃើញហើយ ស្រម័យដៃកាន់ហ្គីតា ប្រដេញតន្ត្រីសំនៀងបេះដូង... !

ភ្លាមនេះ សិលាញញឹមតបវិញ ៖

- សង្ឃឹមថា សៀងហ្គីតានោះអាចរំលឹកអោយគេម្នាក់នឹកមកម្ចាស់ បទភ្លេងនោះមិនខាន ។

ដាវីលួចចោលកន្ទុយភ្នែក ដាក់អ្នកទាំងពីរ ហើយដើរចេញធ្វើ មិនឮការសន្ទនារបស់អ្នកទាំងពីរតទៅទៀត ។

CHANBOKEO.COM

រំពេចនោះ ស្រាប់តែមានរថយន្តធំស្អាតស្រឡាងមួយបរមក ដល់ ចតក្បែរអ្នកទាំងអស់ រួចហើយមានមនុស្សចុះស្ទ្រូស្រទុញ រទេះដាក់អ្នកជម្ងឺពីរនាក់ចូលមកដល់ ។ ដាវិដនិងធីតាភ្ញាក់ក្រញាង កាលបើប្រទះឃើញអ្នកទាំងពីរនោះ ៖

- ភិសម័យ ? អ្នកស្រីម៉ារី ? (ដាវិដលាន់មាត់)

មនុស្សពីរនាក់បានរុញរទេះ នាំភិសម័យមកដល់ចំពោះមុខ ធីតា ដែលកំពុងឈរកាន់ដៃកុមារីដាវ៉ាន់ ។

- កូនវ៉ាន់ ! អោយម្តាយសុំអោបកូនបន្តិចបានទេ ?

ដាវ៉ាន់បែរមើលមុខដាវិដ រួចហើយមើលមុខធីតា ឃើញអ្នក ទាំងពីរងក់ក្បាលជាសញ្ញាថាមិនអីទេ នាងក៏ក៏ដើរទៅជិតភិសម័យ ដែលកំពុងលាតរង្វង់ដៃទទួលកុមារីយកទៅអោបផ្ទាប់នឹងដើមទ្រូង របស់នាង ៖

- វ៉ាន់! អោយម៉ាក់សូមទោសចំពោះអ្វីសព្វយ៉ាងដែលម៉ាក់បានធ្វើ ទៅលើកូន! សូមកូនអភ័យទោសអោយម៉ាក់ផង ។

តែដាវ៉ាន់ស្តាប់មិនយល់ទេ ។ នាងគ្រាន់តែសម្ងំស្ងៀមក្នុងរង្វង់ដៃម្តាយ សម្លេងទឹកមុខរារែក ហាក់មិនដឹងថា តើនាងត្រូវទុកចិត្ត ម្តាយថានឹងស្រឡាញ់នាង ឬក៏ត្រូវខ្លាចម្តាយថានឹងធ្វើបាបនាងជាថ្មី ទៀត ។ រំពេចនោះ ភិសម័យថើបថ្ពាសកូនហើយស្រដីថា ៖

- ទោះជាយ៉ាងណា ក៏កូនមានសំណាងណាស់ដែលប៉ារបស់កូនបាន ថែរក្សាកូនមកយ៉ាងល្អ.. សូមកូនត្រឡប់ទៅវិញដោយសុខសប្បាយ ណាកូន! សូមអោយកូនធំឡើងជាក្មេងល្អ!!

បន្តិចមក ភិសម័យបែរមកធីតាហើយស្រវាចាប់ដៃនាងកាន់ ៖

- ជីវិតនៅអាមេរិកមិនមែនស្រណុកសុខសប្បាយដូចយើងគិតទេ.. បើនាងបានទៅ... នាងត្រូវពុះពារបន្តិចហើយ ។ សង្ឃឹមថានាង មានអំណត់ជាងខ្ញុំ មានការពុះពារជាងខ្ញុំ... អាចទ្រាំទ្រនឹងជីវិត ដែលមានតែការងារជាធំនោះបាន ។ ម្យ៉ាងទៀត មីនីសូតាត្រជាក់ ណាស់ ពិតជាពិបាករស់នៅបន្តិច សំរាប់មនុស្សដែលធ្លាប់រស់នៅ អាកាសធាតុក្តៅដូចស្រុកយើង ហើយបងដាវិដក៏មិនជាសំបូរលុយ កាក់ជួយទំនុកបំរុងយើងប៉ុន្មានដែរ ។ បើយើងគ្មានប្រាជ្ញាចេះរក ការធ្វើ រកប្រាក់ផ្គត់ផ្គង់ខ្លួនឯងទេ នាងច្បាស់ជារស់នៅត្បិតត្បៀតអត្តខាត់បន្តិចហើយ ប្រហែលជាពិបាកនឹងសន្សំផ្ញើបងប្អូនដែលនៅខាងក្រោយឯស្រុកយើងណាស់ ។ ទោះជាយ៉ាងណា ក៏ខ្ញុំសូមជូនពរអោយនាងប្រទះតែជោគជ័យល្អរៀងទៅ កុំអោយធ្លាក់រាសីដូចខ្ញុំ នេះអោយសោះ ។ បើសិនជានាងអាចទ្រាំទ្រការលំបាកនោះបាន ជីវិតនាងនឹងមានពន្លឺជាងខ្ញុំមិនខាន!!

បន្តិចមក ភិសម័យក៏បែរមកដាវិដ ហើយស្រដីថា ៖

- ដាវិដ! ឲ្យខ្ញុំសូមទោសដែលបានបង្កបញ្ហាអោយកូនភិតភ័យ.. ប៉ុន្តែនោះក៏ព្រោះតែភិសម័យនឹកកូន ហើយនឹកសោកស្តាយពេលវេលាដែលមិនបាននៅជាមួយកូនអស់ជាយូរឆ្នាំ ទើបលួចជំរត់នាង មកស្រុកខ្មែរ ។ ថែងន្យខ្ញុំភ្លេចគិតថា គេមិនស្គាល់ខ្ញុំ មិនមាន ចំណងចិត្តជាម្តាយនឹងកូនទេ ព្រោះខ្ញុំឃ្លាតគេយូរឆ្នាំពេក ។ ពេល មកដល់ស្រុកខ្មែរវិញ ដាវ៉ាន់យំរករឿងទារទៅរកបងរាល់ថ្ងៃ រហូត ដល់ខ្ញុំខឹងវាយទះកូន ព្រោះខ្ញុំច្រណែនដែលកូនស្រឡាញ់បងជាង ខ្ញុំជាម្តាយ ។ ការឈឺចាប់របស់ខ្ញុំ

CHANBOKEO.COM

បានធ្វើអោយម្ដាយខ្ញុំឈឺជាមួយ ដែរ ទើបយើងធ្វើអ្វីៗចេញទៅមិនបានគិត គឺធ្វើតាមតែអារម្មណ៍ ពុះកញ្ជ្រោលរោលរាលប៉ុណ្ណោះ ។ ចៃដន្យ ការបញ្ចេញអារម្មណ៍ ដោយខ្វះសតិ ខ្វះការពិចារណា បានធ្វើអោយកូនវ៉ាន់ភ័យខ្លាចរូបខ្ញុំ ជាម្ដាយលើសមុនទៅទៀត ។ ពេលនេះ ខ្ញុំដឹងហើយ ថាខ្ញុំមិនមានគុណសម្បត្តិគ្រប់គ្រាន់សំរាប់ថៃដាវ៉ាន់ អោយនាងមានសេចក្ដី សុខដូចដែលនាងនៅជាមួយបងទេ ។ អោយខ្ញុំសូមផ្ញើកូននឹងបង ផង ដារិន!
ថ្វីត្បិតតែយើងចែកផ្លូវគ្នាមែន តែយើងឈប់ចង អាឃាដគ្នាអី...
សូមអោយកូនមានឱកាសស្គាល់ម្ដាយគេហើយឲ្យ
ម្ដាយមានឱកាសកែខ្លួនហើយបានផ្ដល់សេចក្ដីស្រឡាញ់ និងភាព កក់ក្ដៅក្នុងជីវិតរបស់នាងខ្លះ គ្រាន់បើជាងអោយនាងរងាក្នុងចិត្ត ដោយភាពកំព្រាម្ដាយនោះ មួយជីវិតដែរ ។

ដារិននៅឈរស្ងៀមយ៉ាងយូរ... ទើបស្រដីថា ៖

- ដារិនមិនដែលស្អប់ភិសម័យទេ ថ្វីបើអូនបានដើរចេញពីជីវិត បងទៅក៏ដោយ ។ នាគ្រាមួយនោះ បងតែងគិតសង្ឃឹមថាអូននឹង កែប្រែហើយបងនឹងទទួលអូនវិលមកផ្ទះវិញសាជាថ្មី... ប៉ុន្តែនៅ គ្រានោះ អូនក៏មកភូតកុហកអោយបងអាណិតរួចបណ្ដោយអោយ កូនទៅលេងនឹងម្ដាយ ដើម្បីរិតចំណងសម្ពន្ធ័ម្ដាយនឹងកូនសាជាថ្មី អូនបែរជាក្បត់សេចក្ដីអាណិតស្រឡាញ់របស់បងជាលើកទីពីរដោយ លួចជំរត់កូនពីបងចេញមកស្រុកខ្មែរ ធ្វើអោយបងភិតភ័យល្ងើង មាត់អស់រលីង... គឺពេលនេះហើយដែលបេះដូងរបស់បងរំសាយ ចិត្តឈប់រំពឹងថា នឹងរក្សាចំណងជាមួយអូនតទៅទៀត... ព្រោះអូន មិនព្រមយល់នូវអ្វីដែលបងបានបូជាដើម្បីអូននិងកូនកន្លងមកនោះ ទេ ។ ទោះបីយ៉ាងណាក៏ដោយ សេចក្ដីស្រឡាញ់របស់បង ចំពោះ កូនវ៉ាន់មានន័យធំធេងចំពោះបងណាស់ ទើបបងសំរេចចិត្ត អភ័យ ទោសអោយភិសម័យជាថ្មីដើម្បីឲ្យកូនមានឱកាសឃើញអូនខ្លះៗ ។ ចាប់ពីថ្ងៃនេះទៅ បងសង្ឃឹមថា ភិសម័យនិងកែប្រែដើម្បីកូន និងដើម្បីខ្លួនអូនផ្ទាល់ ។ ជួនកាល ការបែកគ្នារវាងយើងទាំងពីរជា ចំណុចចាប់ផ្ដើមនៃជីវិតរុងរឿងរបស់ភិសម័យ នៅកន្លែងថ្មីមួយ ទៀត ក៏មិនដឹង ។ សង្ឃឹមថា យើងនឹងធ្វើជាមិត្តល្អនឹងគ្នា រៀង រហូតទៅ ដើម្បីសុខមាលភាពផ្លូវចិត្តរបស់ដាវ៉ាន់ ។

CHANBOKEO.COM

ភិសម័យក៏ញញឹមឡើង ៖
- អរគុណណាស់ ដារិង! សូមអរគុណចំពោះទឹកចិត្តដ៏ទូលាយ របស់បង ។ សូមផ្ញើកូនវ៉ាន់ផងណា! ថ្ងៃណាបងមកលេងស្រុកខ្មែរ ទៀត កុំភ្លេចនាំកូនអោយខ្ញុំបានឃើញមុខគេម្តងៗផង ។
- បាទ! បងក៏អរគុណអូនដូចគ្នា ដែលយើងឈប់ចងគំនុំ ចង អាឃាតយកចាញ់យកឈ្នះនឹងគ្នាតទៅទៀត ។
ភ្លាមនោះ ភិសម័យលាតវង្វង់ដៃឡើង ៖
- ឲ្យភិសម័យទទួលនូវភាពកក់ក្តៅជាមិត្ត ពីដារិងបានទេ?
ដារិងក៏សម្រូតខ្លួនចុះនៅពីមុខរទេះកង់ ហើយស្រវាអោប ភិសម័យ ព្រមទាំងអង្អែលខ្នងនារីបន្តើរៗ ៖
- សូមអោយភិសម័យឆាប់ជាសះស្បើយឆាប់ៗ! ហើយរក្សាខ្លួនឲ្យ ល្អ ដើម្បីជួបកូនវិញ នៅពេលដែលគេត្រឡប់មកលេងម្តាយរបស់ គេនៅស្រុកខ្មែរនេះ ។
ភិសម័យញញឹមឡើងទាំងទឹកភ្នែករលីងរលោង ។
ភ្លាមនោះ ស្រាប់តែមានដៃមួយមកចាប់កាន់ដៃដារិងអោយ ងាកទៅរកគេ ។ នរៈងើយមុខឡើងឃើញអ្នកស្រីម៉ារីញញឹមមករក ព្រមទាំងមានប្រសាសន៍ថា ៖
- ម៉ាក់សុំទោស ដែលម៉ាក់ខឹងឆេវឆាវដាក់កូន ហើយបង្កភាពមិន សុខសប្បាយអោយគេឯងភ្ញាក់ផ្អើល... ប៉ុន្តែ នោះព្រោះម៉ាក់ បណ្តោយអោយអារម្មណ៍ ដែលម៉ាក់ព្រួយឈឺចាប់ជ្រួលច្របល់រឿង របស់ភិសម័យដណ្តប់ជីវិតម៉ាក់ខ្លាំងពេក មិនបានពិចារណាឲ្យបាន ត្រឹមត្រូវ ទើបធ្វើអ្វីទទឹងទទែង ។ ពេលនេះ ម៉ាក់បានរំសាយចិត្ត ហើយ ហើយក៏មកសុំចងភាពជាមិត្តនឹងគ្នាវិញ ដើម្បីអោយ ភិសម័យគេមានឱកាសជួបកូនគេខ្លះ...
អ្នកស្រីឈប់ស្ងៀម ទំនងអួលអាក់ក្នុងចិត្ត បន្តិចមកក៏បន្តថា៖
- ជាតិជាម្តាយ ទោះបីជាខ្លួនធ្លាប់ធ្វើខុស ធ្វើអាក្រក់យ៉ាងណាក៏កាត់ ចិត្តមិនដាច់ពីកូនដែរ ។ ចំណែកកូនវិញ មិនថាគេស្គាល់ឬមិន ស្គាល់ម្តាយរបស់គេនោះទេ បេះដូងរបស់គេតែងតែងង្ហោយហៅ រកម្តាយជានិច្ច មិនថាគេចំរើនដល់វ័យណាក៏ដោយ ។ ពេលនេះ ម៉ាក់អរគុណដារិងណាស់ ដែលយល់ចិត្តភិសម័យនិងយល់ចិត្តចៅ វ៉ាន់ដែលកំពុងងង្ហោយការរាប់រកគ្នាវិញដោយល្អ ។

CHANBOKEO.COM

ដារិនលើកដៃសំពះប្រណម្យឡើង ៖
- កូនក៏សូមទោសផងដែរ បើសិនកូនមានការខុសឆ្គងអ្វីចំពោះ ម៉ាក់
និងចំពោះភិសម័យកន្លងមក ។ សូមឲ្យម៉ាក់សុខសប្បាយ!
ពេលណាកូនបានមកលេងស្រុកខ្មែរទៀត កូននឹងនាំចៅស្រីទៅ លេងម៉ាក់មិនខាន ។
អ្នកស្រីម៉ារីញញឹមឡើង លើកដៃបបោសក្បាលដារិនបន្តើរៗ
បង្ហាញនូវការរាប់រកគ្នាជាកូនចៅសាជាថ្មី រួចហើយក៏បែររកមើល ធីតា
បំរុងនឹងមានប្រសាសន៍ជាមួយនាង ស្រាប់តែបាត់នាងចេញ ពីទីនោះទៅ ។
អ្នកស្រីក៏ឧទានឡើងថា ៖
- ដារិន! គូដណ្តឹងរបស់ឯង គេទៅណាហើយ ?
ដារិនងើបឈរឡើងបែររកមើល មិនឃើញនាងសោះ ឃើញ
តែដាវ៉ាន់ដែលកំពុងដើរតោងដៃដារីចូលទៅខាងក្នុង ។ ភ្លាមនេះ ដារីនិងស្រស់ឆោម
លើកដៃបក់ហៅនាយពីចម្ងាយមកថា ៖
- បងដារិន! ដល់ម៉ោងចេញដំណើរហើយ ឆាប់ចូលមក!
- អត់ទេ! បងរកអូនដាសិន... យើងមានទាន់លាគ្នាឯណា ?
គេក៏ស្ទុះទៅសួរឪពុកម្តាយនិងបងប្អូនធីតា តែគ្រប់គ្នាគ្រវី ក្បាលធ្វើមីងមាំងទាំងអស់គ្នា ។
អ៊ំសារីក៏ពោលថា ៖
- ប្រហែលនាងដាគេទៅរកបន្ទប់ទឹកទេដឹង ?
ដារិនស្ទុះរឹងរត់ពាសពេញទីធ្លា ដែលសំរាប់អោយបងប្អូនមក ជូនដំណើរសាច់ញាតិ
នៅទៃមិនឃើញស្រមោលធីតាឡើយ ។ គេ លើកដៃមើលនាឡិកា
ឃើញពេលវេលាចេញដំណើរកាន់តែប្រជុច ញ៉ចឡើងហើយ ៖
- ដា! អូនងរ៉ក់រឿងអ្វីទៀតហើយហ្នឹង ? រឿងភិសម័យទៀត ហើយមែនទេ ? ហេតុអ្វី
ក៏អូនធ្វើខ្លួនជាមនុស្សគិតសាំញ៉ាំម្ល៉េះ ?
ហេតុអ្វីអូនធ្វើអោយបងភ័យព្រួយយ៉ាងហ្នឹង ដា... ?
គេរត់ចុះរត់ឡើង រំពៃរកមើលធីតាទាំងអន្ទះសា ។ លុះគេបែរ ក្រោយមើលតាមជញ្ជាំងកញ្ចក់
ក៏ឃើញដារីនិងស្រស់ឆោមអូសដៃ ដាវ៉ាន់ឡើងជណ្តើរយន្តទៅខាងលើ
ដើម្បីត្រៀមខ្លួនឡើងយន្តហោះ ចេញដំណើរ ។ ចិត្តរបស់គេក៏ចាប់រារែកអន្ទះសាកាន់តែខ្លាំង ។
- ដា! តើបងត្រូវទៅតាមដា ឬក៏ត្រូវឡើងយន្តហោះទៅតាមកូន

CHANBOKEO.COM

រ៉ាន់ ? អូនដា... នេះជាពេលសំខាន់ដែលយើងត្រូវផ្ដែផ្ដាំគ្នា មុននឹងបងចេញដំណើរ ហេតុអ្វីអូនគេចពីបង ?

គិតចុះគិតឡើង គេនឹកខ្លាញ់នឹងនារីយើងណាស់ ដែលនាងចេះតែធ្វើអ្វីប្លែកៗអោយបុរសផ្ដល់ចំណាប់អារម្មណ៍ហួសហេតុពេក ៖

- ឬមកពីបងថ្នមចិត្តអូនពេកឬ បានជាអូនបានចិត្ត ? បើដូច្នោះ មែន បងឈប់ថ្នមចិត្តអូនហើយ... ព្រោះថ្នមកាលណា អូនធ្វើបែប នេះអោយបងអន្ទះសាតាមរកអូន... ដូច្នេះ បងនឹងឡើងយន្តហោះ ទៅដោយមិនបាច់លាអូនទេ ព្រោះអូនក៏មិនបានគិតពីអារម្មណ៍បងអ្វីបន្តិចសោះ ។

គិតដូច្នោះហើយ ដារិនក៏បង្ខំចិត្ត អោនសំពះអ៊ំសាឡាននិងអ៊ំ សារី រួចក៏បបោយដៃលាសិលានិងសុធន ហើយលើកសំពៀតស្ពាយ ដើរចូលទៅខាងក្នុងយ៉ាងរហ័ស ដោយមិនមានបែរមើលក្រោយឲ្យ សញ្ញាថា គេមានក្ដីអាល័យនៅក្នុងចិត្តឡើយ ។ ការពិត គេកំពុងតែ នឹកខ្លាញ់ណាស់ ខ្លាញ់នឹងនារីយើង ប៉ុន្តែ គេមិនអាចបញ្ចេញ អារម្មណ៍អ្វីបាន ព្រោះគេអស់ពេលវេលានឹងគិតតទៅទៀតហើយ ។

ពេលមកដល់មាត់ទ្វារយន្តហោះ ដារិនឃើញអ្នកធ្វើការកំពុងឈរ រង់ចាំរូបនាយ ថែមទាំងស្រដីថា ៖

- យន្តហោះរិះចេញដំណើរចោលហើយ ព្រោះអ្នកដំណើរបានឡើងយន្តហោះអស់ហើយ បាត់តែលោកម្នាក់ដែលមកយឺតជាងគេ ។

ដារិនមិនមាត់ទេ គ្រាន់តែហុចសំបុត្រអោយគេពិនិត្យ ហើយក៏ដើរទៅក្នុងទ្វារឃ្លប់ចូលទៅក្នុងយន្តហោះ ទាំងដួងចិត្តហ្មួហ្មង ។ បន្ទាប់មក គេដើរទៅអង្គុយនៅកៅអីមួយក្បែរបង្អួចធ្វើស្ងៀមស្ងាត់ សូម្បីតែប្រទះដារី ដារ៉ាន់ និងឆោមនៅអង្គុយពីខាងក្រោយនោះ ក៏គេមិនខ្វីហើបមាត់និយាយអ្វីដាក់ពួកគេដែរ ។ ដារិនដាក់ខ្លួនចុះ យកដៃឈ្លីថ្ងាសបែរមើលតាមបង្អួចទៅខាងក្រៅ ហើយនឹកក្នុងចិត្តតែម្នាក់ឯងថា ៖

- តើដំណើរមកភ្នំពេញសានេះ ជាចំណងនិស្ស័យវាសនាមួយជីវិត ឬត្រឹមជាការយល់សប្តិចំនួនបីអាទិត្យប៉ុណ្ណោះ ? ដា... ពេលនេះ តើអូននៅតែជាបច្ចុប្បន្នរបស់បង... ឬក៏អូនកំពុងតែក្លាយជាស្រមោលអតីតកាលរបស់បងទៅវិញហើយ ?

CHANBOKEO.COM

ដារិនដកដង្ហើមយូ យ៉ាងវែងបន្ទរទ្រូង ។ មួយស្របក់មក គេក៏និយាយខ្សឹបៗម្នាក់ឯងថា ៖

- ទោះបីជាយ៉ាងណា ក៏ខ្ញុំនៅតែអរគុណភ្នំពេញដែរ ដែលផ្តល់
អនុស្សាវរីយ៍យ៉ាងល្អបរិសុទ្ធមួយរវាងខ្ញុំនិងធីតា... សង្ឃឹមថានាង
នឹងចងចាំអ្វីៗទាំងអស់រវាងយើងទាំងពីរ ។

បន្តិចក្រោយមក គេក៏ធ្មេចភ្នែកឈ្ងោកមុខ យកដៃឈ្លីថ្ងាស រំសាយការធុញថប់នៅក្នុងខ្លួន ។ ស្រាប់តែមានមនុស្សមកដាក់ ខ្លួនអង្គុយក្បែរនរៈ ចោលក្លិនខ្លួនក្រអូបប្រហើរដូចក្លិនមនុស្សម្នាក់ ដែលគេធ្លាប់ថ្នាក់ថ្នមថ្មីៗនេះ ។ មាណពក៏ងើបមុខឡើង ៖

- អូនដា ?
- ចា៎ស ?

ដារិនបើកភ្នែកធំៗដោយការភ្ញាក់ផ្អើល រួចឧទានថា ៖

- គឺអូនដាមែនតើហ៎ ? ហើយនេះអូន....

ធីតាបែរមុខញញឹមព្រាយដាក់ដារិន ហើយឆ្លើយថា ៖

- ដាកំពុងតែមកជូនដំណើរបងហ្នឹងណា៎ !
- ជូនដំណើរ ? ហើយអូនអាចចូលដល់ក្នុងយន្តហោះជូនដំណើរ បងបានដែរ ?
- គឺបានណា៎ ! ដាអាចជូនដំណើរបងឲ្យដល់អាមេរិកវិញឯណោះ
មិនអោយបងវង្វេងតាមផ្លូវទៅណាឡើយ ។
- ហើយហេតុអ្វីអូនដាចូលមកបាន ? អំបាញមិញបងអំពល់ចិត្ត សឹងស្លាប់ទៅហើយ អូននឹងទេ
ពេលបងរកដាមិនឃើញ មិនបាន លាគ្នាមួយម៉ាត់មុននឹងចេញមក...
ហើយហេតុអ្វីអូនដាដើរគេចពី បងអញ្ចឹង ?
- នរណាគេចង់ទទួលពាក្យលាពីបងនោះ ? ហើយដាមិនបានគេច ពីបងដែរ ។ គឺបងតើហ៎
ដែលដើរចោលដា !
- មានន័យថាម៉េចហ្នឹង អូនដា ?
- ព្រោះមន្ត្រីអន្តោប្រវេសន៍គេអាល័យហៅដាឲ្យទៅពិនិត្យទិដ្ឋាការ និងលិខិតឆ្លងដែន
អូនឃើញបងរវល់លាគ្នាជាមួយម៉ាក់ដារ៉ាន់ទើប មិនហ៊ានកេះប្រាប់កាត់ចង្វាក់ ។
លុះដល់ចេញមកវិញ បងដារិន ដើរទៅចោលដាបាត់តែម្តង ។
- ពិនិត្យទិដ្ឋាការនិងលិខិតឆ្លងដែន ? មានន័យថាអូនបានទទួល
ការអនុញ្ញាត្តិអោយទៅរៀននៅអាមេរិកហើយមែនទេ ?

CHANBOKEO.COM

- ចាស! មែនហើយ!

- ហើយចុះក្រែងថា អូនប្រឡងធ្លាក់ មិនមែនទេ?

- ធ្លាក់នោះធ្លាក់មែនហើយ ប៉ុន្តែ ដារៀនធ្លាក់ចំណាត់ថ្នាក់ទាបជាង មុន ព្រោះដាធ្លាប់តែជាសិស្សពូកែ បានពិន្ទុសុទ្ធតែជាង៩០ភាគរយ ឥឡូវចុះនៅជាង៨០ភាគរយ ទើបដាអន់ចិត្តនោះអី ។ ការពិត ដាមិនបានធ្លាក់មធ្យមភាគឯណា?

- ពុទ្ធោអើយអូនដា! កាលនោះអូនធ្វើអោយបងព្រួយចិត្តអាណិត អូនសឹងតែរលួយបេះដូង...!

- តែពេលនេះ បងដាវិនឈប់ព្រួយទៅ! សើចម្តងបានទេ?

- ដា! បងសប្បាយចិត្តណាស់... បងសប្បាយចិត្តពិតមែន ។

ដាវិនញញឹមបែរមកស្រវាអោបធីតាយ៉ាងណែន ។

- កុំមើស៍ ខ្មាស់គេ.. (ធីតាច្រានទ្រូងបុរសចេញ)

- គឺមកពីបងរំភើបចិត្តពេក ទប់មិនបាននោះអី ។

ដាវិនក៏ព្រលែងដៃ ហើយស្រវាដៃធីតាយកមកក្តាប់ជំនួសវិញ ហាក់ចង់បង្ហាញនូវការជឿជាក់របស់គេ លើនារី ៖

- អរគុណណាស់ ដែលដាប្រឹងប្រែងដើម្បីបង!

- នរណាថា? ដាកំពុងប្រឹងដើម្បីខ្លួនដាទេ ។

- អញ្ចឹងហ្អែស? អញ្ចឹងអូនដាអាចប្រាប់បងបានទេ ថាអូនមាន អារម្មណ៍បែបណាពេលនេះ ចំពោះរឿងយើងទាំងពីរនាក់?

- ក្រែងបងប្រាប់អូនហើយតើហ៎ ថាអោយអូនឆ្លើយនៅពេលបាន ទទួលការពិសោធន៍ជីវិតនៅអាមេរិកសិន?

- អញ្ចឹងក៏បានដែរ តែបងមានរឿងមួយចង់ប្រាប់ដាអោយដឹង ។

- ចាស! រឿងអ្វីដែរទៅ?

- គឺ ចង់ផ្តាំដាទុកថា បើសិននៅថ្ងៃក្រោយ មានរឿងអ្វីដែលបងធ្វើ អោយដាមិនពេញចិត្ត សូមអូនប្រាប់បងដោយត្រង់ៗណា៎ កុំលាក់ កុំគេច... មានន័យថា បងចង់អោយដាចេះពិគ្រោះនឹងបង អំពីអ្វី ដែលធ្វើអោយយើងមិនចុះសម្រុងនឹងគ្នា ដើម្បីឲ្យយើងមានឱកាស ពន្យល់គ្នាទៅវិញទៅមក ហើយកែសម្រួលស្ថានការណ៍មកវិញ ។ បងមិនចង់ប្រទះភាពបរាជ័យក្នុងជីវិតស្នេហា ជាលើកទីពីរទេ ។

CHANBOKEO.COM

- នេះបងគិតថា ធីតាឆេវឆាវដល់ម្លឹងផងហ្មែស ?

- ដាមិនឆេវឆាវទេ តែអូនប៉ុនងង៉ក់ណាស់ ។

- ស្រីៗ មានងង៉ក់ខ្លះអញ្ចឹងហើយ ទើបជីវិតមានរសជាតិ បើមិន ងង៉ក់ខ្លះទេ ធ្វើម៉េចនឹងដឹងថា បុរសគេចាប់អារម្មណ៍ពីយើងប៉ុន ណានោះ ?

- យី! អូនដាខូចណាស់ ។

- មិនខូចទេ គឺកូនគេឆ្លាតនោះអី! (ធិតាពោលទាំងញញឹម)

យន្តហោះក៏បោះពួយកប់អាកាស...

ដាវិដទាញរនាំងបង្អួចបិទ ហើយស្រដីថា ៖

- ដល់ម៉ោងតន្ត្រីប្រគំហើយ អូនចង់ស្តាប់ទេ ដា ?

- តន្ត្រី ? នៅឯណា បង ?

- គឺនៅក្នុងដើមទ្រូងបងនេះអី! អូនដាក់ត្រចៀកស្តាប់បន្តិចមើល៍ ថាបេះដូងរបស់បងកំពុងប្រគំបទអី ?

ធិតាយល់ភ្លាមថា ដាវិដចង់អោយនាងកើយទ្រូងរបស់គេ ។ ធិតាញញឹម បិទនេត្រាទម្លាក់កេសាលើទ្រូងបុរស ដោយឥតប្រកែក ហើយក៏ទទួលយករង្វង់ដៃនរៈអោបក្រសោបរូបនាងយ៉ាងសែនកក់ ក្តៅរកអ្វីប្រៀបស្មើមិនបាន ។

- អូនស្តាប់ឮហើយនៅ ថាបេះដូងបងកំពុងប្រគំតន្ត្រីបទអ្វីដែរ ?

ដាវិដឈ្ងោកសួរខ្សិបៗ ក្បែរត្រចៀកធិតា ។

- គឺតន្ត្រីបេះដូង ចង្វាក់ដួងចិត្តស្នេហាភក្តីទេដឹង ? (ធីតាឆ្លើយ)

- មែនហ្មែស ?

- ចា៎ស! ប្រាកដណាស់!

- អញ្ចឹង អូនអាចហៅម្ចាស់ចម្រៀង អោយគេឡើងច្រៀងអមបទ ភ្លេងមួយបទនេះ បានទេ ?

- មិនបានទេ!

- ហេតុអ្វីមិនបាន អូនដា ?

- ព្រោះបេះដូងរបស់អូន កំពុងតែប្រគំតន្ត្រីឆ្លើយឆ្លង បន្ទរជាមួយ ភ្លេងមួយបទនេះ ស៊ីចង្វាក់គ្នាណាស់ បងដាវិដមានឮទេ ?

ឮដូច្នោះ ដាវិដរំភើបចិត្តណាស់ ក៏ឱនយកនាសាផ្តិតលើសៀត

CHANBOKEO.COM

ផ្កានារីដោយក្ដីសោមនស្សរំភើបក្នុងចិត្ត ។ សំនៀងសុភមង្គលមួយ
បានប្រគំរណ្ដំឆ្លើយឆ្លងគ្នាឡើងយ៉ាងពិរោះភិរម្យកាមា នាំឲ្យដួងចិត្ត
គូស្នេហាបានទទួលនូវសេចក្ដីសុខមួយ ដែលគ្មាននរណាអាចយល់ ដរៅបាន
ក្រៅពីគេតែពីរនាក់ប៉ុណ្ណោះ ។

នៅជួរខាងក្រោយ ដាវ៉ាន់គេងលក់ស្ងប់ស្ងាត់ផ្អែកលើស្មាម្ដាយ
មីងដែលកំពុងវាចាលួងលោមស្រស់ឆោម ។ មើលចុះ ឆោមធ្វើមុខ ស្ពុយប៉ែ
នឹកទៅដល់ម្ចាស់សៀងហ្គីតាឯភ្នំពេញ...

- មិនអីទេណា៎ ឆោម! ពេលទៅដល់កាលីវិញ ឯងនឹងបានស្ដាប់ តន្ត្រីបេះដូងនោះ តាមអ៊ីមែល
ក្នុងឥន្ទីណិតហើយ...

- ប៉ុន្តែស្ដាប់តាមឥន្ទីណិត ធ្វើម៉េចនឹងពិរោះ មានន័យស្មើនឹងបាន ស្ដាប់ផ្ទាល់
ដូចគេពីរនាក់ខាងនោះទៅ ដាវី ?

ស្រស់ឆោមបូញមាត់ទៅដាវិដនិងធិតា ដែលកំពុងឆ្មេចនេត្រា ទទួលកំដៅកាមា
ពីសូរសព្ទតន្ត្រីបេះដូងប្រគំ ដោយកំសួលដួងចិត្ត ស្នេហារវាងគូគាប់ទាំងទ្វេ ។ ធ្វើម៉េចទៅ
បើព្រេងវាសនាចារមក ខុសគ្នា... មើលទៅ ប្រហែលជាស្រស់ឆោមត្រូវវិលមកភ្នំពេញ
សាជាថ្មីម្ដងទៀត ឆាប់ៗនេះហើយ ទើបអាចស្ដាប់ចំរៀងសំនៀង តន្ត្រីបេះដូងផ្ទាល់ចិត្តផ្ទិតកាយ
ដូចគេទាំងពីរនាក់នោះបាន...

មែនទេ មិត្តអ្នកអាន ?

**ចប់**

CHANBOKEO.COM